ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
សាលាភូមិន្ទរដ្ឋបាល

# ការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈ

## ករណីសិក្សា




## មន្ទីរពេទ្យខេត្តកោះកុង

ជ័យលាភីចំណាត់ថ្នាក់លេខ១ CPA ២ ឆ្នាំ២០១៩

រួមគិត រួមធ្វើ រួមទទួលខុសត្រូវ រួមដោះស្រាយ និងរួមអភិវឌ្ឍន៍

សាលាភូមិន្ទរដ្ឋបាល

២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
សាលាភូមិន្ទរដ្ឋបាល

# ការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈ

## ករណីសិក្សា

## មន្ទីរពេទ្យខេត្តកោះកុង

ជ័យលាភីចំណាត់ថ្នាក់លេខ១ CPA2 ឆ្នាំ២០១៩

រួមគិត រួមធ្វើ រួមទទួលខុសត្រូវ រួមដោះស្រាយ និងរួមអភិវឌ្ឍន៍

សាលាភូមិន្ទរដ្ឋបាល
២០២០

# បុព្វកថា

អភិបាលកិច្ចល្អ គឺជាស្នូលនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា តាំងពីដំណាក់កាលទី១ រហូតដល់ដំណាក់កាលទី៤នេះ ដែលត្រូវបានកំណត់ក្រោមចក្ខុវិស័យដឹកនាំផ្ទាល់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។ ទន្ទឹមនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវកម្មវិធីកែទម្រង់ជារចនាសម្ព័ន្ធគន្លឹះ ចំនួនបួន ដែលរួមមានកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ដែលកម្មវិធីកែទម្រង់ទាំងបួននេះជាក្បាលម៉ាស៊ីនដឹកនាំកែលម្អអភិបាលកិច្ចសាធារណៈ សំដៅបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋឱ្យបានកាន់តែមានប្រសិទ្ធភាព។

ការដាក់ចេញនូវគោលនយោបាយកែទម្រង់ឱ្យចំអាទិភាព គឺជាបេសកកម្មរបស់រាជរដ្ឋាភិបាលតែអ្វីដែលរឹតតែត្រូវផ្តល់ការយកចិត្តទុកដាក់នោះ គឺប្រសិទ្ធភាពជាក់ស្តែងនៃគោលនយោបាយទាំងនោះដែលត្រូវអនុវត្តដោយតួអង្គនីមួយៗ តាមមុខងារនិងភារកិច្ចរៀងៗខ្លួន រាប់ចាប់តាំងពីថ្នាក់ជាតិរហូតដល់ថ្នាក់ក្រោមជាតិ។ ដូចនេះ ការចុះអង្កេតដោយផ្ទាល់ ការសិក្សា និងការវាយតម្លៃអំពីការផ្តល់សេវាសាធារណៈនៅក្នុងកម្រិតមូលដ្ឋាន គឺជាកញ្ចក់ឆ្លុះមួយដែលអាចឱ្យរដ្ឋបាលថ្នាក់ជាតិយល់អំពីសភាពការណ៍ពិតធៀបនឹងការដាក់ចេញគោលនយោបាយនៅថ្នាក់ជាតិ។ កន្លងមក រាជរដ្ឋាភិបាលបានដាក់ចេញនូវយន្តការគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ដើម្បីជាការសិក្សា ការវាយតម្លៃ និងស្វែងរកនូវធាតុចូលសំខាន់ៗក្នុងការកែលម្អអភិបាលកិច្ច ដែលនៅក្នុងនោះមានការផ្តល់ចំណាត់ថ្នាក់ជាការលើកទឹកចិត្តដល់អង្គភាពដែលមានអភិបាលកិច្ចនិងការផ្តល់សេវាសាធារណៈល្អប្រសើរជាងគេ។

ក្នុងស្មារតីខាងលើនេះ ខ្ញុំពិតជាមានក្តីរំភើបនិងសូមកោតសរសើរដោយស្មោះចំពោះគំនិតរៀបចំឱ្យមានជាឯកសារ ការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈរបស់មន្ទីរពេទ្យខេត្តកោះកុង «**រួមគិត រួមធ្វើ រួមទទួលខុសត្រូវ រួមដោះស្រាយ និងរួមអភិវឌ្ឍន៍**» នេះ។

ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងសម្រេចចេញជាសមិទ្ធផលនេះឡើង ក្រោមការដឹកនាំរបស់ឯកឧត្តមកិត្តិបណ្ឌិត **ពេជ្រ ប៊ុនធិន** ទេសរដ្ឋមន្ត្រីនិងជាប្រធានគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ដោយមានការចូលរួមសហការយ៉ាងសស្រាក់សស្រាំពីឯកឧត្តមបណ្ឌិត-សភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា ឯកឧត្តមសាស្ត្រាចារ្យ **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងឯកឧត្តម **ព្រុំ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ព្រមទាំងថ្នាក់ដឹកនាំនិងមន្ត្រីរាជការក្រោមឱវាទនៃសាមីក្រសួងនីមួយៗ។

ខ្ញុំរំពឹងថាឯកសារនេះ នឹងក្លាយជាមគ្គុទេសក៍អភិបាលកិច្ចសាធារណៈដ៏មានគុណ-ប្រយោជន៍មួយ សម្រាប់អង្គភាពផ្តល់សេវាសាធារណៈផ្សេងទៀត ជាពិសេសអង្គភាពផ្តល់សេវាសុខាភិបាល អាចយកជាការដកស្រង់បទពិសោធន៍ និងជាធាតុចូលនៃការគ្រប់គ្រងអង្គភាព និងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។ ទន្ទឹមនេះ ឯកសារនេះក៏អាចផ្តល់វិភាគទានខាងពុទ្ធិ ដល់ការយល់ដឹង ការរៀនសូត្រ និងការសិក្សាស្រាវជ្រាវរបស់និស្សិត សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ បញ្ញវន្ត និងសាធារណជនជាទូទៅផងដែរ។

ថ្ងៃ ចន្ទ ១៤រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

# អារម្ភកថា

ការកសាងជំនឿនិងទំនុកចិត្តពីប្រជាពលរដ្ឋ គឺជាការលំបាកដែលរាជរដ្ឋាភិបាល ត្រូវបន្តយកចិត្តទុកដាក់តាមរយៈការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពជូនប្រជាពលរដ្ឋ។ ផ្តើមចេញពីចំណុចនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានបំផុសឡើងវិញនូវយន្តការនៃការលើកទឹកចិត្តមន្រ្តីរាជការ និងអង្គភាពដែលមានស្នាដៃឆ្នើមក្នុងការបង្កើនផលិតភាពការងារក្នុងរដ្ឋបាលសាធារណៈ និងការលើកកម្ពស់គុណភាពសេវាសាធារណៈ ដែលកន្លងមកធ្លាប់ត្រូវបានអនុវត្តនៅអតីតសាធារណៈរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា។ ផ្អែកលើសំណើរបស់ក្រសួងមុខងារសាធារណៈ ក្នុងនាមគណៈ-កម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការរៀបចំឱ្យមានយន្តការនេះឡើងវិញ ដើម្បីលើកទឹកចិត្តដល់បណ្តាអង្គភាពផ្តល់សេវាសាធារណៈ រាជរដ្ឋាភិបាលបានសម្រេចឱ្យមានការប្រកួតប្រជែងអង្គភាពផ្តល់សេវាសាធារណៈគំរូ តាមរយៈការដាក់ឱ្យអនុវត្តអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ស្តីពីការវាយតម្លៃ និងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល។

តាមរយៈអនុក្រឹត្យនេះ គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ និងគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបានរៀបចំនិងបង្កើតឡើង ដើម្បីពិនិត្យនិងវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងកម្រិតវិទ្យាល័យសម្រាប់វិស័យអប់រំ និងក្នុងកម្រិតមន្ទីរពេទ្យបង្អែករាជធានី ខេត្ត និងមន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ ដែលផ្តល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត១ កម្រិត២ និងកម្រិត៣ សម្រាប់វិស័យសុខាភិបាល ដោយផ្អែកលើសូចនាករលក្ខណៈវិនិច្ឆ័យគោល លក្ខណៈវិនិច្ឆ័យរង និងលក្ខណៈវិនិច្ឆ័យលម្អិត។ ការវាយតម្លៃនេះត្រូវបានអនុវត្តផ្អែកលើគោលការណ៍តម្លាភាព សុចរិតភាព និងភាពជឿទុកចិត្តបាន។ ការវាយតម្លៃក៏បានឆ្លុះបញ្ចាំងអំពីការគ្រប់គ្រងនិងការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធ-ភាពនិងនវានុវត្តន៍ ក្នុងក្របខណ្ឌនៃកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់ថ្នាក់ដឹកនាំ មន្ត្រីអង្គភាព អាជ្ញាធរមូលដ្ឋាន សហគមន៍ និងអង្គការដៃគូអភិវឌ្ឍនានា ក្នុងគោលដៅកែលម្អ និងពង្រឹង

គុណភាពសេវាសាធារណៈឱ្យកាន់តែល្អប្រសើរ សម្រាប់បម្រើប្រជាពលរដ្ឋក្នុងមូលដ្ឋានរបស់ខ្លួន។

ក្នុងឱកាសនៃពិធីប្រកាសទទួលស្គាល់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល នាថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានណែនាំឱ្យមានការរៀបចំជាករណីសិក្សា ចងក្រងបទពិសោធន៍នៃការអនុវត្តការងាររបស់បណ្តាជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូ សម្រាប់ផ្សព្វផ្សាយជូនដល់បណ្តាអង្គភាពផ្តល់សេវាសាធារណៈផ្សេងទៀតក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល ដើម្បីដកស្រង់បទពិសោធន៍ និងពង្រីកនវានុវត្តន៍ក្នុងការកែលម្អគុណភាពសេវាសាធារណៈរបស់ខ្លួន។ ក្នុងន័យនេះ គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ បានរៀបចំនិងកំណត់យកអង្គភាពជ័យលាភីលេខ១ ផ្តល់សេវាសាធារណៈគំរូក្នុងកម្រិតវិទ្យាល័យសម្រាប់វិស័យអប់រំ និងអង្គភាពជ័យលាភីលេខ១ ផ្តល់សេវាសាធារណៈគំរូ ក្នុងកម្រិតមន្ទីរពេទ្យបង្អែករាជធានី ខេត្ត និងមន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ ដែលផ្តល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត១ កម្រិត២ និងកម្រិត៣ សម្រាប់វិស័យសុខាភិបាល ទុកជាមេរៀនបទពិសោធន៍សម្រាប់អង្គភាពផ្តល់សេវាសាធារណៈផ្សេងទៀតក្នុងក្របខណ្ឌទូទាំងប្រទេស។

ថ្ងៃ ព្រហ ៩រោច ខែបឋមាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ២០២០

**ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេសនិងជាប្រធាន**

**គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ**

កិត្តិបណ្ឌិត ពេជ្រ ប៊ុនធិន

# អារម្ភកថា

នៅក្នុងនីតិកាលទី៦ នៃរដ្ឋសភា រាជរដ្ឋាភិបាលកម្ពុជា បានប្តេជ្ញាបន្តកិច្ចខិតខំប្រឹងប្រែងក្នុងការកសាងរដ្ឋបាលសាធារណៈ ឱ្យកាន់តែ**ខ្លាំង ស្អាតស្អំ និងផ្តោតលើប្រជាជនជាស្នូល**។ ក្នុងន័យនេះ ការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ច គឺជាលក្ខខណ្ឌចាំបាច់សម្រាប់ការពង្រឹងរដ្ឋបាលសាធារណៈឱ្យកាន់តែមានតម្លាភាព ភាពឆ្លើយតប និងប្រសិទ្ធភាព និងជំនឿទុកចិត្តបាន។

ឈរលើស្មារតីនេះ ក្រសួងមុខងារសាធារណៈ ដែលមានតួនាទីគ្រប់គ្រងនិងអភិវឌ្ឍន៍វិស័យមុខងារសាធារណៈ និងកែលម្អអភិបាលកិច្ចក្នុងរដ្ឋបាលសាធារណៈ បានទទួលការគាំទ្រនិងចូលរួមសហការពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល និងគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ ក្នុងការរៀបចំនូវគោលការណ៍ នីតិវិធី និងដំណើរការនៃការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល ក៏ដូចជាការចូលរួមគាំទ្រក្នុងការរៀបចំឱ្យមានការចងក្រងករណីសិក្សាសម្រាប់អង្គភាពជ័យលាភីលេខ១ នៃអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល។ ករណីសិក្សានេះ នឹងអាចយកទៅប្រើប្រាស់សម្រាប់ធ្វើជាមេរៀនពិសោធន៍ដល់បណ្តាអង្គភាពផ្សេងៗទៀត ដើម្បីពង្រឹងអភិបាលកិច្ចនិងការកែលម្អគុណភាពនៃការផ្តល់សេវាសាធារណៈរបស់ខ្លួនឱ្យកាន់តែមានគុណភាព និងប្រសិទ្ធភាព។

ការកែលម្អ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋគឺជាផ្នែកដ៏សំខាន់មួយ ដែលនឹងរួមចំណែកក្នុងការសម្រេចចក្ខុវិស័យរបស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា ឱ្យទទួលបានជោគជ័យ។ ផ្អែកលើការគាំទ្រ និងការចូលរួមអនុវត្តដ៏សកម្មប្រកបដោយការទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ និងតួអង្គពាក់ព័ន្ធទាំងអស់ ខ្ញុំសង្ឃឹមថា អភិបាលកិច្ចក្នុងរដ្ឋបាលសាធារណៈនឹងមានដំណើរការកាន់តែមានប្រសិទ្ធភាពនិងគាំទ្រដល់ការអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព បរិយាប័ន្ន និងសមធម៌។

ក្នុងនាមក្រសួងមុខងារសាធារណៈ ខ្ញុំសូមបន្តគាំទ្រ និងផ្តល់កិច្ចសហការជាមួយគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាលនិងក្រសួង ស្ថាប័នផ្សេងទៀត ធ្វើការផ្សព្វផ្សាយឯកសារករណីសិក្សានេះឱ្យបានទូលំទូលាយ ដើម្បីពង្រីកវិសាលភាពនៃការអនុវត្តការប្រកួតប្រជែងក្នុងការផ្តល់សេវាសាធារណៈគំរូ នៅតាមអង្គភាពផ្តល់សេវាសាធារណៈផ្សេងៗទៀត។

ថ្ងៃ អង្គារ ០៩ កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

ព្រុំ-សុខា

# អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកសុខភាពរបស់ប្រជាជន គឺជាស្នូលនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ចរបស់ប្រទេស។ ភាពរឹងមាំនៃប្រព័ន្ធសុខាភិបាល រួមជាមួយនឹងវឌ្ឍនភាពនៃវិស័យពាក់ព័ន្ធផ្សេងទៀត ជាពិសេសឆន្ទៈនយោបាយដ៏រឹងមាំរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងវឌ្ឍនភាពឆ្ពោះទៅកាន់ការគ្របដណ្តប់សុខភាពជាសកល រួមជាមួយនឹងវឌ្ឍនភាពនៃកំណែទម្រង់នានា បានផ្តល់ឱកាសឱ្យក្រសួងសុខាភិបាលធ្វើការលើកកម្ពស់វិស័យសុខាភិបាល ក្នុងការផ្តល់សេវាមានគុណភាពនៅគ្រប់មូលដ្ឋានសុខាភិបាល កាន់តែមានភាពឆ្លើយតប និងគណនេយ្យភាពចំពោះប្រជាជន។

លទ្ធផលនៃការអនុវត្តអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ "**ស្តីពីការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល**" បានបង្ហាញឱ្យឃើញថាមន្ទីរពេទ្យបង្អែកផ្តល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត១ ចំនួន ១០ កម្រិត២ ចំនួន ១០ និងកម្រិត៣ ចំនួន ១០ ត្រូវបានវាយតម្លៃ និងទទួលស្គាល់ជាអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យសុខាភិបាល នៅឆ្នាំ២០១៩ ដែលក្នុងនោះមានមន្ទីរពេទ្យបង្អែកបាកាន មន្ទីរពេទ្យខេត្តកោះកុង និងមន្ទីរពេទ្យខេត្តកំពង់ចាម បានទទួលជ័យលាភីជាអង្គភាពផ្តល់សេវាសាធារណៈគំរូថ្នាក់លេខ១។

ការចងក្រងករណីសិក្សាពីមន្ទីរពេទ្យទាំង៣ខាងលើ ដែលបានទទួលជ័យលាភីលេខ១ ស្តីពី "**ការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈរបស់មន្ទីរពេទ្យ**" មានគោលបំណងផ្តល់ជាមេរៀនបទពិសោធន៍ ដើម្បីចែករំលែកពីគុណតម្លៃនៃភាពជាអ្នកដឹកនាំ និងនវានុវត្តន៍ក្នុងវិស័យសុខាភិបាល។ ករណីសិក្សានេះ នឹងបង្ហាញពីដំណើរការនៃការវិវត្តក្នុងអង្គភាព បញ្ហាប្រឈម ដំណោះស្រាយ បទពិសោធន៍ជោគជ័យ និងវិធីសាស្ត្រនានាក្នុងការកែលម្អគុណភាព និងផលិតភាពការងារក្នុងអង្គភាព ជាពិសេស ការចូលរួមចំណែកជំរុញការអនុវត្តនវានុវត្តន៍ និងឧត្តមានុវត្តន៍ ក្នុងការពង្រឹងនិងលើកកម្ពស់សុខុមាលភាពជូនដល់ប្រជាជនកម្ពុជា។

ក្នុងនាមក្រសួងសុខាភិបាល ខ្ញុំសូមកោតសរសើរដ៏ស្មោះដល់មន្ត្រីនិងបុគ្គលិកសុខា-

ភិបាលទាំងអស់ ព្រមទាំងមន្ទីរពេទ្យទទួលជ័យលាភីដែលបាននាំមកនូវវឌ្ឍនភាព និងភាពជោគជ័យដ៏ត្រចះត្រចង់ក្នុងការបម្រើសេវាជូនប្រជាជន។ ជាមួយគ្នានេះ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គភាពគ្រប់លំដាប់ថ្នាក់ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន ព្រមទាំងប្រជាជនកម្ពុជាទាំងអស់ ដែលបានឧបត្ថម្ភ គាំទ្រ សហការ និងចូលរួមចំណែកយ៉ាងសកម្មក្នុងការអនុវត្តសកម្មភាពសុខាភិបាលនាពេលកន្លងទៅ។

ខ្ញុំសង្ឃឹមថា ករណីសិក្សានេះ នឹងបានជាមេរៀនបទពិសោធន៍ល្អៗ សម្រាប់មន្ត្រីគ្រប់គ្រងអង្គភាពសុខាភិបាលទាំងអស់ ដើម្បីធ្វើការកែលម្អ និងអភិវឌ្ឍអង្គភាពរបស់ខ្លួនឱ្យកាន់តែរីកចំរើនថែមទៀត រួមចំណែកលើកកម្ពស់សុខភាព និងសុខុមាលភាពជូនប្រជាជនកម្ពុជាកាន់តែល្អប្រសើរឡើង។

ថ្ងៃសុក្រ ១២កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ២៧ ខែវិច្ឆិកា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

ម៉ម_ប៊ុនហេង

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំសូមសំដែងនូវការគោរពដ៏ខ្ពង់ខ្ពស់ និងកតវេទិតាដ៏ស្មោះស្ម័គ្រជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានគាំទ្រ និងយកចិត្តទុកដាក់ខ្ពស់លើវិស័យអប់រំ និងវិស័យសុខាភិបាល។ ជាពិសេសបានដាក់ចេញនូវអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ស្តីពីការវាយតម្លៃនិងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល។

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបានជំរុញ គាំទ្របង្កើតឱ្យមានការវាយតម្លៃនិងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល និងការរៀបចំចងក្រងបទពិសោធន៍នៃការអនុវត្តការងាររបស់បណ្តាជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈ គំរូនេះឡើង។

ជាមួយគ្នានេះដែរ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ ឯកឧត្តមកិត្តិបណ្ឌិត **ពេជ្រ ប៊ុនធិន** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងឯកឧត្តម **ហ៊្រុំ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ចំពោះការផ្តល់នូវកិច្ចគាំទ្រ និងការជំរុញលើកទឹកចិត្តដល់ក្រុមការងាររៀបចំករណីសិក្សា ដែលជាហេតុធ្វើឱ្យដំណើរការសិក្សាស្រាវជ្រាវទទួលបានលទ្ធផលនាពេលនេះ។

ទន្ទឹមគ្នានេះដែរ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ ឯកឧត្តមសាស្ត្រាចារ្យ **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល ចំពោះការផ្តល់នូវកិច្ចគាំទ្រ សម្របសម្រួល និងអនុញ្ញាតឱ្យក្រុមការងាររៀបចំករណីសិក្សាបានបំពេញភារកិច្ចរបស់ខ្លួន រហូតទទួលបានលទ្ធផលនាពេលនេះ។

នៅក្នុងការងារនេះដែរ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ ឯកឧត្តម **យក់ ប៊ុនណា** រដ្ឋលេខាធិការប្រចាំការនៃក្រសួងមុខងារសាធារណៈ និងជានាយកសាលាភូមិន្ទរដ្ឋបាល ដែលបានផ្តួចផ្តើមគំនិត និងដឹកនាំគម្រោងរៀបចំករណីសិក្សានេះ រហូតទទួលបាន

លទ្ធផលជាទីមោទនៈនាពេលនេះ។

ក្នុងឱកាសនេះ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ លោកជំទាវ **មិថុនា ភួថង** អភិបាល នៃគណៈអភិបាលខេត្តកោះកុង ឯកឧត្តម **ស្រេង ហុង** អភិបាលរងនៃគណៈអភិបាលខេត្តកោះកុង និងលោកវេជ្ជបណ្ឌិត **ឆៅ ម៉ឺង** ប្រធានមន្ទីរសុខាភិបាលខេត្តកោះកុង ចំពោះការលះបង់នូវពេលវេលា ការគាំទ្រ ការសម្របសម្រួល និងការអនុញ្ញាតឱ្យក្រុមការងាររៀបចំករណីសិក្សាបានបំពេញភារកិច្ចរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព និងដោយរលូន រហូតទទួលបានលទ្ធផលនាពេលនេះ។

សូមថ្លែងអំណរគុណចំពោះ លោកវេជ្ជបណ្ឌិត **ម៉ៃ ឡៃស៊ុន** ប្រធានមន្ទីរពេទ្យខេត្តកោះកុង អនុប្រធានមន្ទីរពេទ្យ ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់នៃមន្ទីរពេទ្យខេត្តកោះកុង ដែលបានលះបង់នូវពេលវេលាដ៏ច្រើន ចូលរួមយ៉ាងសកម្ម សម្របសម្រួល និងផ្តល់ទិន្នន័យឱ្យក្រុមការងាររៀបចំករណីសិក្សាបានបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

សូមអរគុណចំពោះថ្នាក់ដឹកនាំនៃទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ) និងជាពិសេសលោកបណ្ឌិត **សំ ចន្ធី** និងក្រុមជំនាញការបច្ចេកទេសនៃកម្មវិធីកំណែទម្រង់វិមជ្ឈការនិងរដ្ឋបាលនៃអង្គការជីអាយហ្សិត (DAR/GIZ) ដែលតែងតែផ្តល់នូវការគាំទ្រ និងការតម្រង់ទិសនៅក្នុងដំណើរការនៃការរៀបចំករណីសិក្សានេះ។

សូមថ្លែងអំណរគុណចំពោះក្រុមការងារដឹកនាំ និងគ្រប់គ្រងគម្រោងរៀបចំករណីសិក្សា ដែលបានណែនាំតម្រង់ទិស និងផ្តល់ជាធាតុចូលក្នុងការរៀបចំចងក្រងករណីសិក្សានេះ។ ជាមួយគ្នានេះដែរ សូមអរគុណចំពោះក្រុមការងាររៀបចំករណីសិក្សារបស់មន្ទីរពេទ្យខេត្តកោះកុង និងក្រុមការងារសម្របសម្រួល ដែលបានលះបង់កម្លាំងកាយចិត្ត និងបញ្ញាក្នុងការសម្របសម្រួល រៀបចំ តាក់តែង និងចងក្រងករណីសិក្សានេះឱ្យទទួលបានលទ្ធផលដូចការគ្រោងទុក។

# បញ្ជីអក្សរកាត់

| អក្សរកាត់ | ពាក្យពេញ |
|---|---|
| បសស | បេឡាជាតិរបបសន្តិសុខសង្គម |
| ADB | Asian Development Bank |
| CPA | Complementary package of Activities |
| CMS | Central Medical Store |
| CSSD | Central Sterilization and Supply Department |
| H-EQIP | Health Equity and Quality Improvement Project |
| HO2 | Hospital |
| HMIS | Health Management Information System |
| HOSDID | Hospital Drug Inventory Database |
| HSSP-2 | Health Sector Support Project-2 |
| ICU | Intensive Care Unit |
| IPC | Infection Prevention and Control |
| MOS | Month Of Stock |
| MTC | Medecine Therapeutic Committee |
| PHD | Provincial Health Department |
| PPE | Personal Protective Equipment |
| PMRS | Patient Management and Registration System |
| Post ID | Post Patient Identity |
| SOA | Special Operating Agency |
| SWOT | Strength Weakness Opportunity Threat |
| USAID | United State Agency for International Development |
| VCCT | Voluntary Confidential Counceling Testing |

# មាតិកានុក្រម

បុព្វកថា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ .................. I
អារម្ភកថា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធាន
គណៈកម្មការវាយតម្លៃអនុភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ .......III
អារម្ភកថា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ........................................ V
អារម្ភកថា រដ្ឋមន្ត្រីក្រសួងសុខាភិបាល ..........................................VII
សេចក្តីថ្លែងអំណរគុណ............................................................... IX
បញ្ជីអក្សរកាត់ ........................................................................ XI
បញ្ជីតារាង ........................................................................... XV
បញ្ជីរូបភាព .......................................................................... XVI
បញ្ជីក្រាហ្វិក.........................................................................XVII
បញ្ជីឧបសម្ព័ន្ធ......................................................................XVIII
ជំពូកទី១. សេចក្តីផ្តើម ................................................................ ១
១.១. លំនាំបញ្ហានៃការស្រាវជ្រាវ................................................... ១
១.២. គោលបំណងនៃការស្រាវជ្រាវ.................................................. ៥
១.៣. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ.................................. ៥
១.៤. វិធីសាស្រ្តសិក្សាចងក្រងករណីសិក្សា ........................................ ៦
១.៥. ក្រមសីលធម៌នៃការសម្ភាស និងការសិក្សាចងក្រងករណីសិក្សា............. ១២
ជំពូកទី២. ស្ថានភាពបច្ចុប្បន្នវិស័យសុខាភិបាល និងសមិទ្ធកម្មមន្ទីរពេទ្យ
ខេត្តកោះកុង ........................................................................ ១៥
២.១. បរិបទរួមនៃការកែទម្រង់រដ្ឋបាលសាធារណៈ................................. ១៥
២.២. ទិដ្ឋភាពរួមនៃប្រព័ន្ធសុខាភិបាល............................................. ១៦

២.៣. ស្ថានភាពទូទៅរបស់មន្ទីរពេទ្យខេត្តកោះកុង................................. ១៩
២.៤. សមិទ្ធផលសុខាភិបាលរបស់មន្ទីរពេទ្យខេត្តកោះកុង.......................... ៣១
២.៥. ចំណុចលេចធ្លោរបស់មន្ទីរពេទ្យ................................................ ៣៨
**ជំពូកទី៣. បទពិសោធន៍ជោគជ័យរបស់មន្ទីរពេទ្យខេត្តកោះកុង.................. ៤៣**
៣.១. ស្តង់ដាសេវាសាធារណៈ ....................................................... ៤៣
៣.២. ស្តង់ដានៃការផ្តល់សេវាសាធារណៈរបស់មន្ទីរពេទ្យខេត្តកោះកុង.......... ៦៤
៣.៣. ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងអង្គភាព............................ ៨៣
៣.៤. ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស.................................. ៩៣
៣.៥. ការរៀបចំ និងកែលម្អបរិស្ថានអង្គភាព ....................................... ១០៣
៣.៦. ទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ សហគមន៍ និងដៃគូអភិវឌ្ឍ ព្រមទាំងការចូលរួមវាយតម្លៃពីអ្នកប្រើប្រាស់សេវាសាធារណៈ ...........១១៣
៣.៧. ការដោះស្រាយបញ្ហាប្រឈមជាមួយប្រជាពលរដ្ឋ និងសហគមន៍........ ១២០
៣.៨. ការផ្តួចផ្តើមគំនិតថ្មីៗ នវានុវត្តន៍ ដើម្បីធ្វើឱ្យអង្គភាពមានដំណើរការ កាន់តែល្អប្រសើរឡើង.......................................................... ១២៤
៣.៩. កត្តាជោគជ័យរបស់មន្ទីរពេទ្យ............................................... ១៣១
**ជំពូកទី៤. សេចក្តីសន្និដ្ឋាន......................................................... ១៣៣**
**គន្ថនិទ្ទេស ................................................................................ ១៣៥**
**ឧបសម្ព័ន្ធ.................................................................................. ១៣៩**

# មាតិកានុក្រមតារាង

តារាងទី១÷ ក្រុមគោលដៅដែលបានប្រមូលព័ត៌មាន និងទិន្នន័យ........................ ៧
តារាងទី២÷ លក្ខណៈវិនិច្ឆ័យគោលទាំងប្រាំបី និងសំណួរគន្លឹះៗ....................... ១០
តារាងទី៣÷ លក្ខណៈវិនិច្ឆ័យសម្រាប់បង្កើតមូលដ្ឋានសុខាភិបាល..................... ១៨
តារាងទី៤÷ តារាងចំនួនមន្ត្រី និងបុគ្គលិកតាមផ្នែក..................................... ២៩
តារាងទី៥÷ តារាងចំនួនមន្ត្រី ........................................................... ៣០
តារាងទី៦÷ តារាងរួមស្ដីពីលទ្ធផលនៃការផ្ដល់សេវាសុខាភិបាលរបស់មន្ទីរពេទ្យ
ខេត្តកោះកុង .................................................................. ៣១

# មាតិកានុក្រម

រូបភាពទី១÷ ប្រព័ន្ធសុខាភិបាលសាធារណៈ........................................... ១៧
រូបភាពទី២÷ រចនាសម្ព័ន្ធរបស់មន្ទីរពេទ្យខេត្តកោះកុង................................ ២៧
រូបភាពទី៣÷ ស្តង់ដាសេវាសាធារណៈ................................................ ៦៣
រូបភាពទី៤÷ ស្តង់ដានៃការផ្តល់សេវាសាធារណៈរបស់មន្ទីរពេទ្យខេត្តកោះកុង....... ៨២
រូបភាពទី៥÷ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងអង្គភាព........................ ៩២
រូបភាពទី៦÷ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស............................ ១០២
រូបភាពទី៧÷ ការរៀបចំ និងកែលម្អបរិស្ថានមន្ទីរពេទ្យ................................ ១១២
រូបភាពទី៨÷ ទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ សហគមន៍ និងដៃគូអភិវឌ្ឍ ព្រមទាំងការចូលរួមវាយតម្លៃពីអ្នកប្រើប្រាស់សេវាសាធារណៈ........ ១១៩
រូបភាពទី៩÷ ការដោះស្រាយបញ្ហាប្រឈមជាមួយប្រជាពលរដ្ឋ និងសហគមន៍... ១២៣
រូបភាពទី១០÷ ការផ្តួចផ្តើមគំនិតថ្មីៗ នវានុវត្តន៍........................................ ១២៨
រូបភាពទី១១÷ ប័ណ្ណសរសើរ........................................................... ១២៩

# មាតិកានុក្រម

ក្រាហ្វិកទី១÷ ចំនួនមន្ត្រី និងបុគ្គលិកបម្រើការងារនៅមន្ទីរពេទ្យ........................ ២៨
ក្រាហ្វិកទី២÷ ចំនួនករណីថ្មីពិនិត្យពិគ្រោះជំងឺក្រៅ.................................... ៣២
ក្រាហ្វិកទី៣÷ ចំនួនអ្នកជំងឺសម្រាកនៅមន្ទីរពេទ្យ........................................ ៣៣
ក្រាហ្វិកទី៤÷ អត្រាស្លាប់.......................................................... ៣៤
ក្រាហ្វិកទី៥÷ ចំនួនស្ត្រីសម្រាលកូន.................................................. ៣៤
ក្រាហ្វិកទី៦÷ ការថែទាំមាតា និងទារកក្រោយសម្រាល.................................. ៣៥
ក្រាហ្វិកទី៧÷ ចំនួនករណីថ្មីពិនិត្យពិគ្រោះជំងឺលើកុមារអាយុក្រោម ៥ឆ្នាំ............. ៣៦
ក្រាហ្វិកទី៨÷ ចំនួនកុមារក្រោម ៥ឆ្នាំ សម្រាកពេទ្យ.................................. ៣៧
ក្រាហ្វិកទី៩÷ ចំនួនករណីវះកាត់ធំសរុប................................................ ៣៧
ក្រាហ្វិកទី១០÷ អត្រាប្រើប្រាស់គ្រែ.................................................. ៣៨
ក្រាហ្វិកទី១១÷ លទ្ធផលនៃការសម្ភាសអតិថិជន........................................ ៤០
ក្រាហ្វិកទី១២÷ ការសម្ភាសអតិថិជនដែលធ្លាប់មកសម្រាកពេទ្យ (លទ្ធផលប្រចាំត្រីមាសទី៤)...................................................... ៨១

# បញ្ជីឧបសម្ព័ន្ធ

**ឯកសារឧទ្ទេស** ........................................ ១៤១
១. សេចក្តីសម្រេចបង្កើតក្រុមការងាររៀបចំករណីសិក្សា ........................ ១៤១
២. កម្រងសំណួរប្រមូលទិន្នន័យ ........................................ ១៥០
៣. បញ្ជីអ្នកចូលរួម ........................................ ១៦៣
**ស្តង់ដារសេវាសាធារណៈ** ........................................ ១៦៧
៤. កម្រងរចនាសម្ព័ន្ធតាមផ្នែករបស់មន្ទីរពេទ្យ ........................................ ១៦៧
៥. បទបញ្ជាផ្ទៃក្នុង ........................................ ១៧៩
៦. ប្លង់បង្ហាញទីតាំងមន្ទីរពេទ្យ ........................................ ១៨០
៧. ប្លង់រំហូរអ្នកជំងឺ ........................................ ១៨១
៨. លិខិតបញ្ជូនអ្នកជំងឺទៅមន្ទីរពេទ្យថ្នាក់ជាតិ/ មន្ទីរពេទ្យប្រទេសថៃ ........... ១៨២
៩. តារាងតម្លៃសេវាហិរញ្ញប្បទាន ........................................ ១៨៤
១០. សេចក្តីសម្រេច និងលិខិតបង្គាប់ការតែងតាំងគណៈកម្មការ អនុគណៈកម្មការ និងក្រុមការងារនានារបស់មន្ទីរពេទ្យ ...................... ១៨៥
**ស្តង់ដារនៃការផ្តល់សេវាសាធារណៈរបស់មន្ទីរពេទ្យខេត្តកោះកុង** ............... ២០១
១១. ចក្ខុវិស័យ បេសកកម្ម និងគោលដៅរបស់មន្ទីរពេទ្យ ........................ ២០១
**ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងអង្គភាព** ................................ ២០៣
១២. ផែនការថវិកា (ត្រីមាស ឆមាស ឆ្នាំ ពង្សាំរំកិល) ............................ ២០៣
១៣. បញ្ជីសារពើភ័ណ្ឌ ........................................ ២៣៧
**ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស** ........................................ ២៤១
១៤. អង្គការលេខរបស់មន្ទីរពេទ្យទាំងមូល ........................................ ២៤១
១៥. លក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃស្នាដៃការងារ ............................ ២៤២

១៦. ទម្រង់កិច្ចសន្យាការងារ (ការពិពណ៌នាមុខតំណែងនិងការបែងចែកការងារ)...២៤៧

**ការរៀបចំ និងកែលម្អបរិស្ថានអង្គភាព** ......................................... ២៥៩

១៧. កាលវិភាគសម្អាតបន្ទប់ និងបន្ទប់ទឹក ......................................... ២៥៩

១៨. ផ្ទាំងរូបភាពបែងចែកធុងសំរាម ......................................... ២៦១

១៩. ផ្លាកសញ្ញាណែនាំពីអនាម័យ និងបរិស្ថាន......................................២៦២

២០. បទបញ្ជាផ្ទៃក្នុងស្តីពីភាពស្អាត......................................... ២៧៣

**ទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ សហគមន៍ និងដៃគូអភិវឌ្ឍ ព្រមទាំងការចូលរួមវាយតម្លៃពីអ្នកប្រើប្រាស់សេវាសាធារណៈ** ..............................២៧៥

២១. កិច្ចព្រមព្រៀង ឬអនុស្សារណៈយោគយល់រវាងមន្ទីរពេទ្យជាមួយដៃគូ....២៧៥

**ការដោះស្រាយបញ្ហាប្រឈមជាមួយប្រជាពលរដ្ឋ និងសហគមន៍**................ ២៨១

២២. ទម្រង់លិខិតបញ្ចេញមតិយោបល់ ឬសំណូមពរ .............................. ២៨១

**ការផ្តួចផ្តើមគំនិតថ្មីៗ នវានុវត្តន៍ ដើម្បីធ្វើឱ្យអង្គភាពមានដំណើរការកាន់តែល្អប្រសើរឡើង** ......................................... ២៨៣

២៣. កម្រងវិញ្ញាបនបត្រទទួលស្គាល់ និងប័ណ្ណសរសើររបស់បុគ្គលិក និង មន្ទីរពេទ្យខេត្តកោះកុង......................................... ២៨៣

២៤. កម្រងរូបភាពពាក់ព័ន្ធនឹងការច្នៃប្រឌិត......................................២៨៨

២៥. កម្រងពាក្យស្លោក ......................................... ២៩២

# ជំពូកទី១. សេចក្តីផ្តើម

## ១.១. លំនាំបញ្ហានៃការស្រាវជ្រាវ

ការប្រកួតប្រជែងការផ្តល់សេវាសាធារណៈនៅតាមអង្គភាពក្នុងស្ថាប័នសាធារណៈ ជាគន្លឹះចាំបាច់មួយ ក្នុងការធានាបាននូវប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ដល់គ្រប់ស្រទាប់ប្រជាពលរដ្ឋទាំងអស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជា មានឆន្ទៈយ៉ាងមោះមុតឥតរាថយ ក្នុងការជំរុញការអនុវត្តការងារកែទម្រង់គ្រប់ផ្នែក គ្រប់វិស័យឱ្យកាន់តែមានលក្ខណៈទូលំទូលាយ និងស៊ីជម្រៅ ក្នុងគោលដៅធ្វើឱ្យប្រទេសកម្ពុជាមានសុខុដុមនីយកម្ម និងការអភិវឌ្ឍប្រកបដោយចីរភាព សំដៅឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រទេសជាតិ និងប្រជាជន។ ផ្អែកលើស្មារតីនេះ ការលើកកម្ពស់អភិបាលកិច្ចក្នុងរដ្ឋបាលសាធារណៈ គឺជាកម្លាំងចលករដ៏ចាំបាច់ដែលរាជរដ្ឋាភិបាលគ្រប់ជាន់ថ្នាក់ត្រូវយកចិត្តទុកដាក់ជាអាទិភាពបំផុត។ អភិបាលកិច្ចត្រូវបានរាជរដ្ឋាភិបាលកំណត់ថាជាចំណុចស្នូលនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល និងបានផ្តល់សារៈសំខាន់ក្នុងការជំរុញការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការកែទម្រង់តាមវិស័យផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល។

ការកសាងជំនឿនិងទំនុកចិត្តពីប្រជាពលរដ្ឋ គឺជាការលំបាកដែលរាជរដ្ឋាភិបាលត្រូវបន្តយកចិត្តទុកដាក់ជាយុទ្ធសាស្ត្រ តាមរយៈការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពជូនប្រជាពលរដ្ឋឱ្យបានកាន់តែប្រសើរឡើង។ ផ្តើមចេញពីស្មារតីនេះ ការពង្រឹងស្ថាប័នផ្តល់សេវាសាធារណៈ និងភាពជាអ្នកដឹកនាំ គឺជាកាតាលីករដ៏មានសារៈសំខាន់ និងអាទិភាពបំផុតក្នុងការកែលម្អការផ្តល់សេវាសាធារណៈនៅក្នុងស្ថាប័នសាធារណៈ។

ពាក់ព័ន្ធនឹងការកែលម្អការផ្តល់សេវាសាធារណៈនេះ រាជរដ្ឋាភិបាលបានដាក់ចេញ

នូវគោលនយោបាយ បទដ្ឋានគតិយុត្ត និងឯកសារណែនាំមួយចំនួន ដូចជា គោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ ព្រះរាជក្រឹត្យស្តីពីគោលការណ៍រួមនៃការបង្កើត និងដាក់ឱ្យដំណើរការទីភ្នាក់ងារប្រតិបត្តិការពិសេស អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិវាយតម្លៃសេវាសាធារណៈ និងឯកសារណែនាំស្តីពីស្តង់ដាសេវាសាធារណៈ និងអនុក្រឹត្យស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាដើម។

ជាមួយគ្នានោះដែរ ក្រសួងសុខាភិបាល ក៏ដូចជាក្រសួង ស្ថាប័នដទៃទៀតដែរ បានដាក់ចេញនូវផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព ប្រកាស និងបទដ្ឋានគតិយុត្តនានា ដើម្បីលើកកម្ពស់គុណភាពសេវាសាធារណៈឱ្យកាន់តែប្រសើរឡើង។ ឯកសារដែលក្រសួងសុខាភិបាលបានដាក់ចេញមានជាអាទិ៍ ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០១៦-២០២០ ផែនការសកម្មភាពសម្រាប់បង្ការ និងគ្រប់គ្រងជំងឺមិនឆ្លង ២០១៦-២០២០ ផែនការសកម្មភាពពហុវិស័យជាតិស្តីពីការការពារ និងប្រយុទ្ធនឹងជំងឺឆ្លង ២០១៨-២០២៨។

ក្នុងការលើកទឹកចិត្តចំពោះអង្គភាពដែលបានខិតខំកែលម្អគុណភាពនៃការផ្តល់សេវារបស់ខ្លួន រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ស្តីពីការវាយតម្លៃ និងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល។ គោលបំណងនៃអនុក្រឹត្យនេះ គឺដើម្បីជំរុញ និងលើកកម្ពស់ប្រសិទ្ធភាព និងគុណភាពនៃដំណើរការរបស់អង្គភាពផ្តល់សេវាសាធារណៈក្នុងវិស័យអប់រំ និងវិស័យសុខាភិបាលឱ្យកាន់តែប្រសើរឡើង តាមរយៈការកំណត់ឱ្យមានការវាយតម្លៃ និងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូ។ យោងតាមស្មារតីអនុក្រឹត្យនេះ គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានបង្កើតឡើង។ គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិមានរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ជាប្រធាន (គណៈកម្មការមុនខែមេសា ឆ្នាំ ២០២០) គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈរាជធានី ខេត្ត មានអភិបាល

នៃគណៈអភិបាលរាជធានី ខេត្ត ឬតំណាងនៃគណៈអភិបាលរាជធានី ខេត្ត ជាប្រធាន និងគណៈកម្មការវាយតម្លៃអង្គភាពផ្ដល់សេវាសាធារណៈក្រុង ស្រុក ខណ្ឌ មានអភិបាល នៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ឬតំណាង នៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ជាប្រធាន។

ដោយផ្អែកលើនីតិវិធី គោលការណ៍ លក្ខណៈវិនិច្ឆ័យ និងភារកិច្ចដែលបានកំណត់ គណៈកម្មការវាយតម្លៃអង្គភាពផ្ដល់សេវាសាធារណៈនៅគ្រប់លំដាប់ថ្នាក់ បានខិតខំបំពេញភារកិច្ចរបស់ខ្លួនយ៉ាងសកម្មក្នុងការវាយតម្លៃ និងជ្រើសរើសអង្គភាពផ្ដល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល។ ជាលទ្ធផល គណៈកម្មការវាយតម្លៃអង្គភាពផ្ដល់សេវាសាធារណៈថ្នាក់ជាតិ បានសម្រេចជ្រើសរើសអង្គភាពផ្ដល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំចំនួន ១០ និងវិស័យសុខាភិបាលចំនួន ៣០ ដើម្បីផ្ដល់ពានរង្វាន់វិញ្ញាបនបត្រទទួលស្គាល់ និងថវិកាជារង្វាន់លើកទឹកចិត្ត។ ក្នុងចំណោមអង្គភាពផ្ដល់សេវាសាធារណៈគំរូក្នុងវិស័យសុខាភិបាលចំនួន ៣០ ខាងលើមាន÷ ១.មន្ទីរពេទ្យបង្អែករាជធានី ខេត្តដែលផ្ដល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត៣ (CPA3) ចំនួន ១០ ២.មន្ទីរពេទ្យបង្អែករាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ដែលផ្ដល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត២ (CPA2) ចំនួន ១០ និង ៣.មន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ ដែលផ្ដល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត១ (CPA1) ចំនួន ១០។ ក្នុងចំណោមមន្ទីរពេទ្យបង្អែករាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ដែលផ្ដល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត២ (CPA2) ចំនួន ១០ គឺមន្ទីរពេទ្យខេត្តកោះកុងទទួលបានចំណាត់ថ្នាក់លេខ១។

ជាការតបស្នងដល់អង្គភាពផ្ដល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាលទាំង ៤០ ខាងលើ ដែលបានខិតខំបំពេញការងារក្នុងការផ្ដល់សេវាជូនប្រជាពលរដ្ឋបានល្អ នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៩ រាជរដ្ឋាភិបាលបានប្រារព្ធពិធីប្រកាសទទួលស្គាល់ជ័យលាភីអង្គភាពផ្ដល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល ក្រោមអធិបតីភាពឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តំណាងដ៏ខ្ពង់ខ្ពស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ជំពូកទី១

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។**

នៅក្នុងពិធីប្រកាសទទួលស្គាល់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាលនោះ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** បានផ្តល់អនុសាសន៍ចំនួនប្រាំបីចំណុច ដែលអនុសាសន៍ទីមួយ គឺស្នើឱ្យមានការរៀបចំចងក្រងបទពិសោធន៍នៃការអនុវត្តការងាររបស់បណ្តាជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូ ដើម្បីធ្វើជាករណីសិក្សា និងបន្តផ្សព្វផ្សាយជូនអង្គភាពវិទ្យាល័យ និងមន្ទីរពេទ្យបង្អែកផ្សេងទៀតនៅទូទាំងប្រទេស សម្រាប់ជាការដកស្រង់បទពិសោធន៍ និងពង្រីកនវានុវត្តន៍សម្រាប់ការកែលម្អគុណភាពសេវាសាធារណៈរបស់ខ្លួនជូនប្រជាពលរដ្ឋ។ បន្ថែមពីលើនេះ ការចែករំលែកបទពិសោធន៍នៃភាពជោគជ័យរវាងអង្គភាពដែលទទួលបានស្នាដៃឆ្នើម និងអង្គភាពផ្សេងៗទៀត ជាកត្តាចាំបាច់ណាស់ក្នុងការបន្តកែលម្អគុណភាពនៃការផ្តល់សេវាសាធារណៈ ពង្រឹងភាពជាអ្នកដឹកនាំ និងការច្នៃប្រឌិត ដែលអាចនឹងជំរុញឱ្យអង្គភាពបោះជំហានទៅមុខប្រកបដោយភាពជឿទុកចិត្ត។

ដោយយោងអនុសាសន៍ខាងលើ និងសច្ចភាពនៃសារៈសំខាន់នៃការសិក្សារៀនសូត្រពីគ្នាទៅវិញទៅមក ក្រសួងមុខងារសាធារណៈ ដែលមានសាលាភូមិន្ទរដ្ឋបាលជាសេនាធិការ បានរៀបចំក្រុមការងារសិក្សា សម្រាប់រៀបចំចងក្រងនូវបទពិសោធន៍ និងមេរៀនល្អៗពីអង្គភាពផ្តល់សេវាសាធារណៈគំរូ ឬដែលទទួលបានជ័យលាភីលេខ១ នាពេលកន្លងមកទាំងក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល។

ក្នុងវិស័យសុខាភិបាលមានអង្គភាពផ្តល់សេវាសាធារណៈគំរូទទួលបានជ័យលាភីលេខ១ ចំនួន ៣ រួមមាន ១.មន្ទីរពេទ្យខេត្តកំពង់ចាម ដែលទទួលបានជ័យលាភីលេខ១ ក្នុងចំណោមមន្ទីរពេទ្យបង្អែករាជធានី ខេត្ត ដែលផ្តល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត ៣ (CPA3) ២.មន្ទីរពេទ្យខេត្តកោះកុង ដែលទទួលបានជ័យលាភីលេខ១ ក្នុងចំណោមមន្ទីរពេទ្យបង្អែករាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌដែលផ្តល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត២ (CPA2) និង៣.មន្ទីរពេទ្យបង្អែកបាកាន នៅខេត្តពោធិ៍សាត់ដែលទទួលបាន

ជ័យលាភីលេខ១ ក្នុងចំណោមមន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ ដែលផ្ដល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត១ (CPA1)។ ហេតុដូច្នេះ មន្ទីរពេទ្យខេត្តកោះកុង បានក្លាយជាអង្គភាពគោលដៅសម្រាប់សិក្សាស្រាវជ្រាវក្នុងការរៀបចំចងក្រងករណីសិក្សានេះឡើង។

## ១.២. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ មានគោលបំណង÷

- ប្រមូលចងក្រងនូវមេរៀន និងបទពិសោធន៍ល្អៗនៅក្នុងដំណើរការគ្រប់គ្រង និងផ្ដល់សេវារបស់មន្ទីរពេទ្យខេត្តកោះកុង ដែលជាជ័យលាភីអង្គភាពផ្ដល់សេវាសាធារណៈគំរូ ទទួលបានចំណាត់ថ្នាក់លេខ១ ក្នុងចំណោមមន្ទីរពេទ្យបង្អែករាជធានីខេត្ត និងក្រុង ស្រុក ខណ្ឌដែលផ្ដល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត២ (CPA2) នៃវិស័យសុខាភិបាល សម្រាប់ជាការចែករំលែកចំណេះដឹងបន្ថែមទៅដល់អង្គភាពផ្ដល់សេវាសាធារណៈផ្សេងៗទៀត
- ផ្ដល់ជាធាតុចូល ឬអនុសាសន៍ទៅលើចំណុចខ្វះខាតមួយចំនួនដល់មន្ទីរពេទ្យខេត្តកោះកុង ដើម្បីបង្កើនគុណភាពការផ្ដល់សេវារបស់អង្គភាពឱ្យកាន់តែប្រសើរឡើង
- សិក្សាស្វែងយល់អំពីការចូលរួមចំណែករបស់ភាគីពាក់ព័ន្ធ (រដ្ឋបាលខេត្ត រដ្ឋបាលក្រុង មន្ទីរសុខាភិបាល ដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធដទៃទៀត) នៅក្នុងដំណើរការនៃការផ្ដល់សេវារបស់មន្ទីរពេទ្យ។

## ១.៣. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះពិនិត្យមើលទៅលើការគ្រប់គ្រង និងការផ្ដល់សេវាសាធារណៈរបស់មន្ទីរពេទ្យខេត្តកោះកុង ក្នុងអំឡុងឆ្នាំ២០១៥ រហូតដល់ឆ្នាំ២០១៩។

ការសិក្សាស្រាវជ្រាវនេះផ្ដោតសំខាន់ទៅលើការអនុវត្តតាមនូវលក្ខណៈវិនិច្ឆ័យគោលទាំង៨ ដែលបានចែងក្នុងអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ស្ដីពីការវាយតម្លៃ និងការទទួលស្គាល់អង្គភាពផ្ដល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និង

ជំពូកទី១

វិស័យសុខាភិបាល។ លក្ខណៈវិនិច្ឆ័យគោលទាំង៨ នោះ រួមមាន ១. ស្តង់ដាសេវាសាធារណៈ ២. ស្តង់ដានៃការផ្តល់សេវាសាធារណៈក្នុងវិស័យសុខាភិបាលសម្រាប់មន្ទីរពេទ្យបង្អែក (CPA2) ៣. ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងអង្គភាព ៤. ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅក្នុងអង្គភាព ៥. ការរៀបចំ និងការកែលម្អបរិស្ថានអង្គភាព ៦. ទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ សហគមន៍ និងដៃគូអភិវឌ្ឍ ព្រមទាំងការចូលរួមវាយតម្លៃពីអ្នកប្រើប្រាស់សេវាសាធារណៈ ៧. ការដោះស្រាយបញ្ហាប្រឈមជាមួយប្រជាពលរដ្ឋ និងសហគមន៍ និង៨. ការផ្តួចផ្តើមគំនិតថ្មីៗ និងនវានុវត្តន៍ ដើម្បីធ្វើឱ្យអង្គភាពមានដំណើរការកាន់តែប្រសើរ។

## ១.៤. វិធីសាស្ត្រសិក្សាចងក្រងករណីសិក្សា

វិធីសាស្ត្រសិក្សាតាមបែបគុណភាព ត្រូវបានយកមកប្រើនៅក្នុងការសិក្សានេះ ដើម្បីប្រមូលចងក្រងបទពិសោធន៍ និងការប្រតិបត្តិជាក់ស្តែងរបស់អង្គភាពផ្តល់សេវាសាធារណៈពោលគឺ មន្ទីរពេទ្យខេត្តកោះកុង សម្រាប់ចែករំលែកចំណេះដឹង និងបម្រើផលប្រយោជន៍ដល់ការរៀនសូត្ររបស់អង្គភាពផ្តល់សេវាសាធារណៈដទៃទៀត។ វិធីសាស្ត្រសិក្សាតាមបែបគុណភាពបានជួយដល់ការសិក្សាស្វែងយល់អំពីការអនុវត្តការងារដឹកនាំ ចាត់ចែង និងសម្របសម្រួលរបស់មន្ទីរពេទ្យខេត្តកោះកុង លើការផ្តល់សេវាសាធារណៈផ្នែកសុខាភិបាលដល់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន និងដើម្បីចងក្រងអំពីយុទ្ធសាស្ត្រ និងនីតិវិធីប្រតិបត្តិរបស់មន្ទីរពេទ្យនេះរហូតដល់ទទួលបានជ័យលាភីលេខ១ ក្នុងចំណោមមន្ទីរពេទ្យដែលផ្តល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត២ នៅទូទាំងប្រទេសកម្ពុជា។

### ១.៤.១. វិសាលភាពនៃការសិក្សា

ការសិក្សាចងក្រងករណីសិក្សានេះផ្តោតទៅលើតែមន្ទីរពេទ្យខេត្តកោះកុង ដែលទទួលបានជ័យលាភីលេខ១ ផ្នែកមន្ទីរពេទ្យដែលផ្តល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត២ ក្នុងវិស័យសុខាភិបាល និងដែលទទួលស្គាល់ដោយអនុក្រឹត្យលេខ ១១០ អនក្រ.បក ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៩។ ជាមួយគ្នានេះផងដែរ ក្រុមការងារចងក្រងករណីសិក្សា

បានជ្រើសរើសកំណត់ក្រុមគោលដៅសំខាន់សម្រាប់ការចុះប្រមូលព័ត៌មាន និងទិន្នន័យ ចម្បងពីភាគីពាក់ព័ន្ធគោល ដែលរួមមានអ្នកផ្តល់សេវាសាធារណៈផ្ទាល់នៅក្នុងអង្គភាពផ្តល់សេវាសាធារណៈ និងអ្នកទទួលសេវាផ្សេងៗដូចមានសង្ខេបក្នុងតារាងខាងក្រោម។

តារាងទី១÷ ក្រុមគោលដៅដែលបានប្រមូលព័ត៌មាន និងទិន្នន័យ

| | |
|---|---|
| ▪ តំណាងអភិបាល នៃគណៈអភិបាលខេត្ត | ០១ នាក់ |
| ▪ គណៈគ្រប់គ្រងមន្ទីរពេទ្យខេត្តកោះកុង (នាយក ឬនាយករង) | ០២ នាក់ |
| ▪ សមាជិកគណៈកម្មការ (ប្រធាន ឬអនុប្រធាន) | ០៩នាក់ (ស្ត្រី០២នាក់) |
| ▪ មន្ទីរសុខាភិបាលខេត្តកោះកុង | ០៥នាក់ (ស្ត្រី០១នាក់) |
| ▪ រដ្ឋបាលថ្នាក់ស្រុក-ក្រុង (អភិបាល ឬអភិបាលរងទទួលបន្ទុក) | ០៣នាក់ (ស្ត្រី០១នាក់) |
| ▪ អ្នកសម្រាកព្យាបាលជំងឺ | ០៨នាក់ (ស្ត្រី០៥នាក់) |
| ▪ អ្នកកំដរអ្នកជំងឺ | ១២នាក់ (ស្ត្រី១០នាក់) |
| ▪ តំណាងសហគមន៍ | ០៨នាក់ (ស្ត្រី០៥នាក់) |
| ▪ បុគ្គលិកមន្ទីរពេទ្យ | ២៦នាក់ (ស្ត្រី១០នាក់) |
| ▪ បុគ្គលិកអនាម័យ | ០៤ នាក់ (ស្ត្រី០៤នាក់) |
| ▪ សន្តិសុខ | ០១នាក់ |

### ១.៤.២. វិធីសាស្ត្រប្រមូលព័ត៌មាន និងទិន្នន័យ

(១) ការសិក្សា ពិនិត្យ និងវិភាគលើឯកសារដែលមានស្រាប់របស់មន្ទីរពេទ្យខេត្តកោះកុង

ក្រុមការងាររចងក្រងករណីសិក្សាសម្រាប់មន្ទីរពេទ្យខេត្តកោះកុង បានពិនិត្យ និងវិភាគលើឯកសារដែលមានស្រាប់ រួមមាន÷

- លិខិតបទដ្ឋានគតិយុត្ត ឯកសារគោលនយោបាយ និងរបាយការណ៍ផ្សេងៗ អំពី

កំណែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល និងដែលពាក់ព័ន្ធនឹងដំណើរការវិវត្តន៍ក្នុងការលើកកម្ពស់ការផ្តល់សេវាសាធារណៈឱ្យបានកាន់តែល្អប្រសើរតាមរយៈអង្គភាពផ្តល់សេវាសាធារណៈ ពិសេសក្នុងវិស័យសុខាភិបាល។

- ឯកសារទាំងឡាយដែលមន្ទីរពេទ្យខេត្តកោះកុងបានផ្ញើមក សម្រាប់ការវាយតម្លៃជ្រើសរើសជ័យលាភីកាលពីឆ្នាំ២០១៨ ត្រូវបានធ្វើការពិនិត្យបន្ថែមក្នុងការកំណត់រកឱ្យឃើញនូវបទពិសោធន៍នានាដែលជំរុញឱ្យអង្គភាពនេះទទួលបានជោគជ័យក្នុងការផ្តល់សេវាសាធារណៈ ដល់ប្រជាជន ក្នុងផ្នែកជាមន្ទីរពេទ្យដែលផ្តល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត២ (CPA2)។

(២) វិធីសាស្រ្ត និងបច្ចេកទេសប្រមូលព័ត៌មាន និងទិន្នន័យ

(ក) បទសម្ភាសន៍ស៊ីជម្រៅជាមួយជនបង្គោល÷ កិច្ចការនេះបានធ្វើឡើងជាមួយប្រធានមន្ទីរពេទ្យ អនុប្រធានមន្ទីរពេទ្យ ប្រធានផ្នែក នៃមន្ទីរពេទ្យខេត្តកោះកុង និងបុគ្គលិកតាមផ្នែក បុគ្គលិកអនាម័យ និងសន្តិសុខ និងថ្នាក់ដឹកនាំសាលាខេត្តកោះកុង។ ក្រុមការងារចងក្រងករណីសិក្សា បានផ្ញើលិខិតសុំការអនុញ្ញាតជួបប្រជុំជាមុន ហើយធ្វើការប្រមូលព័ត៌មានតាមការសាកសួរ និងការថតសំឡេងទុក (ដោយមានការសុំការអនុញ្ញាតទុកជាមុនផង) សម្រាប់ការស្រង់ព័ត៌មានសំខាន់ៗនៅពេលរៀបចំករណីសិក្សា។ ការធ្វើសម្ភាសន៍ស៊ីជម្រៅជាមួយជនបង្គោលសំខាន់ទាំងនេះ បានចំនួន ១៩នាក់ (ស្រ្តី ០៤នាក់) និងមានរយៈពេលយ៉ាងច្រើនពី ៦០-១២០នាទី សម្រាប់បុគ្គលម្នាក់ៗ។

(ខ) ការពិភាក្សាជាក្រុម÷ ក្រុមការងារបានធ្វើការពិភាក្សាជាមួយ(១) ក្រុមបុគ្គលិកមន្ទីរពេទ្យ (២)គ្រួសារអ្នកជំងឺកំពុងសម្រាកពេទ្យ (៣)អ្នកធ្លាប់ប្រើប្រាស់សេវាមន្ទីរពេទ្យ។ ក្រុមការងារធ្វើការពិភាក្សាជាក្រុមជាមួយអ្នកពាក់ព័ន្ធតាមស្ថានភាពជាក់ស្តែងទៅតាមក្រុមនីមួយៗ និងតាមការណាត់អញ្ជើញចូលរួមប្រជុំជាមុននៅតាមពេលវេលា និងទីកន្លែងដែលបានព្រមព្រៀងគ្នា។ សមាជិកក្រុមពិភាក្សា

នីមួយៗ មានសមាជិកពិភាក្សាចំនួនពី ០៦-០៨នាក់ ដោយមានលាយសមាសភាពយេនឌ័រស្មើគ្នា (ប្រុស-ស្រី) និងរយៈពេលពិភាក្សាមានចន្លោះពី ៣០-៤៥នាទីសម្រាប់ក្រុមនីមួយៗ។

(គ) ការចុះអង្កេតផ្ទាល់ដល់ទីតាំងមន្ទីរពេទ្យខេត្តកោះកុង៖ ក្រុមការងារចងក្រងករណីសិក្សាបានចុះសិក្សា និងបានពិនិត្យមើលទីតាំង បរិវេណ និងហេដ្ឋារចនាសម្ព័ន្ធជាក់ស្ដែងរបស់មន្ទីរពេទ្យខេត្តកោះកុងដើម្បីឆ្លើយតបទៅនឹងកិច្ចខិតខំប្រឹងប្រែងរបស់មន្ទីរពេទ្យ ក្នុងការងារផ្ដល់សេវាសាធារណៈដល់ប្រជាពលរដ្ឋ និងដើម្បីថតយករូបភាពសកម្មភាពនៃការផ្ដល់សេវាតាមទិដ្ឋភាពជាក់ស្ដែង។ អ្នកថតរូបបានសុំការអនុញ្ញាតពីមន្ទីរពេទ្យ ឬអ្នកដែលមាននៅក្នុងរូបថតជាមុនសិន ពីព្រោះរូបថតខ្លះត្រូវបានប្រើប្រាស់ជាសាធារណៈនៅក្នុងរបាយការណ៍ករណីសិក្សា។

ព័ត៌មាន និងទិន្នន័យដែលប្រមូលបាន ផ្ដោតជាសំខាន់ទៅលើចំណុចគន្លឹះមួយចំនួនដូចជា (ក) ថាតើមន្ទីរពេទ្យខេត្តកោះកុងបានធ្វើអ្វីខ្លះក្នុងការប្រតិបត្តិការងារផ្ដល់សេវាសុខាភិបាលដល់ប្រជាពលរដ្ឋ ហើយបានអនុវត្តការងារទាំងនោះយ៉ាងដូចម្ដេច ឬមានយុទ្ធសាស្ត្រយ៉ាងណាខ្លះក្នុងការជំរុញប្រសិទ្ធភាពក្នុងការផ្ដល់សេវាសាធារណៈឱ្យកាន់តែប្រសើរឡើង? លើសពីនេះទៀត កិច្ចពិភាក្សាជាមួយមន្ទីរពេទ្យខេត្តកោះកុង រដ្ឋបាលខេត្តកោះកុង និងភាគីពាក់ព័ន្ធទាំងឡាយនេះក៏ផ្ដោតលើទស្សនៈ ឬការយល់ឃើញរបស់អ្នកឆ្លើយតបទាក់ទងនឹងតម្រូវការ ការគាំទ្រ បញ្ហាប្រឈម និងកិច្ចអន្តរាគមន៍នានាដែលបានអនុវត្តកន្លងមក និងសម្រាប់ពេលអនាគត ដើម្បីធានាថាការផ្ដល់សេវាសាធារណៈនៅតែមានសារៈសំខាន់ មានភាពសកម្ម និងទទួលបានការពេញចិត្តពីអ្នកប្រើប្រាស់។ សំណួរគន្លឹះទាំងអស់ដែលនឹងផ្ដោតទៅលើលក្ខណៈវិនិច្ឆ័យទាំងប្រាំបី ដែលត្រូវបានប្រើប្រាស់ក្នុងការជ្រើសរើសអង្គភាពផ្ដល់សេវាសាធារណៈគំរូ តាមរយៈសំណួរគន្លឹះគោលៗសង្ខេបដូចខាងក្រោម៖

តារាងទី២÷ លក្ខណៈវិនិច្ឆ័យគោលទាំងប្រាំបី និងសំណួរគន្លឹះៗ

| លក្ខណៈវិនិច្ឆ័យគោល | សំណួរគន្លឹះៗ |
|---|---|
| (១) ស្តង់ដានៃការផ្តល់សេវាសាធារណៈ ដូចមានចែងក្នុងអនុក្រឹត្យលេខ ៤៥៥ ឆ្នាំ២០១៣ | តើមន្ទីរពេទ្យមានស្តង់ដានៃការផ្តល់សេវាសាធារណៈអ្វីខ្លះ? |
| (២) ស្តង់ដានៃការផ្តល់សេវាសាធារណៈរបស់អង្គភាព | តើមន្ទីរពេទ្យ បានរៀបចំនិងអភិវឌ្ឍស្តង់ដារនៃការផ្តល់សេវាសាធារណៈរបស់អង្គភាពអ្វីខ្លះ និងយ៉ាងដូចម្តេច? |
| (៣) ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរួមមានផែនការហិរញ្ញវត្ថុ ការគ្រប់គ្រងចំណូល និងចំណាយ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងលទ្ធកម្មសាធារណៈ | តើមន្ទីរពេទ្យ មានយុទ្ធសាស្ត្រ និងផែនការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈអ្វីខ្លះ និងយ៉ាងដូចម្តេចទៅលើផែនការហិរញ្ញវត្ថុ ការគ្រប់គ្រងចំណូល និងចំណាយ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងលទ្ធកម្មសាធារណៈ? |
| (៤) ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្សនៅក្នុងអង្គភាព | តើមន្ទីរពេទ្យមានយុទ្ធសាស្ត្រអ្វីខ្លះ និងយ៉ាងដូចម្តេចក្នុងការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅក្នុងអង្គភាព? |
| (៥) ការរៀបចំនិងការកែលម្អបរិស្ថាននៅក្នុងអង្គភាព | តើមន្ទីរពេទ្យមានយុទ្ធសាស្ត្រអ្វីខ្លះ និងយ៉ាងដូចម្តេចក្នុងការរៀបចំ និងការកែលម្អបរិស្ថាននៅក្នុងអង្គភាព? |
| (៦) ទំនាក់ទំនងល្អជាមួយសាធារណជន សហគមន៍ ដៃគូអភិវឌ្ឍ រួមទាំងការចូលរួមវាយតម្លៃដោយអ្នកប្រើប្រាស់សេវាសាធារណៈ | តើមន្ទីរពេទ្យមានយុទ្ធសាស្ត្រអ្វីខ្លះ និងយ៉ាងដូចម្តេចក្នុងការធ្វើទំនាក់ទំនងល្អជាមួយសាធារណជន សហគមន៍ ដៃគូអភិវឌ្ឍ រួមទាំងការចូលរួមវាយតម្លៃដោយអ្នកប្រើប្រាស់សេវាសាធារណៈ? |

| លក្ខណៈវិនិច្ឆ័យគោល | សំណួរគន្លឹះៗ |
|---|---|
| (៧) ការដោះស្រាយ និងឆ្លើយតបនឹងបញ្ហា/វិវាទ/បណ្តឹងតវ៉ា ជាមួយមន្ត្រីរដ្ឋាភិបាល សាធារណជន និងសហគមន៍ | តើមន្ទីរពេទ្យមានផែនការអ្វីខ្លះ និងយ៉ាងដូចម្តេចក្នុងការដោះស្រាយ និងឆ្លើយតបនឹងបញ្ហា ឬវិវាទ ឬបណ្តឹងតវ៉ា ជាមួយមន្ត្រីរដ្ឋាភិបាល សាធារណជន និងសហគមន៍? |
| (៨) ការផ្តួចផ្តើមគំនិតថ្មីៗ និងនវានុវត្តន៍ ដើម្បីឱ្យអង្គភាពមានដំណើរការកាន់តែប្រសើរ។ | តើមន្ទីរពេទ្យមានការផ្តួចផ្តើមគំនិតថ្មីៗ និងនវានុវត្តន៍អ្វីខ្លះ និងធ្វើយ៉ាងដូចម្តេច ដើម្បីឱ្យអង្គភាពមានដំណើរការកាន់តែប្រសើរ? |

*(ឃ)*ការជួបពិភាក្សា និងប្រមូលធាតុចូលពីក្រុមការងារ÷ ក្រុមការងាររចងក្រងករណីសិក្សាសម្រាប់មន្ទីរពេទ្យខេត្តកោះកុង បានរៀបចំសរសេរសេចក្តីព្រាងករណីសិក្សា (ត្រូវផ្អែកតាមទម្រង់ដែលបានឯកភាព) ទៅតាមព័ត៌មាន និងទិន្នន័យផ្តល់ជូនដោយមន្ទីរពេទ្យ។ ក្រុមការងារបានធ្វើសេចក្តីព្រាងករណីសិក្សា ហើយពិគ្រោះយោបល់បន្ថែមជាមួយមន្ទីរពេទ្យ និងភាគីពាក់ព័ន្ធដែលត្រូវបានជួបសម្ភាស ដើម្បីធានាថាអ្វីៗដែលបានសរសេរ និងលើកឡើងនៅក្នុងករណីសិក្សា ពិតជាត្រឹមត្រូវ និងឆ្លុះបញ្ចាំង នូវទិដ្ឋភាពជាក់ស្តែងដែលមន្ទីរពេទ្យខេត្តកោះកុង ធ្លាប់បានឆ្លងកាត់ និងបានកំពុងអនុវត្តផ្ទាល់នាពេលបច្ចុប្បន្ន។ ជាងនេះទៅទៀត ករណីសិក្សាអំពីមន្ទីរពេទ្យខេត្តកោះកុង ត្រូវបានយកមកធ្វើបទបង្ហាញ និងពិភាក្សាជាមួយក្រុមការងារផ្ទៃក្នុង និងជាមួយក្រុមការងារដឹកនាំរួម ដើម្បីប្រមូលធាតុចូល និងមតិកែលម្អនានាពីក្រុមការងារទាំងអស់។ បន្ទាប់មកក្រុមការងារដឹកនាំរួម បានពិនិត្យ និងបានដាក់ជូនករណីសិក្សា ឆ្លងមតិយោបល់

ជាមួយគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ ដើម្បីសម្រេចជាលើកចុងក្រោយមុនពេលបញ្ចប់ករណីសិក្សានេះ និងបោះពុម្ពផ្សាយជាផ្លូវការ។ ការពិនិត្យផ្តល់យោបល់ និងការកែសម្រួលអាចត្រូវបានធ្វើឡើងជាច្រើនដង ដើម្បីធានាឱ្យបាននូវសុក្រឹតភាព និងភាពគ្រប់ជ្រុងជ្រោយនៃករណីសិក្សានេះ។

### ១.៤.៣. វិធីសាស្ត្រវិភាគទិន្នន័យ

- ទិន្នន័យដែលប្រមូលបាន ត្រូវបានយកមកពិនិត្យលើគុណភាពទិន្នន័យ (នៅថ្ងៃទី១ បន្ទាប់ពីប្រមូលបាន និងរៀងរាល់ ២ថ្ងៃម្តង យ៉ាងយូរ ក្នុងអំឡុងពេលប្រមូលទិន្នន័យ) ដោយផ្តោតលើ missing data និង inconsistency របស់ទិន្នន័យ
- រៀបចំទិន្នន័យតាមលក្ខណៈវិនិច្ឆ័យគោលទាំងប្រាំបី
- ធ្វើសុក្រឹតភាពទិន្នន័យ តាមរយៈការប្រៀបធៀបទិន្នន័យដែលទទួលបានពីប្រភពផ្សេងៗ និងការប្រជុំពិភាក្សាក្នុងក្រុមការងារចុះប្រមូលទិន្នន័យ
- វិភាគទិន្នន័យតាមលក្ខណៈវិនិច្ឆ័យគោលទាំងប្រាំបីដែលបានធ្វើឡើងតាមវិធីសាស្ត្រការពិពណ៌នាបែបគុណភាព។

## ១.៥. ក្រមសីលធម៌នៃការសម្ភាស និងការសិក្សាចងក្រងករណីសិក្សា

- សម្រាប់ការរក្សានូវក្រមសីលធម៌ ក្រុមការងារបានធ្វើលិខិតសុំការអនុញ្ញាតពីក្រសួងសុខាភិបាលក្នុងការជួយសហការ និងស្នើអនុញ្ញាតឱ្យមន្ត្រី និងអង្គភាពក្រោមឱវាទដែលពាក់ព័ន្ធអាចឆ្លើយសំណួរសម្រាប់ការសម្ភាស និងការប្រមូលព័ត៌មានណាមួយនៅក្នុងអំឡុងពេលនៃការសិក្សាចងក្រងករណីសិក្សាទាំងនេះ។
- ក្រុមសិក្សាបានប្រកាន់ខ្ជាប់នូវក្រមសីលធម៌ និងត្រូវទទួលបានការឯកភាពជាមុនពីអ្នកដែលត្រូវសម្ភាស ឬអង្គភាព។ ក្រុមការងារ អាចបញ្ឈប់ ឬរំលងសម្ភាសន៍នៅពេលណាដែលអ្នកផ្តល់ការសម្ភាសមានសភាពអសកម្មខាងផ្នែកស្មារតី និងរាងកាយ ឬមិនទទួលបានការអនុញ្ញាតជាដើម។ ម៉្យាងទៀត ក្រុមការងារបាន

ជម្រាបជូនមន្ទីរពេទ្យខេត្តកោះកុង និងអ្នកដែលត្រូវសម្ភាសពីគោលការណ៍ និងក្រមសីលធម៌នេះមុនពេលចាប់ផ្តើមសម្ភាសន៍។ ក្រុមការងារបានអានគោលការណ៍ និងក្រមសីលធម៌នោះឱ្យបានឮៗ ដល់អ្នកដែលត្រូវសម្ភាស ហើយអនុញ្ញាតឱ្យគាត់សួរបញ្ជាក់ចំពោះប្រយោគណាមួយ ដែលគាត់មិនបានយល់ច្បាស់។ ប្រសិនបើគ្មានការយល់ព្រមទេនោះ ក្រុមការងារត្រូវប្តូរទៅរកអ្នកដែលត្រូវសម្ភាសបន្ទាប់ទៀត។ ក្រុមការងាររករណីសិក្សា រក្សាឱ្យបាននូវភាពសម្ងាត់ ឬព័ត៌មានអសាធារណៈរបស់មន្ទីរពេទ្យ លើកលែងតែមានការអនុញ្ញាតឱ្យប្រើប្រាស់ពីមន្ទីរពេទ្យ។

# ជំពូកទី២. ស្ថានភាពបច្ចុប្បន្នវិស័យសុខាភិបាល និងសមិទ្ធកម្ម មន្ទីរពេទ្យខេត្តកោះកុង

## ២.១. បរិបទរួមនៃការកែទម្រង់រដ្ឋបាលសាធារណៈ

រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវកម្មវិធីនយោបាយ ដោយឈរលើគោលការណ៍គ្រឹះសំខាន់ៗ ក្នុងនោះមានការលើកកម្ពស់ការផ្តល់សេវាសាធារណៈជូនប្រជាជនគ្រប់ផ្នែក គ្រប់ថ្នាក់ និងគ្រប់មជ្ឈដ្ឋានឱ្យកាន់តែប្រសើរឡើង ទាំងគុណភាព ប្រសិទ្ធភាព និងវិសាលភាព ពោលគឺជាសេវាសាធារណៈដែលនៅកៀកជាមួយនឹងប្រជាជន និងទទួលបានការជឿទុកចិត្តពីប្រជាជន[១]។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏បាន និងកំពុងបន្តជំរុញដំណើរការការងារកែទម្រង់ស៊ីជម្រៅ និងទូលំទូលាយ រួមមាន÷ ការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងជាពិសេស ដោយផ្តោតសំខាន់លើវិស័យអប់រំ និងសុខាភិបាល សំដៅធ្វើឱ្យសេវាសាធារណៈកាន់តែមានភាពឆ្លើយតប ប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងជំនឿទុកចិត្តពីប្រជាជន។

ជាលទ្ធផល រាជរដ្ឋាភិបាលកម្ពុជា សម្រេចបានសមិទ្ធផលធំៗជាច្រើន ជាពិសេសការសម្រេចបាននូវគោលដៅនៃសូចនាករផ្នែកសង្គមកិច្ច ទាំងក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល។ ជាក់ស្តែង សុខភាពសាធារណៈ ត្រូវបានកែលម្អជាលំដាប់ ក្នុងនោះរាជរដ្ឋាភិបាលកម្ពុជា សម្រេចបានស្ទើរទាំងស្រុងនូវគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា ២ ទៅ ៣ឆ្នាំ មុនកាលវិភាគកំណត់ទាក់ទងនឹង ការកាត់បន្ថយអត្រាមរណភាពមាតា ទារក និងកុមារ ការកាត់បន្ថយបន្ទុកជំងឺឆ្លង ដូចជា ជំងឺអេដស៍ ជំងឺគ្រុនចាញ់ និងជំងឺរបេង ជំងឺមិនឆ្លង និងកត្តាហានិភ័យនានា ដែលមានផលប៉ះពាល់ដល់សុខភាពប្រជាជន ជាពិសេសទទួលបានជោគជ័យក្នុងការលុបបំបាត់ជំងឺកញ្ជ្រឹលទាំងស្រុងនៅឆ្នាំ២០១៦[២]។ បើយើង

[១] រាជរដ្ឋាភិបាលកម្ពុជា, ឆ្នាំ២០១៣ *កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥*, ទំព័រ ៥

[២] រាជរដ្ឋាភិបាលកម្ពុជា. ឆ្នាំ២០១៩ *របាយការណ៍វឌ្ឍនភាពគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ២០១៦-២០៣០*

ក្រឡេកមើលអាយុកាលសង្ឃឹមរស់ជាមធ្យមរបស់ប្រជាជនបានកើនពី ៥៦,៧ឆ្នាំ នៅឆ្នាំ ១៩៩៨ ដល់ ៧០,៦ឆ្នាំ នៅឆ្នាំ២០១៨។ ម្យ៉ាងទៀត រាជរដ្ឋាភិបាលបានបង្កើនការបង្ការហានិភ័យហិរញ្ញវត្ថុ ក្នុងគោលបំណងផ្តល់ការគាំពារផ្នែកហិរញ្ញវត្ថុក្នុងការប្រើប្រាស់សេវាថែទាំសុខភាពរបស់ប្រជាជនតាមយន្តការគាំពារសុខភាពសង្គម ដែលកំពុងត្រូវបានអនុវត្តដូចជាកម្មវិធីមូលនិធិសមធម៌ របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ដល់ស្ត្រីក្រីក្រមានគភ៌ និងកុមារមានអាយុក្រោម ២ឆ្នាំ។ តាមការប៉ាន់ប្រមាណនៅឆ្នាំ២០១៩ ប្រជាជន ៣៨,៥% នៃប្រជាជនកម្ពុជាសរុបជាង ១៦លាននាក់ ត្រូវបានគ្របដណ្តប់ដោយមូលនិធិសមធម៌ និងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព (ដោយមិនរាប់បញ្ចូលការធានារ៉ាប់រងសុខភាពឯកជន) ដោយកើនឡើងពី ៣៥,៧% នៅឆ្នាំ២០១៨[៣]។

ប្រការនេះបានធ្វើឱ្យស្ថានភាពទូទៅរបស់ប្រជាជនកាន់តែប្រសើរឡើង តាមរយៈការលើកកម្ពស់សុខភាព និងសុខុមាលភាពប្រកបដោយសមធម៌ក្នុងចំណោមប្រជាជនដែលមានស្ថានភាពសេដ្ឋកិច្ចខុសៗគ្នា និងរវាងប្រជាជនរស់នៅទីប្រជុំជន និងតំបន់ជនបទ[៤]។

## ២.២. ទិដ្ឋភាពរួមនៃប្រព័ន្ធសុខាភិបាល

**ក្នុងក្របខ័ណ្ឌនៃការកែទម្រង់នេះ** រាជរដ្ឋាភិបាលកម្ពុជា បានគិតគូរយ៉ាងយកចិត្តទុកដាក់ក្នុងការកែលម្អប្រព័ន្ធសុខាភិបាល តាមរយៈការធ្វើកំណែទម្រង់ជាដំណាក់កាលៗ ចាប់តាំងពីឆ្នាំ១៩៩៤ ដោយផ្តោតលើ **«ការកែលម្អ និងពង្រីកការថែទាំសុខភាពបឋមតាមរយៈការអនុវត្តអភិក្រមប្រព័ន្ធសុខាភិបាលស្រុក»** សំដៅឆ្លើយតបទៅនឹងតម្រូវការផ្នែកសុខភាពជាសារវ័ន្តរបស់ប្រជាពលរដ្ឋ។ ការធ្វើកំណែទម្រង់វិស័យសុខាភិបាល បាននាំមកនូវការផ្លាស់ប្តូរជាបណ្តើរៗចំពោះវិស័យសុខាភិបាលកម្ពុជា ដោយបានប្រែក្លាយប្រព័ន្ធសុខាភិបាលកម្ពុជាពី **«ការរៀបចំប្រព័ន្ធសុខាភិបាលឈរលើរចនាសម្ព័ន្ធរដ្ឋបាលទៅរកប្រព័ន្ធសុខាភិបាលផ្អែកលើលក្ខណៈវិនិច្ឆ័យចំនួនប្រជាជន និងលទ្ធភាពមកទទួល**

[៣] ក្រសួងសុខាភិបាល, ឆ្នាំ២០១៩ *របាយការណ៍សមិទ្ធផលសុខាភិបាល*

[៤] ក្រសួងសុខាភិបាល, ឆ្នាំ២០១៦ ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០១៦-២០២០

**យកសេវាសុខភាព»** និងមានការរៀបចំដាក់ចេញជា ៣ថ្នាក់ ដែលមានថ្នាក់កណ្តាល ថ្នាក់រាជធានី/ខេត្ត និងថ្នាក់ស្រុក (រូបភាពទី១) ព្រមទាំងត្រូវបានពិនិត្យ និងកំណត់ច្បាស់លាស់សារជាថ្មីឡើងវិញនូវតួនាទី និងមុខងារនៃថ្នាក់នីមួយៗ[៥]។

រូបភាពទី១÷ ប្រព័ន្ធសុខាភិបាលសាធារណៈ




ក្នុងបរិបទនេះ ប្រព័ន្ធសុខាភិបាល បានផ្តោតជាសំខាន់ទៅលើការអនុវត្តផែនការគ្របដណ្តប់សុខាភិបាល (ផ.គ្រ.ស) ដែលជាក្របខ័ណ្ឌសម្រាប់អភិវឌ្ឍន៍បណ្តាញហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល ដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យពីររួមគ្នា÷ **ចំនួនប្រជាជន និងលទ្ធភាពទទួលបានសេវាសុខភាព** (តារាងទី៣) ព្រមទាំងគិតគូរបន្ថែមអំពីគុណភាពនៃការថែទាំ និងធនធានដែលមាន។ ជាលទ្ធផល រហូតដល់ឆ្នាំ២០១៩ មូលដ្ឋានសុខាភិបាលសាធារណៈទូទាំងប្រទេស រួមមាន÷ មណ្ឌលសុខភាពចំនួន ១.២២១កន្លែង ប៉ុស្តិ៍សុខភាព ១២៧កន្លែង និងមន្ទីរពេទ្យ ១២៦កន្លែង ក្នុងនោះមន្ទីរពេទ្យជាតិ៩ មន្ទីរពេទ្យបង្អែករាជធានី/ខេត្ត ២៥ និងមន្ទីរពេទ្យបង្អែកស្រុកប្រតិបត្តិ ៩២ ស្ថិតក្នុងស្រុកប្រតិបត្តិ ១០៣ ក្នុងរាជធានី/ខេត្តទាំង ២៥។

[៥] សេចក្តីណែនាំសម្រាប់អភិវឌ្ឍន៍ស្រុកប្រតិបត្តិឆ្នាំ២០១៨

ជំពូក២

តារាងទី៣÷ លក្ខណៈវិនិច្ឆ័យសម្រាប់បង្កើតមូលដ្ឋានសុខាភិបាល

| មូលដ្ឋានសុខាភិបាល | ចំនួនប្រជាជន (នាក់) | លទ្ធភាពទទួលបានសេវា |
|---|---|---|
| មណ្ឌលសុខភាព | ចំនួនសមស្រប ១០.០០០ ប្រែប្រួលពី ៨.០០០-១២.០០០ | ក្នុងរង្វង់ ១០គ.ម ឬ ធ្វើដំណើរជាអតិបរមា ២ម៉ោង ដោយថ្មើរជើងក្នុងតំបន់ទទួលខុសត្រូវរបស់មណ្ឌលសុខភាព |
| មន្ទីរពេទ្យបង្អែក | ចំនួនសមស្រប ១០០.០០០ ប្រែប្រួលពី ៦០.០០០-២០០.០០០+ | ក្នុងតំបន់មានប្រជាជនរស់នៅច្រើន÷ ធ្វើដំណើរ ២ម៉ោង ដោយរថយន្តឬកាណូត។ ក្នុងតំបន់ជនបទៈ ធ្វើដំណើរមិនលើសពី ៣ម៉ោង ដោយរថយន្តឬកាណូត |
| ប៉ុស្តិ៍សុខភាព | ប្រែប្រួលពី ២០០០-៣០០០ | ចម្ងាយពីឃុំ/ភូមិទៅមណ្ឌលសុខភាពជិតបំផុត លើសពី ១៥គ.ម ហើយមានរបាំងភូមិសាស្ត្រ (ទន្លេ ភ្នំ ឬស្ថានភាពផ្លូវពិបាក) |

ទន្ទឹមនឹងនេះ ក្នុងការបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ រាជរដ្ឋាភិបាលកម្ពុជាក៏បានដាក់ចេញនូវគោលការណ៍រួមនៃការបង្កើត និងដាក់ឱ្យដំណើរការទីភ្នាក់ងារប្រតិបត្តិការពិសេស (SOA) នៅឆ្នាំ២០០៨ ក្នុងគោលបំណង ដើម្បីលើកកម្ពស់ការគ្រប់គ្រងផ្អែកលើលទ្ធផលការងារ ដោយភាពប្រុងប្រយ័ត្ន មានប្រសិទ្ធភាព និងមានតម្លាភាព និង

អភិវឌ្ឍសមត្ថភាពក្នុងការផ្តល់សេវាសាធារណៈ។ គោលការណ៍នេះ ត្រូវបានដាក់ឱ្យអនុវត្ត ចំពោះក្រសួងសុខាភិបាលនៅឆ្នាំ២០០៩[៦] លើស្រុកប្រតិបត្តិចំនួន ២២ និងមន្ទីរពេទ្យបង្អែក ខេត្តចំនួន ៨ ដែលមន្ទីរពេទ្យខេត្តទាំង ៨ នោះរួមមាន÷ មន្ទីរពេទ្យខេត្តកោះកុង ខេត្ត រតនគិរី ខេត្តមណ្ឌលគិរី ខេត្តព្រះវិហារ ខេត្តកំពង់ចាម ខេត្តឧត្តរមានជ័យ ខេត្តសៀមរាប និងខេត្តតាកែវ។ ជាលទ្ធផល ការអនុវត្តយន្តការនេះ ទទួលបានជោគជ័យ និងបានពង្រីក វិសាលភាពនៃការអនុវត្ត ជាបន្តបន្ទាប់ ហើយការសម្រេចជោគជ័យនេះ ក៏ជាផ្នែកមួយនៃ ការសម្រេចបាននូវកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈផងដែរ។

## ២.៣. ស្ថានភាពទូទៅរបស់មន្ទីរពេទ្យខេត្តកោះកុង

### ២.៣.១. ភូមិសាស្ត្រមន្ទីរពេទ្យខេត្តកោះកុង

ខេត្តកោះកុង មានទីតាំងស្ថិតនៅទិសនិរតី នៃព្រះរាជាណាចក្រកម្ពុជា មានចំងាយ ២៩១ គីឡូម៉ែត្រពីរាជធានីភ្នំពេញ មានព្រំប្រទល់ខាងកើតជាប់នឹងខេត្តព្រះសីហនុ ខាង លិចជាប់នឹងព្រះរាជាណាចក្រថៃ ខាងជើងជាប់នឹងខេត្តពោធិ៍សាត់និងខេត្តកំពង់ស្ពឺ និង ខាងត្បូងជាប់នឹងក្រុងព្រះសីហនុនិងឈូងសមុទ្រថៃ។ ខេត្តកោះកុងមានផ្ទៃដីសរុបចំនួន ១០.០៤៥,៥៨ គីឡូម៉ែត្រក្រឡា មានវិសាលភាពគ្របដណ្តប់លើក្រុង និងស្រុកចំនួន ៧ ដែល ក្នុងនោះមានក្រុងចំនួន ១ និងស្រុកចំនួន ៦ មានឃុំសង្កាត់សរុបចំនួន ២៩ និងត្រូវបាន បែងចែកជាភូមិចំនួន ១១២ ភូមិ ដែលមានប្រជាជនសរុបចំនួន ១៣៧.៣៩០នាក់[៧]។ ផ្ទៃដីនៃខេត្តភាគច្រើនគ្របដណ្តប់ដោយខ្ពង់រាប ព្រៃភ្នំ កោះ និងឆ្នេរសមុទ្រ។ ប្រជាពលរដ្ឋ រស់នៅក្នុងខេត្តនេះ ភាគច្រើនប្រកបរបរនេសាទសមុទ្រ និងធ្វើចំការ។

[៦] រាជរដ្ឋាភិបាលកម្ពុជា, អនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ ស្តីពីការបង្កើត និង ដាក់ឱ្យដំណើរការទីភ្នាក់ងារប្រតិបត្តិការពិសេសនៃក្រសួងសុខាភិបាល

[៧] ទិន្នន័យផ្ទៃដី និងទិន្នន័យប្រជាជន ស្រង់ចេញពីរបាយការណ៍ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខេត្តកោះកុង ប្រចាំឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០

មន្ទីរពេទ្យខេត្តកោះកុង មានផ្ទៃដីសរុបចំនួន ៣៣.០០០ ម៉ែតក្រឡា[៨] និងគ្របដណ្ដប់លើស្រុកប្រតិបត្តិចំនួន ២÷ ទី១.ស្រុកប្រតិបត្តិស្មាច់មានជ័យ ដែលស្រុកប្រតិបត្តិនេះគ្របដណ្ដប់លើមណ្ឌលសុខភាពចំនួន ៧ និងប៉ុស្តិ៍សុខភាពចំនួន ៧។ ទី២.ស្រុកប្រតិបត្តិស្រែអំបិល ដែលស្រុកប្រតិបត្តិនេះគ្របដណ្ដប់លើមណ្ឌលសុខភាពចំនួន ៦ និងប៉ុស្តិ៍សុខភាពចំនួន ២។

### ២.៣.២. ប្រវត្តិរបស់មន្ទីរពេទ្យខេត្តកោះកុង

មន្ទីរពេទ្យខេត្តកោះកុង ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៦៣ ក្នុងសម័យសង្គមរាស្ត្រនិយម និងបានបន្តដំណើរការរហូតដល់ឆ្នាំ១៩៧៥។ ចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ មន្ទីរពេទ្យនេះ ត្រូវបានទុកចោលដោយសារសង្គ្រាម។

នៅឆ្នាំ១៩៧៩ ក្រោមគំនិតផ្ដួចផ្ដើមរបស់អាជ្ញាធរខេត្តនាពេលនោះ បានចាប់ផ្ដើមកសាង និងដាក់ឱ្យដំណើរការមន្ទីរពេទ្យខេត្តកោះកុងឡើងវិញ ដោយមានអគារឈើ និងសាងសង់អគារថ្មបន្ថែម។

នៅក្នុងឆ្នាំ១៩៩១ អគារផ្នែកវះកាត់ធំត្រូវបានជួយជួសជុលឡើងវិញ ក្រោមជំនួយហិរញ្ញវត្ថុពីកាកបាទក្រហមនៃព្រះរាជាណាចក្រថៃ។

រហូតមកដល់ឆ្នាំ២០០០ អគារមួយចំនួន ដូចជាអគារផ្នែកវះកាត់ ផ្នែកជំងឺឆ្លង ផ្នែកជំងឺទូទៅត្រូវបានជួសជុលឡើងវិញ ក្រោមជំនួយហិរញ្ញវត្ថុពីអង្គការស្វីស របស់ប្រទេសអ៊ីតាលី។

នៅឆ្នាំ២០០៥ អគារអន្តេវាសិកដ្ឋាន ១ខ្នង សម្រាប់មន្ត្រីសុខាភិបាលមន្ទីរពេទ្យខេត្តកោះកុង ត្រូវបានឧបត្ថម្ភសាងសង់ ដោយ **សម្ដេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី** និងលោកជំទាវ និងឯកឧត្ដម **យុទ្ធ ភូថង** អតីតអភិបាល នៃគណៈអភិបាលខេត្តកោះកុង និងលោកជំទាវ។

[៨] ផ្ទៃដីនេះ រួមបញ្ចូលមន្ទីរពេទ្យខេត្តកោះកុង ការិយាល័យស្រុកប្រតិបត្តិស្មាច់មានជ័យ មណ្ឌលសុខភាពស្មាច់មានជ័យ និងមន្ទីរសុខាភិបាលខេត្តកោះកុង យោងតាមកំណត់ហេតុអង្កេតដីឆ្នាំ១៩៩៧

ដោយសារកត្តាភាពទ្រុឌទ្រោមរបស់អគារចាស់នៅឆ្នាំ២០០៨ ក្នុងពេលនៃការអនុវត្តគម្រោង HSSP-2 (Health Sector Support Project-2) អគារមួយចំនួន ត្រូវបានជួសជុលឡើងវិញ និងសាងសង់បន្ថែម ដោយក្រសួងសុខាភិបាល ដោយប្រើប្រាស់កម្ចីហិរញ្ញប្បទានពីធនាគារអភិវឌ្ឍអាស៊ី ADB។

ដោយសារខេត្តកោះកុងជាខេត្តស្ថិតនៅភូមិភាគនិរតីនៃប្រទេសកម្ពុជាយើងមានចម្ងាយ ២៩១ គីឡូម៉ែត្រពីរាជធានីភ្នំពេញ ហើយមានទីតាំងភូមិសាស្ត្រស្មុគស្មាញជាតំបន់កោះ ព្រៃភ្នំ ហេតុនេះមិនសូវមានអង្គការជាតិ ឬអន្តរជាតិ ឬដៃគូ ចាប់អារម្មណ៍ក្នុងការធ្វើកិច្ចសហប្រតិបត្តិការ។ អ្វីដែលជោគជ័យ គឺមន្ទីរពេទ្យបានខិតខំស្វះស្វែងរកជំនួយដោយខ្លួនឯង ក្រោមការអភិវឌ្ឍដោយខ្លួនឯង និងមានការជួយជ្រោមជ្រែងជាច្រើនពីមន្ទីរសុខាភិបាលខេត្ត អាជ្ញាធរខេត្ត និងក្រសួងសុខាភិបាល។

**ប្រវត្តិនៃការដឹកនាំមន្ទីរពេទ្យ និងសមិទ្ធផលសំខាន់ៗដែលសម្រេចបាន÷**

នៅ១៩៧៩ ដល់ឆ្នាំ១៩៨០ លោក **ស៊ីយ ចាំកេសន** ត្រូវបានតែងតាំងជាប្រធានមន្ទីរពេទ្យខេត្តកោះកុងដំបូងគេបង្អស់ក្រោយប្រទេសត្រូវបានរំដោះចេញពីរបបប្រល័យពូជសាសន៍។ នៅក្នុងអំឡុងពេលនៃការគ្រប់គ្រង លោកបានប្រមូលធនធានមនុស្សមួយចំនួនតូច និងបានរៀបចំកែលម្អហេដ្ឋារចនាសម្ព័ន្ធ ដោយបានជួសជុលអគារចាស់ៗដែលមានស្រាប់ ដើម្បីបើកឱ្យដំណើរការមន្ទីរពេទ្យខេត្តកោះកុងឡើងវិញ។

បន្ទាប់មក ចាប់ពីឆ្នាំ១៩៨០ ដល់ឆ្នាំ១៩៨៥ លោកស្រី **ហ៊ាន់ថៃ សាំងថង** ត្រូវបានតែងតាំងជាប្រធានមន្ទីរពេទ្យ ក្នុងរយៈពេល ៥ឆ្នាំ នៃការគ្រប់គ្រងមន្ទីរពេទ្យខេត្តកោះកុង លោកស្រីបានកសាងនូវអគារចំនួនពីរខ្នង ធ្វើអំពីឈើ ប្រក់ហ្វីប្រូស៊ីម៉ង់ មានចំនួន ៨បន្ទប់។

បន្ទាប់មកទៀត ពីឆ្នាំ១៩៨៥ ដល់ឆ្នាំ១៩៩១ លោក **ពូ ប៉ាកើ** ត្រូវបានតែងតាំងជាប្រធានមន្ទីរពេទ្យ នៅក្នុងអំឡុងពេលនៃការគ្រប់គ្រង លោកបានកសាងនូវអគារចំនួនពីរខ្នងធ្វើអំពីឈើ ប្រក់ហ្វីប្រូស៊ីម៉ង់ មានចំនួន ៨បន្ទប់ និងបានបើកវគ្គបណ្តុះបណ្តាលបុគ្គលិកពេទ្យបឋម បានចំនួនមួយលើក ដល់បុគ្គលិកចំនួន ២៧នាក់ នៅក្នុងមន្ទីរពេទ្យក្នុងឆ្នាំ១៩៨៧។

នៅឆ្នាំ១៩៩១ ដល់២០០០ លោកវេជ្ជបណ្ឌិត **ពិន សារ៉ាត** ត្រូវបានតែងតាំងជាប្រធានមន្ទីរពេទ្យ ក្នុងរយៈពេល ៩ឆ្នាំ នៃការគ្រប់គ្រងរបស់លោក បានបន្តការថែទាំហេដ្ឋានរចនាសម្ព័ន្ធ និងបណ្តុះបណ្តាលធនធានមនុស្ស ក្នុងនោះមានការជួសជុលឡើងវិញនូវអគារផ្នែកជំងឺទូទៅចំនួន ២ខ្នង អគារជំងឺឆ្លង ១ខ្នង ផ្នែកវះកាត់ធំ ១ខ្នង និងបន្តការបណ្តុះបណ្តាលធនធានមនុស្ស។

នៅឆ្នាំ២០០០ លោកស្រីវេជ្ជបណ្ឌិត **ម៉ាត់លី ហៃរុណុប** ត្រូវបានតែងតាំងជាប្រធានមន្ទីរពេទ្យ លោកស្រីវេជ្ជបណ្ឌិត បានបន្តគ្រប់គ្រងមន្ទីរពេទ្យរហូតដល់ឆ្នាំ២០១២ ដែលមានរយៈពេល ១២ឆ្នាំ។ ក្រោមការដឹកនាំរបស់លោកស្រីប្រធានមន្ទីរពេទ្យ មន្ទីរពេទ្យត្រូវបានបន្តការបណ្តុះបណ្តាលធនធានមនុស្ស និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធ ដូចជាការកសាងឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធថ្មី និងថែរក្សាអគារដែលមានស្រាប់ រហូតមន្ទីរពេទ្យមានអគារចំនួន ២០ មកដល់សព្វថ្ងៃ។ ចាប់ឆ្នាំ២០១២-២០១៥ លោកវេជ្ជបណ្ឌិត **សួន សាមិត្ត** ត្រូវបានតែងតាំងជាប្រធានមន្ទីរពេទ្យជំនួស លោកស្រីវេជ្ជបណ្ឌិត **ម៉ាត់ ហៃរុណុប**។ ក្នុងរយៈពេលនៃការដឹកនាំរបស់លោក បានបន្តការបណ្តុះបណ្តាលធនធានមនុស្ស ការកៀរគរសប្បុរសជន ដៃគូអភិវឌ្ឍ និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធមន្ទីរពេទ្យ។

ចាប់ពីឆ្នាំ២០១៥ រហូតមកដល់ពេលបច្ចុប្បន្ន លោកវេជ្ជបណ្ឌិត **ហៃ ឡៃសុន** ត្រូវបានតែងតាំងជាប្រធានមន្ទីរពេទ្យខេត្តកោះកុង ក្រោមការដឹកនាំរបស់លោក មន្ទីរពេទ្យទទួលបានការរីកចំរើន និងសមិទ្ធផលជាច្រើន ដូចជា÷

១. ការកែលម្អសោភ័ណភាព ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងមន្ទីរពេទ្យ ដូចជាសួនច្បារពណ៌បៃតងគ្រប់បណ្តាផ្នែក កន្លែងហាត់កីឡា របងជុំវិញមន្ទីរពេទ្យ ខ្លោងទ្វារមន្ទីរពេទ្យថ្មី និងចំណតម៉ូតូ និងចំណតយានយន្តសម្រាប់អតិថិជន និងបុគ្គលិកមន្ទីរពេទ្យ ចំណតសម្រាប់រថយន្តគិលានសង្គ្រោះ និងអាហារដ្ឋាន ជាពិសេសគ្រប់ហេដ្ឋារចនាសម្ព័ន្ធតាមបណ្តាផ្នែកទាំងអស់ត្រូវបានជួសជុល កែលម្អឱ្យមានសោភ័ណភាព និងទំនើបកម្ម និងពង្រឹងផ្នែកអនាម័យដែលធ្វើឱ្យមន្ទីរពេទ្យស្អាតជានិច្ច អាចជួយទប់ស្កាត់ការចម្លងរោគក្នុងមន្ទីរពេទ្យ

បានយ៉ាងល្អ។

២. ការរៀបចំប្រព័ន្ធរំហូរការងារច្បាស់លាស់ ដោយមានហេដ្ឋារចនាសម្ព័ន្ធរដ្ឋបាលច្បាស់លាស់ដូចជាប្រព័ន្ធបម្រើផ្នែកជួរមុខ ប្រព័ន្ធបម្រើផ្នែកជួរក្រោយ ប្រព័ន្ធគ្រប់គ្រងតាមដានទិន្នន័យអ្នកជំងឺ (PMRS) ផ្នែកជំងឺផ្លូវចិត្ត ផ្នែកសង្គ្រោះបន្ទាន់កម្រិតធ្ងន់ (ICU) ផ្នែករម្ងាប់មេរោគកណ្ដាលរួម (Central Sterilazation and Supply Department) ផ្នែកជំងឺឆ្លង បន្ទប់អប់រំសុខភាពសាធារណៈ (Public Health Education) បណ្ណាល័យរួម បណ្ណាល័យសម្រាប់កូនក្មេងជាដើម។

៣. ការពង្រឹង និងពង្រីកជាបញ្ហាអាទិភាពលើការបណ្ដុះបណ្ដាលធនធានមនុស្សក្នុងប្រទេស និងក្រៅប្រទេស និងការសហការកៀរគរសប្បុរសជន ដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិ។

៤. ការពង្រឹងគុណភាព ប្រសិទ្ធភាពនៃសេវា និងការពង្រីកផ្នែកផ្ដល់សេវាឯកទេសបន្ថែមជាច្រើនទៀត ដូចជាផ្នែកជំងឺទឹកនោមផ្អែម ផ្នែកជំងឺផ្លូវចិត្ត ផ្នែកថែទាំ និងព្យាបាលជំងឺភ្នែក ផ្នែកសង្គ្រោះបន្ទាន់កម្រិតធ្ងន់ ដែលសរុបមានចំនួន ២០ផ្នែក។

៥. ការរៀបចំបង្កើតចក្ខុវិស័យ បេសកកម្ម និងទិសដៅច្បាស់លាស់សម្រាប់មន្ទីរពេទ្យក្នុងការគ្រប់គ្រងប្រសិទ្ធភាពការងារ ដូចជាការធ្វើប្រតិភូកម្មការគ្រប់គ្រងដល់បណ្ដាផ្នែក ការរៀបចំបេសកកម្មស្ដីពី អប់រំសុខភាពសាធារណៈទាំងនៅក្នុងមន្ទីរពេទ្យ ទាំងនៅក្នុងសហគមន៍ជាដើម។

៦. ក្នុងឆ្នាំ២០១៩ មន្ទីរពេទ្យបានទទួលកិត្តិយសជ័យលាភីលេខ១ ជាអង្គភាពផ្ដល់សេវាសាធារណៈគំរូលើវិស័យសុខាភិបាល សំណុំសកម្មភាពបង្គ្រប់កម្រិត២ (CPA2)។

### ២.៣.៣. ចក្ខុវិស័យ បេសកកម្ម និងគោលដៅរបស់មន្ទីរពេទ្យ

ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងដឹកនាំមន្ទីរពេទ្យ និងពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការផ្ដល់សេវាសុខាភិបាលជូនប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរឡើង មន្ទីរពេទ្យបានដាក់ចេញនូវចក្ខុវិស័យ បេសកកម្ម និងគោលដៅដែលជាត្រីវិស័យសម្រាប់ថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិករបស់មន្ទីរពេទ្យអនុវត្ត ដែលមានដូចខាងក្រោម÷

### ២.៣.៣.១. ចក្ខុវិស័យ

មន្ទីរពេទ្យមានចក្ខុវិស័យបម្រើសេវាសុខាភិបាលជូនប្រជាពលរដ្ឋទូទៅប្រកបដោយប្រសិទ្ធភាព គុណភាពខ្ពស់ និងតម្លាភាព ដែលធ្វើយ៉ាងណាឱ្យពួកគាត់រស់នៅប្រកបដោយភាពសុខដុមរមនាទាំងផ្លូវកាយ និងផ្លូវចិត្ត។

### ២.៣.៣.២. បេសកកម្ម

ដើម្បីសម្រេចបាននូវចក្ខុវិស័យខាងលើ មន្ទីរពេទ្យបានកំណត់នូវបេសកកម្មចំនួន ៧ចំណុច ដូចខាងក្រោម÷

១. ការគ្រប់គ្រងធនធានមនុស្ស

២. ការគ្រប់គ្រងហិរញ្ញវត្ថុ

៣. ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថាន អនាម័យស្អាត ពណ៌បៃតង

៤. ជាគ្រឹះស្ថានបណ្តុះបណ្តាល

៥. ជាគ្រឹះស្ថានអប់រំសុខភាពសាធារណៈ

៦. ការផ្សារភ្ជាប់ជាមួយសហគមន៍ (ភូមិ ឃុំ ស្រុក)

៧. កិច្ចសហប្រតិបត្តិការល្អ និងការកៀរគរធនធានដៃគូអភិវឌ្ឍ។

### ២.៣.៣.៣. គោលដៅ

ដើម្បីសម្រេចបាននូវចក្ខុវិស័យនិងបេសកកម្មខាងលើ មន្ទីរពេទ្យបានដាក់ចេញនូវគោលដៅចំនួន ៧ចំណុច ដូចខាងក្រោម÷

១. បង្កើនកេរ្តិ៍ឈ្មោះអង្គភាព

២. ធ្វើឱ្យអង្គភាពមានភាពល្បីល្បាញ

៣. បង្កើនការទទួលស្គាល់ និងទំនុកចិត្ត

៤. លើកទឹកចិត្តមន្ត្រី និងបុគ្គលិក

៥. បង្កើនប្រសិទ្ធភាពការងារ

៦. អភិវឌ្ឍន៍អង្គភាព

៧. បង្កើនល្បឿនការងារ និងសមិទ្ធផលការងារ។

## ២.៣.៤. ទស្សនៈ: វិស័យក្នុងការដឹកនាំ និងគ្រប់គ្រងអង្គភាព

### ២.៣.៤.១. មានចក្ខុវិស័យ បេសកកម្ម និងទិសដៅច្បាស់លាស់

មន្ទីរពេទ្យបានរៀបចំចក្ខុវិស័យ បេសកកម្ម និងទិសដៅរបស់ខ្លួនយ៉ាងច្បាស់លាស់ ដូចខាងលើ និងបានអនុវត្តជាប្រចាំ ប្រកបដោយប្រសិទ្ធភាព ការទទួលខុសត្រូវខ្ពស់ និង មានការត្រួតពិនិត្យត្រឹមត្រូវ។

### ២.៣.៤.២. យន្តការជំរុញការទទួលខុសត្រូវ និងការចូលរួមរបស់មន្ត្រី

មន្ត្រីមន្ទីរពេទ្យ មានឆន្ទៈក្នុងការអនុវត្តការងារ ភារកិច្ច តាមជំនាញរបស់ខ្លួនក្នុង ការបម្រើសេវាសុខភាព ជូនប្រជាពលរដ្ឋប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ និងមានភាព ទន់ភ្លន់ រួសរាយរាក់ទាក់ និងរហ័សរហួន។ មន្ត្រីទាំងអស់ មានឆន្ទៈមោះមុត និងមានស្មារតី ទទួលខុសត្រូវខ្ពស់ ក្នុងការបំពេញការងារជាក្រុម ដើម្បីសម្រេចគោលដៅរបស់ខ្លួន ដោយ ផ្អែកលើទស្សនៈរបស់មន្ទីរពេទ្យ “**រួមគិត រួមធ្វើ រួមទទួលខុសត្រូវ រួមដោះស្រាយ និង រួមអភិវឌ្ឍន៍**”។

ថ្នាក់ដឹកនាំមន្ទីរពេទ្យ បានចូលរួមសហការយ៉ាងជិតស្និទ្ធជាមួយមន្ត្រីគ្រប់លំដាប់ថ្នាក់ និងរកវិធីជំរុញបង្កើត បង្កើន និងលើកកម្ពស់ស្មារតីទទួលខុសត្រូវដល់មន្ត្រី ក្នុងគោលបំណង ឱ្យមន្ត្រីទាំងអស់មានការទទួលខុសត្រូវក្នុងការបំពេញការងារ ភារកិច្ចរបស់ខ្លួនឱ្យបាន ត្រឹមត្រូវ មានសុវត្ថិភាព និងប្រសិទ្ធភាពខ្ពស់ ដែលទាំងនេះជាបញ្ហាអាទិភាពក្នុងការឈាន ឆ្ពោះទៅទទួលបានការពេញចិត្ត និងភាពជោគជ័យក្នុងការដឹកនាំ និងគ្រប់គ្រងការងារ របស់ខ្លួនផង។

### ២.៣.៤.៣. ការធ្វើប្រតិភូកម្មដឹកនាំ គ្រប់គ្រងដល់គ្រប់បណ្តាផ្នែកទាំងអស់

មន្ទីរពេទ្យបានធ្វើប្រតិភូកម្មការដឹកនាំ គ្រប់គ្រងដល់គ្រប់បណ្តាផ្នែកនីមួយៗក្នុងការ ដឹកនាំ គ្រប់គ្រងផ្នែករបស់ខ្លួនឱ្យមានប្រសិទ្ធភាពទៅតាមចក្ខុវិស័យ បេសកកម្ម ផែនការ និងទិសដៅរបស់មន្ទីរពេទ្យ ក្នុងនោះផ្នែកនីមួយៗត្រូវរៀបចំ និងអនុវត្តផែនការសកម្មភាព

ឱ្យបានត្រឹមត្រូវ ដូចជាផែនការសកម្មភាពប្រចាំខែ ផែនការសកម្មភាពប្រចាំត្រីមាស ផែនការសកម្មភាពប្រចាំឆ្នាំ ក្នុងគោលបំណងពង្រឹងប្រព័ន្ធដឹកនាំ គ្រប់គ្រងតាមបណ្តាផ្នែកនីមួយៗឱ្យមានគុណភាព ប្រសិទ្ធភាពខ្ពស់ ដើម្បីឈានឆ្ពោះទៅសម្រេចគោលដៅរបស់មន្ទីរពេទ្យ។

### ២.៣.៤.៤. ការទំនាក់ទំនង កិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរ

មន្ទីរពេទ្យ តែងតែមានទំនាក់ទំនងល្អជាមួយថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ ជាពិសេសជាមួយមន្ទីរសុខាភិបាលខេត្ត រដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ភូមិ និងសហគមន៍ ក្នុងការអនុវត្តផែនការសកម្មភាពរបស់ខ្លួនឱ្យបានជោគជ័យ។

មន្ទីរពេទ្យតែងតែចាត់ទុកអាជ្ញាធរគ្រប់លំដាប់ថ្នាក់ មន្ទីរអង្គភាពនានាជុំវិញខេត្ត ជាដៃគូមិនអាចខ្វះបានក្នុងការចូលរួមសហការ ជំរុញអភិវឌ្ឍវិស័យសុខាភិបាលឱ្យមានការរីកចម្រើន ដូចជាការចូលរួមផ្សព្វផ្សាយសេវាសុខភាព ការផ្តល់ព័ត៌មាន ការសម្របសម្រួលប្រព័ន្ធបញ្ជូនអ្នកជំងឺ ជាដើម។

### ២.៣.៤.៥. ការកៀរគរសប្បុរសជន ដៃគូអភិវឌ្ឍ

មន្ទីរពេទ្យ តែងតែបានស្វែងរក កៀរគរសប្បុរសជន ដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិនានាក្នុងការអភិវឌ្ឍអង្គភាពរបស់ខ្លួនទាំងហេដ្ឋារចនាសម្ព័ន្ធ ទាំងការបណ្តុះបណ្តាលធនធានមនុស្ស និងសម្ភារបរិក្ខារដើម្បីបង្កើន ពង្រីកគុណភាពការថែទាំ ការព្យាបាលអ្នកជំងឺឱ្យមានប្រសិទ្ធភាព និងគុណភាពខ្ពស់។

ជាលទ្ធផល មន្ទីរពេទ្យទទួលបានការគាំទ្រពីសប្បុរសជន ដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិនានាក្នុងការអភិវឌ្ឍអង្គភាពរបស់ខ្លួនឱ្យមានការរីកចម្រើនដូចសព្វថ្ងៃនេះ មានកិច្ចសហប្រតិបត្តិការជាមួយបេសកកម្មស្ម័គចិត្តប្រចាំឆ្នាំរបស់ក្រុមគ្រូពេទ្យប្រទេសបារាំង (Humanitarian Organization) ចំនួន ២ក្រុម ជារៀងរាល់ឆ្នាំ ទីភ្នាក់ងារប្រតិបត្តិការអន្តរជាតិប្រទេសថៃឡង់ (TICA) មន្ទីរសុខាភិបាលខេត្តត្រាត មន្ទីរពេទ្យស្រុកខ្លុងយ៉ៃ មន្ទីរពេទ្យខេត្តត្រាតប្រទេសថៃ និងសប្បុរសជនក្នុងស្រុកជាច្រើនទៀត ជាដើម។

## ២.៣.៥. រចនាសម្ព័ន្ធរបស់មន្ទីរពេទ្យ

នាពេលបច្ចុប្បន្ន មន្ទីរពេទ្យខេត្តកោះកុង ដឹកនាំ និងគ្រប់គ្រងដោយប្រធាន ១រូប និងអនុប្រធាន ១រូប និងបានបែងចែកជា ៥ផ្នែក ដែលរួមមាន÷ ផ្នែកគណនេយ្យ ផ្នែកឱសថស្ថាន ផ្នែកពិនិត្យអមគ្លីនិក ផ្នែកពិគ្រោះជំងឺ និងផ្នែកសម្រាកពេទ្យ។ ផ្នែកទាំង ៥នេះត្រូវបានបែងចែកជាផ្នែកតូចៗសរុបចំនួន ១៩ផ្នែក ដូចមានក្នុងអង្គការលេខខាងក្រោម។ បន្ថែមលើរចនាសម្ព័ន្ធដែលបានលើកឡើងនេះ មន្ទីរពេទ្យខេត្តកោះកុង បានបង្កើតគណៈកម្មការគ្រប់គ្រងមន្ទីរពេទ្យ និងគណៈកម្មការជំនាញមួយចំនួនទៀត ដើម្បីបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង ដឹកនាំមន្ទីរពេទ្យ និងបង្កើនគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសុខាភិបាលនៅក្នុងមន្ទីរពេទ្យខេត្តកោះកុង។

រូបភាពទី២÷ រចនាសម្ព័ន្ធរបស់មន្ទីរពេទ្យខេត្តកោះកុង



## ២.៣.៦. ស្ថានភាពមន្ត្រី និងបុគ្គលិករបស់មន្ទីរពេទ្យ

គិតមកដល់ខែឧសភា ឆ្នាំ២០១៩ មន្ទីរពេទ្យខេត្តកោះកុងមានមន្ត្រី និងបុគ្គលិកសរុបចំនួន ៩២នាក់ ក្នុងនោះស្រីមានចំនួន ៣៨នាក់។ ក្នុងចំណោមមន្ត្រី និងបុគ្គលិកទាំង ៩២ នាក់នោះ មន្ត្រីក្របខ័ណ្ឌរដ្ឋ មានចំនួន ៦៩នាក់ ស្រីចំនួន ៤៣នាក់។ មន្ត្រីកិច្ចសន្យារបស់រដ្ឋមានចំនួន ៨នាក់ ស្រីចំនួន ៤នាក់ និងមន្ត្រីកិច្ចសន្យារបស់មន្ទីរពេទ្យមានចំនួន ១៥នាក់ ស្រីចំនួន ១១នាក់[៩]។

ក្រាហ្វិកទី១÷ ចំនួនមន្ត្រី និងបុគ្គលិកបម្រើការងារនៅមន្ទីរពេទ្យ




តារាងខាងក្រោមបង្ហាញពីចំនួនមន្ត្រី និងបុគ្គលិកបម្រើការងារនៅតាមផ្នែកនីមួយៗ និងចំនួនមន្ត្រីជំនាញបច្ចេកទេស ដែលបម្រើការងារនៅមន្ទីរពេទ្យខេត្តកោះកុង ដូចខាងក្រោម÷

[៩] ទិន្នន័យឆ្នាំ២០១៩ មន្ទីរពេទ្យខេត្តកោះកុង

## ២.៣.៥.១. តារាងស្តីពីចំនួនមន្ត្រី និងបុគ្គលិកតាមផ្នែក

តារាងទី៤÷ តារាងចំនួនមន្ត្រី និងបុគ្គលិកតាមផ្នែក

| លរ | ផ្នែក | ចំនួន | | សរុប |
|---|---|---|---|---|
| | | ប្រុស | ស្រី | |
| ១ | ថ្នាក់ដឹកនាំ | ២ | ០ | ២ |
| ២ | រដ្ឋបាលនិងគណនេយ្យ | ៤ | ១ | ៥ |
| ៣ | បែងចែកជំងឺ (Triage) | ០ | ៣ | ៣ |
| ៤ | សង្គ្រោះបន្ទាន់ | ៣ | ៣ | ៦ |
| ៥ | ជំងឺទូទៅ | ៤ | ១ | ៥ |
| ៦ | ជំងឺកុមារ | ២ | ៣ | ៥ |
| ៧ | ជំងឺវះកាត់ | ៥ | ០ | ៥ |
| ៨ | ប្រពោធនកម្ម | ៣ | ០ | ៣ |
| ៩ | សម្ភពនិងរោគស្ត្រី | ១ | ៧ | ៨ |
| ១០ | ជំងឺរបេង | ៣ | ០ | ៣ |
| ១១ | ពិគ្រោះជំងឺក្រៅ | ២ | ០ | ២ |
| ១២ | ជំងឺទឹកនោមផ្អែម | ២ | ០ | ២ |
| ១៣ | មន្ទីរពិសោធន៍ | ៤ | ០ | ៤ |
| ១៤ | រូបសាស្ត្រ | ៣ | ០ | ៣ |
| ១៥ | ឱសថស្ថាន | ១ | ២ | ៣ |
| ១៦ | គ្លីនិកសុខភាពគ្រួសារ | ១ | ២ | ៣ |
| ១៧ | ផ្នែក VCCT | ១ | ១ | ២ |
| ១៨ | មណ្ឌលផ្តល់ឈាម | ១ | ០ | ១ |
| ១៩ | សុខភាពមាត់ធ្មេញ | ៣ | ០ | ៣ |
| ២០ | ថែទាំឧបករណ៍បរិក្ខារពេទ្យ | ១ | ០ | ១ |
| | សរុបរួម | ៤៦ នាក់ | ២៣ នាក់ | ៦៩ នាក់ |

ជំពូកទី២

## ២.៣.៥.២. តារាងស្ដីពីចំនួនមន្ត្រីតាមជំនាញបច្ចេកទេស

តារាងទី៥÷ តារាងចំនួនមន្ត្រី

| លរ | ជំនាញបច្ចេកទេស | ចំនួន | | សរុប |
|---|---|---|---|---|
| | | ប្រុស | ស្រី | |
| ១ | វេជ្ជបណ្ឌិតឯកទេស | ១ | ១ | ២ |
| ២ | វេជ្ជបណ្ឌិតជំនាញ | ២ | ០ | ២ |
| ៣ | វេជ្ជបណ្ឌិត | ១០ | ២ | ១២ |
| ៣ | ឱសថការីឧត្តម | ១ | ២ | ៣ |
| ៤ | ទន្តបណ្ឌិត | ១ | ០ | ១ |
| ៥ | បរិញ្ញាបត្រគិលានុបដ្ឋាក | ២ | ២ | ៤ |
| ៦ | បរិញ្ញាបត្រឆ្មប | ០ | ១ | ១ |
| ៧ | ទន្តគិលានុបដ្ឋាក | ៣ | ០ | ៣ |
| ៨ | ឆ្មបមធ្យម | ០ | ១០ | ១០ |
| ៩ | គិលានុបដ្ឋាកមធ្យម | ១៤ | ៣ | ១៧ |
| ១០ | ពិសោធនិមធ្យម | ៤ | ០ | ៤ |
| ១១ | វិទ្យុសាស្ត្រ | ១ | ០ | ១ |
| ១២ | ព្យាបាលដោយចលនា | ១ | ០ | ១ |
| ១៣ | ឆ្មបបឋម | ០ | ១ | ១ |
| ១៤ | គិលានុបដ្ឋាកបឋម | ៤ | ០ | ៤ |
| ១៥ | គណនេយ្យឧត្តម | ១ | ០ | ១ |
| ១៦ | ព័ត៌មានវិទ្យា | ១ | ០ | ១ |
| ១៧ | ថែទាំឧបករណ៍បរិក្ខារពេទ្យ | ១ | ០ | ១ |
| ១៨ | ជំនាញផ្សេងៗ | ០ | ១ | ១ |

## ២.៤. សមិទ្ធផលសុខាភិបាលរបស់មន្ទីរពេទ្យខេត្តកោះកុង

### ២.៤.១. តារាងរួមស្ដីពីលទ្ធផលនៃការផ្ដល់សេវាសុខាភិបាលរបស់មន្ទីរពេទ្យខេត្តកោះកុង

តារាងខាងក្រោមបង្ហាញអំពីលទ្ធផល នៃការអនុវត្តការផ្ដល់សេវារបស់មន្ទីរពេទ្យខេត្តកោះកុងក្នុងរយៈពេល ៥ឆ្នាំ គឺគិតចាប់ពីឆ្នាំ២០១៥ រហូតដល់ឆ្នាំ២០១៩។

តារាងទី៦÷ តារាងរួមស្ដីពីលទ្ធផលនៃការផ្ដល់សេវាសុខាភិបាល
របស់មន្ទីរពេទ្យខេត្តកោះកុង

| លរ | ប្រភេទសេវា | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ |
|---|---|---|---|---|---|---|
| ១ | ចំនួនករណីថ្មីពិគ្រោះជំងឺក្រៅ | ១៤.៤៤៨ | ១៥.៤៤១ | ១៧.៧២២ | ២២.៩៣១ | ២៣.៦៤០ |
| ២ | ចំនួនអ្នកជំងឺសម្រាកពេទ្យគិតទាំងរបេង | ៤.២៧១ | ៤.៥៨១ | ៥.០៣៦ | ៦.១៣៧ | ៨.៤៨១ |
| ៣ | អត្រាប្រើប្រាស់គ្រែ | ៧២,៥៩ | ៧៣,២២ | ៧៤,៤១ | ៨៤,៩០ | ១២៩,៤៧ |
| ៤ | អត្រាស្លាប់ | ១,៥៥ | ១,៣១ | ១,២១ | ០,៩៣ | ០,៧០ |
| ៥ | ចំនួនសម្រាលកូន | ៦៨៦ | ៧៨៧ | ៩០៣ | ១.០៤២ | ១.២៣០ |
| ៦ | ចំនួនសម្រាលកូនដោយវះកាត់ | ៣០ | ៤៦ | ៥៧ | ៣៥ | ៨១ |
| ៧ | ការថែទាំមាតា និងទារកក្រោយសម្រាលកូនលើកទី១ | ៦៨០ | ៧៨៥ | ៨៩៧ | ១.០០០ | ១.២២១ |
| ៨ | ចំនួនករណីថ្មីពិគ្រោះជំងឺក្រៅលើកុមារអាយុក្រោម ៥ឆ្នាំ | ៧៤២ | ១.២១៧ | ៩៩២ | ១.០១៤ | ១.៦៧១ |
| ៩ | ចំនួនកុមារក្រោម ៥ឆ្នាំសម្រាកពេទ្យ | ១៥៣ | ២១៤ | ២៣០ | ២៤១ | ២៤១ |

| លរ | ប្រភេទសេវា | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ |
|---|---|---|---|---|---|---|
| ១០ | ចំនួនករណីវះកាត់ធំសរុប | ៧០ | ១២០ | ១៥៤ | ១១៥ | ១៨៦ |

តាមលទ្ធផលនៅក្នុងតារាងខាងលើ បានបង្ហាញឱ្យឃើញថា គ្រប់ប្រភេទសេវាដែលផ្តល់ដោយមន្ទីរពេទ្យខេត្តកោះកុងមានការកើនឡើងគួរកត់សម្គាល់ពីមួយឆ្នាំទៅមួយឆ្នាំ ក្នុងរយៈពេល ៥ឆ្នាំ គឺចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៩។ ដោយឡែកអត្រាស្លាប់នៅមន្ទីរពេទ្យមានការថយចុះជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ គឺពី ១,៥៥ % នៅឆ្នាំ២០១៥ មកនៅត្រឹម ០,៧០% ឆ្នាំ២០១៩។

ក្រាហ្វិកខាងក្រោមនឹងបង្ហាញអំពី ក. ចំនួនករណីថ្មីពិនិត្យពិគ្រោះជំងឺក្រៅ ខ. អ្នកសម្រាកព្យាបាលនៅមន្ទីរពេទ្យ គ. អត្រាស្លាប់ និងឃ. ការសម្រាលកូនធម្មតា និងដោយវះកាត់។

### ២.៤.២. ចំនួនករណីថ្មីពិនិត្យពិគ្រោះជំងឺក្រៅ

ក្រាហ្វិកទី២÷ ចំនួនករណីថ្មីពិនិត្យពិគ្រោះជំងឺក្រៅ



ក្នុងក្រាហ្វិកខាងលើបានបង្ហាញថា លទ្ធផលនៃការផ្ដល់សេវាពិនិត្យ និងពិគ្រោះជំងឺក្រៅនៅមន្ទីរពេទ្យខេត្តកោះកុងមានការកើនឡើងជាប្រក្រតីពីក្នុងរង្វង់ ១ពាន់នាក់ ក្នុងមួយឆ្នាំចាប់ពីឆ្នាំ២០១៥ រហូតដល់ឆ្នាំ២០១៧។ ចំនួននៃការផ្ដល់សេវាផ្នែកនេះមានការកើនឡើងទ្វេដង គឺក្នុងរង្វង់ ៥ពាន់នាក់ ក្នុងឆ្នាំ២០១៨ និងនៅតែបន្តកើនឡើងក្នុងរង្វង់ ១ពាន់នាក់ ក្នុងឆ្នាំ២០១៩។

### ២.៤.៣. អ្នកសម្រាកព្យាបាលនៅមន្ទីរពេទ្យ

ក្រាហ្វិកទី៣÷ ចំនួនអ្នកជំងឺសម្រាកនៅមន្ទីរពេទ្យ




ចំនួនអ្នកជំងឺសម្រាកព្យាបាលនៅមន្ទីរពេទ្យដែលបានបង្ហាញក្នុងក្រាហ្វិកខាងលើមានការកើនឡើងជាប្រក្រតី គឺមានអ្នកជំងឺចំនួន ៤.២៧១នាក់ នៅឆ្នាំ២០១៥ កើនដល់ ៦.១៣៧នាក់ នៅឆ្នាំ២០១៨ ហើយចំនួននេះបានកើនឡើងរហូតដល់ ៨.៤៨១នាក់ នៅឆ្នាំ២០១៩។

### ២.៤.៤. អត្រាស្លាប់

ក្រាហ្វិកទី៤÷ អត្រាស្លាប់




តាមក្រាហ្វិកខាងលើបានបង្ហាញថា អត្រាអ្នកជំងឺស្លាប់នៅមន្ទីរពេទ្យខេត្តកោះកុង មានកម្រិតទាបគឺជាមធ្យមក្នុង ១%។ អត្រាស្លាប់មានការថយចុះគួរឱ្យកត់សម្គាល់ពីមួយឆ្នាំទៅមួយឆ្នាំ គឺក្នុងអត្រា ១,៥៥% នៅឆ្នាំ២០១៥ បានធ្លាក់ចុះរហូតដល់ 0,៧0% ក្នុងឆ្នាំ២០១៩។

### ២.៤.៥. ចំនួនស្ត្រីសម្រាលកូន

ក្រាហ្វិកទី៥÷ ចំនួនស្ត្រីសម្រាលកូន



ក្នុងរយៈពេល ៥ឆ្នាំ ចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៩ ចំនួនស្ត្រីមកសម្រាលកូននៅមន្ទីរពេទ្យខេត្តកោះកុងមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ គឺមានចំនួន ៦៨៦នាក់ នៅឆ្នាំ២០១៥ បានកើនដល់ចំនួន ១.២៣០នាក់ នៅឆ្នាំ២០១៩។ ក្នុងនោះដែរ ចំនួនសម្រាលកូនដោយការវះកាត់មានចំនួនតិច គឺក្នុងអត្រាពី ៤% ទៅ ៦% បើប្រៀបធៀបទៅនឹងចំនួនសម្រាលកូនធម្មតាប្រចាំឆ្នាំនីមួយៗ។

### ២.៤.៦. ការថែទាំមាតា និងទារកក្រោយសម្រាល

ក្រាហ្វិកទី៦÷ ការថែទាំមាតា និងទារកក្រោយសម្រាល




តាមក្រាហ្វិកខាងលើបង្ហាញថា ក្នុងរយៈពេល ៥ឆ្នាំ នៃការផ្តល់សេវាថែទាំមាតា និងទារកក្រោយសម្រាលមានការកើនឡើងជាលំដាប់រង្វង់ ១០០នាក់ ក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៨។ នៅឆ្នាំ២០១៩ ការផ្តល់សេវាថែទាំមាតា និងទារកក្រោយសម្រាលមានចំនួនកើនឡើងរហូតដល់ ១.២២១នាក់។

## ២.៤.៧. ចំនួនករណីថ្មីពិនិត្យពិគ្រោះជំងឺលើកុមារអាយុក្រោម ៥ឆ្នាំ

ក្រាហ្វិកទី៧÷ ចំនួនករណីថ្មីពិនិត្យពិគ្រោះជំងឺលើកុមារអាយុក្រោម ៥ឆ្នាំ




ចំនួនកុមារអាយុក្រោម ៥ឆ្នាំ បានមកទទួលសេវាពិនិត្យ និងពិគ្រោះជំងឺ នៅមន្ទីរពេទ្យខេត្តកោះកុងមានការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ នៅឆ្នាំ២០១៥ កុមារអាយុក្រោម ៥ឆ្នាំ បានមកទទួលសេវាពិនិត្យ និងពិគ្រោះជំងឺ ចំនួន ៧៤២នាក់ ហើយនៅឆ្នាំ២០១៦ មានការកើនឡើងដល់ ចំនួន ១.២១៧នាក់។ នៅឆ្នាំ២០១៧ ចំនួនកុមារអាយុក្រោម ៥ឆ្នាំ មកទទួលសេវាពិនិត្យ និងពិគ្រោះជំងឺមានការធ្លាក់ចុះមកនៅត្រឹមចំនួន ៩៩២នាក់ និងក្នុងឆ្នាំ២០១៩ ចំនួនកុមាអាយុក្រោម ៥ឆ្នាំ បានមកទទួលសេវាពិនិត្យ និងពិគ្រោះជំងឺមានការកើនឡើងខ្លាំងរហូតដល់ ១.៦៧១នាក់។

### ២.៤.៨. ចំនួនកុមារក្រោម ៥ឆ្នាំ សម្រាកពេទ្យ

ក្រាហ្វិកទី៨÷ ចំនួនកុមារក្រោម ៥ឆ្នាំ សម្រាកពេទ្យ




តាមក្រាហ្វិកខាងលើបង្ហាញថា ចំនួនកុមារសម្រាកព្យាបាលនៅមន្ទីរពេទ្យមានចំនួន ១៥៣នាក់ នៅឆ្នាំ២០១៥ ប៉ុន្តែចំនួនកុមារសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្តកោះកុង មានការកើនឡើងដល់ ២១៤នាក់ នៅឆ្នាំ២០១៦។ នៅឆ្នាំ២០១៨ និងឆ្នាំ២០១៩ កំណើន ចំនួនកុមារសម្រាកព្យាបាលនៅមន្ទីរពេទ្យមានចំនួន ២៤១នាក់។

### ២.៤.៩. ចំនួនករណីវះកាត់ធំសរុប

ក្រាហ្វិកទី៩÷ ចំនួនករណីវះកាត់ធំសរុប



ក្រាហ្វិកខាងលើបង្ហាញថា ចំនួនប្រជាពលរដ្ឋដែលមកទទួលយកសេវាវះកាត់ធំនៅមន្ទីរពេទ្យខេត្តកោះកុងមានការកើនឡើងចាប់ពី ៧០នាក់ នៅឆ្នាំ២០១៥ រហូតដល់ ១៥៤នាក់ នៅឆ្នាំ២០១៧។ ចំនួនប្រជាពលរដ្ឋមកទទួលយកសេវាប្រភេទនេះ មានការធ្លាក់ចុះមកនៅត្រឹម ១១៥នាក់ នៅឆ្នាំ២០១៨ ប៉ុន្តែករណីនេះ មានការកើនឡើងវិញដល់ចំនួន ១៨៦នាក់ ក្នុងឆ្នាំ២០១៩។

### ២.៤.១០. អត្រាប្រើប្រាស់គ្រែ

ក្រាហ្វិកទី១០÷ អត្រាប្រើប្រាស់គ្រែ




តាមទិន្នន័យក្នុងក្រាហ្វិកខាងលើបង្ហាញថា អត្រាប្រើប្រាស់គ្រែមានការកើនឡើងតិចតួចចាប់ពីឆ្នាំ២០១៥ មានចំនួន ៧២,៩% កើនដល់ចំនួន ៨៤,៩% នៅឆ្នាំ២០១៨។ ប៉ុន្តែអត្រាប្រើប្រាស់គ្រែកើនឡើងយ៉ាងខ្លាំងនៅឆ្នាំ២០១៩ គឺមានរហូតដល់ ១២៩,៤៧%។

## ២.៥. ចំណុចលេចធ្លោរបស់មន្ទីរពេទ្យ

### ២.៥.១. ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានអនាម័យស្រស់ស្អាត

មន្ទីរពេទ្យខេត្តកោះកុងមានហេដ្ឋារចនាសម្ព័ន្ធល្អស្អាតតាមស្តង់ដា ដោយមានខ្លោងទ្វាររបងអគារតាមផ្នែកនីមួយៗល្អស្អាត មានសួនច្បារ ដើមឈើពណ៌បៃតង បង់អង្គុយលំហែ ទីធ្លាសម្រាក លេងកីឡា នៅតាមបណ្តាផ្នែកទាំងអស់នៅក្នុងបរិវេណមន្ទីរពេទ្យ ដែលជា

ទឹកន្លែងប្រកបដោយផាសុកភាព បរិស្ថានអនាម័យពណ៌ខៀវស្រងាត់ អមដោយដើមរុក្ខជាតិនានាតាមរបងជុំវិញមន្ទីរពេទ្យ។

មន្ទីរពេទ្យបានរៀបចំប្រព័ន្ធរំហូរការងារទៅតាមស្តង់ដា ដោយមានប្រព័ន្ធបម្រើជួរមុខដែលមានការរៀបចំបានយ៉ាងល្អត្រឹមត្រូវ និងប្រព័ន្ធបម្រើផ្នែកខាងក្រោយ ដែលជាផ្នែកផ្តល់សេវាសុខភាពប្រកបដោយផាសុកភាព ប្រសិទ្ធភាព សុវត្ថិភាព និងមានធនធានមនុស្សមានសមត្ថភាពគ្រប់គ្រាន់ ព្រមទាំងបំពាក់នូវសម្ភារបរិក្ខារវេជ្ជសាស្ត្រគ្រប់គ្រាន់។

### ២.៥.២. សេវាប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់

មន្ទីរពេទ្យបានរៀបចំការផ្តល់សេវាជូនប្រជាពលរដ្ឋប្រកបដោយគុណភាព ប្រសិទ្ធភាពខ្ពស់ និងគណនេយ្យភាព ដែលធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋទទួលបានភាពសុខដុមរមនាទាំងផ្លូវកាយ និងផ្លូវចិត្ត។

ដោយសារកត្តាទាំងអស់នេះហើយ ទើបបានធ្វើឱ្យប្រជាពលរដ្ឋពេញចិត្តយ៉ាងខ្លាំងទាំងការបម្រើសេវា ទាំងគុណភាពសេវា ដោយមានការបម្រើសេវាស្មើភាពគ្នា និងប្រកបដោយតម្លាភាព ដូចជាអ្នកជំងឺក្រីក្រជាដើម ក្នុងនោះការប្រើប្រាស់ប័ណ្ណមូលនិធិសមធម៌ចំពោះជនក្រីក្រ ប័ណ្ណបេឡាជាតិសន្តិសុខសង្គម (បសស) សម្រាប់មន្ត្រីរាជការ កម្មករក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ និងការលើកលែងបង់ថ្លៃសេវាចំពោះព្រះសង្ឃ ដូនជី តាជី ពិរុទ្ធជនកុមារកំព្រា ជនអនាថា ជាដើម។

### ២.៥.៣. លទ្ធផលនៃការសម្ភាសអតិថិជន

ក្រាហ្វិកទី១១÷ លទ្ធផលនៃការសម្ភាសអតិថិជន




*ប្រភព÷ គម្រោង H-EQIP*

ក្រោមការអនុវត្តគម្រោង H-EQIP មន្ទីរពេទ្យខេត្តកោះកុងទទួលលទ្ធផលពីការសម្ភាសអតិថិជននៅក្នុងត្រីមាសទី៤ នៃឆ្នាំ២០១៧ ទទួលបាន ៦៩% ឆ្នាំ២០១៨ ទទួលបាន ៨០% និងនៅឆ្នាំ២០១៩ ទទួលបាន ៨៤,៧៩%។

### ២.៥.៤. មានចក្ខុវិស័យ បេសកកម្ម និងទិសដៅច្បាស់លាស់

មន្ទីរពេទ្យមានចក្ខុវិស័យ បេសកកម្ម ផែនការសកម្មភាព និងទិសដៅរបស់ខ្លួនយ៉ាងច្បាស់លាស់ ហើយមន្ត្រីគ្រប់រូបសុទ្ធតែទទួលបានការយល់ដឹងច្បាស់ ក្នុងការអនុវត្តការងារ និងភារកិច្ចរបស់ខ្លួនតាមកិច្ចសន្យាការងារប្រចាំឆ្នាំ (Job Description) ទៅតាមចក្ខុវិស័យរបស់មន្ទីរពេទ្យ។

### ២.៥.៥. ការបញ្ជ្រាបការយល់ដឹងអំពីសុខភាពសាធារណៈ (Health Education) និងបរិស្ថានអនាម័យស្អាតដល់ប្រជាជនទាំងក្នុងមន្ទីរពេទ្យ និងទាំងនៅក្នុងសហគមន៍

មន្ទីរពេទ្យខេត្តកោះកុងបានអនុវត្តការបញ្ជ្រាបការយល់ដឹងអំពីសុខភាពសាធារណៈ (Health Education) និងបរិស្ថានអនាម័យស្អាតដល់ប្រជាជនទាំងនៅក្នុងមន្ទីរពេទ្យ ទាំងនៅក្នុងសហគមន៍ តាមវិធីសាស្ត្រដូចខាងក្រោម÷

❖ **ការអប់រំផ្ទាល់**

ជាលក្ខណៈបុគ្គល (រវាងគ្រូពេទ្យ និងអ្នកជំងឺរួមទាំងអ្នកកំដរ)÷ អនុវត្តតាមរយៈការចុះពិនិត្យ ព្យាបាល និងថែទាំអ្នកជំងឺប្រចាំថ្ងៃស្ដីពីការអប់រំសុខភាពសាធារណៈ និងបរិស្ថានអនាម័យ

ជាលក្ខណៈក្រុម (រវាងក្រុមគ្រូពេទ្យ និងក្រុមអ្នកជំងឺ រួមទាំងអ្នកកំដរ)÷ អនុវត្តតាមរយៈការអញ្ជើញអ្នកជំងឺ និងអ្នកកំដរចូលរួមស្ដាប់ការអប់រំសុខភាពសាធារណៈ និងបរិស្ថានអនាម័យ នៅក្នុងបន្ទប់អប់រំសុខភាព (Education Room) ប្រចាំសប្ដាហ៍។

❖ **ការអប់រំតាមរយៈខិតប័ណ្ណ**

មន្ទីរពេទ្យបានរៀបចំប្រអប់ដាក់ខិតប័ណ្ណអប់រំសុខភាពសាធារណៈ និងបរិស្ថានអនាម័យ នៅតាមបណ្ដាផ្នែកទាំងអស់ ដើម្បីបង្កលក្ខណៈងាយស្រួលដល់អ្នកទទួលសេវាក្នុងការទទួលព័ត៌មានច្បាស់លាស់ និងបន្តផ្សព្វផ្សាយនៅក្នុងសហគមន៍របស់គាត់ (វប្បធម៌ចែករំលែកព័ត៌មាន)។

❖ **តាមរយៈការផ្សព្វផ្សាយតាមបណ្ដាញសង្គម**

មន្ទីរពេទ្យបានផ្សព្វផ្សាយអំពីការអប់រំសុខភាពសាធារណៈ និងបរិស្ថានអនាម័យស្អាត និងបំផុសស្មារតី នៃការចូលរួមរបស់អ្នកទទួលសេវាក្នុងគោលបំណងការបញ្ជ្រាបការយល់ដឹង និងការលើកកម្ពស់សុខុមាលភាពដល់ប្រជាពលរដ្ឋ

ជំពូកទី២

❖ **ការអប់រំផ្សព្វផ្សាយនៅតាមសហគមន៍**

មន្ទីរពេទ្យមានបេសកកម្មក្នុងការចុះពិនិត្យព្យាបាល និងផ្សព្វផ្សាយស្តីពីការអប់រំសុខភាពសាធារណៈ និងបរិស្ថានអនាម័យនៅតាមសហគមន៍ ប្រចាំត្រីមាស។

# ជំពូកទី៣. បទពិសោធន៍ជោគជ័យរបស់មន្ទីរពេទ្យខេត្តកោះកុង

## ៣.១. ស្តង់ដារសេវាសាធារណៈ

ស្តង់ដារសេវាសាធារណៈ គឺជាម៉ែត្រវាស់កម្រិតគុណភាព និងចរិតលក្ខណៈ ក្នុងការផ្តល់សេវាសាធារណៈ ដើម្បីទទួលបានការពេញចិត្តពីអ្នកប្រើប្រាស់សេវាសាធារណៈតាមលក្ខខណ្ឌកំណត់(ដូចជានីតិវិធី ពេលវេលា តម្លៃ និងទីកន្លែង) និងឆ្លើយតបទៅនឹងសេចក្តីត្រូវការ និងផលប្រយោជន៍របស់អ្នកប្រើប្រាស់សេវាសាធារណៈ[១០] ដែលរួមមាន ១.គុណភាពព័ត៌មាន ២.ភាពងាយស្រួលក្នុងការទទួលយកសេវា ៣.ភាពយកចិត្តទុកដាក់ក្នុងការទទួលអ្នកប្រើប្រាស់សេវា និង ៤.ការផ្តល់សេវាតាមគោលការណ៍កំណត់ និងអភិបាលកិច្ចល្អ។

### ៣.១.១. គុណភាពព័ត៌មាន

គុណភាពព័ត៌មាន សំដៅដល់ព័ត៌មានដែលបានផ្តល់ជូនអ្នកប្រើប្រាស់សេវា ត្រូវមានលក្ខណៈងាយយល់ ច្បាស់លាស់ ត្រឹមត្រូវ មានបច្ចុប្បន្នភាព និងងាយទទួលយក។ គុណភាពព័ត៌មាន មានលក្ខណៈវិនិច្ឆ័យដូចជា ១.ការរៀបចំ និងរក្សាទុកបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសេវា ២.ព័ត៌មានដែលផ្សព្វផ្សាយ និង ៣.មធ្យោបាយផ្សព្វផ្សាយ។

#### ៣.១.១.១. ការរៀបចំ និងរក្សាទុកបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសេវា

ផ្នែករដ្ឋបាលរបស់មន្ទីរពេទ្យខេត្តកោះកុង មានការរក្សាទុកនូវច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ពាក់ព័ន្ធនឹងការផ្តល់សេវារបស់មន្ទីរពេទ្យ ដោយបានទុកដាក់នៅក្នុងទូរឯកសារ និងបែងចែកទៅតាមប្រភេទ។ ក្នុងករណីប្រជាពលរដ្ឋមានចម្ងល់ ឬមន្ទិលសង្ស័យអំពីប្រភេទនិងតម្លៃសេវា ឬព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈរបស់មន្ទីរពេទ្យ ប្រជាពលរដ្ឋអាចធ្វើការទាក់ទងជាមួយផ្នែករដ្ឋបាលរបស់មន្ទីរពេទ្យ ដើម្បីស្នើសុំពិនិត្យលើច្បាប់ លិខិតបទដ្ឋានគតិយុត្ត ឬឯកសារនានាពាក់ព័ន្ធនឹងការផ្តល់សេវាដែលខ្លួនចង់ដឹង នោះមន្ត្រីផ្នែករដ្ឋបាលនឹងយកឯកសារនោះជូនអ្នកស្នើសុំដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់។

[១០] ឯកសារណែនាំស្តីពីស្តង់ដារសេវាសាធារណៈ ឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យលេខ ៤៥៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិវាយតម្លៃសេវាសាធារណៈ

### ៣.១.១.២. ព័ត៌មានដែលផ្សព្វផ្សាយ

មន្ទីរពេទ្យខេត្តកោះកុងបានធ្វើការផ្សព្វផ្សាយនូវ ប្រភេទនិងតម្លៃសេវា ឯកសារតម្រូវ និងលក្ខខណ្ឌក្នុងការទទួលបានសេវាសាធារណៈ ម៉ោងពេលបំពេញការងារ មធ្យោបាយទំនាក់ទំនងអង្គភាពផ្តល់សេវា រយៈពេលរង់ចាំ និងការចុះឈ្មោះអ្នកជំងឺ និងបទបញ្ជាផ្ទៃក្នុង។

#### ៣.១.១.២.១. ប្រភេទ និងតម្លៃសេវា

ដើម្បីបង្ហាញពីតម្លាភាពក្នុងការផ្តល់សេវាសាធារណៈ មន្ទីរពេទ្យខេត្តកោះកុងមានការបោះពុម្ពបិទផ្សាយលើក្តារខៀននូវតារាងសេវាហិរញ្ញប្បទានដែលមានកំណត់អំពីប្រភេទ និងតម្លៃសេវានានារបស់មន្ទីរពេទ្យនៅផ្នែកផ្តល់ព័ត៌មានក្នុងទម្រង់ជាក្តារខៀនពត៌មាន ទំហំ ១,២ម៉ែត្រ x ២,៥ម៉ែត្រ និងតារាងសេវាហិរញ្ញប្បទានរបស់ផ្នែកជំនាញនៅតាមផ្នែកនីមួយៗរបស់មន្ទីរពេទ្យ។

#### ៣.១.១.២.២. ឯកសារតម្រូវ និងលក្ខខណ្ឌក្នុងការទទួលបានសេវាសាធារណៈ

មន្ទីរពេទ្យបានបិទផ្សាយនូវផ្ទាំងបង្ហាញពីឯកសារតម្រូវ និងលក្ខខណ្ឌក្នុងការទទួលសេវាសាធារណៈ តាមក្តារព័ត៌មាននៅតាមបណ្តាផ្នែកទាំងអស់ក្នុងមន្ទីរពេទ្យ ជាពិសេសនៅផ្នែកជួរមុខនៃមន្ទីរពេទ្យ ក្នុងទម្រង់ក្រដាស A4 ជូនដល់អ្នកប្រើប្រាស់សេវាដើម្បីអាចដឹងថាត្រូវភ្ជាប់អ្វីទៅជាមួយពេលត្រូវទៅប្រើប្រាស់សេវារបស់មន្ទីរពេទ្យ។

ឯកសារតម្រូវ និងលក្ខខណ្ឌក្នុងការទទួលបានសេវាសាធារណៈដែលអ្នកប្រើប្រាស់សេវាត្រូវភ្ជាប់មកជាមួយពេលមកចុះឈ្មោះនៅផ្នែកជួរមុខ គឺរួមមាន៖ អត្តសញ្ញាណប័ណ្ណលិខិតឆ្លងដែន ឬប័ណ្ណសម្គាល់ខ្លួន ដោយភ្ជាប់ជាមួយនូវប័ណ្ណមួយចំនួនទៀត ដោយផ្អែកលើលក្ខខណ្ឌ ឬករណី ដូចខាងក្រោម៖

- ❖ ក្នុងករណីអ្នកប្រើប្រាស់សេវាជាកម្មករ បុគ្គលិក ឬមន្ត្រីរាជការ ត្រូវភ្ជាប់មកជាមួយនូវ ប័ណ្ណ ប.ស.ស (បើគ្មានប័ណ្ណ ប.ស.ស ត្រូវបង់ថ្លៃទៅតាមតារាងសេវា

ហិរញ្ញប្បទានរបស់មន្ទីរពេទ្យ)

❖ ករណីអ្នកប្រើប្រាស់សេវាជាពលរដ្ឋក្រីក្រ ត្រូវភ្ជាប់មកជាមួយនូវប័ណ្ណមូលនិធិសមធម៌ ដើម្បីទទួលសេវាដោយឥតបង់ថ្លៃ។ ក្នុងករណី គ្មានប័ណ្ណមូលនិធិសមធម៌ គឺត្រូវធ្វើបទសម្ភាសន៍ទៅតាមកម្រងសំណួរ (កម្រងសំណួរសម្រាប់បញ្ជាក់អត្ត-សញ្ញាណកម្មគ្រួសារជនក្រីក្រនៅមន្ទីរពេទ្យ) ដែលចេញដោយ ក្រសួងសុខាភិបាល ជាមួយមន្ត្រីរបស់ក្រសួងសុខាភិបាលនៅប៉ុស្តិ៍ ID (បន្ទប់មូលនិធិសមធម៌)។ ប្រសិនបើពួកគាត់សម្ភាសន៍មិនជាប់ ហើយនៅតែគ្មានថវិកាបង់ គណៈកម្មការហិរញ្ញប្បទានមន្ទីរពេទ្យនឹងលើកសំណើជូនប្រធានមន្ទីរពេទ្យ ដើម្បីពិនិត្យ និងសម្រេចលើកលែងការបង់ថ្លៃ

❖ ក្នុងករណីអ្នកជំងឺជាពិការទ្ធជន កុមារកំព្រា ជនអនាថា ឬជនគ្មានទីពឹង ត្រូវបានលើកលែងក្នុងការបង់ថ្លៃសេវាថែទាំ និងព្យាបាលនៅក្នុងមន្ទីរពេទ្យ។ ក្នុងករណីអ្នកប្រើប្រាស់សេវាជាអតីតអ្នកជំងឺដែលធ្លាប់មកទទួលសេវានៅមន្ទីរពេទ្យរួចមកហើយ ត្រូវភ្ជាប់មកជាមួយនូវប័ណ្ណសុខភាពដែលមន្ទីរពេទ្យធ្លាប់បានផ្តល់ជូន។ អ្នកជំងឺដែលធ្លាប់មកទទួលសេវានៅមន្ទីរពេទ្យ ត្រូវបានមន្ទីរពេទ្យរក្សាទុកប្រវត្តិជំងឺ និងអត្តសញ្ញាណ និងទុកនៅក្នុងទូរឯកសារ ដូច្នេះពេលគាត់អញ្ជើញមកម្តងទៀត គ្រាន់តែបង្ហាញប័ណ្ណសុខភាពនោះជាការស្រេច

❖ ក្នុងករណីអ្នកជំងឺថ្មី មិនដែលមានប្រវត្តិទទួលសេវានៅមន្ទីរពេទ្យខេត្តកោះកុង ត្រូវភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន ឬប័ណ្ណសម្គាល់ខ្លួន និងឯកសារដូចបានរៀបរាប់ខាងលើ ខាងមន្ទីរពេទ្យនឹងបំពេញប័ណ្ណសុខភាពថ្មីជូន

❖ សម្រាប់ស្ត្រីក្រីក្រមានផ្ទៃពោះ និងកុមារក្រោមអាយុ ២ឆ្នាំ មន្ទីរពេទ្យខេត្តកោះកុង បានចូលរួមអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលស្តីអំពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីក្រីក្រមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ផងដែរ។

### ៣.១.១.២.៣. ម៉ោងពេលបំពេញការងារ

មន្ទីរពេទ្យខេត្តកោះកុងបើកបម្រើសេវាជូនប្រជាពលរដ្ឋជារៀងរាល់ថ្ងៃ ដោយបានបែងចែកម៉ោងបំពេញការងារជាពីរ និងបានធ្វើការបិទផ្សាយនូវម៉ោងពេលបំពេញការងារនៅតាមផ្នែកនីមួយៗរួមមាន÷ ទី១ ម៉ោងសម្រាប់បុគ្គលិកបំពេញការងារផ្នែកពិគ្រោះជំងឺក្រៅ និងបុគ្គលិកផ្នែករដ្ឋបាល គឺ ៨ម៉ោង ក្នុង ១ថ្ងៃ និងមាន ២ពេល ពេលព្រឹកចាប់ពីម៉ោង ៧: ០០នាទី ដល់ម៉ោង ១១: ៣០នាទី និងពេលរសៀលចាប់ពីម៉ោង ១៤: ៣០នាទី ដល់ម៉ោង ១៧: ៣០នាទី (៨ម៉ោង/១ថ្ងៃ ៤០ម៉ោង/១សប្តាហ៍) និងទី២ ម៉ោងសម្រាប់បុគ្គលិកយាមប្រចាំការប្រចាំថ្ងៃ និងថ្ងៃឈប់សម្រាក គឺម៉ោងបំពេញការងារ ២៤/២៤ម៉ោង។

ដោយសារកត្តាចំនួនបុគ្គលិករបស់មន្ទីរពេទ្យខេត្តកោះកុងនៅមានកម្រិត តាមផ្នែកនីមួយៗបានដាក់ចេញនូវតារាងផែនការប្រចាំខែ ដែលតារាងនេះកំណត់កាលវិភាគបំពេញការងាររបស់បុគ្គលិកម្នាក់ៗ ដោយបានកំណត់អំពីម៉ោងធ្វើការ ម៉ោងប្តូរវេនប្រចាំការ និងម៉ោងយាមជាទៀងទាត់ ដើម្បីធានាថាផ្នែកនីមួយៗ មានបុគ្គលិកបំពេញការងារគ្រប់គ្រាន់ក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋ។ ក្នុងករណីការព្យាបាលមានតម្រូវការអ្នកបច្ចេកទេសរូបណាជាបន្ទាន់ មន្ទីរពេទ្យនឹងធ្វើការទំនាក់ទំនងទៅមន្ត្រីបច្ចេកទេសសាមី ដើម្បីមកជួយបំពេញការងារនៅមន្ទីរពេទ្យភ្លាម ទោះបីមិនមែនជាពេលវេលាបំពេញការងាររបស់មន្ត្រីរូបនោះក៏ដោយ។

មន្ទីរពេទ្យខេត្តកោះកុងក៏មានបិទផ្សាយផងដែរនូវ ម៉ោងសួរសុខទុក្ខអ្នកជំងឺ ក្នុងទម្រង់ក្រដាស A4 និងមានអក្សរទំហំធំច្បាស់ នៅផ្នែកជួរមុខរបស់មន្ទីរពេទ្យ និងនៅតាមផ្នែកនីមួយៗ ដើម្បីអាចឱ្យឪពុកម្តាយ បងប្អូន សាច់ញាតិ ឬមិត្តភក្តិរបស់អ្នកជំងឺ មកសួរសុខទុក្ខទៅតាមកាលវិភាគកំណត់ដោយមន្ទីរពេទ្យ ដែលមានដូចខាងក្រោម÷

- ពេលព្រឹក ÷ ចាប់ពីម៉ោង ០៧ ដល់ម៉ោង ០៨ព្រឹក
- ពេលថ្ងៃត្រង់ ÷ ចាប់ពីម៉ោង ១១ ដល់ម៉ោង ១២ថ្ងៃត្រង់
- ពេលល្ងាច ÷ ចាប់ពីម៉ោង ០៥ ដល់ម៉ោង ០៦ល្ងាច

### ៣.១.១.២.៤. មធ្យោបាយទំនាក់ទំនងអន្តរភាពផ្ដល់សេវា

ដើម្បីធានាការផ្ដល់សេវាប្រកបដោយប្រសិទ្ធភាព និងឆ្លើយតបទាន់ពេលវេលា មន្ទីរពេទ្យខេត្តកោះកុងបានបង្កើតមធ្យោបាយទំនាក់ទំនងក្នុងទម្រង់ដូចខាងក្រោម÷

- លេខទូរស័ព្ទទំនាក់ទំនងមន្ទីរពេទ្យ ០៣៥ ៩៣៦ ២៦៩ ដែលមានក្រុមការងារផ្នែករដ្ឋបាល នៅប្រចាំការដើម្បីទទួលការទំនាក់ទំនងរបស់អ្នកប្រើប្រាស់សេវា ២៤ម៉ោងក្នុងមួយថ្ងៃ
- លេខទូរស័ព្ទរថយន្តគិលានសង្គ្រោះ ០១៦ ៣០០ ១១៩ ដែលត្រូវបានប្រធានផ្នែករដ្ឋបាល និងគណនេយ្យ ជាអ្នកទទួលបន្ទុកកាន់ដោយផ្ទាល់ និងប្រើប្រាស់ ២៤ម៉ោងក្នុងមួយថ្ងៃ
- មាន E-mail : phkohkong@gmail.com
- មាន Facebook Page ឈ្មោះ “មន្ទីរពេទ្យខេត្តកោះកុង”។

ករណីទំនាក់ទំនងដើម្បីសង្គ្រោះអ្នកជំងឺដែលនៅឆ្ងាយ÷ ពេលមានប្រជាពលរដ្ឋទំនាក់ទំនងទៅលេខទូរស័ព្ទរថយន្តគិលានសង្គ្រោះរបស់មន្ទីរពេទ្យ លោកប្រធានផ្នែករដ្ឋបាល ជាអ្នកកាន់ដោយផ្ទាល់និងធ្វើការហៅចូល ២៤ម៉ោង។ ពេលទទួល លោកនឹងសួរនាំអំពីទីតាំង និងស្ថានភាពជាក់ស្ដែងរបស់អ្នកជំងឺដែលត្រូវសង្គ្រោះ ដើម្បីរាយការណ៍ជូនដល់មន្ទីរពេទ្យឱ្យធ្វើការត្រៀមឧបករណ៍ និងគ្រូពេទ្យជំនាញដើម្បីត្រៀមទទួលសង្គ្រោះអ្នកជំងឺដែលនឹងមកដល់មន្ទីរពេទ្យតាមពេលវេលាដែលបានកំណត់ និងទាក់ទងទៅមន្ទីរ-ពេទ្យបង្អែក ឬមណ្ឌលសុខភាពដែលនៅជិតទីកន្លែងរបស់អ្នកជំងឺ ដើម្បីធ្វើការជួយសង្គ្រោះបឋម និងជួយបញ្ជូនអ្នកជំងឺ (តាមរយៈទូកសង្គ្រោះ ឬរថយន្តគិលានសង្គ្រោះរបស់មន្ទីរពេទ្យបង្អែក ឬមណ្ឌលសុខភាព) ឆ្ពោះទៅរកកន្លែងដែលបានណាត់ជាមួយមន្ទីរពេទ្យខេត្តកោះកុង ដើម្បីធ្វើការផ្ទេរអ្នកជំងឺ និងបញ្ជូនបន្តទៅកាន់មន្ទីរពេទ្យ ដើម្បីឱ្យគ្រូពេទ្យជំនាញដែលបានត្រៀមរួចរាល់ធ្វើការសង្គ្រោះ។

### ៣.១.១.២.៥. រយៈពេលរង់ចាំ និងការចុះឈ្មោះអ្នកជំងឺ

ដើម្បីលើកកម្ពស់គុណភាពនៃការផ្តល់សេវាសាធារណៈរបស់មន្ទីរពេទ្យខេត្តកោះកុង ឱ្យកាន់តែឆាប់រហ័សជូនប្រជាពលរដ្ឋ មន្ទីរពេទ្យបានដាក់ចេញជាគោលការណ៍ដោយកំណត់រយៈពេលយ៉ាងយូរបំផុតមិនឱ្យលើសពី ៣០នាទី គិតចាប់តាំងពីការចាប់លេខរហូតដល់ចុះឈ្មោះ និងត្រូវបានមន្ទីរពេទ្យបិទផ្សាយជាសាធារណៈលើផ្ទាំងដែលព្រីនក្នុងទម្រង់អក្សរធំៗ នៅលើមាត់បង្អួចនៃបន្ទប់ផ្នែកជួរមុខ (បន្ទប់ទ្រីយ៉ា)។

### ៣.១.១.២.៦. បទបញ្ជាផ្ទៃក្នុង

បទបញ្ជាផ្ទៃក្នុងរបស់មន្ទីរពេទ្យត្រូវបានរៀបចំឡើងដោយគណៈកម្មការវិន័យនិងទណ្ឌកម្ម និងត្រូវបានដាក់ប្រជុំពិគ្រោះយោបល់ ជាមួយប្រធាន និងបុគ្គលិកតាមផ្នែកជំនាញ មុននឹងត្រូវបានអនុម័តដោយគណៈកម្មការគ្រប់គ្រងមន្ទីរពេទ្យ។ បទបញ្ជាផ្ទៃក្នុងនេះត្រូវបានរៀបចំឡើងដោយផ្អែកលើមូលដ្ឋានច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យស្តីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា និងត្រូវបានប្រកាសផ្សព្វផ្សាយយ៉ាងទូលំទូលាយមុននឹងដាក់ឱ្យបុគ្គលិកអនុវត្ត។

បទបញ្ជាផ្ទៃក្នុងត្រូវបានបិទផ្សាយនៅតាមបណ្តាជញ្ជាំងនៃអគារ និងតាមផ្នែករបស់មន្ទីរពេទ្យ។ ដើម្បីធានាថាបុគ្គលិកទាំងអស់អនុវត្តតាមបទបញ្ជាផ្ទៃក្នុងរបស់មន្ទីរពេទ្យបានយ៉ាងត្រឹមត្រូវ គណៈគ្រប់គ្រងមន្ទីរពេទ្យបានសម្រេចបង្កើតក្រុមការងារត្រួតពិនិត្យ និងវាយតម្លៃវត្តមាន និងប្រសិទ្ធភាពការងារបុគ្គលិក ដើម្បីត្រួតពិនិត្យ តាមដាន និងវាយតម្លៃទៅលើការអនុវត្តរបស់បុគ្គលិកគ្រប់រូបដោយធ្វើការពិនិត្យ និងតាមដានចំនួន ២ដង ក្នុងមួយសប្តាហ៍ ដូចជាការដើរត្រួតពិនិត្យវត្តមានរបស់បុគ្គលិកនៅតាមផ្នែកនីមួយៗ ដោយក្រុមការងារត្រួតពិនិត្យ វាយតម្លៃវត្តមាន គុណភាព និងប្រសិទ្ធភាពការងារបុគ្គលិក និងធ្វើការរាប់ចំនួនបុគ្គលិកជាក់ស្តែង និងផ្ទៀងផ្ទាត់ជាមួយតារាងបែងចែកការងាររបស់ផ្នែកសាមីនោះ។

### ៣.១.១.៣. មធ្យោបាយផ្សព្វផ្សាយ

ដើម្បីធ្វើការផ្សព្វផ្សាយព័ត៌មាននៃការផ្ដល់សេវាសាធារណៈ មន្ទីរពេទ្យបានប្រើប្រាស់មធ្យោបាយផ្សព្វផ្សាយ តាមរយៈប្រព័ន្ធអេឡិចត្រូនិក ឬបណ្ដាញសង្គម និងប្រព័ន្ធមិនមែនអេឡិចត្រូនិក (វិទ្យុ ទូរទស្សន៍ ផ្សព្វផ្សាយតាមសហគមន៍ ខិត្តប័ណ្ណ និងការផ្សាយនៅហ្នឹងកន្លែង)។

យោងទៅតាមបរិបទនៃបច្ចេកវិទ្យាដែលបានផ្លាស់ប្ដូរពីមួយថ្ងៃទៅមួយថ្ងៃ និងនិន្នាការនៃការប្រើប្រាស់បណ្ដាញសង្គមកាន់តែកើនឡើងមន្ទីរពេទ្យបានបង្កើតនូវទំព័រហ្វេសប៊ុករបស់ខ្លួននៅឆ្នាំ២០១៦ ដោយបានដាក់ឈ្មោះជាភាសាខ្មែរថា **"មន្ទីរពេទ្យខេត្តកោះកុង"** ដែលមានបុគ្គលិកចំនួន ៣នាក់ ទទួលបន្ទុក។ ទំព័រហ្វេសប៊ុកនេះត្រូវបានបង្កើតឡើងសម្រាប់ធ្វើការផ្សព្វផ្សាយព័ត៌មានសំខាន់ៗ និងមានបច្ចុប្បន្នភាព ដូចជា÷ ១. ការផ្សព្វផ្សាយអំពីប្រភេទ និងគុណភាពសេវាសុខាភិបាលនៅក្នុងមន្ទីរពេទ្យ ២. ការអប់រំ និងការលើកកម្ពស់សុខភាពសាធារណៈ បរិស្ថាន និងអនាម័យ និង៣. សកម្មភាពនៃការបណ្ដុះបណ្ដាលធនធានមនុស្ស ការចូលរួមរបស់អ្នកទទួលសេវា និងសប្បុរសជននានា។ ទំព័រហ្វេសប៊ុកនេះ ក៏ត្រូវបានចាត់ទុកជាយន្តការ ដើម្បីទទួលយកនូវរាល់មតិយោបល់របស់ប្រជាពលរដ្ឋចំពោះមន្ទីរពេទ្យ និងឆ្លើយតបបកស្រាយបំភ្លឺនូវរាល់ព័ត៌មានដែលពាក់ព័ន្ធនឹងមន្ទីរពេទ្យផងដែរ។

លើសពីនេះ មន្ទីរពេទ្យខេត្តកោះកុងក៏មានផ្សព្វផ្សាយព័ត៌មាន និងសេចក្ដីជូនដំណឹងផ្សេងៗតាមប្រព័ន្ធមិនមែនអេឡិចត្រូនិក ដែលមានដូចជា ក្ដារខៀនព័ត៌មាន ខិត្តប័ណ្ណ ការផ្សាយតាមវិទ្យុប៉ុស្តិ៍ ១០៣.៥។ ការផ្សព្វផ្សាយនេះ ធ្វើឡើងនៅពេលមានបេសកកម្មរបស់ក្រុមគ្រូពេទ្យស្ម័គ្រចិត្តមកពីប្រទេសបារាំង ប្រទេសថៃ និងក្រុមការងារដៃគូផ្សេងៗ ដែលគ្រោងនឹងធ្វើការវះកាត់ ពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ ដោយធ្វើការផ្សព្វផ្សាយជូនដំណឹង ២សប្ដាហ៍មុន ៣ថ្ងៃ ក្នុងមួយសប្ដាហ៍ និង ១ថ្ងៃ ៣ដង ដើម្បីឱ្យប្រជា-ពលរដ្ឋមកទទួលសេវាបានទាន់ពេលវេលា។ រួមជាមួយគ្នានេះដែរ មន្ទីរពេទ្យក៏បានរៀបចំឱ្យមានការអប់រំតាមផ្នែកនីមួយៗជូនអ្នកជំងឺ និងអ្នកកំដរអ្នកជំងឺ ដែលការអប់រំនេះ បាន

កំណត់កាលវិភាគ និងប្រធានបទច្បាស់លាស់ ដូចជាការអប់រំសុខភាពសាធារណៈទូទៅ និងភាពស្អាត បរិស្ថានអនាម័យស្អាត ការរស់នៅស្អាតជាដើម ដោយធ្វើការអប់រំក្នុង ១សប្ដាហ៍ ១ដង។ ក្រៅពីនេះ មន្ទីរពេទ្យខេត្តកោះកុងក៏មានកិច្ចសហការជាមួយការិយាល័យបង្ការជំងឺរបស់មន្ទីរសុខាភិបាលខេត្តកោះកុងក្នុងការផ្សព្វផ្សាយព័ត៌មាន សេចក្ដីជូនដំណឹង និងការចុះអប់រំអំពីចំណេះដឹងពាក់ព័ន្ធនឹងការថែរក្សាសុខភាពទូទៅដូចជាការថែទាំកុមារ បញ្ហារោគស្ត្រី ជំងឺគ្រុនឈាម ជំងឺគ្រុនចាញ់ និងថ្មីៗនេះពាក់ព័ន្ធនឹងជំងឺកូវីដ-១៩ ជាដើម។ ការអប់រំនេះ ត្រូវបានធ្វើឡើងតាមរយៈការចាក់មេក្រូតាមរថយន្ត ឬរៀបចំវេទិកាសាធារណៈនៅទីតាំងផ្ទាល់តាមតំបន់មួយចំនួននៅក្នុងខេត្ត។ វេទិកាសាធារណៈប្រព្រឹត្តទៅ ២ដង ក្នុងមួយឆ្នាំ(រយៈពេល១ថ្ងៃ ក្នុងវេទិកានីមួយៗ) នៅតាមបណ្ដាឃុំ ស្រុកដោយមានការចូលរួមពីក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត គណៈអភិបាលក្រុង ស្រុក មេភូមិ មេឃុំ ចៅសង្កាត់ មន្ទីរពាក់ព័ន្ធជុំវិញខេត្ត និងប្រជាពលរដ្ឋក្នុងមូលដ្ឋាន។

### ៣.១.២. ភាពងាយស្រួលក្នុងការទទួលយកសេវា

ភាពងាយស្រួលក្នុងការទទួលយកសេវា សំដៅដល់អ្នកផ្ដល់សេវាសាធារណៈសម្រប-សម្រួលដល់អ្នកប្រើប្រាស់សេវាលើនីតិវិធី ទំនាក់ទំនង ការបំពេញបែបបទ និងការទទួលយកសេវាទៅប្រើប្រាស់។ ភាពងាយស្រួលក្នុងការទទួលយកសេវាមានលក្ខណៈវិនិច្ឆ័យដូចជា ១.ទីតាំង និងហេដ្ឋារចនាសម្ព័ន្ធ និង២.នីតិវិធី និងលក្ខខណ្ឌ។

#### ៣.១.២.១. ទីតាំង និងហេដ្ឋារចនាសម្ព័ន្ធ

នៅចំណុចនេះមានការលើកឡើងអំពី ១.ស្ថានភាពហេដ្ឋារចនាសម្ព័ន្ធជុំវិញមន្ទីរពេទ្យ ២.ការបិទបង្ហាញប្លង់ទីតាំងមន្ទីរពេទ្យ និងផ្លាកសញ្ញាប្រាប់ពីឈ្មោះផ្នែកផ្ដល់សេវានីមួយៗច្បាស់លាស់ ៣.ទីតាំងផ្ដល់សេវាប្រកបដោយផាសុកភាព និង ៤.អ្នកផ្ដល់សេវាផ្នែកជួរមុខមានចំនួនគ្រប់គ្រាន់ និងមានវត្តមាននៅក្នុងពេលបំពេញការងារជាប្រចាំ។

### ៣.១.២.១.១. ស្ថានភាពហេដ្ឋារចនាសម្ព័ន្ធជុំវិញមន្ទីរពេទ្យ

មន្ទីរពេទ្យខេត្តកោះកុងមានខ្លោងទ្វារដ៏ធំដែលអាចឱ្យយានយន្តគ្រប់ប្រភេទចេញចូលបាន និងមានផ្លាកឈ្មោះរបស់មន្ទីរពេទ្យនៅលើខ្លោងទ្វារ ព្រមទាំងមានរបងព័ទ្ធជុំវិញបរិវេណរបស់មន្ទីរពេទ្យ។ មន្ទីរពេទ្យមានអគារចំនួន ២០ និងត្រូវបានបែងចែកទៅតាមផ្នែកជំនាញនីមួយៗ ដោយបានបែងចែកជាបន្ទប់ធ្វើការ បន្ទប់សម្រាកព្យាបាល និងបន្ទប់ទឹកស្រី ប្រុស និងបន្ទប់ទឹកសម្រាប់ជនពិការនៅគ្រប់ផ្នែកទាំងអស់ ឡដុតសំណល់ និងបន្ទប់តម្កល់សាក-សព។ ដើម្បីបង្កើនសោភ័ណភាព បរិយាកាស និងខ្យល់បរិសុទ្ធនៅក្នុងបរិវេណមន្ទីរពេទ្យ គណៈគ្រប់គ្រងមន្ទីរពេទ្យបានរៀបចំដាំនូវដើមឈើ ផ្កា និងសួនច្បារ និងផ្ដួចផ្ដើមគំនិតដល់បុគ្គលិកគ្រប់ផ្នែកត្រូវចេះថែរក្សា និងស្វែងរកជំនួយពីសប្បុរសជននានាជួយឧបត្ថម្ភនូវដើមឈើ ផ្កា បង់អង្គុយឬបរិក្ខារផ្សេងៗ ដើម្បីបង្កើនភាពស្រស់បំព្រងនៅក្នុងបរិវេណរបស់បណ្ដាផ្នែកនីមួយៗ និងមន្ទីរពេទ្យ។ មន្ទីរពេទ្យក៏បានបង្កើតភាពងាយស្រួលដល់អ្នកប្រើប្រាស់សេវា ដោយរៀបចំចាក់ជាបេតុង រៀបឥដ្ឋការ៉ូឡា និងបានប្រក់ដំបូលការពារទឹកភ្លៀងសម្រាប់ផ្លូវថ្មើរជើងរបស់អ្នកប្រើប្រាស់សេវា ព្រមទាំងមានរៀបចំជាផ្លូវជម្រាលសម្រាប់ជនពិការដែលអញ្ជើញមកទទួលសេវាផងដែរ។ ក្រៅពីការបង្កើនសោភ័ណភាពមន្ទីរពេទ្យបានរៀបចំសណ្ដាប់ធ្នាប់ក្នុងបរិវេណបានយ៉ាងល្អប្រសើរតាមរយៈ ការរៀបចំឱ្យមានចំណតរថយន្តបុគ្គលិក(អាចចតរថយន្តប្រហាក់ប្រហែលចំនួន ២០គ្រឿង) ចំណតរថយន្តគិលានសង្គ្រោះ(អាចចតរថយន្តប្រហាក់ប្រហែលចំនួន ៦គ្រឿង) ចំណតរថយន្តអ្នកប្រើប្រាស់សេវា(អាចចតរថយន្តប្រហាក់ប្រហែលចំនួន ៣០គ្រឿង) និងចំណតម៉ូតូ (មានរោងម៉ូតូ និងដំបូលការពារមិនឱ្យត្រូវភ្លៀង)។

### ៣.១.២.១.២. ការបិទបង្ហាញប្លង់ទីតាំង និងស្លាកសញ្ញាច្រាប់ពីឈ្មោះផ្នែកផ្តល់សេវានីមួយៗច្បាស់លាស់

រដ្ឋបាលមន្ទីរពេទ្យបានរៀបចំបិទនូវផ្ទាំងបង្ហាញប្លង់អគារទាំងមូល និងសញ្ញាចង្អុលទៅតាមផ្នែកនីមួយៗរបស់មន្ទីរពេទ្យក្នុងទម្រង់ផ្ទាំងធំ នៅច្រកចូលមន្ទីរពេទ្យ។ ខ្លោងទ្វារមាន

ជំពូកទី៣

ដាក់ឈ្មោះទាំងជាភាសាខ្មែរ "មន្ទីរពេទ្យខេត្តកោះកុង" និងភាសាអង់គ្លេស "KOH KONG PROVINCIAL HOSPITAL"។ ចំពោះបន្ទប់នីមួយៗមានបិទឈ្មោះនៅពីលើមាត់ទ្វារ និងជាពិសេសមានការបង់លេខសម្គាល់បន្ថែម ដើម្បីសម្រួលក្នុងការស្វែងរករបស់ប្រជាពលរដ្ឋដែលមិនចេះអក្សរ តែអាចស្គាល់ត្រឹមលេខ។ ចំណែកឯ បន្ទប់ទឹក គឺមានការបែងចែកបន្ទប់ទឹកប្រុស បន្ទប់ទឹកស្រី និងបន្ទប់ទឹកជនពិការ។

### ៣.១.២.១.៣. ទីតាំងផ្តល់សេវាសាធារណៈប្រកបដោយផាសុកភាព

នៅក្នុងបរិវេណមន្ទីរពេទ្យ និងនៅទីតាំងផ្តល់សេវាតាមបណ្តាផ្នែកនីមួយៗ គ្មានសម្លេងរំខាន គ្មានភក់ គ្មានក្លិនស្អុយ មានកន្លែងអង្គុយរង់ចាំ មានខ្យល់ចេញចូលគ្រប់គ្រាន់ មានការថែរក្សាអនាម័យ មានការគ្រប់គ្រងសំណល់ត្រឹមត្រូវ មានការសម្អាត និងការសម្លាប់មេរោគជាប្រចាំ និងមានការបង្កើតវប្បធម៌ឱ្យបុគ្គលិកចេះផ្តួចផ្តើមគំនិតច្នៃប្រឌិតតាមផ្នែករៀងៗខ្លួន ក្នុងការថែរក្សាអនាម័យ បង្កើតបរិយាកាស និងខ្យល់បរិសុទ្ធតាមរយៈការរៀបចំសួន ដាំដើមឈើ ទីកន្លែងសម្រាប់សម្រាក និងអង្គុយលេង (ដែលបានពីការចូលរួមរបស់បុគ្គលិក និងសប្បុរសជន)។

### ៣.១.២.១.៤. អ្នកផ្តល់សេវាផ្នែកជួរមុខមានចំនួនគ្រប់គ្រាន់ និងមានវត្តមាននៅក្នុងពេលបំពេញការងារ

នៅផ្នែកជួរមុខ (កន្លែងបែងចែកអ្នកជំងឺ ឬទ្រីយ៉ា) មានបុគ្គលិកទទួលបន្ទុកផ្នែកជួរមុខគ្រប់គ្រាន់ដោយមានចំនួន ៤រូប និងប្រចាំការ ២៤ម៉ោង (តាមរយៈការផ្លាស់វេនគ្នា) ដែលបុគ្គលិកទាំងអស់សុទ្ធតែជាអ្នកបច្ចេកទេស មានសមត្ថភាពអាចផ្តល់នូវព័ត៌មានជាច្រើនពាក់ព័ន្ធនឹងសេវារបស់មន្ទីរពេទ្យ និងអាចដឹងពីស្ថានភាពអ្នកជំងឺក្នុងកម្រិតបឋម ព្រមទាំងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងវិហ្វរអ្នកជំងឺ ដែលមកប្រើប្រាស់សេវារបស់មន្ទីរពេទ្យ ដើម្បីធ្វើការបែងចែកទៅផ្នែកជំនាញណាមួយនៃមន្ទីរពេទ្យ។

### ៣.១.២.២. នីតិវិធី និងលក្ខខណ្ឌ

ចំណុចនេះលើកឡើងអំពី ១.នីតិវិធីនៃការផ្តល់សេវា ២.ទម្រង់បែបបទមានលក្ខណៈងាយយល់ និងងាយបំពេញ និង ៣.អ្នកប្រើប្រាស់សេវាអាចចូលយកសេវាដោយគ្មានការរំខានពីអន្តរការី។

#### ៣.១.២.២.១. នីតិវិធីនៃការផ្តល់សេវា

ដើម្បីផ្តល់ភាពងាយស្រួលជូនអ្នកប្រើប្រាស់សេវា មន្ទីរពេទ្យមានការរៀបចំជាផ្ទាំងបង្ហាញដល់អ្នកប្រើប្រាស់សេវាអំពីវិហ្វូរឬចរន្តនៃការផ្តល់សេវា ឬបណ្តាកន្លែងដែលអ្នកជំងឺនឹងទទួលបានសេវានៅក្នុងដំណើរការនៃការទទួលសេវាពីមន្ទីរពេទ្យខេត្តកោះកុង នៅផ្នែកជួរមុខរបស់មន្ទីរពេទ្យ។ ដើម្បីប្រើប្រាស់សេវារបស់មន្ទីរពេទ្យខេត្តកោះកុង អ្នកប្រើ-ប្រាស់សេវាត្រូវឆ្លងកាត់នីតិវិធីដូចខាងក្រោម÷

- **ករណីអ្នកជំងឺធម្មតា÷** ពេលធ្វើដំណើរចូលទៅក្នុងមន្ទីរពេទ្យ អ្នកប្រើប្រាស់សេវាត្រូវឆ្ពោះទៅបន្ទប់លេខ១ (កន្លែងបែងចែកអ្នកជំងឺ ឬទ្រីយ៉ា) រួចបន្តទៅបន្ទប់លេខ២ (កន្លែងចុះឈ្មោះ) ជាបន្ទាប់ទៅបន្ទប់ពិគ្រោះជំងឺ បន្ទាប់មកបើក្នុងករណីត្រូវទទួលការសម្រាកព្យាបាលនៅមន្ទីរពេទ្យ អ្នកជំងឺត្រូវទៅបន្ទប់សម្រាកព្យាបាលនៅតាមផ្នែក។ បើក្នុងករណីអ្នកជំងឺមិនត្រូវសម្រាកទេនោះ គឺត្រូវបន្តទៅកន្លែងបង់ថ្លៃសេវា (ការបង់សេវាត្រូវបានគិតទៅតាមប្រភេទអ្នកជំងឺដែលបង់លុយធម្មតា អ្នកប្រើប័ណ្ណ ប.ស.ស និងប័ណ្ណមូលនិធិសមធម៌) និងចុងក្រោយត្រូវទៅបន្ទប់ឱសថស្ថានដើម្បីបើកថ្នាំមុនចាកចេញពីមន្ទីរពេទ្យ។
- **ករណីសង្គ្រោះបន្ទាន់÷** អ្នកជំងឺនឹងត្រូវបញ្ជូនទៅកាន់បន្ទប់សង្គ្រោះបន្ទាន់ ដើម្បីទទួលបានការសង្គ្រោះភ្លាមៗ បន្ទាប់មកត្រូវបញ្ជូនទៅបន្ទប់សម្រាកព្យាបាល។ បន្ទាប់ពីជាសះស្បើយ អ្នកជំងឺត្រូវទៅបន្ទប់បង់ថ្លៃសេវា និងចុងក្រោយត្រូវទៅបន្ទប់ឱសថស្ថានដើម្បីបើកថ្នាំមុននឹងចាកចេញពីមន្ទីរពេទ្យ។

- **ករណីស្ថានភាពជំងឺដែលមន្ទីរពេទ្យខេត្តកោះកុងមិនអាចព្យាបាលបាន÷** មន្ទីរពេទ្យត្រូវធ្វើការទំនាក់ទំនង និងរៀបចំលិខិតបញ្ជូនទៅមន្ទីរពេទ្យគោលដៅ និងបញ្ជូនអ្នកជំងឺតាមរថយន្តគិលានសង្គ្រោះដើម្បីទទួលការព្យាបាលបន្ត។
- រាល់អ្នកជំងឺកំពុងសម្រាកពេទ្យទាំងអស់មិនតម្រូវឱ្យទូទាត់បង់សេវាព្យាបាលនោះទេ ការបង់សេវាទៅតាមប្រភេទនីមួយៗ(ការបង់ប្រាក់ដោយខ្លួនឯង ការប្រើបាស់ប័ណ្ណមូលនិធិសមធម៌ ការប្រើប្រាស់ប័ណ្ណ ប.ស.ស ឬការលើកលែងការបង់ថ្លៃសេវា) លុះត្រាតែពួកគាត់ត្រូវអនុញ្ញាតឱ្យចេញពីមន្ទីរពេទ្យក្រោយព្យាបាលរួចរាល់ ។

#### ៣.១.២.២.២. ទម្រង់បែបបទមានលក្ខណៈងាយយល់ និងងាយបំពេញ

ទម្រង់បែបបទ ឬឯកសារនានាដែលត្រូវបំពេញដើម្បីប្រើប្រាស់សេវារបស់មន្ទីរពេទ្យ គឺប្រើប្រាស់ស្របទៅតាមគំរូស្តង់ដាររបស់ក្រសួងសុខាភិបាល។ បុគ្គលិកមន្ទីរពេទ្យតែងតែជួយសម្របសម្រួលដល់អ្នកប្រើប្រាស់ ដោយរាល់ការបំពេញទម្រង់បែបបទ ឬឯកសារទាំងអស់គឺអ្នកផ្តល់សេវានៅផ្នែកជួរមុខតែងតែជួយបំពេញជំនួស។ សម្រាប់អ្នកប្រើប្រាស់សេវាដែលមិនចេះអក្សរ បុគ្គលិកពេទ្យតែងតែអានឱ្យស្តាប់ មុននឹងបុគ្គលិកពេទ្យចាប់ផ្តើមជួយបំពេញបែបបទនានាក្នុងដំណើរការប្រើប្រាស់សេវារបស់មន្ទីរពេទ្យ។

#### ៣.១.២.២.៣. អ្នកប្រើប្រាស់សេវាអាចចូលទទួលសេវាដោយគ្មានការរំខានពីអន្តរការី

ការប្រើប្រាស់សេវានៅមន្ទីរពេទ្យខេត្តកោះកុង គ្មានការរំខានពីអន្តរការីគ្រប់រូបភាពជាច្រើនឆ្នាំមកហើយ។ ថ្នាក់ដឹកនាំមន្ទីរពេទ្យ តែងតែក្រើនរំលឹក និងណែនាំដល់បុគ្គលិកក្នុងមន្ទីរពេទ្យទាំងអស់ក្នុងពេលប្រជុំ ហាមមិនឱ្យមានជាដាច់ខាតនូវការបង្កើតឱ្យមានការរំខានពីអន្តរការីក្នុងដំណើរផ្តល់សេវារបស់មន្ទីរពេទ្យ បើរកឃើញថាមានបុគ្គលិករូបណាប្រព្រឹត្តបំពាននោះនឹងមានវិធានការដាក់ទណ្ឌកម្ម។ ដោយធ្វើលិខិតអញ្ជើញមកឆ្លើយបំភ្លឺ ប្រសិនបើរកឃើញថាពិតជាបានប្រព្រឹត្តខុសមែន នឹងត្រូវធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរនៅចំពោះមុខគណៈកម្មការវិន័យ និងទណ្ឌកម្ម ប៉ុន្តែបើករណីបុគ្គលិកនោះនៅតែបន្ត ប្រព្រឹត្ត

ខុសទៀត គណៈកម្មការវិន័យ និងទណ្ឌកម្មនឹងដាក់ទណ្ឌកម្មជាបន្តបន្ទាប់ស្របទៅតាមស្មារតីនៃបទប្បញ្ញត្តិច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។

### ៣.១.៣. ភាពយកចិត្តទុកដាក់ក្នុងការទទួលអ្នកប្រើប្រាស់សេវា

ភាពយកចិត្តទុកដាក់ក្នុងការទទួលអ្នកប្រើប្រាស់សេវា សំដៅដល់សមត្ថភាពរបស់ក្រសួង ស្ថាប័ន និងអ្នកផ្តល់សេវាសាធារណៈក្នុងការប្រើប្រាស់មធ្យោបាយ និងនីតិវិធីការងារដើម្បីដោះស្រាយ ឬឆ្លើយទៅនឹងសំណូមពររបស់អ្នកប្រើប្រាស់សេវាសាធារណៈ។ ភាពយកចិត្តទុកដាក់ក្នុងការទទួលអ្នកប្រើប្រាស់សេវាមានលក្ខណៈវិនិច្ឆ័យដូចជា ១.ការទទួលអ្នកប្រើប្រាស់សេវា ២.យន្តការសម្របសម្រួល និង ៣.វិធានការកែលម្អ។

#### ៣.១.៣.១. ការទទួលអ្នកប្រើប្រាស់សេវា

នៅចំណុចនេះ មានការលើកឡើងអំពី ១.អ្នកផ្តល់សេវាមានភាពរួសរាយរាក់ទាក់ មានសុជីវធម៌ទាំងអាកប្បកិរិយា និងពាក្យសំដី ២.ការពាក់ឯកសណ្ឋាន និងស្លាកឈ្មោះសម្គាល់ខ្លួនជាប្រចាំ និង ៣.ការរៀបចំឱ្យមានការិយាល័យ តុ ឬកន្លែងសម្រាប់ផ្តល់ព័ត៌មាន និងផ្តល់ការបំភ្លឺផ្សេងៗពាក់ព័ន្ធនឹងសេវាសាធារណៈរបស់អង្គភាព។

##### ៣.១.៣.១.១. អ្នកផ្តល់សេវាមានភាពរួសរាយរាក់ទាក់ មានសុជីវធម៌ទាំងអាកប្បកិរិយា និងពាក្យសំដី

ក្រុមសីលធម៌របស់គ្រូពេទ្យ[១១] តែងតែត្រូវបានថ្នាក់ដឹកនាំ និងប្រធានផ្នែកនីមួយៗលើកឡើងជារៀងរាល់កិច្ចប្រជុំប្រចាំខែរបស់មន្ទីរពេទ្យ និងកិច្ចប្រជុំប្រចាំថ្ងៃរបស់បណ្តាផ្នែកនីមួយៗដើម្បីឱ្យបុគ្គលិកម្នាក់ៗត្រូវប្រកាន់ខ្ជាប់ជានិច្ច។ ដូច្នេះទើបគ្រប់បុគ្គលិកចាប់តាំងពីថ្នាក់ក្រោមរហូតដល់ថ្នាក់ដឹកនាំ ជាពិសេសអ្នកផ្តល់សេវាផ្នែកជួរមុខរបស់មន្ទីរពេទ្យខេត្តកោះកុង មានភាពរួសរាយរាក់ទាក់ មានអាកប្បកិរិយាល្អ មានសុជីវធម៌ ក្នុងការស្វាគមន៍ដល់អ្នកប្រើប្រាស់សេវា។

[១១] អនុក្រឹត្យលេខ ៦១ អនក្រ.បក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៣ ស្តីពីក្រមសីលធម៌របស់គ្រូពេទ្យ

កត្តាជោគជ័យដែលនាំឱ្យបុគ្គលិកទាំងអស់របស់មន្ទីរពេទ្យខេត្តកោះកុងមានភាពរួសរាយរាក់ទាក់ មានអាកប្បកិរិយាល្អ មានសុជីវធម៌ ក្នុងការស្វាគមន៍ដល់អ្នកប្រើប្រាស់សេវា ព្រោះមានកត្តាភាពជាគំរូរបស់ថ្នាក់ដឹកនាំដែលបានប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួន ស្របតាមក្រមសីលធម៌របស់គ្រូពេទ្យក្នុងការបំពេញភារកិច្ចរបស់ខ្លួនចំពោះអ្នកប្រើប្រាស់សេវា និងកត្តាលើកទឹកចិត្តដល់បុគ្គលិកទាំងអស់។ ករណីបុគ្គលិកមានសុជីវធម៌ មានអាកប្បកិរិយាល្អ និងរួសរាយរាក់ទាក់ ជាកត្តាធ្វើឱ្យប្រជាពលរដ្ឋមកប្រើសេវារបស់មន្ទីរពេទ្យកាន់តែច្រើន នឹងនាំឱ្យចំណូលសេវាហិរញ្ញប្បទាន របស់មន្ទីរពេទ្យមានការកើនឡើង នោះមន្ទីរពេទ្យនឹងមានថវិកាកាន់តែច្រើនដើម្បីឧបត្ថម្ភលើកទឹកចិត្តកាន់តែច្រើនដល់បុគ្គលិកម្នាក់ៗ។

### ៣.១.៣.១.២. ការពាក់ឯកសណ្ឋាន និងស្លាកឈ្មោះសម្គាល់ខ្លួនជាប្រចាំ

បុគ្គលិកទាំងអស់របស់មន្ទីរពេទ្យខេត្តកោះកុងតែងតែពាក់ឯកសណ្ឋាន និងពាក់ស្លាកឈ្មោះសម្គាល់ខ្លួនជាប្រចាំក្នុងពេលបំពេញការងារស្របទៅតាមការណែនាំរបស់ថ្នាក់ដឹកនាំ និងស្មារតីនៃបទបញ្ជាផ្ទៃក្នុងរបស់មន្ទីរពេទ្យ។ ឯកសណ្ឋានរបស់បុគ្គលិកដែលបំពេញការងារនៅក្នុងមន្ទីរពេទ្យត្រូវបានបែងចែកតាមប្រភេទដូចតទៅ÷ ឯកសណ្ឋានបុគ្គលិករដ្ឋបាល ឯកសណ្ឋានវេជ្ជបណ្ឌិត ឯកសណ្ឋានបុគ្គលិកថែទាំ ឯកសណ្ឋានឆ្មប ឯកសណ្ឋានបុគ្គលិកវះកាត់ ឯកសណ្ឋានបុគ្គលិកអនាម័យ ឯកសណ្ឋានអ្នកបើកបរ និងឯកសណ្ឋានសន្តិសុខ។

### ៣.១.៣.១.៣. ការរៀបចំឱ្យមានការិយាល័យ ឬ កន្លែងសម្រាប់ផ្តល់ព័ត៌មាន និងផ្តល់ការបំភ្លឺផ្សេងៗពាក់ព័ន្ធនឹងសេវាសាធារណៈរបស់អង្គភាព

មន្ទីរពេទ្យខេត្តកោះកុង មានរៀបចំនូវទីកន្លែងសម្រាប់ផ្តល់ព័ត៌មាន និងផ្តល់ការបំភ្លឺផ្សេងៗពាក់ព័ន្ធនឹងសេវារបស់មន្ទីរពេទ្យយ៉ាងសមរម្យចំនួន ២កន្លែង ដោយ ១កន្លែងនៅផ្នែកបែងចែកជំងឺ និង១កន្លែងទៀតនៅផ្នែកពិគ្រោះជំងឺក្រៅ។ សម្ភារៈដែលបានរៀបចំនៅកន្លែងផ្តល់ព័ត៌មានរួមមាន ទែម៉ូម៉ែត្រ ឧបករណ៍វាស់សំពាធឈាម ឧបករណ៍វាស់

អុកស៊ីហ្សែនក្នុងឈាម ក្រដាសបែងចែកអ្នកជំងឺ រូបភាពគំរូ (ប័ណ្ណសុខភាព ប័ណ្ណមូលនិធិសមធមិ ប័ណ្ណ ប.ស.ស) ដើម្បីបង្ហាញអ្នកប្រើប្រាស់សេវានៅពេលមានចម្ងល់ពីការទទួលយកសេវានៅមន្ទីរពេទ្យ។

### ៣.១.៣.២. យន្តការសម្របសម្រួល

មន្ទីរពេទ្យខេត្តកោះកុងបានយកចិត្តទុកដាក់ជាខ្លាំង លើអ្នកប្រើប្រាស់សេវាដែលជាជនពិការ ជនចាស់ជរា កុមារ ស្ត្រីមានផ្ទៃពោះ ឬមានកូនតូច ដោយមន្ទីរពេទ្យតែងតែជួយសម្របសម្រួលគ្រប់រូបភាពដើម្បីឱ្យអ្នកប្រើប្រាស់សេវាដែលមានលក្ខណៈខាងលើ អាចចូលទៅប្រើប្រាស់សេវារបស់មន្ទីរពេទ្យបាន តាមរយៈ÷

- ការរៀបចំរទេះរុញនិងជួយរុញរទេះដឹកអ្នកជំងឺ មានឈើច្រត់និងមានការជួយលើកឬជួយគ្រាអ្នកជំងឺ មានកៅអីអង្គុយរង់ចាំ មានការរៀបចំផ្លូវដែលមានជម្រាលសម្រាប់ជនពិការជាដើម
- ទោះបីជាការប្រើប្រាស់សេវារបស់មន្ទីរពេទ្យតម្រូវឱ្យមានការអង្គុយរង់ចាំការចាប់លេខ ប៉ុន្តែ ក៏នៅមានករណីសម្របសម្រួលលើកលែងចំពោះជនចាស់ជរា ស្ត្រីមានផ្ទៃពោះ ស្ត្រីមានកូនតូច កុមារ ជនពិការ ឬព្រះសង្ឃជាដើម អាចចូលទៅចុះឈ្មោះមុនអ្នកប្រើប្រាស់សេវាដែលបានចាប់លេខផងដែរ
- ក្នុងករណីខ្លះអ្នកប្រើប្រាស់សេវាគ្មានឯកសារតម្រូវនានាដែលត្រូវបានកំណត់ មន្ទីរពេទ្យនៅតែទទួលស្វាគមន៍ និងផ្តល់ការបម្រើសេវាជូនពួកគាត់ផងដែរ
- ចំពោះរាល់ការបំពេញបែបបទនានាត្រូវបានមន្ត្រីនៅផ្នែកជួរមុខសម្របសម្រួលជួយបំពេញជំនួសអតិថិជនដែលទៅប្រើប្រាស់សេវារបស់មន្ទីរពេទ្យ និងជាពិសេសអ្នកដែលមិនចេះអក្សរ
- ក្រៅពីមានយន្តការសម្របសម្រួលចំពោះក្រុមគោលដៅខាងលើ មន្ទីរពេទ្យក៏មានយន្តការសម្របសម្រួលដោយផ្អែកលើករណីជាក់ស្តែងជាច្រើនទៀត ដូចជាករណីកម្មករជួលសន្លប់ជាច្រើននាក់ យោងតាមសភាពការណ៍បន្ទាន់បុគ្គលិកមន្ទីរពេទ្យ

ទាំងអស់សហការគ្នាចេញទៅជួយលើក រុញ ឬសែង ដើម្បីបញ្ជូនទៅបន្ទប់សម្រាកព្យាបាលភ្លាមៗ។ យន្តការសម្របសម្រួលទាំងនេះមិនត្រូវបានអ្នកដែលមកប្រើ-ប្រាស់សេវាទូទៅ ធ្វើការរិះគន់អំពីករណីលើកលែងទាំងនោះទេ ផ្ទុយទៅវិញយន្តការទាំងនេះទទួលបានការគាំទ្រយ៉ាងពេញទំហឹងពីអ្នកប្រើប្រាស់សេវាទាំងអស់។

### ៣.១.៣.៣. វិធានការកែលម្អ

ដើម្បីធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាសាធារណៈ និងបង្កើននូវទំនុកចិត្តពីអ្នកប្រើប្រាស់សេវា មន្ទីរពេទ្យខេត្តកោះកុង បានបង្កើតយន្តការត្រួតពិនិត្យ កែលម្អ និងធ្វើបច្ចុប្បន្នកម្មលើដំណើរការ និងនីតិវិធីនៃការផ្តល់សេវាសាធារណៈ ព្រមទាំងអនុវត្តវិធានការកែលម្អការផ្តល់សេវាទៅតាមមតិកែលម្អរបស់អ្នកប្រើប្រាស់សេវា។ ជារៀងរាល់ខែ តាមផ្នែកនីមួយៗ មានបើកកិច្ចប្រជុំលើកកម្ពស់គុណភាពនៅតាមផ្នែក ដោយមានការចូលរួមពីប្រធានផ្នែក និងបុគ្គលិក ដើម្បីពិនិត្យទៅលើលទ្ធផលការងារ កំណត់បញ្ហាប្រឈមរបស់ផ្នែក និងឆ្លើយតបទៅសំណូមពរ មតិយោបល់ និងការរិះគន់ដើម្បីស្តាបនានានារបស់ប្រជាពលរដ្ឋដែលបានមកពីការបើកប្រអប់សំបុត្រ ទំព័រហ្វេសប៊ុក (Facebook) ឬប្រភពផ្សេងៗទៀត (ដូចជាតាមរយៈផ្ទាល់មាត់ ឬទូរស័ព្ទជាដើម) ព្រមទាំងពិភាក្សាដើម្បីសម្រេចដាក់ចេញនូវដំណោះស្រាយចំពោះរាល់បញ្ហាប្រឈម និងឆ្លើយតប ឬបកស្រាយបំភ្លឺរាល់សំណូមពរ មតិយោបល់ ឬបណ្តឹងតវ៉ារបស់ប្រជាពលរដ្ឋទាំងនោះ។ ក្រោយពីកិច្ចប្រជុំក្រុមការងារលើកកម្ពស់គុណភាពនៅតាមផ្នែករួច ទើបមានកិច្ចប្រជុំក្រុមការងារលើកកម្ពស់គុណភាព និងសុវត្ថិភាពថ្នាក់មន្ទីរពេទ្យ (Quality Improvement Team) ដើម្បីប្រមូលបញ្ហាប្រឈមផ្សេងៗ និងដំណោះស្រាយ ព្រមទាំងបណ្តាសំណូមពរ មតិយោបល់ ឬបណ្តឹងតវ៉ារបស់ប្រជាពលរដ្ឋ ដែលបានស្នើដោយផ្នែកនីមួយៗ ដើម្បីដាក់បន្តពិភាក្សា និងសម្រេច ក្នុងគោលបំណងសំយោគកំណត់បញ្ហាជាក់ស្តែង និងបញ្ហាអាទិភាព និងដាក់ចេញយន្តការដោះស្រាយផ្អែកលើលទ្ធភាពរបស់មន្ទីរពេទ្យ និងឈានដល់ការកៀរគរធនធាន និងកិច្ចសហប្រតិបត្តិការពីសហគមន៍ អាជ្ញាធរមូលដ្ឋាន ឬដៃគូអភិវឌ្ឍ ដើម្បី

សហការរៀបចំយន្តការដោះស្រាយ កែលម្អការផ្តល់សេវា និងអភិវឌ្ឍន៍មន្ទីរពេទ្យឱ្យកាន់តែប្រសើរឡើង។ បន្ទាប់ពីសម្រេចនិងឯកភាពក្នុងកិច្ចប្រជុំក្រុមការងារលើកកម្ពស់គុណភាពនិងសុវត្ថិភាពមន្ទីរពេទ្យ អង្គប្រជុំត្រូវធ្វើសំណើឆ្លងការសម្រេចពីគណៈគ្រប់គ្រងមន្ទីរពេទ្យ និងត្រូវស្នើសុំការសម្រេចឯកភាពពីមន្ទីរសុខាភិបាលខេត្ត ឬអាជ្ញាធរថ្នាក់ខេត្ត បើក្នុងករណីបញ្ហានោះហួសពីសមត្ថកិច្ចរបស់មន្ទីរពេទ្យ។

### ៣.១.៤. ការផ្តល់សេវាតាមគោលការណ៍កំណត់ និងអភិបាលកិច្ចល្អ

ការផ្តល់សេវាតាមគោលការណ៍កំណត់ និងអភិបាលកិច្ចល្អ សំដៅដល់អង្គភាពផ្តល់សេវាសាធារណៈ ត្រូវមានសមត្ថភាពក្នុងការអនុវត្តការងារឱ្យទទួលបានលទ្ធផលខ្ពស់ ដោយប្រើប្រាស់ធនធានដែលមានស្រាប់ឱ្យអស់លទ្ធភាព។

#### ៣.១.៤.១. ផ្តល់សេវាតាមគោលការណ៍កំណត់

មន្ទីរពេទ្យខេត្តកោះកុងជាមន្ទីរពេទ្យផ្តល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត២ (CPA2) ដែលបានអនុវត្តស្របទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សេចក្តីសម្រេច ឬពិធីសារជាតិនានា ដែលបានចេញដោយរាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល ជាពិសេសបានអនុវត្តការផ្តល់សេវាសាធារណៈស្របទៅតាមសេចក្តីណែនាំស្តីពីសំណុំសកម្មភាពបង្គ្រប់សម្រាប់អភិវឌ្ឍន៍មន្ទីរពេទ្យបង្អែក ឆ្នាំ២០១៤ (Guideline CPA) របស់ក្រសួងសុខាភិបាល។ មន្ទីរពេទ្យតែងតែអនុវត្តទៅតាមគោលការណ៍ណែនាំ ឬពិធីសារជាតិថ្មីៗរបស់ក្រសួងសុខាភិបាល ជាក់ស្តែងដូចជា ករណីជំងឺកូវីដ-១៩ ក្រសួងបានចេញពិធីសារកាលពីខែកុម្ភៈ ដើម្បីប្រើប្រាស់ថ្នាំបង្ការ និងប្រឆាំងវីរុស ក្នុងការទប់ស្កាត់និងព្យាបាលអ្នកឆ្លងជំងឺកូវីដ-១៩ និងការរក្សាអនាម័យដើម្បីបង្ការកុំឱ្យឆ្លងជំងឺកូវីដ-១៩។ ថ្នាក់ដឹកនាំមន្ទីរពេទ្យ មិនត្រឹមតែអនុវត្តទៅតាមពិធីសារជាតិតែប៉ុណ្ណោះទេ ថែមទាំងខិតខំស្រាវជ្រាវដើម្បីរកវិធីសាស្ត្រព្យាបាលអ្នកជំងឺកូវីដ-១៩ រហូតដល់ជាសះស្បើយ ដោយបានប្រើប្រាស់បន្ថែមនូវថ្នាំបង្កើនប្រព័ន្ធភាពស៊ាំ និងវីតាមីន និងវិធីសាស្ត្រអប់រំផ្លូវចិត្ត និងលើកទឹកចិត្តអ្នកជំងឺជាប្រចាំ។

ជំពូកទី៣

យន្តការការវាយតម្លៃការផ្តល់សេវារបស់មន្ទីរពេទ្យមួយចំនួនត្រូវបានដាក់ឱ្យអនុវត្ត ដើម្បីពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវារបស់មន្ទីរពេទ្យខេត្តកោះកុង ដែលមានដូចខាងក្រោម÷

ទី១. ទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាល អនុវត្តនូវគម្រោងលើកកម្ពស់គុណភាព និងសមធម៌សុខាភិបាល (ហៅកាត់ថា “H-EQIP”) មានគោលបំណងជាក់លាក់ធ្វើឱ្យប្រសើរឡើងនូវការទទួលបានសេវាសុខាភិបាលប្រកបដោយសមភាពដល់ប្រជាពលរដ្ឋក្រីក្រ។ ការវាយតម្លៃនេះគឺបានប្រើវិធីសាស្ត្រចុះផ្ទៀងផ្ទាត់ឯកសាររបស់មូលដ្ឋានសុខាភិបាលដើម្បី ធានាថាការបំពេញឯកសារមានលក្ខណៈត្រឹមត្រូវ ការចុះសម្ភាសន៍អ្នកជំងឺក្រីក្រនៅតាមមូលដ្ឋានសុខាភិបាល និងនៅតាមគេហដ្ឋានរបស់អ្នកជំងឺផ្ទាល់ ដោយប្រើប្រាស់បញ្ជីសំណួរ របាយការណ៍ហិរញ្ញវត្ថុ ដើម្បីប្រមូលព័ត៌មានអំពីការផ្តល់សេវា គុណភាពសេវា អាកប្បកិរិយារបស់គ្រូពេទ្យ ការស្នើសុំនិងទទួលយកប្រាក់ក្រៅផ្លូវការដោយអ្នកផ្តល់សេវា ជាដើម។

ទី២. ក្រុមការងារវាយតម្លៃគុណភាពសេវាថ្នាក់មន្ទីរសុខាភិបាលត្រូវចុះមកធ្វើការវាយតម្លៃប្រចាំត្រីមាសនៅមន្ទីរពេទ្យ ដែលមានសមាសភាពមកពីមន្ទីរសុខាភិបាលខេត្តនានាក្រៅពីខេត្តកោះកុង តាមកាលវិភាគរបស់ក្រសួងសុខាភិបាលដែលបានកំណត់ដោយបានធ្វើការវាយតម្លៃលើផ្នែកចំនួន៣ រួមមាន (១) គុណភាពរចនាសម្ព័ន្ធ (២) គុណភាពដំណើរការ និង (៣) គុណភាពនៃលទ្ធផល ដែលផ្នែកទី៣នេះតម្រូវឱ្យមានការសម្ភាសជាមួយអ្នកប្រើប្រាស់សេវាក្នុងរង្វង់ ១០នាក់ តាមរយៈការប្រើប្រាស់ទូរស័ព្ទ។ ជាក់ស្តែងការវាយតម្លៃគុណភាពប្រចាំត្រីមាសរបស់មន្ទីរពេទ្យខេត្តកោះកុងក្នុងត្រីមាសទី៤ ឆ្នាំ២០១៩ ទទួលបាន ៩៤,២៥% និង

ទី៣. ការរៀបចំដាក់ប្រអប់សំបុត្រ និងទម្រង់លិខិតបញ្ចេញមតិយោបល់ និងសំណូមពររបស់អតិថិជននៅតាមបណ្តាផ្នែកនីមួយៗ ដើម្បីឱ្យអតិថិជនអាចបង្ហាញពីភាពពេញចិត្ត ឬមិនពេញចិត្ត និងមានមតិយោបល់ ឬសំណូមពរផ្សេងៗចំពោះមន្ទីរពេទ្យ។

### ៣.១.៤.២. សេវាផ្តល់មានអភិបាលកិច្ចល្អ

មន្ទីរពេទ្យព្យាយាមប្រើធនធានឱ្យអស់លទ្ធភាពទាំងធនធានមនុស្ស និងសម្ភារៈស្របទៅតាមសេចក្តីណែនាំស្តីពីសំណុំសកម្មភាពបង្គ្រប់ សម្រាប់អភិវឌ្ឍន៍មន្ទីរពេទ្យបង្អែក ឆ្នាំ២០១៤ (Guideline CPA) របស់ក្រសួងសុខាភិបាល។ ដូច្នេះគ្រូពេទ្យ ឬបុគ្គលិកម្នាក់អាចទទួលបន្ទុកការងារ ២ ឬ ៣មុខងារ ក្នុងផ្នែកនីមួយៗប្រកបដោយប្រសិទ្ធភាព ដោយត្រូវទទួលការបណ្តុះបណ្តាលទៅលើផ្នែកជំនាញដែលនឹងត្រូវទទួលបន្ទុកបន្ថែម និងអនុវត្តវិធីសាស្ត្រផ្លាស់វេនគ្នាដើម្បីប្រចាំការនៅមន្ទីរពេទ្យ ដែលជាហេតុធ្វើឱ្យមន្ទីរពេទ្យមានបុគ្គលិកគ្រប់គ្រាន់ដើម្បីបំពេញការងារ និងបម្រើសេវាជូនប្រជាពលរដ្ឋ។

មន្ទីរពេទ្យខេត្តកោះកុងបានរៀបចំនូវយន្តការ ដែលអាចផ្តល់ឱកាស និងជំរុញឱ្យមានការចូលរួមពីអ្នកប្រើប្រាស់សេវា ដើម្បីលើកកម្ពស់សេវាប្រកបដោយអភិបាលកិច្ចល្អ តាមរយៈការដាក់ប្រអប់សំបុត្រ ការប្រើប្រាស់ទំព័រហ្វេសប៊ុក (Facebook Page) ដែលអាចឱ្យអ្នកប្រើប្រាស់សេវាផ្តល់មតិយោបល់ ឬសំណូមពរ ដោយមានក្រុមការងារលើកកម្ពស់គុណភាព និងសុវត្ថិភាពតាមផ្នែក និងថ្នាក់មន្ទីរពេទ្យលើកយកទៅពិនិត្យ និងពិភាក្សាក្នុងអង្គប្រជុំដើម្បីសម្រេច និងកែលម្អតាម ព្រមទាំងមានការរៀបចំជាវេទិកាសាធារណៈដែលផ្តួចផ្តើមឡើងដោយអាជ្ញាធរមូលដ្ឋាន នៅតាមតំបន់ផ្សេងៗដើម្បីធ្វើការអប់រំណែនាំ និងផ្សព្វផ្សាយ ព្រមទាំងលើកទឹកចិត្តដល់ប្រជាពលរដ្ឋដែលបានចូលរួមក្នុងវេទិកាសាធារណៈធ្វើការផ្តល់មតិយោបល់ ឬសំណូមពរផ្សេងៗដល់មន្ទីរពេទ្យ។

### ៣.១.៤.៣. ការទទួលបានវិញ្ញាបនបត្រទទួលស្គាល់គុណភាពសេវាសាធារណៈ

ជាលទ្ធផលនៃការខិតខំបំពេញការងារក្នុងការផ្តល់សេវាសាធារណៈ មន្ទីរពេទ្យខេត្តកោះកុងទទួលបានវិញ្ញាបនបត្រទទួលស្គាល់គុណភាពសេវាសាធារណៈមួយចំនួនដូចខាងក្រោម៖

ជំពូកទី៣

- វិញ្ញាបនបត្រទទួលស្គាល់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូរបស់រាជ-រដ្ឋាភិបាល ដែលទទួលស្គាល់មន្ទីរពេទ្យខេត្តកោះកុង ជាមន្ទីរពេទ្យខេត្តផ្តល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត២ (CPA2) ចំណាត់ថ្នាក់លេខ១ ប្រចាំឆ្នាំ២០១៩
- វិញ្ញាបនបត្រទទួលស្គាល់ មន្ទីរពេទ្យខេត្តកោះកុង ក្នុងការចូលរួមចំណែកអនុវត្តការកែលម្អគុណភាពសេវាសុខាភិបាលតាមរយៈលទ្ធផលនៃការវាយតម្លៃដោយប្រើប្រាស់ឧបករណ៍វាយតម្លៃកម្រិត១ លើកទី២ ឆ្នាំ២០១១ សម្រេចជោគជ័យក្នុងពិន្ទុកម្រិត ៩0% របស់ក្រសួងសុខាភិបាល
- វិញ្ញាបនបត្រទទួលស្គាល់ មន្ទីរពេទ្យខេត្តកោះកុង ក្នុងការចូលរួមចំណែកអនុវត្តការកែលម្អគុណភាពសេវាសុខាភិបាល តាមរយៈលទ្ធផលនៃការវាយតម្លៃដោយប្រើប្រាស់ឧបករណ៍វាយតម្លៃកម្រិត១ លើកទី១ ឆ្នាំ២០០៩ សម្រេចជោគជ័យក្នុងពិន្ទុកម្រិត ៧៦% របស់ក្រសួងសុខាភិបាល
- ប័ណ្ណសរសើរក្នុងការចូលរួម Australian Volunteers for International Development Program ដែលទទួលបានពី Australian Aid ឆ្នាំ២០១៥
- ប័ណ្ណសរសើរសម្រាប់ការចូលរួមបំពេញការងារបានយ៉ាងល្អ ក្នុងកម្មវិធីឆ្លើយតបការរីករាលដាលនៃជំងឺឆ្លងរបស់មហាអនុតំបន់ទន្លេមេគង្គក្រោមជំនួយរបស់ USAID (GMS-RID) ដែលទទួលពី USAID ឆ្នាំ២០១២។

## រូបភាពទី៣÷ ស្តង់ដាសេវាសាធារណៈ



កន្លែងចុះឈ្មោះអ្នកជំងឺ (២០១៨)



ករណីជួយសង្គ្រោះកម្មករជួលសន្លប់ (២០១៨)



គំនូសបំព្រួញរំហូរអ្នកជំងឺ (២០១៨)



)

ទូររក្សាទុកច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត



ការជួយសម្រួលអ្នកជំងឺចាស់ជរា (២០១៩)



កន្លែងបែងចែកអ្នកជំងឺ (ទ្រីយ៉ា២០១៨)

## ៣.២. ស្តង់ដានៃការផ្តល់សេវាសាធារណៈរបស់មន្ទីរពេទ្យខេត្តកោះកុង

### ៣.២.១. ការដឹកនាំ និងការគ្រប់គ្រងមន្ទីរពេទ្យខេត្តកោះកុង

បទពិសោធនិជោគជ័យលើការដឹកនាំ និងគ្រប់គ្រងមន្ទីរពេទ្យខេត្តកោះកុង មានសូចនាករ ៣ផ្នែក សំខាន់ៗដែលត្រូវបានវាយតម្លៃរួមមាន÷ (១)ការរៀបចំផែនការ និងការអនុវត្តផែនការការងារ (២)ការគ្រប់គ្រងប្រព័ន្ធព័ត៌មានសុខាភិបាល និង (៣)ការគ្រប់គ្រងមន្ទីរពេទ្យខេត្តកោះកុង។

#### ៣.២.១.១. ការរៀបចំផែនការ និងអនុវត្តផែនការការងារ

មន្ទីរពេទ្យខេត្តកោះកុងបានបំពេញការងារដោយឈរលើទស្សនៈការងារជាក្រុម។ ក្រុមដំបូងគឺគណៈកម្មការគ្រប់គ្រងមន្ទីរពេទ្យ និងក្រុមបន្ទាប់គឺគណៈកម្មការផ្សេងៗទៀត។ ដូច្នេះដោយយោងតាមគំនិតផ្តួចផ្តើមរបស់ថ្នាក់ដឹកនាំយល់ឃើញថា មន្ទីរពេទ្យគឺជាអង្គភាពមួយដែលអាចរីកចម្រើនទៅបានលុះត្រាតែរៀបចំឱ្យមានចក្ខុវិស័យ បេសកកម្ម និងគោលដៅច្បាស់លាស់សម្រាប់មន្ទីរពេទ្យ។ ហេតុដូច្នេះហើយទើបគណៈកម្មការគ្រប់គ្រងមន្ទីរពេទ្យសម្រេចបង្កើតចក្ខុវិស័យ បេសកកម្ម និងគោលដៅនេះឡើងតាំងពីឆ្នាំ២០១៥ ក៏ប៉ុន្តែមិនទាន់បានទូលំទូលាយ និងច្បាស់លាស់ទេ រហូតទាល់តែមានគម្រោងលើកកម្ពស់គុណភាព និងសមធម៌សុខាភិបាលបង្កើតឡើងក្នុងឆ្នាំ២០១៦ ទើបគណៈកម្មការគ្រប់គ្រងមន្ទីរពេទ្យកែសម្រួលចក្ខុវិស័យ បេសកកម្ម និងគោលដៅឱ្យបានល្អប្រសើរឡើង។

ដំណើរការដំបូងក្នុងការបង្កើតចក្ខុវិស័យ បេសកកម្ម និងគោលដៅនេះឡើងគឺចាប់ផ្តើមពីគណៈកម្មការគ្រប់គ្រងមន្ទីរពេទ្យបានណែនាំឱ្យតាមផ្នែកនីមួយៗធ្វើការប្រជុំដើម្បីបង្កើតចក្ខុវិស័យ បេសកកម្ម និងគោលដៅរៀងៗខ្លួន រួចយកមកប្រជុំរួមជាមួយគណៈកម្មការគ្រប់គ្រងមន្ទីរពេទ្យ ដើម្បីកែលម្អ និងបញ្ចូលគ្នាជាគំនិតរួមមួយក្នុងការបង្កើតជាចក្ខុវិស័យ បេសកកម្ម និងគោលដៅច្បាស់លាស់សម្រាប់មន្ទីរពេទ្យ។

មន្ទីរពេទ្យបង្កើតក្រុមការងាររៀបចំផែនការថវិកា នៅក្រោមការទទួលខុសត្រូវរបស់អនុប្រធានទទួលបន្ទុកមួយរូប ដើម្បីទទួលខុសត្រូវក្នុងការកសាងផែនការរយៈពេលខ្លី និង

រយៈពេលមធ្យម ដើម្បីអភិវឌ្ឍន៍មន្ទីរពេទ្យប្រកបដោយចីរភាព ក្នុងនោះរួមមានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍មន្ទីរពេទ្យ ផែនការយុទ្ធសាស្ត្រថវិកា ៣ឆ្នាំ រំកិល និងផែនការប្រតិបត្តិប្រចាំឆ្នាំនិងថវិកាប្រចាំឆ្នាំ[១២]។

ប្រធានមន្ទីរពេទ្យខេត្តកោះកុងមានគោលបំណងចង់បណ្តុះគំនិតឱ្យប្រធានផ្នែកនីមួយៗចេះគិតគូរថាតើផ្នែកនីមួយៗត្រូវការអភិវឌ្ឍអ្វីខ្លះក្នុងមន្ទីរពេទ្យ ចេះគ្រប់គ្រងសម្ភារៈប្រើប្រាស់ក្នុងផ្នែក ដឹងពីតម្រូវការរបស់ផ្នែករៀងៗខ្លួន និងចេះរៀបចំផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ ផែនការបណ្តុះបណ្តាល បុគ្គលិក និងផែនការបណ្តុះបណ្តាលអប់រំសុខភាពសាធារណៈជូនប្រជាជន។

ហេតុដូច្នេះហើយទើបគណៈគ្រប់គ្រងមន្ទីរពេទ្យបានប្រគល់សិទ្ធិអំណាចដល់ប្រធានផ្នែកនីមួយៗ រៀបចំផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ រួមទាំងផែនការបណ្តុះបណ្តាលអប់រំសុខភាពសាធារណៈជូនប្រជាជន និងផែនការ ៣ឆ្នាំ រំកិលតាមផ្នែករៀងៗខ្លួន។

មន្ទីរពេទ្យខេត្តកោះកុងបានកសាងផែនការយុទ្ធសាស្ត្រថវិកា និងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរពេទ្យដោយសំយោគផែនការសកម្មភាព និងផែនការថវិកាពីគ្រប់ផ្នែកទាំងអស់ ហើយដាក់ជូនគណៈកម្មការគ្រប់គ្រងមន្ទីរពេទ្យពិនិត្យ និងសម្រេចមុនផ្ញើទៅមន្ទីរសុខាភិបាល/ក្រសួងសុខាភិបាល។

ក្នុងដំណើរការរៀបចំផែនការនេះមន្ទីរពេទ្យបានព្យាយាមយកសំណូមពរពីសហគមន៍មកពិភាក្សា និងដាក់បញ្ចូលក្នុងផែនការប្រតិបត្តិរបស់មន្ទីរពេទ្យ។

### ៣.២.១.២. ការគ្រប់គ្រងប្រព័ន្ធព័ត៌មានសុខាភិបាល

ព័ត៌មានត្រឹមត្រូវ មានគុណភាព និងទាន់ពេលវេលា គឺជាឧបករណ៍ដ៏មានសក្តានុពលជួយឱ្យថ្នាក់ដឹកនាំមន្ទីរពេទ្យ និងមន្ត្រីទទួលខុសត្រូវគ្រប់ផ្នែកទាំងអស់ធ្វើការសម្រេចចិត្តបានត្រឹមត្រូវ ក្នុងការលើកកម្ពស់សកម្មភាពនៃការគ្រប់គ្រង និងផ្តល់សេវា ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកជំងឺ ឬអតិថិជន។

[១២] សេចក្តីណែនាំស្តីពីសំណុំសកម្មភាពបង្គ្រប់សម្រាប់អភិវឌ្ឍន៍មន្ទីរពេទ្យបង្អែកឆ្នាំ២០១៤

ជំពូកទី៣

មន្ទីរពេទ្យខេត្តកោះកុងបញ្ចូលទិន្នន័យប្រចាំខែនីមួយៗតាមប្រព័ន្ធព័ត៌មានសុខាភិបាលតាម គេហទំព័រ (HMIS) ដោយមន្ត្រីពីរនាក់ដែលបានទទួលការបណ្តុះបណ្តាល។ ចំពោះដំណើរការក្នុងការបញ្ចូលទិន្នន័យក្នុងប្រព័ន្ធព័ត៌មានសុខាភិបាលនេះ ជាទូទៅតាមផ្នែកមានសៀវភៅបញ្ជីកត់ត្រា និងបញ្ជីសម្រង់ទិន្នន័យប្រចាំថ្ងៃដែលកំណត់ឱ្យប្រើប្រាស់ដោយក្រសួងសុខាភិបាល[១៣]។

ជារៀងរាល់ខែមន្ត្រីដែលទទួលបន្ទុកបញ្ចូលទិន្នន័យបានយកបញ្ជីសម្រង់ទិន្នន័យផ្តល់ជូនផ្នែកដែលពាក់ព័ន្ធ ដើម្បីបូកសរុបទិន្នន័យពីបញ្ជីកត់ត្រានីមួយៗ និងត្រូវធ្វើឡើងនៅថ្ងៃចុងក្រោយនៃខែ (ពីថ្ងៃទី១ ដល់ថ្ងៃចុងក្រោយនៃខែ) រួចហើយទើបបញ្ចូលក្នុងទម្រង់របាយការណ៍ប្រចាំខែសម្រាប់មន្ទីរពេទ្យ (ទម្រង់ HO2)។ មន្ទីរពេទ្យបានបញ្ចូលទិន្នន័យប្រចាំខែនីមួយៗតាមប្រព័ន្ធព័ត៌មានសុខាភិបាលតាមគេហទំព័រ (HMIS) មុនថ្ងៃទី៥ នៃខែបន្ទាប់។

ចំណែកការងារពិនិត្យលទ្ធផលប្រចាំត្រីមាសរបស់មន្ទីរពេទ្យដោយផ្អែកលើប្រព័ន្ធព័ត៌មាន (HO2) រយៈពេល ៣ខែ គឺលោកប្រធានរដ្ឋបាលបានយកទិន្នន័យមកវិភាគ ក្នុងកិច្ចប្រជុំជាមួយប្រធានផ្នែកទាំងអស់ហើយកិច្ចប្រជុំនោះ ប្រព្រឹត្តទៅក្រោយពេលក្រុមការងារវាយតម្លៃគុណភាពសេវាសុខាភិបាលថ្នាក់មន្ទីរសុខាភិបាល (PHD Assessor) ដែលអញ្ជើញមកពីខេត្តផ្សេងៗ បានចុះមកធ្វើការវាយតម្លៃរួច។ កិច្ចប្រជុំនេះមានគោលបំណង ពិនិត្យតាមដានលទ្ធផលប្រចាំខែ និងប្រចាំត្រីមាស ធៀបនឹងគោលដៅប្រចាំឆ្នាំសម្រាប់ធ្វើការវិភាគ និងរកវិធីដោះស្រាយលើចំណុចណាដែលមិនទាន់សម្រេចបានដល់គោលដៅកំណត់ និងធ្វើផែនការកែលម្អគុណភាពសម្រាប់ត្រីមាសបន្ត។

យោងតាមសំណុំឧបករណ៍តាមដានការកែលម្អគុណភាពសេវាសុខាភិបាល (H-EQIP) តម្រូវឱ្យមន្ទីរពេទ្យធ្វើការវិភាគលទ្ធផលប្រចាំត្រីមាសតែ៤ ផ្នែកទេគឺផ្នែកពិគ្រោះជំងឺក្រៅ ផ្នែកជំងឺកុមារ ផ្នែកសម្ភពនិងរោគស្ត្រី និងផ្នែកសង្គ្រោះបន្ទាន់ ប៉ុន្តែថ្នាក់ដឹកនាំមន្ទីរពេទ្យ

[១៣] សេចក្តីណែនាំស្តីពីបញ្ជីកត់ត្រាឆ្នាំ២០១២ នាយកដ្ឋានផែនការ ក្រសួងសុខាភិបាល

ខេត្តកោះកុងបានលើកទឹកចិត្តឱ្យគ្រប់ផ្នែកទាំងអស់ត្រូវធ្វើការវិភាគចំណុចខ្លាំង ចំណុចខ្សោយ ឱកាស ការគំរាមកំហែង (SWOT) ប្រចាំត្រីមាស។

ដូច្នេះនៅមន្ទីរពេទ្យខេត្តកោះកុងតាម ផ្នែកនីមួយៗ ត្រូវចេះវិភាគលទ្ធផលប្រចាំត្រីមាស (SWOT) ដើម្បីកំណត់រកភាពជោគជ័យ បញ្ហាប្រឈម និងសកម្មភាពត្រូវអនុវត្តបន្ត។

ចំពោះមន្ទីរពេទ្យខេត្តកោះកុង ចំណុចខ្លាំងគឺពិនិត្យមើលភាពខ្លាំងទាំងការងារក្នុងផ្នែក និងទំនាក់ទំនងល្អជាមួយផ្នែកផ្សេងៗក្នុងមន្ទីរពេទ្យ។ ចំណុចខ្សោយគឺពិនិត្យមើលភាពខ្សោយរបស់ផ្នែកមានដូចជាកង្វះធនធានមនុស្ស បុគ្គលិកមួយចំនួនមកធ្វើការមិនទៀងទាត់ និងការផ្សព្វផ្សាយរបស់មន្ទីរពេទ្យអំពីសេវាថ្មីៗដែលទើបតែបង្កើតមិនទាន់បានដល់ប្រជាពលរដ្ឋ។ល។

រីឯឱកាសរបស់មន្ទីរពេទ្យដូចជាមន្ទីរពេទ្យមានដៃគូអភិវឌ្ឍច្រើនជួយគាំទ្រថវិកា និងផ្នែកបច្ចេកទេស (ដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិ) មន្ទីរសុខាភិបាល/ ក្រសួងសុខាភិបាល និងអាជ្ញាធរដែនដី ។ល។ ដើម្បីអភិវឌ្ឍន៍មន្ទីរពេទ្យ (ការបណ្ដុះបណ្ដាលទាំងក្នុង និងក្រៅប្រទេស ការបង្វឹក ការគ្រប់គ្រងអភិបាល ការតាមដាន ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ផ្ដល់សម្ភារៈឧបករណ៍ពេទ្យ។ល។)។

ការគំរាមកំហែងគឺកត្តាប្រឈមទាំងឡាយណាដែលកើតមាននៅខាងក្រៅមន្ទីរពេទ្យមានដូចជា÷ ការដាច់ចរន្តអគ្គិសនីញឹកញាប់ពីកន្លែងផ្គត់ផ្គង់ចរន្តអគ្គិសនីខេត្ត ធ្វើឱ្យរំខានដល់ការបំពេញការងារ (វះកាត់សម្រាលកូន) ឬមួយមន្ទីរពេទ្យមានការប្រកួតប្រជែងជាមួយសេវាគ្លីនិកឯកជនជាច្រើន។ ដូច្នេះក្នុងកិច្ចប្រជុំប្រចាំត្រីមាសម្ដងៗ ផ្នែកនីមួយៗបានលើកយកលទ្ធផលដែលបានមកពីការវិភាគមកបង្ហាញក្នុងក្រុមការងារលើកកម្ពស់គុណភាពមន្ទីរពេទ្យដើម្បីរកវិធានការដោះស្រាយ។

ឧទាហរណ៍ជាក់ស្ដែង÷ ឡស៊ីស៊ីមនៅមន្ទីរពេទ្យខេត្តកោះកុងខូចបានជួសជុលម្ដងរួចហើយ ប៉ុន្តែលោកប្រធានរដ្ឋបាលបានលើកផែនការស្នើសុំទៅក្រសួងសុខាភិបាលតាម



ជំពូកទី៣

រយៈមន្ទីរសុខាភិបាលជាទៀងទាត់រៀងរាល់ត្រីមាស រហូតដល់បច្ចុប្បន្នគឺក្រសួងសុខាភិបាលសម្រេចផ្ដល់ជូនឡដល់មន្ទីរពេទ្យ និងមានគម្រោងសាងសង់នៅ ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២០។

### ៣.២.១.៣. ការគ្រប់គ្រងមន្ទីរពេទ្យខេត្តកោះកុង

នៅក្នុងការគ្រប់គ្រង មន្ទីរពេទ្យបានរៀបចំជាកិច្ចប្រជុំតាមដានរួមមាន (១)កិច្ចប្រជុំប្រចាំខែនៃគណៈកម្មការគ្រប់គ្រងមន្ទីរពេទ្យ (២)កិច្ចប្រជុំប្រចាំខែនៃគណៈកម្មការបច្ចេកទេសមន្ទីរពេទ្យ និង (៣)កិច្ចប្រជុំប្រចាំខែនៃគណៈកម្មការហិរញ្ញប្បទានមន្ទីរពេទ្យ។

កិច្ចប្រជុំប្រចាំខែរបស់គណៈកម្មការគ្រប់គ្រងមន្ទីរពេទ្យ ផ្ដោតការពិភាក្សាលើចំណុចសំខាន់ៗចំនួន ៤ គឺ (១)ផ្ដោតលើការគ្រប់គ្រងជាទូទៅ រួមទាំងការគ្រប់គ្រងសម្ភារបរិក្ខារពេទ្យផងដែរ (២)ផ្ដោតលើការគ្រប់គ្រងធនធានមនុស្ស និងការគ្រប់គ្រងថវិការបស់ផ្នែកនីមួយៗ ដោយលើកយកទាំងភាពជោគជ័យ និងបញ្ហាប្រឈមមកដោះស្រាយ (៣)ផ្ដោតលើគុណភាពនៃការថែទាំ និងការត្រួតពិនិត្យការចម្លងរោគក្នុងមន្ទីរពេទ្យ (៤)ផ្ដោតលើបញ្ហាប្រឈមតាមផ្នែកនីមួយៗ។

អង្គប្រជុំក៏បានប្រមូលយកផែនការលើកកម្ពស់គុណភាពតាមផ្នែក និងសំណូមពរមកពិនិត្យ និងដាក់បញ្ចូលក្នុងផែនការលើកកម្ពស់គុណភាពរួមរបស់មន្ទីរពេទ្យ។ កិច្ចប្រជុំនេះក៏បានពិនិត្យតាមដានការអនុវត្តសេចក្ដីសម្រេចនានាដែលបានអនុម័តក្នុងកិច្ចប្រជុំលើកមុន និងដាក់ទិសដៅសម្រាប់ត្រីមាសបន្ទាប់។

គណៈកម្មការបច្ចេកទេស គឺជាគណៈកម្មការមួយដែលជាគ្រឹះដ៏រឹងមាំរបស់មន្ទីរពេទ្យ ហើយ គណៈកម្មការនេះ អាចរីកចម្រើនទៅបាន ទាមទារឱ្យសមាជិកទាំងអស់ត្រូវភ្ជាប់ខ្លួនជាមួយក្រុមការងារលើកកម្ពស់គុណភាពតាមផ្នែកដើម្បីពង្រឹងបច្ចេកទេស ហើយមានតួនាទី (១)ត្រួតពិនិត្យបច្ចេកទេសជាទូទៅ (២)ត្រួតពិនិត្យការប្រើប្រាស់ឱសថសមស្រប (MTC) (៣)ត្រួតពិនិត្យការចម្លងរោគ (IPC) (៤)ត្រូវភ្ជាប់ខ្លួនជាមួយគណៈកម្មការហិរញ្ញប្បទាន (៥)ពិនិត្យមើលលើតម្រូវការបុគ្គលិកបន្ថែមប៉ុន្មាននាក់ទៀត និងទាមទារបណ្ដុះបណ្ដាល

ជំនាញអ្វីខ្លះទៀត។

គណៈកម្មការបច្ចេកទេសបានធ្វើសវនកម្មគ្រប់ករណីស្លាប់ទាំងអស់ ដោយមិនទុកឱ្យលើសពី ៧២ម៉ោង ទេ។ មុនដំបូង សមាជិកគណៈកម្មការបច្ចេកទេសជាតួអង្គមួយក្នុងការអញ្ជើញមន្ត្រីក្នុងផ្នែកដែលមានករណីស្លាប់មកធ្វើសវនកម្ម បន្ទាប់មកគឺ តំណាងមន្ត្រីក្នុងផ្នែកដែលមានករណីស្លាប់កើតឡើងត្រូវទៅធ្វើបទបង្ហាញជូនគណៈកម្មការបច្ចេកទេស ហើយគណៈកម្មការបច្ចេកទេសគឺជាអ្នកដែលរកគន្លឹះដើម្បីដោះស្រាយ និងកែប្រែបញ្ហារបស់មន្ទីរពេទ្យ។

សរុបមកថ្នាក់ដឹកនាំមន្ទីរពេទ្យយល់ឃើញថា មន្ទីរពេទ្យមួយមានគណៈកម្មការបច្ចេកទេសខ្លាំងពូកែ គឺអាស្រ័យលើសមត្ថភាព និងដំណើរការល្អ របស់ក្រុមការងារលើកកម្ពស់គុណភាពតាមផ្នែក។

គណៈកម្មការហិរញ្ញប្បទានមានអនុប្រធានមន្ទីរពេទ្យម្នាក់ ជាអ្នកទទួលខុសត្រូវក្នុងការធ្វើផែនការថវិកាប្រចាំឆ្នាំ ដឹកនាំកិច្ចប្រជុំប្រចាំខែនិងប្រចាំត្រីមាស និងធានាថាការគ្រប់គ្រងចំណូល និងចំណាយរបស់មន្ទីរពេទ្យមានតម្លាភាព និងមានអនុគណៈកម្មការចំនួន៣ទៀតគឺ÷

(១) អនុគណៈកម្មការតាមដាន និងវាយតម្លៃ

(២) អនុគណៈកម្មការផ្គត់ផ្គង់ និងលទ្ធកម្ម

(៣) អនុគណៈកម្មការវិន័យ និងទណ្ឌកម្ម

ក្រុមការងារលើកកម្ពស់គុណភាព និងសុវត្ថិភាពក្នុងមន្ទីរពេទ្យ បើកកិច្ចប្រជុំប្រចាំខែដោយលើកយករបាយការណ៍ និងសំណូមពររបស់ក្រុមការងារលើកកម្ពស់គុណភាពតាមផ្នែកមកប្រជុំរកដំណោះស្រាយ ដើម្បីសំយោគធ្វើជាផែនការរួមរបស់មន្ទីរពេទ្យ។

ក្រៅពីផ្តល់សេវាព្យាបាល និងថែទាំសុខភាពជូនប្រជាពលរដ្ឋ មន្ទីរពេទ្យខេត្តកោះកុងជាមណ្ឌលមួយសម្រាប់បុគ្គលិកសុខាភិបាលនៅតាមមណ្ឌលសុខភាព ប៉ុស្តិ៍សុខភាពនានា មន្ត្រីសុខាភិបាលយោធា និងនិស្សិតនៃសាលាភូមិភាគកំពតចុះធ្វើកម្មសិក្សា។ នាយសាល

ទាំងអស់ ដែលមានតួនាទីជាសមាជិកក្រុមការងារថៃទាំ និងជាគ្រូបង្គោលបណ្តុះបណ្តាល បង្វឹកនិស្សិតកម្មសិក្សាទាំងនោះបានបើកកិច្ចប្រជុំស្តីពីគម្រោងផែនការបណ្តុះបណ្តាល និងដោះស្រាយលើបញ្ហានិស្សិត ព្រមទាំងអនុវត្តការងារបង្ការ និងត្រួតពិនិត្យការចម្លងរោគ ដោយប្រតិបត្តិតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាលឆ្នាំ២០១៧ និងមគ្គុទេសក៍ណែនាំស្តីពីសុវត្ថិភាពនៃការចាក់ថ្នាំឆ្នាំ២០១៤[១៤]។

មន្ទីរពេទ្យ មានឱសថស្ថានសម្រាប់រក្សាទុកដាក់ គ្រប់គ្រង និងចែកចាយឱសថបរិក្ខារ នៅក្នុងមន្ទីរពេទ្យ និងធ្វើការប៉ាន់ប្រមាណអំពីតម្រូវការរៀបចំសំណើសុំឱសថ និងគ្រប់គ្រងការប្រើប្រាស់ ដើម្បីធានាការគ្រប់គ្រងផ្គត់ផ្គង់ឱសថ បរិក្ខារពេទ្យឱ្យបានគ្រប់គ្រាន់សម្រាប់បម្រើសេវានៅក្នុងមន្ទីរពេទ្យ។

ចំពោះដំណើរការគ្រប់គ្រងស្តុកឱសថ មន្ទីរពេទ្យខេត្តកោះកុងបានប្រើប្រាស់សម្រង់ប្រើប្រាស់ប្រចាំថ្ងៃដែលចែកជា ២ផ្នែក ធំៗ (ទី១)ផ្នែកពិគ្រោះជំងឺក្រៅ និង (ទី២)ផ្នែកសម្រាកពេទ្យ។ សម្រង់ប្រើប្រាស់ប្រចាំថ្ងៃត្រូវយកមកបញ្ចូលទិន្នន័យក្នុងប្រព័ន្ធគ្រប់គ្រងឱសថរបស់មន្ទីរពេទ្យ (HOSPDID) ដើម្បីសរុបសម្រង់ការប្រើប្រាស់ឱសថប្រចាំខែ។

បន្ទាប់មកឱសថការីពិនិត្យមើលស្ថានភាពស្តុកឱសថប្រចាំខែដោយផ្ទៀងផ្ទាត់ជាមួយសម្រង់ការប្រើប្រាស់ឱសថប្រចាំខែ គឺការធ្វើសារពើភ័ណ្ឌឱសថប្រចាំខែ។ ឱសថការីក៏បានធ្វើសំណើប្រចាំត្រីមាសដោយគិតជាមធ្យម MOS (month of stock) ឱ្យបាន ១,៥ ព្រោះឱសថស្ថានត្រូវទុកពេលវេលាផ្គត់ផ្គង់ពីឃ្លាំងឱសថកណ្តាល (CMS)។ ក្នុងការថែរក្សាស្តុកឱសថឱ្យមានលំនឹងគឺឱសថការីបានធ្វើសំណើទិញឱសថបន្ថែម ដោយឆ្លងគណៈកម្មការបច្ចេកទេសដោយយោងតាមតម្រូវការជាក់ស្តែងតាមផ្នែក។

ចំពោះនិរន្តរភាពឱសថ គឺមន្ទីរពេទ្យមិនដែលមានដាច់ស្តុកទេ ដោយសារមន្ទីរពេទ្យមានធ្វើការប៉ាន់ប្រមាណឱសថប្រើប្រាស់ប្រចាំខែ ប្រចាំឆ្នាំ និងការធ្វើសារពើភ័ណ្ឌឱសថប្រចាំខែ។

[១៤] មគ្គុទ្ទេសក៍ណែនាំស្តីពីសុវត្ថិភាពនៃការចាក់ថ្នាំឆ្នាំ២០១៤ របស់នាយកដ្ឋានមន្ទីរពេទ្យ នៃក្រសួងសុខាភិបាល

ចំណែកឱសថខូចគុណភាព និងឱសថហួសកាលកំណត់ប្រើប្រាស់គឺប្រមូលទុកដាក់ដោយឡែកនៅក្នុងប្រអប់មួយ ដែលមានកត់សម្គាល់ថាឱសថខូចគុណភាពឬឱសថហួសកាលកំណត់ប្រើប្រាស់ហើយទុកដាក់នៅក្រោមធ្នើ និងមានមន្ត្រីម្នាក់ធ្វើរបាយការណ៍បញ្ជូនមកប្រធានឃ្លាំងឱសថ និងមានការឯកភាពពីលោកប្រធានមន្ទីរពេទ្យ រួចធ្វើសំណើសុំកម្ទេចឱសថនៅការិយាល័យនិយ័តកម្មរបស់មន្ទីរសុខាភិបាល និងបញ្ជូនទៅដុតនៅក្នុងឡរបស់កាកបាទក្រហមនៅរាជធានីភ្នំពេញ។

ឱសថស្ថានមានម៉ាស៊ីនត្រជាក់រក្សាសីតុណ្ហភាព ២៥អង្សាសេ ជានិច្ច ដោយមានទែម៉ូម៉ែត្រសម្រាប់វាស់សីតុណ្ហភាពជាប្រចាំ និងមានប្រព័ន្ធត្រជាក់ស្តង់ដា (សីតុណ្ហភាព ២ ទៅ ៦អង្សាសេ) សម្រាប់ដាក់វ៉ាក់សាំង ក្នុងករណីដាច់ចរន្តអគ្គិសនីម្តងម្កាលមន្ទីរពេទ្យមានម៉ាស៊ីនភ្លើងបំរុង។

ក្រៅពីការគ្រប់គ្រងឱសថមន្ទីរពេទ្យក៏មានការគ្រប់គ្រងឧបករណ៍វេជ្ជសាស្ត្រដែរ។ ការថែទាំ ជួសជុលសម្ភារៈ ឬឧបករណ៍ដែលមិនដំណើរការ ឬខូចខាត គឺជាការចាំបាច់ដែលមន្ទីរពេទ្យមានរោងជាងមួយដែលមានទំហំ៥ម x ៦ម។

ជារៀងរាល់ឆ្នាំ នៅក្នុងខែធ្នូ ក្រុមការងារគ្រប់គ្រងឧបករណ៍វេជ្ជសាស្ត្រមានការរៀបចំធ្វើផែនការប្រចាំឆ្នាំ នៃការថែទាំសម្រាប់រៀងរាល់សប្តាហ៍ នូវឧបករណ៍នីមួយៗ និងមានការកត់ត្រាទុកជារបាយការណ៍ថែទាំ បន្ទាប់ពីអ្នកបច្ចេកទេសបានធ្វើការថែទាំរួច[១៥]។

ការធ្វើរបាយការណ៍ប្រចាំឆមាសដែលអាចវាស់វែងទាំងគុណភាពដំណើរការ និងគុណភាពផ្តល់សេវារបស់ឧបករណ៍នីមួយៗក៏ត្រូវបានក្រុមការងាររៀបចំ និងមានការធ្វើបញ្ជីសារពើភ័ណ្ឌឧបករណ៍វេជ្ជសាស្ត្រជារៀងរាល់ឆ្នាំ។ ចំណែកឧបករណ៍ខូចជួសជុលមិនបាន មន្ទីរពេទ្យទុកដាក់ក្នុងឃ្លាំងដោយអនុវត្តតាមនីតិវិធីនិងគោលការណ៍នៃច្បាប់ក្នុងករណីមានការជម្រះ/លក់។

ពាក់ព័ន្ធនឹងវត្តមានឈាមក្រហម គឺមន្ទីរពេទ្យខេត្តកោះកុងមានឈាមបម្រុងគ្រប់គ្រាន់

[១៥] របាយការណ៍ថែទាំឧបករណ៍វេជ្ជសាស្ត្ររបស់មន្ទីរពេទ្យខេត្តកោះកុង ឆ្នាំ២០១៩

ដែលមានសុវត្ថិភាពបំផុតសម្រាប់ផ្ដល់ឱ្យអ្នកជំងឺដើម្បីសង្គ្រោះជីវិត យោងតាមតម្រូវការចាំបាច់នៃលក្ខខណ្ឌវេជ្ជសាស្ត្រ។ ដើម្បីធានាថាមន្ទីរពេទ្យមានឈាមបម្រុងគ្រប់គ្រាន់គឺមន្ទីរពេទ្យមានវិធីសាស្ត្រក្នុងការប្រមូល ការរក្សាទុក និងការប្រើប្រាស់ឈាម។

វត្តមាននៃឈាមក្រហមត្រូវបានគ្រប់គ្រងដោយដេប៉ូឈាម (Blood Depot)។ ការប្រមូលឈាម តាមរយៈគ្រួសារអ្នកជំងឺ តាមរយៈអ្នកស្ម័គ្រចិត្តគឺប្រធានមន្ទីរពេទ្យបានទំនាក់ទំនងប្រមូលតារាងឈ្មោះ និងលេខទូរស័ព្ទ អ្នកស្ម័គ្រចិត្ត ធ្វើការបរិច្ចាគយកមករក្សាទុក ដូច្នេះពេលមន្ទីរពេទ្យត្រូវការឈាម គ្រូពេទ្យទូរស័ព្ទហៅអ្នកស្ម័គ្រចិត្តបរិច្ចាគទាំងនោះ។

វិធីសាស្ត្រមួយទៀតក្នុងការប្រមូលឈាមគឺបង្កើតគណៈកម្មការគ្រប់គ្រងឈាមដែលមានលោកអភិបាលរងខេត្តម្នាក់ជាប្រធានគណៈកម្មការ ប្រធានមន្ទីរសុខាភិបាលជាអនុប្រធានគណៈកម្មការ និងប្រធានមន្ទីរអង្គភាពនានាជាសមាជិក ហើយគណៈកម្មការនេះមានតួនាទីបង្កើតកម្មវិធីផ្សព្វផ្សាយតាមអង្គភាពនានាចំណុះខេត្តឱ្យចូលរួមបរិច្ចាគឈាមដោយធ្វើការផ្លាស់វេនគ្នាពីអង្គភាពមួយទៅអង្គភាពមួយទៀត ហេតុដូច្នេះហើយការផ្គត់ផ្គង់ឈាមមិនសូវមានការខ្វះខាតទេ។

ម្យ៉ាងទៀតមន្ទីរពេទ្យមានលក្ខខណ្ឌតម្រូវឱ្យគ្រប់អ្នកជំងឺវះកាត់ត្រូវផ្ដល់ឈាមសម្រាប់ត្រៀមបម្រុងយ៉ាងតិចចំនួន ២ប្លោក ក្នុងមួយករណី ប៉ុន្តែពេលខ្លះមន្ទីរពេទ្យក៏មិនបានប្រើប្រាស់ឈាមទាំងអស់នោះដែរ។ ហេតុដូច្នេះមន្ទីរពេទ្យក៏មានសល់ឈាមខ្លះបម្រុងសម្រាប់អ្នកជំងឺក្រោយៗ។

ពេលប្រមូលបានហើយ ត្រូវពិនិត្យមើលមេរោគ រួចរាល់ទើបរក្សាទុកក្នុងទូទឹកកកដាក់ឈាម (មិនមែនទូធម្មតាទេ) ដែលមានសីតុណ្ហភាព ២ ទៅ ៦អង្សាសេ ហើយក៏មានការពិនិត្យសីតុណ្ហភាពទូរទឹកកកជារៀងរាល់ថ្ងៃដែរ។ ជាប្រចាំថ្ងៃ មន្ទីរពេទ្យមានស្តុកឈាមសរុបប្រហែល ១០ប្លោក ទៅតាមប្រភេទឈាមដូចជា ប្រភេទ O⁺, A⁺, B⁺ ជាមធ្យមក្នុង ១ខែ មន្ទីរពេទ្យត្រូវការប្រើប្រាស់ឈាមប្រហែល ២៥ប្លោក។

ពេលបញ្ចេញឈាមប្រើប្រាស់ ទាមទារឱ្យអ្នកជំងឺរកថ្នូរមកជូវវិញ ដើម្បីបំពេញស្តុកចំនួន ១០ប្លោក កុំឱ្យអស់។ ក្នុងករណីគ្មានថ្នូរទេ ក៏មន្ទីរពេទ្យផ្តល់ឱ្យសិន រួចចាំប្រមូលពីអ្នកជំងឺតាមក្រោយ។

### ៣.២.២. ការបង្ការ និងការត្រួតពិនិត្យការចម្លងរោគ

ការឆ្លងរោគនៅក្នុងមន្ទីរពេទ្យគឺជាបញ្ហាប្រឈមមួយដែលមន្ទីរពេទ្យត្រូវយកចិត្តទុកដាក់។ មានកត្តាជាច្រើនដែលបង្កឱ្យមានការឆ្លងរោគនៅក្នុងមន្ទីរពេទ្យ។ កត្តាចម្បងរួមមានការលាងសម្អាត និងការសម្លាប់មេរោគលើសម្ភារៈ/ឧបករណ៍មិនបានត្រឹមត្រូវ ហើយយកឧបករណ៍សម្ភារៈនោះទៅប្រើប្រាស់ឡើងវិញក្នុងការវះកាត់ ព្យាបាល និងថែទាំអ្នកជំងឺ។ មន្ទីរពេទ្យនីមួយៗត្រូវរៀបចំឱ្យមានផ្នែករម្ងាប់មេរោគ និងផ្គត់ផ្គង់កណ្តាលរួមមួយ។ ផ្នែកនេះត្រូវប្រមូលឧបករណ៍សម្ភារៈដែលប្រើប្រាស់រួចហើយ ពីគ្រប់ផ្នែកទាំងអស់ក្នុងមន្ទីរពេទ្យមកត្រាំ លាងសម្អាត សម្ងួត វេចខ្ចប់ និងសម្លាប់មេរោគក្នុងឆ្នាំងរម្ងាប់មេរោគ បន្ទាប់មកចែកចាយទៅតាមផ្នែកនីមួយៗវិញដើម្បីប្រើប្រាស់។ វិធីមួយទៀតគឺបុគ្គលិកតាមអគារនីមួយៗត្រូវត្រាំ លាងសម្អាត សម្ងួត និងវេចខ្ចប់រួចជាស្រេច មុននឹងបញ្ជូនមកផ្នែករម្ងាប់ និងផ្គត់ផ្គង់កណ្តាល ដើម្បីសម្លាប់មេរោគ[១៦]។

#### ៣.២.២.១. ផ្នែករម្ងាប់មេរោគ និងផ្គត់ផ្គង់កណ្តាល

មន្ទីរពេទ្យខេត្តកោះកុងមិនទាន់មានផ្នែករម្ងាប់មេរោគ និងផ្គត់ផ្គង់កណ្តាលទេ ក៏ប៉ុន្តែបច្ចុប្បន្នបានជួសជុលកែលម្អអគាររម្ងាប់មេរោគដែលមានស្រាប់ និងបំពាក់សម្ភារបរិក្ខារទំនើបមួយចំនួនក្រោមជំនួយរបស់ទីភ្នាក់ងារប្រតិបត្តិការអន្តរជាតិថៃ (TICA) ដោយមន្ទីរពេទ្យបានរៀបចំឱ្យមានផ្នែករម្ងាប់មេរោគ និងផ្គត់ផ្គង់កណ្តាលរួចរាល់ហើយ ប៉ុន្តែមានការពន្យារពេលក្នុងការបំពាក់ឧបករណ៍ដោយសារមានការបិទច្រកព្រំដែនកម្ពុជាថៃព្រោះមូលហេតុផ្ទុះជំងឺកូវីដ១៩ ហើយនិងត្រូវបានផ្គត់ផ្គង់នៅក្នុងចុងឆ្នាំ២០២០ ខាងមុខនេះ។

[១៦] គោលការណ៍ណែនាំស្តីពីការបង្ការ និងការត្រួតពិនិត្យការចម្លងរោគ ឆ្នាំ២០១៧ របស់នាយកដ្ឋានមន្ទីរពេទ្យ ក្រសួងសុខាភិបាល

ជំពូកទី៣

សព្វថ្ងៃការរម្ងាប់មេរោគលើឧបករណ៍សម្ភារៈប្រើប្រាស់ឡើងវិញ គឺធ្វើនៅតាមផ្នែករៀងៗខ្លួនដោយមានការធានាថាឧបករណ៍សម្ភារៈទាំងនោះត្រូវបានធ្វើការរម្ងាប់មេរោគបានយ៉ាងល្អ ត្រឹមត្រូវតាមគោលការណ៍ណែនាំស្ដីពីការបង្ការ និងការត្រួតពិនិត្យការចម្លងរោគដោយមានការប្រើប្រាស់ស្កុតតេស្ត និងកត់ត្រាកាលបរិច្ឆេទប្រើប្រាស់ ក្នុងការត្រួតពិនិត្យឧបករណ៍សម្ភារៈទាំងនោះ។

### ៣.២.២.២. ការអនុវត្តបានត្រឹមត្រូវនូវការចាក់ថ្នាំមានសុវត្ថិភាព

ការចាក់ថ្នាំមានសុវត្ថិភាពគឺជាការប្រតិបត្តិទាំងឡាយដែលធ្វើឡើងប្រកបដោយអនាម័យម៉ត់ចត់ត្រឹមត្រូវ អនុលោមតាមមគ្គុទេសក៍ណែនាំស្ដីពីសុវត្ថិភាពនៃការចាក់ថ្នាំដើម្បីកុំឱ្យបង្កគ្រោះថ្នាក់ ការចម្លងរោគដល់អ្នកជំងឺ និងអ្នកផ្ដល់សេវា ដែលនាំឱ្យមានហានិភ័យណាមួយជាយថាហេតុ។ គណៈកម្មការគ្រប់គ្រង និងត្រួតពិនិត្យការចម្លងរោគធ្វើការប្រជុំរៀងរាល់ខែ បានពង្រឹងការអនុវត្តមគ្គុទ្ទេសក៏ណែនាំស្ដីពីសុវត្ថិភាពនៃការចាក់ថ្នាំដោយគោរពតាមការប្រតិបត្តិត្រឹមត្រូវទាំង ១០ចំណុច សំខាន់ៗដូចខាងក្រោម÷ (១) អ្នកជំងឺត្រឹមត្រូវ (២) ឱសថត្រឹមត្រូវ (៣) រូបមន្តត្រឹមត្រូវ (៤) ឧបករណ៍ចាក់ថ្នាំត្រឹមត្រូវ (៥) ដូសត្រឹមត្រូវ (៦) ពេលវេលាត្រឹមត្រូវ (៧) ផ្លូវបញ្ចូលឱសថត្រឹមត្រូវ (៨) ការរក្សាឯកសារត្រឹមត្រូវ (៩) ការទុកដាក់ត្រឹមត្រូវ និង (១០) ការបោះចោលត្រឹមត្រូវ។

### ៣.២.២.៣. ការអនុវត្តផែនការគ្រប់គ្រងសំណល់របស់មន្ទីរពេទ្យ

សំណល់ពីមូលដ្ឋានព្យាបាល និងថែទាំសុខភាព ត្រូវគ្រប់គ្រងឱ្យបានត្រឹមត្រូវ ដើម្បីការពារបុគ្គលិក អ្នកជំងឺ ប្រជាពលរដ្ឋ សត្វ និងបរិស្ថាន។ ការគ្រប់គ្រងសំណល់ពីការថែទាំសុខភាពរាប់បញ្ចូលទាំង (១) ការញែកសំណល់ (២) ការប្រមូលទុកដាក់ក្នុងកន្លែងមានសុវត្ថិភាពបណ្ដោះអាសន្ន (៣) ការធ្វើប្រព្រឹត្តិកម្មមានសុវត្ថិភាព និង (៤) ការបោះចោលចុងក្រោយដោយសុវត្ថិភាពដែលមិនបង្កឱ្យមានភាពកខ្វក់ដល់បរិស្ថាន។

ពាក់ព័ន្ធនឹងការញែកសំណល់ មន្ទីរពេទ្យបានរៀបចំដូចតទៅ÷ (១) សំណល់ទូទៅបានដាក់ក្នុងធុងសំរាមពណ៌បៃតងចង់ពណ៌ខ្មៅ និងបានធ្វើកិច្ចសន្យាជាមួយភ្នាក់ងារដឹក

ជញ្ជូនសំរាមក្រុង (២) សំណល់ឆ្លងរោគដាក់ធុងពណ៌លឿង ថង់លឿង ឡូហ្គោខ្មៅ អក្សរខ្មៅ (៣) វត្ថុមុតស្រួចដាក់ក្នុងប្រអប់សុវត្ថិភាព រួចប្រមូលយកទៅដាក់ក្នុងរោងស្តុកសំណល់បណ្តោះអាសន្នដែលមានរបង និងដំបូលត្រឹមត្រូវ ដើម្បីរង់ចាំកម្ទេចចោលដោយមិនឱ្យលើស ២ថ្ងៃ ទេ ដោយប្រើប្រាស់ឡដុតសំណល់ឆ្លងរោគ និងឡស៊ីស៊ីមដែលធ្លាប់បានខូច និងបានជួសជុលវិញហើយ។ សំណល់អំពូលដាក់ក្នុងរណ្តៅលូមានគម្រប ចំណែកសំណល់សរីរាង្គដូចជាសុកបោះចោលក្នុងរណ្តៅកប់សុក។

ក្រៅពីការគ្រប់គ្រងចាត់ចែងសំណល់ដូចខាងលើ មន្ទីរពេទ្យបានប្រើប្រាស់ផ្ទាំងរូបភាព (Poster) ស្តីពីការណែនាំអនុវត្តការញែកសំណល់ដោយមានបិទនៅតាមជញ្ជាំងត្រង់កន្លែងដែលមានដាក់ធុងសំរាម។

### ៣.២.៣. អនាម័យ

ការធ្វើអនាម័យដៃរបស់បុគ្គលិកពេទ្យគឺជាបច្ចេកទេសដែលមានសារៈសំខាន់បំផុតតែមួយគត់ ក្នុងការការពារ និងបន្ថយការចម្លងរោគនៅក្នុងមូលដ្ឋានព្យាបាលនិងថែទាំសុខភាព។ តាមរយៈការលាងដៃញឹកញាប់ ឬការអនុវត្តអនាម័យដៃរបស់បុគ្គលិក កាត់បន្ថយហានិភ័យពីការចម្លងរោគ ឬនាំភ្នាក់ងារបង្ករោគទៅឱ្យអ្នកដទៃ (អ្នកជំងឺ ភ្ញៀវ ឬសមាជិកសហគមន៍/ សមាជិកគ្រួសាររបស់គេ)។

បុគ្គលិកតាមផ្នែកនីមួយៗរៀន និងអនុវត្តតាមជំហានទាំង ៦ នៃការធ្វើអនាម័យដៃមានដូចជា÷ (១) ដុសលាងប្រអប់ដៃទាំងពីរ (២) ដុសបាតដៃលើខ្នងដៃឆ្វេងស្តាំម្តងម្ខាងដោយម្រាមដៃឆ្លាស់គ្នា (៣) ដុសប្រអប់ដៃលើប្រអប់ដៃដោយម្រាមដៃឆ្លាស់គ្នា (៤) ដុសខ្នងម្រាមដៃ និងប្រអប់ដៃឆ្វេងស្តាំម្តងម្ខាងដោយម្រាមដៃចាក់ស្រេះគ្នា (៥) ក្តាប់ប្រអប់ដៃលើមេដៃហើយបង្វិលឆ្វេងស្តាំម្តងម្ខាង (៦) បង្វិលដុសចុងម្រាមដៃលើប្រអប់ដៃឆ្វេងស្តាំម្តងម្ខាង។

បុគ្គលិកមន្ទីរពេទ្យទាំងអស់បានគោរពតាមពេលវេលាទាំង ៥ ក្នុងការអនុវត្តអនាម័យដៃតាមគោលការណ៍ណែនាំស្តីពីការបង្ការ និងត្រួតពិនិត្យការចម្លងរោគរួមមាន÷ (១) មុនពេលប៉ះអ្នកជំងឺ (២) មុនពេលធ្វើទម្រង់ការអាសិបទិក (៣) ក្រោយពេលប៉ះពាល់វត្ថុរាវ

ចេញពីអ្នកជំងឺ (៤) ក្រោយពេលប៉ះអ្នកជំងឺ (៥) ក្រោយពេលប៉ះវត្ថុជុំវិញអ្នកជំងឺ។ គ្រូពេទ្យត្រូវបង្រៀនអ្នកអនាម័យ អ្នកជំងឺ អ្នកកំដរឱ្យដឹងពីរបៀបលាងដៃ និងមានបំពាក់សម្ភារៈប្រើប្រាស់គ្រប់គ្រាន់សម្រាប់ធ្វើអនាម័យដៃមានដូចជាសាប៊ូ កន្សែងជូតដៃ អាល់កុលលាងដៃ និងគ្រប់កន្លែងលាងដៃមានបិទរូបភាពបង្ហាញពីជំហាននៃការលាងដៃ។

តាមបណ្ដាផ្នែកនីមួយៗការបង្ហាត់បង្ហាញដល់អ្នកជំងឺ/អ្នកកំដរ គឺមានការបង្ហាញអំពីការថែទាំសុខភាព អំពីការអនុវត្តអនាម័យដៃ និងអនាម័យទូទៅ ហើយចំពោះអតិថិជនផ្នែកពិនិត្យជំងឺក្រៅមានចាក់ផ្សាយសារអប់រំតាមរយៈទូរទស្សន៍។

### ៣.២.៤. ការរៀបចំការលើកកម្ពស់គុណភាព

មន្ទីរពេទ្យខេត្តកោះកុងក៏បានបង្កើតក្រុមការងារលើកកម្ពស់គុណភាព និងសុវត្ថិភាពតាមផ្នែកទាំងអស់ ការគ្រប់គ្រងមន្ទីរពេទ្យខេត្តកោះកុងគឺលោកប្រធានមន្ទីរពេទ្យបានផ្តល់សិទ្ធិអំណាចជូនផ្នែកនីមួយៗក្នុងការរៀបចំផែនការលើកកម្ពស់គុណភាព និងសុវត្ថិភាពរបស់ផ្នែក ដូចជា÷ (១) មានជាផែនការប្រចាំខែ និងប្រចាំត្រីមាស (២) មានការពិនិត្យឡើងវិញនូវផែនការជារៀងរាល់ខែ និងធ្វើរបាយការណ៍ជូនក្រុមការងារលើកកម្ពស់គុណភាព និងសុវត្ថិភាពមន្ទីរពេទ្យឱ្យបានត្រឹមថ្ងៃទី២៥ ជារៀងរាល់ខែ។

ចំណែកក្រុមការងារលើកកម្ពស់គុណភាព និងសុវត្ថិភាពរបស់មន្ទីរពេទ្យវិញ បន្ទាប់ពីទទួលបានរបាយការណ៍ពីគ្រប់ផ្នែករួចហើយ ទើបមានការប្រជុំដើម្បីបង្កើតផែនការលើកកម្ពស់គុណភាព និងសុវត្ថិភាពរបស់មន្ទីរពេទ្យប្រចាំខែ និងត្រីមាសផងដែរ។ កិច្ចប្រជុំក្រុមការងារលើកកម្ពស់គុណភាព និងសុវត្ថិភាពតាមផ្នែក គណៈកម្មការបច្ចេកទេស និងគណៈកម្មការប្រើប្រាស់ឱសថសមស្រប (MTC) មាន ភារៈកិច្ចពិនិត្យមើលលើគុណភាពនៃការព្យាបាល ដោយគោរពតាមពិធីសារនៃការព្យាបាលថ្នាក់ជាតិ។

នៅតាមផ្នែកនីមួយៗដូចជាផ្នែកជំងឺទូទៅ ផ្នែកជំងឺកុមារ ផ្នែកវះកាត់ ផ្នែកសម្ភព-រោគស្ត្រី និងផ្នែកសង្គ្រោះបន្ទាន់ មានរៀបចំតម្កល់ទុកពិធីសារព្យាបាល ឬគោលការណែនាំចំនួនយ៉ាងតិច ៤ពិធីសារ/គោលការណ៍ណែនាំសម្រាប់មន្ត្រីតាមផ្នែកប្រើប្រាស់ប្រចាំថ្ងៃ

និងមានរៀបចំទូធំមួយនៅក្នុងបន្ទប់ប្រជុំសម្រាប់រក្សាទុកពិធីសារព្យាបាល/ គោលការណ៍ណែនាំរួមគ្រប់ផ្នែកទាំងអស់។

### ៣.២.៤.១. ការព្យាបាលការសម្រាលកូនធម្មតា ការសម្រាលកូនពិបាក ការសម្រាលកូនដោយវះកាត់

ការសម្រាលកូនធម្មតាគឺនៅពេលស្ត្រីមកសម្រាកពេទ្យ (ទី១) គ្រូពេទ្យនិងបុគ្គលិកឆ្មបបានបំពេញឯកសារគ្រប់ស្ត្រីទាំងអស់ដោយធ្វើការបំពេញទម្រង់សិទ្ធិអតិថិជន និងកិច្ចសន្យាទទួលសេវា ហើយឯកសារទាំងអស់គឺជាទម្រង់គោលការណ៍ណែនាំថ្នាក់ជាតិ (ទី២) ស្ត្រីសម្រាលមានទិន្នន័យពេញលេញតាមស្តង់ដាគឺគ្រូពេទ្យបានបំពេញទិន្នន័យទាំងអស់តាមសៀវភៅពិនិត្យផ្ទៃពោះរបស់អ្នកជំងឺ (ទី៣) មានការពិនិត្យគ្លីនិក និងការតាមដានសភាពជំងឺ និងការព្យាបាលប្រចាំថ្ងៃ។ ការបំពេញឯកសារស្ត្រីសម្រាល គឺគ្រូពេទ្យជាអ្នកបំពេញទម្រង់ឯកសារនៃការវិវត្តរបស់ជំងឺជារៀងរាល់ថ្ងៃនៅពេលពិនិត្យជំងឺ (ទី៤) មានការសុំធ្វើតេស្តមន្ទីរពិសោធន៍ និងការពិនិត្យផ្សេងៗទៀតសម្រាប់ធ្វើរោគវិនិច្ឆ័យគ្លីនិក គឺត្រូវមើលតេស្តឈាម និងមើលអ៊ុលត្រាសោន (អេកូ) គ្រប់ស្ត្រីសម្រាល និងមានក្រដាសលទ្ធផលមកកិបជាប់ជាមួយគ្រប់ឯកសារស្ត្រីសម្រាលទាំងអស់ (ទី៥) ប៉ាតូក្រាហ្វគឺមន្ទីរពេទ្យបានប្រើប្រាស់ប៉ាតូក្រាហ្វទើបកែសម្រួលថ្មីៗចុងក្រោយដោយមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក។

ការបំពេញប៉ាតូក្រាហ្វគឺគ្រូពេទ្យឆ្មបបានបំពេញ និងត្រួតពិនិត្យដោយខ្លួនឯងឱ្យបានម៉ត់ចត់ត្រឹមត្រូវជាមុនសិន បន្ទាប់មកគណៈកម្មការបច្ចេកទេសមន្ទីរពេទ្យមានភារកិច្ចពិនិត្យម្តងទៀតសារឡើងវិញនៅក្នុងកិច្ចប្រជុំពេលព្រឹកប្រចាំថ្ងៃ។ នៅក្នុងផ្នែកគឺនាយសាលឬនាយសាលរងជួយពិនិត្យម្តងទៀតមុននឹងបញ្ចូលឯកសារស្ត្រីសម្រាលនេះទៅទុកក្នុងកន្លែងតម្កល់ឯកសារ។

ចំណែកការសម្រាលកូនពិបាកគឺគ្រូពេទ្យបានបំពេញឯកសារដូចការសម្រាលកូនធម្មតាដែរ ក៏ប៉ុន្តែមានបន្ថែមមួយចំនុចទៀតដោយមានអំណះអំណាងនៃរោគវិនិច្ឆ័យគ្លីនិក

ជំពូកទី៣

និងរៀបរាប់លម្អិតពីដំណើរការព្យាបាល គឺត្រង់កន្លែងនេះគ្រូពេទ្យឆ្មបត្រូវសរសេររៀបរាប់នៅក្នុងសាលាកប័ត្រតាមដាន ចំណែកគ្រូពេទ្យព្យាបាលត្រូវសរសេរអំណះអំណាងនៃរោគវិនិច្ឆ័យគ្លីនិកនៅក្នុងអត្ថបទជំងឺ។

ចំពោះការសម្រាលកូនដោយវះកាត់គ្រូពេទ្យបានបំពេញឯកសារដូចសម្រាលកូនធម្មតា និងសម្រាលកូនពិបាកដែរ ក៏ប៉ុន្តែមានបន្ថែមរបាយការណ៍វះកាត់យកកូន ដោយប្រើពិធីសារវះកាត់ដែលបានដកស្រង់ចេញពីសេចក្ដីណែនាំស្ដីពីសំណុំសកម្មភាពបង្គ្រប់សម្រាប់អភិវឌ្ឍន៍មន្ទីរពេទ្យបង្អែក និងរបាយការណ៍នៃការដាក់ថ្នាំសណ្ដំដោយប្រើពិធីសារដាក់ថ្នាំសណ្ដំដែលបានយកគំរូតាមមន្ទីរពេទ្យកាល់ម៉ែត។

### ៣.២.៤.២. ការថែទាំសារវន្តទារកទើបកើត

ភ្លាមៗបន្ទាប់ពីសម្រាល ឆ្មប ឬគ្រូពេទ្យជំនាញខាងទារកទើបកើត ឬគ្រូពេទ្យជំនាញខាងសម្ភព/ រោគស្ត្រី វាយតម្លៃការយំ/ ការដកដង្ហើម និងសកម្មភាពរបស់ទារក។ បើទារកដកដង្ហើម/ យំនិងសកម្ម គ្រូពេទ្យឆ្មប ឬគ្រូពេទ្យត្រូវតែ (រាយនាមចំណុចទាំង ១០ ដោយមិនបាច់មើលលើឯកសារណែនាំ)[១៧]។

គ្រូពេទ្យព្យាបាលនិងគ្រូពេទ្យឆ្មបទាំងអស់បានអនុវត្តការថែទាំសារវន្តទារកទើបកើតដោយគោរព តាមជំហានទាំង ១០ តាមលំដាប់លំដោយគ្រប់ទារកទាំងអស់ជារៀងរហូតមក។ ម្យ៉ាងវិញទៀតទាក់ទងទៅនឹងការវាយតម្លៃខ្លួនឯងលើគុណភាពសេវាដោយក្រុមវាយតម្លៃផ្ទៃក្នុងរបស់មន្ទីរពេទ្យ (self assessment) ដោយតម្រូវឱ្យបុគ្គលិកគ្រប់រូបនៅផ្នែកសម្ភពចេះចាំ និងអនុវត្តឱ្យបានស្ទាត់គ្រប់ជំនាញ និងមានការអង្កេតពីគ្រូពេទ្យម្ដងម្នាក់។

ការថែទាំករណីធ្ងន់ធ្ងរទារកទើបកើតជាវិធីសាស្ត្រអនុវត្តដើម្បីវាយតម្លៃ និងធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃការថែទាំជាប្រចាំក្នុងអំឡុងពេលទារកទើបកើតភ្លាមៗ។ ការថែទាំករណីធ្ងន់ធ្ងរទារកទើបកើតនៅមន្ទីរពេទ្យខេត្តកោះកុងគឺ ទាំងគ្រូពេទ្យឆ្មបទាំងគ្រូពេទ្យព្យាបាល មិនត្រឹមតែចាំយ៉ាងស្ទាត់ប៉ុណ្ណោះទេ ថែមទាំងអនុវត្តទៅលើទារកទាំងអស់ដោយ

[១៧] ឧបករណ៍តាមដានការកែលម្អគុណភាពសេវាសុខាភិបាល

គោរពតាមលំដាប់លំដោយនូវជំហានទាំងអស់។

រីឯសម្ភារបរិក្ខារសម្រាប់សង្គ្រោះបន្ទាន់ទារកទើបកើតវិញគឺខាងមន្ទីរពេទ្យកោះកុងអាចរកបាន និងដំណើរការល្អគ្រប់ឧបករណ៍ទាំងអស់ដោយ ឧបករណ៍មួយចំនួនបានមកពីគម្រោងលើកកម្ពស់គុណភាពនិងសមធម៌សុខាភិបាល និងជំនួយពីមន្ទីរពេទ្យក្នុងស្រុកមួយចំនួន និងមួយចំនួនទៀតបានមកពីជំនួយពីបរទេសដូចជាៈ មន្ទីរពេទ្យប្រទេសថៃ ប្រទេសបារាំងក៏បានមកខ្លះ ទោះបីមិនច្រើនក៏ដោយ និងសម្ភារៈខ្លះទៀតទិញក្នុងស្រុក។

### ៣.២.៤.២. ការថែទាំកុមារ

ពេលកុមារចូលមកសម្រាកពេទ្យគឺគ្រូពេទ្យបានបំពេញឯកសារដូចផ្នែកផ្សេងៗដែរមានដូចជា÷ (១)ទម្រង់សិទ្ធិអតិថិជន (២)កិច្ចសន្យាទទួលសេវាដោយមានចុះហត្ថលេខានិងផ្តិតមេដៃរបស់អាណាព្យាបាលកុមារ។ ទម្រង់សិទ្ធិអតិថិជន និងកិច្ចសន្យាទទួលសេវាដែលបានដកស្រង់យកមកពីឧបសម្ព័ន្ធទី៩ នៃសំណុំឧបករណ៍តាមដានការកែលម្អគុណភាពសេវាសុខាភិបាល។

ឯកសារកុមារសម្រាកពេទ្យគឺមានការបំពេញគ្រប់ចំណុចទាំងអស់ ឧ.ដូចជាលេខទូរស័ព្ទរបស់អ្នកជំងឺ អាសយដ្ឋាន មូលហេតុចូលសម្រាកពេទ្យ លេខគ្រែ លេខបន្ទប់ ដោយមានការផ្តិតមេដៃ ចុះហត្ថលេខា របស់អាណាព្យាបាល ឬក៏អ្នកជំងឺផ្ទាល់។ល។ គ្រូពេទ្យព្យាបាលមានបំពេញប្រវត្តិជំងឺ ការពិនិត្យគ្លីនិក ការសុំធ្វើតេស្តមន្ទីរពិសោធន៍ និងការពិនិត្យផ្សេងៗទៀតសម្រាប់ធ្វើរោគវិនិច្ឆ័យគ្លីនិក បន្ទាប់មកធ្វើអំណះអំណាងនៃរោគវិនិច្ឆ័យគ្លីនិករោគវិនិច្ឆ័យញែកពីជំងឺផ្សេងទៀតដើម្បីងាយស្រួលក្នុងការព្យាបាល មានការរៀបរាប់លម្អិតពីដំណើរការព្យាបាល និងការតាមដានសភាពជំងឺជាប្រចាំថ្ងៃ។

### ៣.២.៤.៣. ការកែលម្អគុណភាពសេវានៅផ្នែកវះកាត់

ផ្នែកវះកាត់ ដើរតួនាទីយ៉ាងសំខាន់មួយ ដោយផ្នែកនេះមានទាំងធនធានមនុស្ស មានទាំងសម្ភារៈមួយចំនួនក្នុងការបម្រើសេវាសុខាភិបាលជូនប្រជាជនប្រកបដោយគុណភាពប្រសិទ្ធភាព និងតម្លាភាព ស្របទៅតាមចក្ខុវិស័យ បេសកកម្ម និងទិសដៅរបស់មន្ទីរពេទ្យ

ជំពូកទី៣

ដោយមន្ត្រីម្នាក់ៗបំពេញការងារប្រកបដោយឆន្ទៈ និងការទទួលខុសត្រូវខ្ពស់។

ចំពោះផ្នែកវះកាត់ក៏ដូចជាផ្នែកផ្សេងៗដែរ ដោយមានទម្រង់សិទ្ធិអតិថិជន កិច្ចសន្យាទទួលសេវា ដែលបានដកស្រង់យកមកពីឧបសម្ព័ន្ធទី៩ នៃសំណុំឧបករណ៍តាមដានការកែលម្អគុណភាពសេវាសុខាភិបាល។

គ្រូពេទ្យព្យាបាលបានបំពេញការពិនិត្យគ្លីនិក បានបំពេញអំណះអំណាងគ្លីនិកនៃការវះកាត់ឬយុទ្ធសាស្ត្រនៃការព្យាបាល ការតាមដានសភាពជំងឺ និងការព្យាបាលប្រចាំថ្ងៃ និងមានការកត់ត្រាអំពីការក្លាយរោគនៅត្រង់មុខរបួសវះកាត់ប្រសិនបើមានរបួសក្លាយរោគ។

ចំណែកពិធីសារវះកាត់បានដកស្រង់ចេញពីសេចក្តីណែនាំស្តីពីសំណុំសកម្មភាពបង្គ្រប់សម្រាប់អភិវឌ្ឍន៍មន្ទីរពេទ្យបង្អែក និងរបាយការណ៍នៃការដាក់ថ្នាំសណ្តំ ដោយប្រើពិធីសារដាក់ថ្នាំសណ្តំដែលបានយកគំរូតាមមន្ទីរពេទ្យកាល់ម៉ែត។

### ៣.២.៥. ការសម្ភាសអតិថិជនដែលធ្លាប់មកសម្រាកពេទ្យ

ចំពោះនីតិវិធីក្នុងការសម្ភាសអតិថិជនដែលធ្លាប់មកសម្រាកពេទ្យគឺធ្វើឡើងតាមរយៈការជ្រើសរើស តាមសំណុំឧបករណ៍តាមដានការកែលម្អគុណភាពសេវាសុខាភិបាល។ ការសម្ភាសអតិថិជននឹងត្រូវធ្វើតាមរយៈការហៅទូរស័ព្ទទៅកាន់អ្នកជំងឺដែលធ្លាប់មកសម្រាកនៅមន្ទីរពេទ្យ។ អ្នកជំងឺចំនួន ១០នាក់ ត្រូវបានជ្រើសរើសដោយចៃដន្យពីផ្នែកនីមួយៗនៃផ្នែកចំនួន ៤ នៃមន្ទីរពេទ្យ ផ្នែកជំងឺទូទៅ ផ្នែកជំងឺកុមារ ផ្នែកសម្ភព និងផ្នែកវះកាត់។

ក្រាហ្វិកទី១២÷ ការសម្ភាសអតិថិជនដែលធ្លាប់មកសម្រាកពេទ្យ (លទ្ធផលប្រចាំត្រីមាសទី៤)




ក្រោមការអនុវត្តគម្រោងលើកកម្ពស់គុណភាព និងសមធម៌សុខាភិបាល (H-EQIP) មន្ទីរពេទ្យខេត្តកោះកុងទទួលលទ្ធផលពីការសម្ភាសអតិថិជននៅក្នុងត្រីមាសទី៤ នៃឆ្នាំ ២០១៧ ទទួលបាន ៦៩% ឆ្នាំ២០១៨ ទទួលបាន ៨០% និងនៅឆ្នាំ២០១៩ ទទួលបាន ៨៤,៧៩%។

ជំពូកទី៣

## រូបភាពទី៤÷ ស្តង់ដានៃការផ្តល់សេវាសាធារណៈរបស់មន្ទីរពេទ្យខេត្តកោះកុង



ការថែទាំករណីធ្ងន់ធ្ងរទារកទើបកើត (២០១៩)



ការបង្រៀនពីរបៀបនៃការបំបៅដោះកូន (២០១៨)



ការផ្តល់សារអប់រំដល់ស្ត្រីក្រោយសម្រាល (២០១៧)



ការអនុវត្តអនាម័យដៃរបស់អ្នកថែទាំអ្នកជំងឺ (២០១៩)



ស្ត្រីសម្រាលកូនលើទូក (២០១៩)



ការបញ្ជូនអ្នកជំងឺតាមកាណូតគិលានសង្គ្រោះ (២០១៩)

## ៣.៣. ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងអង្គភាព

បច្ចុប្បន្ន រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលកម្មវិធីនេះជាកម្មវិធីកែទម្រង់រយៈពេលវែង ព្រមទាំងមានចក្ខុវិស័យប្រកបដោយមហិច្ឆិតា និងប្រាកដនិយម សំដៅការផ្លាស់ប្តូរប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជាឆ្ពោះទៅរកស្តង់ដាអន្តរជាតិដែលមានលក្ខណៈ**បែបមជ្ឈការ/ ផ្តោតលើធាតុចូល** ឆ្ពោះទៅរកប្រព័ន្ធហិរញ្ញវត្ថុ**បែបវិមជ្ឈការ/ផ្តោតលើសមិទ្ធកម្ម**។ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ ត្រូវប្រកាន់ខ្ជាប់តាមអភិក្រមជាខឿន និងបែងចែកចេញជាបួនដំណាក់កាល រួមមាន÷

- **ដំណាក់កាលទី១ "ភាពជឿទុកចិត្តនៃថវិកា" ពីឆ្នាំ២០០៥-២០០៩**
- **ដំណាក់កាលទី២ "គណនេយ្យភាពហិរញ្ញវត្ថុ" ពីឆ្នាំ២០០៩-២០១៥**
- **ដំណាក់កាលទី៣ "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ" ពីឆ្នាំ២០១៦-២០២០**
- **ដំណាក់កាលទី៤ "គណនេយ្យភាពសមិទ្ធកម្ម" ពីឆ្នាំ២០២១-២០២៥។**

ការវាយតម្លៃលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់មន្ទីរពេទ្យខេត្តកោះកុងត្រូវបានកំណត់ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យវងមួយចំនួន រួមមានៈ ១)ការរៀបចំផែនការថវិកា ២) ការរៀបចំបញ្ជីសារពើភណ្ឌកត់ត្រាចំណូល ចំណាយ និងរបាយការណ៍។

### ៣.៣.១. ការរៀបចំផែនការថវិកា

ការរៀបចំផែនការថវិកា ជាដំណើរការនៃការរៀបចំកញ្ចប់ថវិកាសម្រាប់ការអនុវត្តនៅឆ្នាំបន្ទាប់ដែលត្រូវផ្សារភ្ជាប់នឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ និងផែនការប្រតិបត្តិការប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ន និងអង្គភាពនីមួយៗ។ ក្នុងន័យនេះដែរ ការរៀបចំផែនការត្រូវឆ្លុះបញ្ចាំងពីគោលបំណងគោលនយោបាយ កម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាព ភ្ជាប់ជាមួយលទ្ធផលក្នុងឆ្នាំ សូចនាករសមិទ្ធកម្មគន្លឹះ និងគោលដៅដែលបានកំណត់។ ការរៀបចំផែនការថវិកានេះដែរ ត្រូវអនុលោមតាមសារាចរណែនាំប្រចាំឆ្នាំ

របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងផែនការថវិកាប្រចាំឆ្នាំ និងការណែនាំលម្អិតបន្ថែមពីក្រសួង ស្ថាប័ន និងអង្គភាពសាមីនីមួយៗ។

ដោយឡែក ពាក់ព័ន្ធនឹងដំណើរការនៃការប្រមូលទិន្នន័យ និងការរៀបចំផែនការថវិកាប្រចាំឆ្នាំរបស់មន្ទីរពេទ្យខេត្តកោះកុង គឺមានការចូលរួមពីអ្នកពាក់ព័ន្ធមួយចំនួនរួមមាន ប្រធាន អនុប្រធានមន្ទីរពេទ្យ ក្រុមការងារដែលជាសមាជិកគណៈកម្មការគ្រប់គ្រងមន្ទីរពេទ្យ ប្រធានផ្នែក ក្នុងគោលបំណង ដើម្បីឱ្យប្រធានផ្នែកនីមួយៗ ឬបុគ្គលិកគ្រប់ផ្នែកទាំងអស់ លើកឡើងអំពីតម្រូវការថវិកាសម្រាប់គាំទ្រដល់ដំណើរការប្រតិបត្តិប្រចាំថ្ងៃ និងប្រចាំត្រីមាសតាមផ្នែករៀងៗខ្លួន ដើម្បីដាក់បញ្ចូលទៅក្នុងផែនការថវិកាមេរបស់មន្ទីរពេទ្យ។

ក្នុងវិស័យសុខាភិបាល ការរៀបចំធ្វើផែនការប្រចាំឆ្នាំ គឺត្រូវដឹងអំពីចំនួនថវិកាសរុបពីប្រភពនានាដែលមន្ទីរពេទ្យ នឹងទទួលបានសម្រាប់គាំទ្រដល់ចំណាយប្រតិបត្តិការប្រចាំថ្ងៃ ហើយការធ្វើផែនការថវិកាប្រចាំឆ្នាំ ឬផែនការសកម្មភាពសម្រាប់អនុវត្តនេះដែរ គឺត្រូវគិតពីតម្រូវការនៃផ្នែកនីមួយៗ លើការចំណាយទិញសម្ភារបរិក្ខារពេទ្យ និងការជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ។ល។ ថវិការបស់មន្ទីរពេទ្យដែលទទួលបានមាន ពីរប្រភពសំខាន់ គឺ (១) ថវិការដ្ឋ និង (២) ថវិកាហិរញ្ញប្បទាន (ចំណូលបានមកពី ប.ស.ស មូលនិធិសមធម៌ និងការបង់សេវាផ្ទាល់ពីអតិថិជន)។

ក្រោយពីប្រមូលទិន្នន័យបានពីគ្រប់ផ្នែកទាំងអស់ទើបគណៈកម្មការគ្រប់គ្រងមន្ទីរ-ពេទ្យប្រជុំត្រួតពិនិត្យមើលផែនការសកម្មភាព និងផែនការថវិកាតាមផ្នែកនីមួយៗ និងកំណត់យកសកម្មភាពណាដែលគិតថាសំខាន់ និងអាទិភាពសម្រាប់អនុវត្តដោយផ្អែកតាមចំនួនថវិកាដែលទទួលបានពីប្រភពនីមួយៗ រួចដាក់បញ្ចូលទៅក្នុងផែនការសកម្មភាព និងផែនការថវិកាប្រចាំត្រីមាស និងប្រចាំឆ្នាំរបស់មន្ទីរពេទ្យ។ ក្រោយពីបានរៀបចំផែនការសកម្មភាព និងថវិការួច ប្រធានមន្ទីរពេទ្យត្រូវរៀបចំបញ្ជូនផែនការនេះទៅមន្ទីរសុខាភិបាលដើម្បីពិនិត្យនិងចាត់ចែងបញ្ជូនបន្តទៅក្រសួងសុខាភិបាល ដើម្បីពិនិត្យមុននឹងក្រសួងសុខាភិបាលបញ្ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ដំណើរការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់មន្ទីរពេទ្យ

| | |
|---|---|
| ការប្រមូលទិន្នន័យ ↓ | រៀបចំកិច្ចប្រជុំពិភាក្សាអំពីប្រភេទ និងវិធីសាស្ត្រប្រមូលទិន្នន័យ៖<br>▪ ប្រធាន និងអនុប្រធានមន្ទីរពេទ្យ<br>▪ សមាជិកគណៈកម្មការគ្រប់គ្រងមន្ទីរពេទ្យ<br>▪ ប្រធានផ្នែកនីមួយៗ |
| ទិន្នន័យសរុបដែលប្រមូលបាន ↓ | ពិនិត្យ និងផ្ទៀងផ្ទាត់ទិន្នន័យជាមួយនឹងផែនការសកម្មភាព និងថវិកាគ្រប់ផ្នែកទាំងអស់ |
| រៀបចំកិច្ចប្រជុំអនុម័តលើផែនការថវិកាកម្រិតមន្ទីរពេទ្យ ↓ | កំណត់យកផែនការអាទិភាព និងថវិកាគាំទ្រដើម្បីយកទៅអនុវត្តតាមផ្នែកនីមួយៗ |
| បញ្ជូនសេចក្តីព្រាងផែនការសកម្មភាព និងថវិកាទៅមន្ទីរសុខាភិបាលខេត្ត | ដើម្បីពិនិត្យ និងរៀបចំបន្តតាមនីតិវិធី |

ក្រៅពីផែនការថវិកាប្រចាំឆ្នាំ មន្ទីរពេទ្យបានរៀបចំផែនការយុទ្ធសាស្ត្រថវិកា ៣ឆ្នាំរំកិលដែលជាឧបករណ៍សម្រាប់ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់ក្រសួង ស្ថាប័ន និងគោលនយោបាយរាជរដ្ឋាភិបាល។ ជាទូទៅការធ្វើផែនការយុទ្ធសាស្ត្រថវិកា ៣ឆ្នាំ រំកិលរបស់មន្ទីរពេទ្យ គឺប្រធានមន្ទីរពេទ្យត្រូវពិនិត្យលើផែនការដែលបានរៀបចំ រួចដាក់ឆ្លងមន្ទីរសុខាភិបាល អំពីផែនការ និងកំណើននៃតម្រូវការជាក់ស្តែងរបស់មន្ទីរពេទ្យដែលអាចនឹងមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ ពាក់ព័ន្ធនឹងការរៀបចំផែនការយុទ្ធសាស្ត្រ ៣

ឆ្នាំរំកិលនេះដែរ ចំពោះវិស័យសុខាភិបាលមានលក្ខណៈខុសប្លែកពីវិស័យដទៃ ត្រង់ថាសកម្មភាពខ្លះត្រូវការអនុវត្តភ្លាមៗ (ឧៈ ការផ្ទុះជំងឺឆ្លង និងគ្រោះមហន្តរាយផ្សេងៗ) និងបន្ទាន់ដោយសកម្មភាពនោះមិនបានគ្រោងនៅក្នុងផែនការឡើយ ដូច្នេះមន្ទីរពេទ្យត្រូវដកកញ្ចប់ថវិកាពីផ្នែកណាមួយ ឬពីសកម្មភាពណាមួយមកប្រើប្រាស់ជាមុនសិន ហើយនឹងធ្វើការទូទាត់សងវិញតាមនីតិវិធីតាមក្រោយ។

## ដំណើរការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ៣ឆ្នាំរំកិល របស់មន្ទីរពេទ្យ

| | |
|---|---|
| ការប្រមូលទិន្នន័យ | រៀបចំកិច្ចប្រជុំណែនាំអំពីការប្រមូលទិន្នន័យតម្រូវថវិការយៈពេល ៣ឆ្នាំ តាមផ្នែកនីមួយៗៈ<br>▪ ប្រធាន និងអនុប្រធានមន្ទីរពេទ្យ<br>▪ សមាជិកគណៈកម្មការគ្រប់គ្រងមន្ទីរពេទ្យ<br>▪ ប្រធានផ្នែកនីមួយៗ |
| ↓ ទិន្នន័យសរុបដែលប្រមូលបាន | រៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រថវិកា ៣ឆ្នាំរំកិល តាមផ្នែកនីមួយៗ |
| ↓ អនុម័តលើសេចក្តីព្រាងផែនការយុទ្ធសាស្ត្រថវិកា ៣ឆ្នាំរំកិល | ប្រជុំរៀបចំបញ្ចូលផែនការយុទ្ធសាស្ត្រថវិកា ៣ឆ្នាំរំកិល តាមផ្នែកនីមួយៗ ជាផែនការយុទ្ធសាស្ត្រថវិកា ៣ឆ្នាំរំកិល របស់មន្ទីរពេទ្យ |
| ↓ បញ្ជូនសេចក្តីព្រាងផែនការយុទ្ធសាស្ត្រថវិកា ៣ឆ្នាំរំកិលទៅមន្ទីរសុខាភិបាលខេត្ត | ដើម្បីពិនិត្យ និងរៀបចំបន្តតាមនីតិវិធី |

ក្រោយពីផែនការថវិកាប្រចាំឆ្នាំរបស់មន្ទីរពេទ្យត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត ប្រធានមន្ទីរពេទ្យតែងរៀបចំកិច្ចប្រជុំផ្សព្វផ្សាយដល់គ្រប់ភាគី និងគ្រប់ផ្នែកពាក់ព័ន្ធដែលបានចូលរួមក្នុងដំណើរការរៀបចំផែនការសកម្មភាព និងផែនការថវិកាឱ្យបានដឹងអំពីចំនួនថវិការបស់មន្ទីរពេទ្យដែលទទួលបានសម្រាប់គាំទ្រដល់ដំណើរការប្រតិបត្តិប្រចាំថ្ងៃរបស់ខ្លួន។ លើសពីនេះទៀត ដើម្បីឱ្យមានតម្លាភាពពាក់ព័ន្ធនឹងការប្រើប្រាស់កញ្ចប់ថវិកា មន្ទីរពេទ្យខេត្តកោះកុងតែងរៀបចំកិច្ចប្រជុំប្រចាំខែអំពីចំណូលចំណាយផ្សេងៗ ជាមួយគណៈកម្មការហិរញ្ញប្បទាន ប្រធានផ្នែក បុគ្គលិកទាំងអស់។

ម្យ៉ាងវិញទៀត ដើម្បីគាំទ្រដល់ដំណើរការប្រតិបត្តិប្រចាំថ្ងៃរបស់មន្ទីរពេទ្យឱ្យមាននិរន្តរភាព គណៈគ្រប់គ្រងមន្ទីរពេទ្យចាំបាច់ត្រូវរៀបចំផែនការចំណូលចំណាយឱ្យបានច្បាស់លាស់ និងត្រឹមត្រូវ (សូមអាន ចំណុច៧. បញ្ជិកាគណនេយ្យ) ក្នុងនោះផងដែរទាមទារនូវការស្នើជាធម្មតាទាន់ពេលវេលាដោយសារការចំណាយថវិការបស់អង្គភាពមានការរៀបចំផែនការបានច្បាស់លាស់ និងយកធ្វើការទូទាត់ជាមួយរតនាគារខេត្ត និងស្នើសុំថវិកាថ្មីឱ្យបានទាន់ពេលវេលា។

### ៣.៣.២. ការរៀបចំបញ្ជីសារពើភណ្ឌកត់ត្រាចំណូល ចំណាយ និងរបាយការណ៍

ជាទូទៅ ការចំណាយរបស់មន្ទីរពេទ្យខេត្តកោះកុង គឺធ្វើឡើងស្របតាមផែនការថវិកាដែលបានគ្រោង។ ទន្ទឹមនឹងនេះ រាល់ការចំណាយទាំងអស់ត្រូវធ្វើការផ្ទៀងផ្ទាត់ជាប្រចាំជាមួយនឹងផែនការដែលបានគ្រោងធ្វើប្រចាំខែ ប្រចាំត្រីមាស ដោយត្រូវធ្វើយ៉ាងណាមិនឱ្យខុសពីផែនការដែលមានគ្រោងនោះទេ។ អ្វីដែលគួរឱ្យធ្វើការកត់សម្គាល់នោះគឺថា រាល់ការចំណាយមួយចំនួនដែលចំណាយខុសពីផែនការថវិកា ឬមិនបានគ្រោង ប្រធានមន្ទីរពេទ្យអាចដកយកពីប្រភពថវិកាផ្សេងៗទៀតដូចជា ថវិកាលើកកម្ពស់គុណភាពនិងសមធម៌សុខាភិបាល ឬថវិកាហិរញ្ញប្បទាន ៣៩% ដែលប្រើសម្រាប់ទុកគាំទ្រដល់ដំណើរការប្រតិបត្តិប្រចាំថ្ងៃរបស់មន្ទីរពេទ្យ មកបង្វែរលើការចំណាយផ្សេងៗដែលមានលក្ខណៈបន្ទាន់ និងចាំបាច់។

ជំពូកទី៣

ការកត់ត្រាចំណូលចំណាយរបស់មន្ទីរពេទ្យ គឺត្រូវរៀបចំឡើងតាមប្រព័ន្ធកុំព្យូទ័រ ដោយប្រើប្រាស់កម្មវិធី Excel បន្ទាប់មកព្រីនចេញជាឯកសារ ដើម្បីយកមកធ្វើការទូទាត់។ ពាក់ព័ន្ធនឹងការប្រើប្រាស់ទម្រង់បញ្ជិកា គណនេយ្យ គឺទទួលបានការណែនាំពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យប្រើប្រាស់ទម្រង់បញ្ជិការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយយោងតាមគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យទូទៅ គណនេយ្យរដ្ឋទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ លេខ ០០២ សហវ ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ[១៨]។

ពាក់ព័ន្ធនឹងរបាយការណ៍ទូទាត់គឺមានដូចជា សលាកបត្រចុះលេខនានា ទិន្នានុប្បវត្តិសៀវភៅធំ បញ្ជីវិភាគ តារាងសរុបវិភាគ តារាងតុល្យភាពគណនីប្រចាំខែ និងប្រចាំឆ្នាំ និងរៀបចំរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ របាយការណ៍លទ្ធផលប្រចាំឆ្នាំ របាយការណ៍ស្តីអំពីការអនុវត្តចំណូល ចំណាយថវិកាប្រចាំខែ និងប្រចាំឆ្នាំ តារាងផ្ទៀងផ្ទាត់សមតុល្យគណនីប្រាក់បញ្ញើនៅរតនាគារ បញ្ជីបេឡា និងតារាងឧបសម្ព័ន្ធផ្សេងៗទៀតដែលចាំបាច់។ ក្នុងនោះផងដែរក៏មានសំណើស្នើសុំថវិកាដើម្បីអនុវត្តសកម្មភាពដូចមានកំណត់ក្នុងផែនការប្រចាំឆ្នាំរបស់មន្ទីរពេទ្យទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរតនាគារខេត្ត ឯកសារទាំងអស់ត្រូវការរៀបចំយ៉ាងតិចចំនួន ០៣ច្បាប់ ០១ច្បាប់ សម្រាប់បញ្ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ០១ច្បាប់ សម្រាប់បញ្ជូនទៅរតនាគារខេត្ត និង ១ច្បាប់ ទៀតសម្រាប់រក្សាទុកនៅមន្ទីរពេទ្យធ្វើជាឯកសារកាលប្បវត្តិ។

ដោយឡែកការកត់ត្រាចំណូល ចំណាយសម្រាប់មន្ទីរពេទ្យ គឺធ្វើឡើងជារៀងរាល់ថ្ងៃដូចជាប័ណ្ណចំណូល ទាក់ទងជាមួយនឹងហិរញ្ញប្បទាន គឺត្រូវមានបញ្ជីបេឡាសម្រាប់កត់ត្រាចំណូល ចំណាយប្រចាំថ្ងៃ និងជារៀងរាល់ខែ ហើយក្នុងរយៈពេល ១ខែ ធ្វើការបិទបញ្ជីម្តង។ ជារៀងរាល់ដំណាច់ខែការកត់ត្រាចំណូល ចំណាយប្រចាំខែនេះទៀតសោត គឺត្រូវបាន

[១៨] គោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យទូទៅ គណនេយ្យរដ្ឋទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិលេខ ០០២ សហ ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ដាក់ជារបៀបវារៈនៅក្នុងកិច្ចប្រជុំប្រចាំខែផងដែរ ដែលកិច្ចប្រជុំនេះជាទូទៅ ធ្វើឡើងជារៀងរាល់ដើមសប្តាហ៍ទីមួយនៃខែបន្ទាប់ ដោយយករបាយការណ៍ហិរញ្ញវត្ថុស្តីពីការកត់ត្រាចំណូលចំណាយគ្រប់ប្រភពនានាទាំងអស់ ដើម្បីយកមកបង្ហាញជូនបុគ្គលិកក្នុងអង្គប្រជុំ ក្នុងគោលបំណងបង្ហាញអំពីតម្លាភាពចំណូល ចំណាយ និងចាត់ចែងកញ្ចប់ថវិកាដែលមន្ទីរពេទ្យទទួលបាន។ បេឡាករមានតួនាទី រៀបចំ និងគ្រប់គ្រងថវិកាតាមនីតិវិធីហិរញ្ញវត្ថុ រក្សាបញ្ជីវិក័យបត្របង់ប្រាក់ និងឯកសារដទៃទៀតពាក់ព័ន្ធនឹងថ្លៃសេវា ថែមទាំងធ្វើរបាយការណ៍ចំណូល ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ។ រជ្ជទេយ្យករត្រូវកាន់បញ្ជីគណនេយ្យទ្វេភាគក្នុងលក្ខណៈច្រើន ឬតិច ធ្វើឱ្យបានសាមញ្ញទៅតាមទំហំរជ្ជទេយ្យចំណូល និងចំណាយ។ បញ្ជីគណនេយ្យរបស់រជ្ជទេយ្យករចំណូលត្រូវមានបញ្ជីបេឡា ទិន្នានុប្បវត្តិទូទៅ និងសៀវភៅធំ។

រជ្ជទេយ្យករត្រូវរៀបចំរបាយការណ៍គណនេយ្យរជ្ជទេយ្យចំណូល និងចំណាយត្រូវមានតារាងតុល្យភាពគណនីរជ្ជទេយ្យចំណូល និងចំណាយ ដែលបង្ហាញប្រតិបត្តិការរជ្ជទេយ្យចំណូល និងចំណាយសរុបប្រចាំខែ ទៅតាមផ្នែកខាងឥណពន្ធ និងផ្នែកខាងឥណទាននៃគណនេយ្យរជ្ជទេយ្យចំណូល។ តារាងតុល្យភាពគណនីចំណូល និងចំណាយរៀបរាប់អំពីចលនា និងសមតុល្យទៅតាមលំដាប់លេខគណនេយ្យរជ្ជទេយ្យពីតូចទៅធំ។ នៅដំណាច់ខែនីមួយៗ រជ្ជទេយ្យករ ត្រូវបញ្ចប់កិច្ចបញ្ជិកា និងរៀបចំតារាងតុល្យភាពគណនីរជ្ជទេយ្យចំណូល និងចំណាយរៀងរាល់ចុងខែនីមួយៗដោយមានហត្ថលេខារបស់រជ្ជទេយ្យករ ប្រធានការិយាល័យគណនេយ្យ និងប្រធានអង្គភាព ហើយត្រូវផ្ញើរបាយការណ៍ទៅមន្ទីរសុខាភិបាល មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរតនាគារខេត្ត យ៉ាងយូរត្រឹមថ្ងៃទី១៥ នៃខែបន្ទាប់។

បន្ថែមពីការមានបញ្ជីកត់ត្រាចំណូលចំណាយត្រឹមត្រូវមន្ទីរពេទ្យបានធ្វើរបាយការណ៍សមិទ្ធកម្ម និងផ្ញើទៅមន្ទីរសុខាភិបាលនៅរៀងរាល់ក្រោយការបិទបញ្ជី (ប្រចាំខែ ប្រចាំត្រីមាស និងចុងឆ្នាំ) ហើយការផ្ញើរបាយការណ៍នេះ គឺមិនឱ្យលើសពីសប្តាហ៍ទី១ នៃខែបន្ទាប់។ សម្រាប់មន្ទីរពេទ្យខេត្តកោះកុង ការបិទបញ្ជីចំណូលចំណាយរបស់មន្ទីរពេទ្យ គឺ

ធ្វើឡើងជារៀងរាល់ខែ សម្រាប់របាយការណ៍ប្រចាំខែ ការបិទបញ្ជីរៀងរាល់ត្រីមាស សម្រាប់របាយការណ៍ត្រីមាស និងការបិទបញ្ជីប្រចាំឆ្នាំ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។ បន្ទាប់មក មន្ទីរសុខាភិបាលពិនិត្យមើលរបាយការណ៍របស់អង្គភាពក្រោមឱវាទរបស់ខ្លួន ក្នុងគោល-បំណងតាមដានអំពីការប្រើប្រាស់ និងចាត់ចែងកញ្ចប់ថវិកាដែលទទួលបាន ថាតើ ថវិកាដែលទទួលបានគ្រប់គ្រាន់ ឬមិនគ្រប់គ្រាន់ និងដើម្បីពិនិត្យអំពីការអនុវត្តចំណូលចំណាយឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាព ឬគ្មានប្រសិទ្ធភាពសម្រាប់គាំទ្រដល់ដំណើរការប្រតិបត្តិ ហើយនឹងរកវិធីដើម្បីជួយគាំទ្រក្នុងករណីមានការខ្វះខាត។

ក្រៅពីការកត់ត្រាចំណូល ចំណាយ និងការធ្វើរបាយការណ៍ មន្ទីរពេទ្យបានធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរៀងរាល់ ៥ឆ្នាំម្តង នៅក្នុងខែមករា នៃឆ្នាំបន្ទាប់ក៏ប៉ុន្តែការធ្វើបច្ចុប្បន្នភាពនៃបញ្ជីសារពើភណ្ឌគឺបានធ្វើឡើងជារៀងរាល់ឆ្នាំក្រោយពេលដែលបានធ្វើបញ្ជីសារពើភណ្ឌរួច ហើយការកត់ត្រានៅក្នុងបញ្ជីសារពើភណ្ឌ គឺធ្វើឡើងនៅពេលណាដែលមានទ្រព្យសម្បត្តិចូលថ្មី និងត្រូវមានលិខិតប្រគល់ទទួលឱ្យទៅផ្នែកនីមួយៗ បន្ទាប់មកលិខិតប្រគល់ទទួលទាំងនោះ ត្រូវយកមកបញ្ចូលនៅក្នុងបញ្ជីកើន/ថយនៃឆ្នាំនីមួយៗ។ ពាក់ព័ន្ធនឹងការធ្វើកិច្ចការងារនេះជារៀងរាល់ឆ្នាំមន្ទីរពេទ្យបានរៀបចំបង្កើតឱ្យមានជាក្រុមការងារមួយ គឺក្រុមការងារសារពើភណ្ឌ មានសមាជិកចំនួន ០៨នាក់ ដែលមានតួនាទី និងភារកិច្ចចុះអង្កេតមើលនៅតាមផ្នែកនីមួយៗ ដើម្បីធ្វើការផ្ទៀងផ្ទាត់នូវសម្ភារៈដែលផ្នែកនីមួយៗមាន។

ចំណែកផ្នែកនីមួយៗ ត្រូវដឹងថាផ្នែករបស់ខ្លួនមានបញ្ជីសម្ភារៈអ្វីខ្លះ? កើនប៉ុន្មាន និងថយប៉ុន្មានក្នុងឆ្នាំនេះ? បន្ទាប់ពីក្រុមការងារដែលទទួលបន្ទុកធ្វើកិច្ចការនេះរួចរាល់ គឺក្រុមការងារនេះត្រូវបញ្ចូលទិន្នន័យទាំងនោះទៅក្នុងបញ្ជីសារពើភណ្ឌតាមផ្នែកនីមួយៗទាំងអស់ ដើម្បីចងក្រងបានជាបញ្ជីសារពើភណ្ឌរបស់មន្ទីរពេទ្យ ដោយឡែកការធ្វើបញ្ជីទ្រព្យសម្បត្តិរដ្ឋកើន ឬថយក៏មានដំណើរការគ្រប់គ្រងនិងចាត់ចែងដូចគ្នាទៅនឹងដំណើរការគ្រប់គ្រង និងចាត់ចែងរៀបចំបញ្ជីសារពើភណ្ឌផងដែរ។

ចំពោះសម្ភារៈចាស់ៗ ឬខូចមិនដំណើរការមន្ទីរពេទ្យធ្លាប់បានធ្វើការជម្រុះបញ្ជីអស់មួយចំនួន និងបានដកចេញពីបញ្ជីសារពើភណ្ឌរបស់មន្ទីរពេទ្យផងដែរ រួមមាន រថយន្តគិលានសង្គ្រោះ ម៉ាស៊ីនភ្លើង ម៉ាស៊ីនកាត់ស្មៅ និងអគារចាស់ទ្រុឌទ្រោមមួយខ្នង ដែលមានអាយុកាលច្រើនឆ្នាំ (កសាងតាំងពីឆ្នាំ១៩៦៣) ដោយនីតិវិធីនៃការជម្រុះ គឺបានបង្កើតក្រុមការងារមួយក្រុម ដែលមានសមាសភាពចូលរួមជាមន្ត្រីអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធដែលមិនមែនសារពើពន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មន្ត្រីការិយាល័យទ្រព្យសម្បត្តិរដ្ឋនៃក្រសួងសុខាភិបាល អនុប្រធានមន្ទីរសុខាភិបាល ប្រធានមន្ទីរពេទ្យ មន្ត្រីពាក់ព័ន្ធនៃមន្ទីរសុខាភិបាល និងមន្ទីរពេទ្យ មន្ត្រីការិយាល័យទ្រព្យសម្បត្តិរដ្ឋនៃមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត មន្ត្រីការិយាល័យទ្រព្យសម្បត្តិរដ្ឋនៃសាលាខេត្ត ដែលមានតួនាទី ភារកិច្ចក្នុងការប្រជុំ ពិនិត្យវាយតម្លៃ រួចធ្វើសំណើទៅក្រសួងសុខាភិបាល តាមរយៈមន្ទីរសុខាភិបាលខេត្ត មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត និងរដ្ឋបាលខេត្តកោះកុង ហើយក្រសួងសុខាភិបាលជាអ្នកបញ្ជូនសំណើនេះបន្តទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

តាមបទពិសោធន៍ជាក់ស្តែងរបស់មន្ទីរពេទ្យក្នុងការអនុវត្តនូវការជម្រុះបញ្ជីសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋកន្លងមកគឺអនុវត្តបានតែចំនួនមួយលើក ដោយឡែកសម្ភារបរិក្ខារចាស់ៗមួយចំនួនដែលមិនអាចប្រើការកើត មន្ទីរពេទ្យខេត្តកោះកុងបានរក្សាទុកនៅក្នុងឃ្លាំងមួយ ដើម្បីទុកស្នើសុំការជម្រុះនៅពេលក្រោយ។

ជំពូកទី៣

## រូបភាពទី៥÷ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងអង្គភាព



សៀវភៅតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង-ថយចុះរបស់មន្ទីរពេទ្យខេត្តកោះកុង ឆ្នាំ២០១៨



ផែនការយុទ្ធសាស្ត្ររំកិល ៣ឆ្នាំ ប្រចាំឆ្នាំ២០១៨-២០២០









## ៣.៤. ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស

### ៣.៤.១. ការគ្រប់គ្រងធនធានមនុស្ស

#### ៣.៤.១.១. ការធ្វើផែនការធនធានមនុស្ស

មន្ទីរពេទ្យខេត្តកោះកុងបានរៀបចំផែនការធនធានមនុស្សជារៀងរាល់ឆ្នាំ តាមគោលការណ៍ណែនាំរបស់មន្ទីរសុខាភិបាលខេត្ត ក៏ដូចជាក្រសួងសុខាភិបាល។ ដើម្បីធានាបាននូវការរៀបចំផែនការធនធានមនុស្សឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងយកទៅអនុវត្តបានប្រកបដោយប្រសិទ្ធភាព មន្ទីរពេទ្យខេត្តកោះកុងបានរៀបចំផែនការធនធានមនុស្សដោយផ្អែកតាមដំណាក់កាលដូចខាងក្រោម÷

ការប្រមូលទិន្នន័យ÷ ដើម្បីមានមូលដ្ឋានទិន្នន័យក្នុងការរៀបចំផែនការធនធានមនុស្សឱ្យបានច្បាស់លាស់មន្ទីរពេទ្យតម្រូវឱ្យគ្រប់ផ្នែកទាំងអស់ធ្វើរបាយការណ៍ស្ដីពីតម្រូវការធនធានមនុស្សតាមផ្នែកនីមួយៗទៅតាមផែនការរបស់គណៈកម្មការគ្រប់គ្រងមន្ទីរពេទ្យ។ ការរៀបចំរបាយការណ៍តម្រូវការធនធានមនុស្សនេះត្រូវមានការពិគ្រោះយោបល់ជាមួយគណៈកម្មការគ្រប់គ្រងមន្ទីរពេទ្យ និងមន្ត្រី ថ្នាក់ដឹកនាំតាមផ្នែកនីមួយៗ។ ផ្នែកនីមួយៗត្រូវបញ្ជូនផែនការធនធានមនុស្សទៅផ្នែករដ្ឋបាលទទួលបន្ទុកការងារបុគ្គលិករបស់មន្ទីរពេទ្យ ដើម្បីបូកសរុប និងរៀបចំសេចក្ដីព្រាងដាក់ឆ្លងកិច្ចប្រជុំថ្នាក់ដឹកនាំមន្ទីរពេទ្យដើម្បីអនុម័ត ក្នុងត្រីមាសទីមួយនៃឆ្នាំបន្ទាប់។

ការវិភាគទិន្នន័យ÷ ការវិភាគទិន្នន័យស្ដីពីតម្រូវការធនធានមនុស្សនៅមន្ទីរពេទ្យខេត្តកោះកុងធ្វើឡើងតាមរយៈកិច្ចប្រជុំថ្នាក់ដឹកនាំមន្ទីរពេទ្យ និងមានការចូលរួមពីប្រធានផ្នែកគ្រប់ផ្នែកទាំងអស់។ ការវិភាគនេះត្រូវធ្វើដោយផ្អែកលើកំណើនអ្នកជំងឺ កំណើនគ្រែអ្នកជំងឺ កំណើនអគារ ការពង្រីកឬបន្ថែមសេវាសុខាភិបាល និងកំណើនរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់គ្របដណ្ដប់របស់មន្ទីរពេទ្យស្របទៅតាមសំណុំសកម្មភាពបង្គ្រប់។

ការអនុម័តលើសេចក្ដីព្រាងផែនការធនធានមនុស្ស÷ បន្ទាប់ពីទទួលបាននូវរបាយ-ការណ៍ស្ដីពីតម្រូវការធនធានមនុស្សពីគ្រប់ផ្នែកទាំងអស់ហើយមន្ត្រីទទួលបន្ទុកបុគ្គលិក

ជំពូកទី៣

ត្រូវរៀបចំរបាយការណ៍បូកសរុប និងត្រូវរៀបចំសេចក្តីព្រាងផែនការធនធានមនុស្សរបស់មន្ទីរពេទ្យដោយផ្អែកលើទិន្នន័យដែលទទួលបានពីគ្រប់ផ្នែកទាំងអស់នោះ។

ដើម្បីធានាបាននូវតម្លាភាព និងមានការចូលរួម សេចក្តីព្រាងផែនការធនធានមនុស្សត្រូវបានដាក់ឆ្លងកិច្ចប្រជុំដែលមានការចូលរួមពីគ្រប់ផ្នែកពាក់ព័ន្ធ និងគណៈកម្មការគ្រប់គ្រងមន្ទីរពេទ្យ ដើម្បីពិនិត្យ ពិភាក្សា និងអនុម័តលើសេចក្តីព្រាងផែនការធនធានមនុស្សនេះ។ បន្ទាប់ពីទទួលបានការឯកភាពនិងអនុម័តពីថ្នាក់គ្រប់គ្រងមន្ទីរពេទ្យរួចហើយ សេចក្តីព្រាងផែនការធនធានមនុស្សនេះ ត្រូវបញ្ជូនទៅមន្ទីរសុខាភិបាលខេត្ត ដើម្បីរៀបចំនីតិវិធីបន្តតាមគោលការណ៍ និងបទដ្ឋានគតិយុត្តជាធរមាន។

#### ៣.៤.១.២. ការរៀបចំដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍

មន្ទីរពេទ្យខេត្តកោះកុងបានរៀបចំដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍បានទាន់ពេលវេលាដោយពុំមានការថ្នាំងថ្នាក់ចិត្តពីមន្ត្រីណាម្នាក់ឡើយ។ ពោលគឺមន្ទីរពេទ្យបានរៀបចំដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍បានយ៉ាងខ្ជាប់ខ្ជួនអនុលោមតាមគោលការណ៍ និងបទដ្ឋានគតិយុត្តជាធរមាន។ លើសពីនេះ និវត្តជនដែលមានគុណវុឌ្ឍិ សមត្ថភាព ជំនាញ និងមានមនសិការឆន្ទៈចង់បម្រើការងារនៅមន្ទីរពេទ្យតទៅទៀត មន្ទីរពេទ្យបានជ្រើសរើសជាមន្ត្រីជាប់កិច្ចសន្យារបស់មន្ទីរពេទ្យ ដើម្បីបំពេញការងារតាមជំនាញ ដដែល និងកន្លែងដែលមានតម្រូវការ។ មន្ត្រីចូលនិវត្តន៍មួយចំនួន ត្រូវបានអនុញ្ញាតឱ្យបំពេញការងារជាទីប្រឹក្សាបច្ចេកទេស ដើម្បីផ្ទេរចំណេះដឹងដល់មន្ត្រីជំនាន់ក្រោយដទៃទៀត។

### ៣.៤.២. ការគ្រប់គ្រងគុណផល

#### ៣.៤.២.១. ការកំណត់ការពិពណ៌នាមុខតំណែង និងការបែងចែកការងារ

មន្ទីរពេទ្យខេត្តកោះកុងបានរៀបចំការពិពណ៌នាមុខតំណែង និងការបែងចែកការងារដល់មន្ត្រី និងបុគ្គលិកគ្រប់រូបដែលបម្រើការងារនៅមន្ទីរពេទ្យបានច្បាស់លាស់ក្នុងទម្រង់ជាកិច្ចសន្យាការងារ។ កិច្ចសន្យាការងារនេះ បានកំណត់នូវលក្ខខណ្ឌសំខាន់ៗដូចជា÷ (១)ទីតាំង ម៉ោងធ្វើការ និងការត្រួតពិនិត្យការអនុវត្តការងារ (២)ការផ្តល់ប្រាក់ឧបត្ថម្ភ និង

ការលើកទឹកចិត្ត (៣)ចរិតលក្ខណសម្បត្តិ (៤)ភារកិច្ចនៃការទទួលខុសត្រូវនៃមុខតំណែង (៥)ការទំនាក់ទំនងក្នុងពេលអនុវត្តការងារ (៦)គុណវុឌ្ឍិ និង (៧)រយៈពេលបំពេញការងារ[១៩]។

### ៣.៤.២.២. ការគ្រប់គ្រងវត្តមានជាទៀងទាត់

ការគ្រប់គ្រងវត្តមានរបស់មន្ត្រី និងបុគ្គលិកនៅមន្ទីរពេទ្យខេត្តកោះកុង ត្រូវបានអនុវត្តដោយផ្អែកតាមអនុក្រឹត្យលេខ ២១ អនក្រ.បក ស្តីពីការកំណត់ម៉ោងការងារប្រចាំសប្តាហ៍របស់មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ និងអនុក្រឹត្យលេខ ៥៦ អនក្រ.បក ស្តីពីការគ្រប់គ្រងវត្តមានរបស់មន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យានៃព្រះរាជាណាចក្រកម្ពុជា[២០]។ តាមបទដ្ឋានគតិយុត្តទាំងពីរខាងលើ មន្ទីរពេទ្យបានផ្ទេរសិទ្ធិក្នុងការគ្រប់គ្រងវត្តមានដល់គ្រប់ផ្នែកទាំងអស់ជាអ្នកគ្រប់គ្រងផ្ទាល់ និងបានកំណត់ម៉ោងធ្វើការនៅក្នុងមន្ទីរពេទ្យ គឺពេលព្រឹកចាប់ពីម៉ោង ៧:០០ រហូតដល់ម៉ោង ១១:៣០ នាទី និងពេលរសៀលចាប់ពីម៉ោង ២:០០ ដល់ម៉ោង ៥:៣០។ លើសពីនេះគ្រប់ផ្នែកទាំងអស់ត្រូវធានាឱ្យមានមន្ត្រី និងបុគ្គលិកបម្រើការងារ ២៤ម៉ោង លើ ២៤ម៉ោង និងត្រូវកំណត់ម៉ោងយាមប្រចាំការសម្រាប់មន្ត្រី និងបុគ្គលិកគ្រប់រូបដោយបត់បែនទៅតាមស្ថានភាពការងារជាក់ស្តែងតាមផ្នែកនីមួយៗ។

មន្ទីរពេទ្យខេត្តកោះកុងបានប្រើប្រាស់វិធីសាស្ត្រក្នុងការគ្រប់គ្រងវត្តមានមន្ត្រីរាជការ និងបុគ្គលិករបស់មន្ទីរពេទ្យដោយចុះហត្ថលេខាលើបញ្ជីវត្តមាន ក្នុង១ថ្ងៃ ចំនួន ៤ដង (ព្រឹក÷ ម៉ោងចូល ម៉ោងចេញ រសៀល÷ ម៉ោងចូល ម៉ោងចេញ)។ លទ្ធផលនៃការគ្រប់គ្រងវត្តមានប្រចាំថ្ងៃរបស់មន្ត្រី និងបុគ្គលិកត្រូវបានកត់ត្រាទុកដោយមន្ត្រីផ្នែករដ្ឋបាលទទួលបន្ទុកការងារបុគ្គលិក និងត្រូវបានប្រើប្រាស់ជាលក្ខណៈវិនិច្ឆ័យមួយក្នុងចំណោមលក្ខណៈ

[១៩] គំរូកិច្ចសន្យាការងាររបស់មន្ទីរពេទ្យខេត្តកោះកុង

[២០] អនុក្រឹត្យលេខ ២១ អនក្របក ស្តីពីការកំណត់ម៉ោងការងារប្រចាំសប្តាហ៍របស់មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ និងអនុក្រឹត្យលេខ ៥៦ អនក្របក ស្តីពីការគ្រប់គ្រងវត្តមានរបស់មន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យានៃព្រះរាជាណាចក្រកម្ពុជា

វិនិច្ឆ័យជាច្រើនទៀតសម្រាប់វាយតម្លៃស្នាដៃក្នុងការផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែ។

ដើម្បីធានាបាននូវសុក្រឹត្យភាព និងប្រសិទ្ធភាពក្នុងការគ្រប់គ្រងវត្តមានតាមផ្នែកនីមួយៗ មន្ទីរពេទ្យបានផ្តល់សិទ្ធិឱ្យក្រុមការងារត្រួតពិនិត្យតាមដាន វាយតម្លៃគុណភាព និងប្រសិទ្ធភាពការងារ (Spotcheck and Monitoring Evaluation Team) ជាអ្នកត្រួតពិនិត្យលើវត្តមានតាមផ្នែកនីមួយៗ ដោយក្រុមនេះត្រូវចុះត្រួតពិនិត្យវត្តមាននៅតាមផ្នែកនីមួយៗ ដោយមិនជូនដំណឹងជាមុន។ ជាធម្មតាក្រុមការងារនេះ ត្រូវចុះត្រួតពិនិត្យវត្តមាននៅតាមផ្នែកនីមួយៗ ចំនួន ២ដង ក្នុងមួយសប្តាហ៍ ពោលគឺ ៨លើក ក្នុងមួយខែ និងត្រូវធ្វើរបាយការណ៍ជូនគណៈគ្រប់គ្រងមន្ទីរពេទ្យជាប្រចាំរៀងរាល់ខែ។

### ៣.៤.២.៣. ការវាយតម្លៃគុណផល និងការលើកទឹកចិត្ត

មន្ទីរពេទ្យខេត្តកោះកុងបាននិងកំពុងអនុវត្តប្រព័ន្ធវាយតម្លៃគុណផល។ តាមការអនុវត្តជាក់ស្តែង សមាសភាពសំខាន់ៗនៃប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តដែលមានដូចជា÷ ផែនការការងារប្រចាំឆ្នាំរបស់មន្ទីរពេទ្យ និងផែនការប្រចាំឆ្នាំរបស់ផ្នែកនីមួយៗត្រូវបានរៀបចំយ៉ាងច្បាស់លាស់ផ្អែកតាមការណែនាំក្នុងក្របខ័ណ្ឌនៃការអនុវត្តថវិកាកម្មវិធីរបស់រដ្ឋាភិបាល ការពិពណ៌នាមុខតំណែង និងការបែងចែកការងារត្រូវបានរៀបចំក្នុងទម្រង់ជាកិច្ចសន្យាការងារ លក្ខណៈវិនិច្ឆ័យក្នុងការវាយតម្លៃសមិទ្ធកម្មត្រូវបានកំណត់ និងមានការដាក់ពិន្ទុច្បាស់លាស់ មានការផ្តល់ការលើកទឹកចិត្តផ្អែកតាមលទ្ធផលនៃការវាយតម្លៃគុណផលក្នុងទម្រង់ជាហិរញ្ញវត្ថុ (រង្វាន់លើកទឹកចិត្តជាថវិកា) និងមិនមែនហិរញ្ញវត្ថុ (មានការផ្តល់ប័ណ្ណសរសើរស្នាដៃការងារ ក្នុងកម្រិតអង្គភាព និងបុគ្គលម្នាក់ៗ)។

មន្ត្រី និងបុគ្គលិកគ្រប់រូបនៅមន្ទីរពេទ្យខេត្តកោះកុងត្រូវបានវាយតម្លៃស្នាដៃការងារ ឬការវាយតម្លៃគុណផលការងារដោយផ្អែកលើតារាងវាយតម្លៃដែលមានកំណត់នូវលក្ខណៈវិនិច្ឆ័យគោលចំនួន ៥ ហើយលក្ខណៈវិនិច្ឆ័យនីមួយៗ មាន ៣កម្រិត សម្រាប់ដាក់ពិន្ទុ គឺ កម្រិត១ ២៥% កម្រិត២ ៥០% និងកម្រិត៣ ១០០% តាមគោលការណ៍ណែនាំរបស់

ឧបករណ៍វាយតម្លៃ តាមដាន កែលម្អគុណភាពរបស់គម្រោង H-EQIP។ លក្ខណៈវិនិច្ឆ័យគោលទាំង ៥ មានដូចខាងក្រោម÷

១-ឥរិយាបទវិជ្ជាជីវៈ (មាន ២០ពិន្ទុ)÷ លក្ខណៈវិនិច្ឆ័យគោលនេះ បានកំណត់នូវលក្ខណៈវិនិច្ឆ័យ លម្អិតចំនួន ៣ទៀត មានដូចជា÷ ភាពទាន់ពេលវេលា វត្តមាន និងការប្រើប្រាស់ឯកសណ្ឋានក្នុងពេលបំពេញការងារ។

២-ឥរិយាបទការងារជាក្រុម (មាន ៣០ពិន្ទុ)÷ លក្ខណៈវិនិច្ឆ័យគោលនេះ បានកំណត់នូវលក្ខណៈវិនិច្ឆ័យលម្អិតចំនួន ៤ទៀត មានដូចជា÷ ទំនាក់ទំនងបុគ្គល ការសហការសណ្តាប់ធ្នាប់ការងារ និងការផ្តួចផ្តើមគំនិត។

៣-សមត្ថភាពបច្ចេកទេស និងភាពបត់បែនក្នុងម៉ោងការងារ (មាន ៤០ពិន្ទុ)÷ ក្នុងលក្ខណៈវិនិច្ឆ័យគោលនេះ បានកំណត់នូវលក្ខណៈវិនិច្ឆ័យលម្អិតចំនួន ៣ទៀត មានដូចជា÷ ភាពរៀបរយក្នុងការអនុវត្តការងារ គុណភាពការងារ និងលទ្ធផលការងារ។

៤-មានបំណង និងឆន្ទៈក្នុងការអភិវឌ្ឍអាជីព មាន ១០ពិន្ទុ÷ លក្ខណៈវិនិច្ឆ័យនេះសំដៅដល់ការយកចិត្តទុកដាក់អនុវត្តតាមអនុសាសន៍ដែលបានផ្តល់ឱ្យដើម្បីកែលម្អក្នុងការអនុវត្តការងារ។

៥-លទ្ធផលនៃការគ្រប់គ្រងវត្តមាន÷ លក្ខណៈវិនិច្ឆ័យនេះ សំដៅដល់ការកំណត់យកលទ្ធផលនៃការគ្រប់គ្រងវត្តមានជាលក្ខណៈវិនិច្ឆ័យមួយក្នុងចំណោមលក្ខណៈវិនិច្ឆ័យដទៃទៀត ហើយលក្ខណៈវិនិច្ឆ័យនេះ ត្រូវបានប្រើប្រាស់ជាមូលដ្ឋានក្នុងការគណនាប្រាក់រង្វាន់លើកទឹកចិត្ត។

### ៣.៤.៣. ការរៀបចំផែនការបណ្តុះបណ្តាល

ជាទូទៅមន្ទីរពេទ្យខេត្តកោះកុង បានរៀបចំផែនការបណ្តុះបណ្តាលជារៀងរាល់ឆ្នាំ។ ផែនការបណ្តុះបណ្តាលរបស់មន្ទីរពេទ្យខេត្តកោះកុងរៀបចំឡើងដោយផ្អែកលើតម្រូវការជាក់ស្តែងដែលផ្តល់ដោយគ្រប់ផ្នែកទាំងអស់របស់មន្ទីរពេទ្យ។ ដើម្បីធានាបាននូវប្រសិទ្ធភាព និងគុណភាពនៃផែនការបណ្តុះបណ្តាល មន្ទីរពេទ្យបានតម្រូវឱ្យគ្រប់ផ្នែកទាំងអស់សិក្សា

អំពីតម្រូវការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រី និងបុគ្គលិកផ្នែកតាមជំនាញ និងស្ថានភាពជាក់ស្តែងរបស់ផ្នែកនីមួយៗ រួចផ្ញើរបាយការណ៍ជូនទៅផ្នែករដ្ឋបាល (មន្ត្រីទទួលបន្ទុកបុគ្គលិក) ដើម្បីបូកសរុប។ បន្ទាប់ពីទទួលបាននូវរបាយការណ៍ស្តីពីតម្រូវការបណ្តុះបណ្តាលពីគ្រប់ផ្នែកទាំងអស់ មន្ត្រីទទួលបន្ទុកបុគ្គលិកត្រូវរៀបចំរបាយ-ការណ៍រួមមួយ និងត្រូវរៀបចំសេចក្តីព្រាងផែនការបណ្តុះបណ្តាលរបស់មន្ទីរពេទ្យដោយផ្អែកលើព័ត៌មាន ឬទិន្នន័យដែលទទួលបានពីគ្រប់ផ្នែកទាំងអស់។

ដើម្បីធានាបាននូវតម្លាភាពនិងមានការចូលរួម សេចក្តីព្រាងផែនការបណ្តុះបណ្តាលត្រូវបានដាក់ឆ្លងកិច្ចប្រជុំពិគ្រោះយោបល់ដែលមានការចូលរួមពីគ្រប់ផ្នែកពាក់ព័ន្ធនិងគណៈកម្មការគ្រប់គ្រងមន្ទីរពេទ្យ ដើម្បីពិនិត្យ ពិភាក្សា និងអនុម័តមុននឹងសេចក្តីព្រាងផែនការបណ្តុះបណ្តាលនេះ ត្រូវបានចុះហត្ថលេខាដាក់ឱ្យអនុវត្តដោយប្រធានមន្ទីរពេទ្យ។

លើសពីនេះ ក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍមន្ទីរពេទ្យខេត្តកោះកុងបានសហការជាមួយមន្ទីរពេទ្យនៃប្រទេសថៃ ដើម្បីរៀបចំផែនការបណ្តុះបណ្តាលទ្វេភាគីតាមរយៈការធ្វើផែនការរួមគ្នា ផែនការសកម្មភាពប្រចាំឆ្នាំ ផែនការសកម្មភាព ៥ឆ្នាំរំកិលរវាងមន្ទីរពេទ្យខេត្តកោះកុងនិងមន្ទីរពេទ្យខេត្តជាប់ព្រំដែន (ខេត្តត្រាត) នៃប្រទេសថៃ។

### ៣.៤.៣.១. ការអនុវត្តការបណ្តុះបណ្តាល

មន្ទីរពេទ្យខេត្តកោះកុង អនុវត្តការបណ្តុះបណ្តាលមន្ត្រីរាជការ និងបុគ្គលិកក្នុងមន្ទីរពេទ្យតាមវិធីសាស្ត្រជាច្រើនរួមមាន៖

ការបណ្តុះបណ្តាលផ្ទៃក្នុងអង្គភាព៖ ជារៀងរាល់សប្តាហ៍ មន្ទីរពេទ្យខេត្តកោះកុងបានរៀបចំវគ្គបណ្តុះបណ្តាលផ្ទៃក្នុងលើប្រធានបទផ្សេងៗទៅតាមតម្រូវការជាក់ស្តែងរបស់មន្ទីរពេទ្យ ដែលជាទូទៅមានមន្ត្រីនិងបុគ្គលិកចូលរួមក្នុងរង្វង់ ៣០នាក់ ក្នុង១វគ្គ។

ការបណ្តុះបណ្តាលដោយផ្ទាល់៖ មន្ទីរពេទ្យបានប្រើប្រាស់វិធីសាស្ត្របណ្តុះបណ្តាលឬបង្វឹកដោយផ្ទាល់ (Coaching) តាមរយៈការរៀនសូត្របណ្តើរ អនុវត្តការងារបណ្តើរដល់មន្ត្រី និងបុគ្គលិកដែលបម្រើការងារនៅមន្ទីរពេទ្យលើជំនាញបច្ចេកទេសមួយចំនួន។

ឧទាហរណ៍ជាក់ស្តែង÷ មន្ត្រីជំនាញវះកាត់របស់មន្ទីរពេទ្យ ១រូប បានចូលនិវត្តន៍ ប៉ុន្តែដោយសារមន្ទីរពេទ្យខ្វះជំនាញផ្នែកនេះ និងសាមីមន្ត្រីរូបនេះ មានឆន្ទៈ មនសិការចង់បន្តបម្រើការងារនៅមន្ទីរពេទ្យតទៅទៀត មន្ទីរពេទ្យបានជ្រើសរើសរូបគាត់ជាមន្ត្រីជាប់កិច្ចសន្យារបស់មន្ទីរពេទ្យ ទទួលបន្ទុកជាទីប្រឹក្សាបច្ចេកទេស និងជាគ្រូបង្វឹកដោយផ្ទាល់លើជំនាញវះកាត់នេះ ដល់មន្ត្រី និងបុគ្គលិករបស់មន្ទីរពេទ្យដែលទទួលបន្ទុកជំនាញផ្នែកវះកាត់។

ការបណ្តុះបណ្តាលរយៈពេលខ្លីនិងមធ្យមនៅក្នុង និងក្រៅប្រទេស÷ ក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការជាមួយមន្ទីរពេទ្យនៃប្រទេសថៃ ដូចដែលបានលើកឡើងនៅក្នុងការរៀបចំផែនការធនធានមនុស្សខាងលើ មន្ទីរពេទ្យខេត្តកោះកុងបានបញ្ជូនមន្ត្រីទៅបណ្តុះបណ្តាលបន្តនៅប្រទេសថៃបានចំនួន ៤វគ្គ ក្នុង ១ឆ្នាំ (៤នាក់ ក្នុងមួយវគ្គ) សរុបក្នុងឆ្នាំ២០១៧ បានចំនួន ១៦នាក់ ឆ្នាំ២០១៨ បានចំនួន ១៦នាក់ ២០១៩ បានចំនួន ១៦នាក់ លើជំនាញមួយចំនួនដូចជា សង្គ្រោះបន្ទាន់កម្រិតធ្ងន់ (ICU) ជំងឺមិនឆ្លង (NCD) ផ្នែកសម្ភព (Maternity) ផ្នែកវះកាត់ (Surgery training) ផ្នែកកុមារ និងទារក (Neonatal Rescuscitation) ជាដើម។

បន្ទាប់ពីទទួលបានការបណ្តុះបណ្តាលនៅប្រទេសថៃ សិក្ខាកាមទាំងអស់ត្រូវបានចាត់ឱ្យទៅបំពេញការងារតាមផ្នែកជំនាញនីមួយៗ ដើម្បីពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការផ្តល់សេវានៅតាមផ្នែកទាំងនោះ។

ក្រៅពីការបញ្ជូនមន្ត្រីទៅបណ្តុះបណ្តាលនៅក្រៅប្រទេស មន្ទីរពេទ្យក៏បានព្យាយាមទំនាក់ទំនង និងសហការជាមួយស្ថាប័ន អង្គការ ដៃគូអភិវឌ្ឍដែលធ្វើការពាក់ព័ន្ធនឹងវិស័យសុខាភិបាល ក្នុងស្រុកដើម្បីបញ្ជូនមន្ត្រីទៅបណ្តុះបណ្តាលបន្ត។ ជាលទ្ធផលនៃការខិតខំប្រឹងប្រែងនេះ មន្ទីរពេទ្យបានបញ្ជូនមន្ត្រីទៅបណ្តុះបណ្តាលបន្ត ដែលមានរយៈពេលលើសពី ៣ខែ លើជំនាញឯកទេសមួយចំនួនដូចជា÷ ជំនាញការព្យាបាលជំងឺកុមារ ជំនាញវះកាត់កូន ជំនាញពិគ្រោះយោបល់ជំងឺផ្លូវចិត្ត ជំនាញជំងឺឆ្លងតាមផ្លូវបន្តពូជ វគ្គបណ្តុះ-

ជំពូកទី៣

បណ្ដាលស្ដីពីការព្យាបាលជំងឺឱកាសនិយម និងការប្រើប្រាស់ឱសថប្រឆាំងមេរោគអេដស៍លើមនុស្សពេញវ័យ និងកុមារ។ល។

ជាលទ្ធផលនៃការបណ្ដុះបណ្ដាលខាងលើ សេវាថ្មីចំនួន ០២ ត្រូវបានបង្កើតឡើងដូចខាងក្រោម÷

- សេវាពិគ្រោះ និងព្យាបាលជំងឺផ្លូវចិត្តត្រូវបានបង្កើតឡើងនៅខែតុលា ឆ្នាំ២០១៦
- សេវាពិនិត្យស្រាវជ្រាវរកជំងឺមហារីកមាត់ស្បូន ត្រូវបានបង្កើតឡើងនៅខែមេសា ឆ្នាំ២០២០។

ការចូលរួមសិក្ខាសាលាថ្នាក់ជាតិ និងកម្មវិធីផ្សេងៗ÷ ក្រៅពីការបណ្ដុះបណ្ដាលខាងលើ មន្ទីរពេទ្យបានបញ្ជូនមន្ត្រី និងបុគ្គលិកទៅទទួលយកនូវចំណេះដឹងថ្មី និងអភិវឌ្ឍសមត្ថភាពបន្ថែមតាមរយៈ សិក្ខាសាលា ឬកម្មវិធីផ្សេងៗដែលរៀបចំឡើងដោយរដ្ឋាភិបាល ឬអង្គការ ដៃគូអភិវឌ្ឍនានា លើជំនាញមួយចំនួន ដូចជា÷ការគ្រប់គ្រងទិន្នន័យអ្នកជំងឺ (Database Management) វគ្គគ្រប់គ្រងគុណភាពមន្ទីរពិសោធន៍ (Laboratory training laboratory quality monitoring system) វគ្គគុណភាពធនាគារឈាម (blood bank) ជំងឺមិនឆ្លង ដូចជាជំងឺផ្លូវចិត្ត ជំងឺទឹកនោមផ្អែម ជំងឺលើសឈាមជាដើម។ ការចែករំលែកចំណេះដឹងតាមរយៈកិច្ចប្រជុំផ្ទៃក្នុង÷ ដើម្បីចូលរួមលើកកម្ពស់ការអភិវឌ្ឍសមត្ថភាពដល់មន្ត្រី និងបុគ្គលិកគ្រប់រូបនៅក្នុងមន្ទីរពេទ្យ និងបង្កើតនូវវប្បធម៌ចែករំលែកចំណេះដឹង មន្ទីរពេទ្យខេត្តកោះកុងបានតម្រូវឱ្យមន្ត្រី និងបុគ្គលិកគ្រប់រូបដែលទទួលបានការបណ្ដុះ-បណ្ដាល ឬចូលរួមសិក្ខាសាលាពីខាងក្រៅយកចំណេះដឹង និងបទពិសោធន៍ដែលខ្លួនទទួលបានមកចែករំលែកដល់មន្ត្រី និងបុគ្គលិកគ្រប់រូបនៅក្នុងកិច្ចប្រជុំប្រចាំសប្ដាហ៍ ប្រចាំខែ ប្រចាំត្រីមាស ដែលត្រូវបានធ្វើឡើងជាទៀងទាត់។

ការប្រើប្រាស់ធនធានដែលបានមកពីការបណ្ដុះបណ្ដាល÷ មន្ទីរពេទ្យខេត្តកោះកុងបានប្រើប្រាស់ធនធានមនុស្ស ដែលទទួលបានការបណ្ដុះបណ្ដាលបានត្រឹមត្រូវចំគោលដៅ និងឆ្លើយតបទៅនឹងតម្រូវការជាក់ស្ដែងរបស់មន្ទីរពេទ្យ ពោលគឺចំណេះដឹង បទពិសោធន៍

ដែលមន្ត្រីគ្រប់រូបទទួលបានពីការបណ្តុះបណ្តាលត្រូវបានយកទៅប្រើប្រាស់នៅផ្នែករៀងៗខ្លួន និងអង្គភាពដែលមានតម្រូវការពិតប្រាកដ។ ការប្រតិបត្តិកិច្ចការបានល្អនេះ ដោយសារតែកត្តា ៤ ដូចខាងក្រោម÷

- ការសិក្សាអំពីតម្រូវការបណ្តុះបណ្តាលនិងការរៀបចំផែនការធនធានមនុស្សរបស់មន្ទីរពេទ្យបានច្បាស់លាស់
- ការបញ្ជូនមន្ត្រីទៅបណ្តុះបណ្តាលប្រកបដោយតម្លាភាព ផ្អែកលើផែនការបណ្តុះ-បណ្តាល និងតម្រូវការពិតប្រាកដរបស់មន្ត្រីនិងអង្គភាព
- ផ្តល់ឱកាសដល់មន្ត្រីបញ្ចេញស្នាដៃ និងប្រើប្រាស់ចំណេះដឹងដែលទទួលបានការបណ្តុះបណ្តាល
- មន្ត្រីដែលទទួលបានការបណ្តុះបណ្តាលលើសពី ៣ខែ ត្រូវចុះកិច្ចសន្យាជាមួយមន្ទីរពេទ្យ ដោយត្រូវបម្រើការងារឱ្យមន្ទីរពេទ្យ និងមិនអនុញ្ញាតឱ្យផ្ទេរចេញក្នុងរយៈពេលយ៉ាងតិច ៥ឆ្នាំ។

## រូបភាពទី៦÷ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស



ការចូលរួមវគ្គបណ្តុះបណ្តាលនៅក្រៅប្រទេស (ឆ្នាំ២០១៨)



ការអនុវត្តការសង្គ្រោះបឋម (២០១៩)



វគ្គបណ្តុះបណ្តាលរបស់គម្រោង H-EQIP (២០១៨)



វគ្គបណ្តុះបណ្តាលផ្ទៃក្នុងមន្ទីរពេទ្យ (២០១៨)



វគ្គបណ្តុះបណ្តាលថ្នាក់ជាតិ (២០១៩)



វគ្គបណ្តុះបណ្តាលផ្ទៃក្នុងមន្ទីរពេទ្យ (២០១៨)

## ៣.៥. ការរៀបចំ និងកែលម្អបរិស្ថានអនាម័យ

មន្ទីរពេទ្យគឺជាអង្គភាពផ្តល់សេវាសុខាភិបាលជូនប្រជាពលរដ្ឋ ដូច្នេះត្រូវមានការរៀបចំកែលម្អឱ្យមានអនាម័យ មានខ្យល់អាកាសបរិសុទ្ធដែលជាអំណោយផលល្អសម្រាប់អ្នកជំងឺដែលមកទទួល និងប្រើប្រាស់សេវារបស់មន្ទីរពេទ្យ។ ការរៀបចំកែលម្អបរិស្ថានឱ្យមានសណ្តាប់ធ្នាប់ល្អ មានអនាម័យ មានផាសុកភាព និងមានភាពបៃតងស្រស់ស្អាតនេះស្របទៅតាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន ស្តីពី មេត្រីភាពបរិស្ថាន និងគោរពតាមគោលការណ៍ណែនាំស្តីពីការបង្ការ និងការត្រួតពិនិត្យការចម្លងរោគរបស់ក្រសួងសុខាភិបាល។ ដើម្បីអនុវត្តតាមបេសកកម្មរបស់មន្ទីរពេទ្យដែលបានដាក់ចេញ **"ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថាន អនាម័យស្អាត ពណ៌បៃតង"** មន្ទីរពេទ្យខេត្តកោះកុងបានអនុវត្តការងារមួយចំនួនដូចជា÷ (១)ការបញ្ជ្រាបការយល់ដឹងពីបរិស្ថាន និងភាពស្អាត (២) ភាពស្អាតនៅក្នុងបរិវេណមន្ទីរពេទ្យ និងភាពបៃតង (៣)រៀបចំទីតាំងអង្គុយលំហែ និងចំណតយានជំនិះ(៤)ការគ្រប់គ្រងសំណល់រាវ(៥)ការប្រើប្រាស់ទឹកស្អាត ការគ្រប់គ្រងការបំពុលដោយក្លិន និងសំឡេង (៦)ការចាត់តាំងការងាររបស់ក្រុមត្រួតពិនិត្យការបង្ការ និងការចម្លងរោគក្នុងមន្ទីរពេទ្យ។

### ៣.៥.១. ការបញ្ជ្រាបការយល់ដឹងពីបរិស្ថាន និងភាពស្អាត

មន្ទីរពេទ្យខេត្តកោះកុងបានរៀបចំបើកវគ្គបណ្តុះបណ្តាល ដើម្បីបញ្ជ្រាបការយល់ដឹងពីបរិស្ថានដល់បុគ្គលិកដែលជាគ្រូពេទ្យ និងបុគ្គលិកអនាម័យ រួមទាំងនិស្សិតដែលមកធ្វើកម្មសិក្សានៅក្នុងមន្ទីរពេទ្យនេះជាប្រចាំ។ ការបណ្តុះបណ្តាលសម្រាប់ត្រីមាសទី៤ ចុងឆ្នាំ ២០១៩ ផ្តោតទៅលើប្រធានបទមួយចំនួនដូចជា (១)ការគ្រប់គ្រងសំណល់ (២)ការអនុវត្តអនាម័យដៃ និង (៣)មូលដ្ឋានគ្រឹះនៃការចម្លងរោគ។ ដោយឡែកវគ្គបណ្តុះបណ្តាលដល់បុគ្គលិកក្នុងត្រីមាសទី១ ឆ្នាំ២០២០ នេះ ផ្តោតសំខាន់ទៅលើជំងឺកូវីដ-១៩ និងការប្រើប្រាស់ឧបករណ៍ការពារខ្លួន (PPE)។

ការបញ្ជ្រាបអំពីបរិស្ថានដែលស្របទៅតាមគោលការណ៍មេត្រីភាពបរិស្ថាន បានធ្វើ

ជំពូកទី៣

ឡើងជារៀងរាល់កិច្ចប្រជុំគណៈកម្មការនានារបស់មន្ទីរពេទ្យ ដែលការណែនាំនេះធ្វើឡើង ដោយប្រធានមន្ទីរពេទ្យប្រធានគណៈកម្មការផ្សេងៗ ឬប្រធានផ្នែកនីមួយៗ។ ស្របពេល ជាមួយគ្នានេះដែរ គោលការណ៍មួយចំនួនត្រូវបានយកមកអនុវត្តដូចជា÷ **(១)យ៉ាងហោចណាស់បុគ្គលិកម្នាក់ត្រូវដាំដើមឈើឱ្យបាន១ ដើម (២)តាមផ្នែកនីមួយៗទទួលខុសត្រូវកែលម្អសួនជុំវិញអគារ ដោយមានបដិភាគ ពី ៣០ ទៅ ៥០% ពីផ្នែកនីមួយៗចូលរួមជាមួយមន្ទីរពេទ្យ (៣)នៅតាមផ្នែក បុគ្គលិកម្នាក់ៗ ត្រូវកៀរគររកដៃគូ ឬសប្បុរសជនឱ្យបានយ៉ាងតិចម្នាក់។**

ក្រោយពីទទួលការយល់ដឹងពីបរិស្ថាន និងអនាម័យរួចហើយ គ្រូពេទ្យទាំងអស់ត្រូវតែធ្វើការចែករំលែកបទពិសោធន៍ថ្មី និងការយល់ដឹងពីបរិស្ថាននេះបន្តទៅដល់អ្នកជំងឺ និងសាច់ញាតិអ្នកជំងឺដែលមកទទួលសេវា។ លើសពីនេះគ្រូពេទ្យត្រូវតែបណ្តុះគំនិតអ្នកប្រើប្រាស់សេវាឱ្យយល់ដឹងពីអត្ថប្រយោជន៍នៃបរិស្ថានស្អាត និងណែនាំគាត់ឱ្យចេះស្រលាញ់ និងថែទាំបរិស្ថាន ហើយពេលត្រឡប់ទៅគេហដ្ឋានវិញ អ្នកប្រើប្រាស់សេវាទាំងអស់ត្រូវបន្តការស្រលាញ់ និងថែរក្សាបរិស្ថាននៅក្នុងគ្រួសារ និងសហគមន៍ ផងដែរ។ ការណែនាំនេះត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ និងមានធ្វើជាខិត្តប័ណ្ណណែនាំដាក់ជូនអ្នកប្រើប្រាស់សេវានៅក្នុងប្រអប់ខាងមុខផ្នែកនីមួយៗ និងមានរៀបចំជាពាក្យស្លោក បិទនៅតាមដើមឈើទាំងអស់ក្នុងបរិវេណមន្ទីរពេទ្យ។

ជារៀងរាល់ថ្ងៃ គ្រូពេទ្យប្រចាំការតែងធ្វើការណែនាំពីរបៀបសម្អាត និងការថែរក្សាអនាម័យដល់អ្នកជំងឺ និងអ្នកកំដរ អំពីការធ្វើអនាម័យដៃក្រោយចេញពីបន្ទប់ទឹកដោយត្រូវលាងសម្អាតដៃជាមួយនឹងសាប៊ូ ជូតដៃនឹងក្ដូនកន្សែង ហើយដាក់ក្ដូនកន្សែងដែលប្រើប្រាស់រួចទៅក្នុងកញ្ច្រែង។ កន្សែងដែលប្រើរួចនេះ បុគ្គលិកអនាម័យនឹងយកទៅបោកគក់រួចយកមកបត់ដាក់ជូនអ្នកជំងឺប្រើប្រាស់នៅមុខបន្ទប់ទឹកវិញ។

ម្យ៉ាងទៀតគ្រូពេទ្យក៏បានណែនាំឱ្យស្ត្រីទើបសម្រាលកូនបានដឹងពីការធ្វើអនាម័យដៃ អនាម័យខ្លួនប្រាណមុនកាន់កូន បំបៅកូន។ ការណែនាំបញ្ជ្រាបការយល់ដឹងអំពីបរិស្ថាន

ស្អាត អនាម័យល្អដល់អ្នកប្រើប្រាស់សេវានេះធ្វើឡើងជាប្រចាំ និងជាច្រើនរូបភាពដូចជា÷

១- ផ្តល់សារអប់រំដោយផ្ទាល់មាត់ជារៀងរាល់ថ្ងៃនៅតាមបន្ទប់សម្រាកព្យាបាលរបស់អ្នកជំងឺដោយគ្រូពេទ្យប្រចាំការតាមវេន និងគ្រូពេទ្យដែលជាសមាជិកក្រុមការងារត្រួតពិនិត្យតាមដាន វាយតម្លៃគុណភាព និងប្រសិទ្ធភាពការងាររបស់មន្ទីរពេទ្យ។

២- រៀបចំវីដេអូសម្រាប់ចាក់ផ្សព្វផ្សាយពីសេវាដែលផ្តល់ដោយមន្ទីរពេទ្យ នីតិវិធីនៃការផ្តល់សេវា តម្លៃសេវា និងការអប់រំផ្សេងៗរបស់មន្ទីរពេទ្យ រួមទាំងការបញ្ជ្រាបការយល់ដឹងពីបរិស្ថានស្អាត និងអនាម័យល្អដល់អ្នកប្រើប្រាស់សេវាទាំងអស់។

៣- អញ្ជើញអ្នកកំដរមកស្តាប់សារអប់រំ ស្តីអំពីបរិស្ថាន និងអនាម័យនៅក្នុងបន្ទប់អប់រំរបស់មន្ទីរពេទ្យ។ អ្នកធ្វើបទបង្ហាញក្នុងការផ្តល់សារអប់រំនិងការបញ្ជ្រាបការយល់ដឹងស្តីពីបរិស្ថាន និងអនាម័យនេះអាចជាគ្រូពេទ្យនៅតាមផ្នែកនីមួយៗ ឬអាចជាគ្រូបង្គោលទទួលបន្ទុកផ្នែកបរិស្ថាននៅក្នុងមន្ទីរពេទ្យ។

៤- ក្រៅពីសកម្មភាពអប់រំផ្សព្វផ្សាយនេះ មន្ទីរពេទ្យបានធ្វើជាខិត្តប័ណ្ណផ្សព្វផ្សាយដាក់ជូនសាធារណជនដើម្បីបញ្ជ្រាបការយល់ដឹងអំពីអត្ថប្រយោជន៍ បរិស្ថានស្អាត អនាម័យល្អ។

៥- បិទផ្សព្វផ្សាយនៅតាមដើមឈើនូវពាក្យស្លោកផ្សេងៗពាក់ព័ន្ធនឹងបរិស្ថាន អនាម័យ និងតួនាទីរបស់ប្រជាពលរដ្ឋល្អក្នុងការថែរក្សាបរិស្ថាន និងអនាម័យ ក៏ដូចជាបម្រាមមួយចំនួនដែលប្រជាពលរដ្ឋល្អមិនគួរធ្វើ ឬមិនត្រូវធ្វើដើម្បីបរិស្ថាន។

៦- ផ្សព្វផ្សាយអំពី បទបញ្ជាផ្ទៃក្នុងស្តីពីភាពស្អាត នៅតាមអគារ និងនៅគ្រប់ផ្នែកទាំងអស់នៃមន្ទីរពេទ្យ។

៧- លាងសម្អាតបន្ទប់ទឹកនិងបង្គន់អនាម័យជាមួយសាប៊ូ និងទឹកសម្លាប់មេរោគជាប្រចាំរៀងរាល់ថ្ងៃ។

បន្ថែមលើនេះ មន្ទីរពេទ្យបានណែនាំ ហាមប្រាមអ្នកលក់ដូរក្នុងមន្ទីរពេទ្យមិនឱ្យលក់ដូរចំណីអាហារ ភេសជ្ជៈដែលអាចនាំឱ្យប៉ះពាល់សុខភាពរបស់ប្រជាពលរដ្ឋមានដូចជារបស់ហួសសុពលភាពប្រើប្រាស់ របស់ខូចគុណភាព គ្រឿងស្រវឹង បារី ឬថ្នាំជក់គ្រឿងញៀន។

### ៣.៥.២. ភាពស្អាតនៅក្នុងបរិវេណ មន្ទីរពេទ្យ និងភាពបៃតង

ថ្នាក់ដឹកនាំមន្ទីរពេទ្យបានប្រគល់ការទទួលខុសត្រូវដល់ប្រធានផ្នែកនីមួយៗ ដើម្បីរៀបចំកែលម្អបរិស្ថាន និងសួនច្បារនៅជុំវិញអគារ តាមផ្នែករបស់ខ្លួនដើម្បីភាពស្អាតនៅក្នុងបរិវេណ និងជុំវិញមន្ទីរពេទ្យ។ ចាប់តាំងពីមានការផ្តល់ឱកាសឱ្យតាមផ្នែកទាំងអស់ទទួលខុសត្រូវ ជាពិសេស ប្រធានផ្នែកនីមួយៗបានបង្កើតគំនិតច្នៃប្រឌិតក្នុងការចូលរួមកែលម្អបរិស្ថានជុំវិញអគារនៅតាមផ្នែករៀងៗខ្លួនបានយ៉ាងស្អាត ហើយក៏បានចូលរួមក្នុងការថែរក្សា និងសម្អាតបរិស្ថានជារៀងរហូត។ មន្ទីរពេទ្យមានកម្មវិធីដឹកនាំការសម្អាតបរិស្ថានដោយមានការចូលរួមពីបុគ្គលិកទាំងអស់នៅរៀងរាល់រសៀលថ្ងៃព្រហស្បតិ៍ ដូចជាសម្អាតនៅតាមបន្ទប់ តាមអគារ តាមផ្នែកនីមួយៗ និងបរិស្ថាននៅជុំវិញផ្នែករៀងៗខ្លួន និងមានរៀបចំធ្វើជាសួន ដាំផ្កា ដាំដើមឈើ និងរៀបបង់សម្រាប់ឱ្យអ្នកជំងឺ និងអ្នកកំដរអង្គុយលំហែ។ កង់ឡានចាស់ៗត្រូវបានយកមកកែច្នៃធ្វើជាជើងផ្កា ជើងដាំដើមឈើលម្អក្នុងសួនក្បែរអគារឱ្យមានសោភ័ណភាព និងធ្វើឱ្យមានបរិស្ថានស្អាត បរិយាកាសល្អ និងអនាម័យល្អក្នុងបន្ទប់ ក្នុងអគារ និងក្នុងមន្ទីរពេទ្យទាំងមូល។ ម្យ៉ាងវិញទៀតដើម្បីថែរក្សាសមិទ្ធផលរបស់ផ្នែកនីមួយៗឱ្យនៅតែមានភាពស្អាតប្រកបដោយផាសុកភាព ទាមទារឱ្យបុគ្គលិកក្នុងផ្នែកនីមួយៗត្រូវតែចូលរួមក្នុងការសម្អាត ការថែរក្សា ការស្រោចទឹកដាក់ជីជម្រះស្មៅក្នុងសួនច្បារនៅតាមផ្នែករបស់ខ្លួន។

មន្ទីរពេទ្យខេត្តកោះកុងមានបុគ្គលិកអនាម័យចំនួន ៨នាក់ ដែលធ្វើការសម្អាតជាប្រចាំទៅតាមកាលវិភាគសម្អាតរបស់ខ្លួននៅតាមបន្ទប់ តាមអគារ និងតាមផ្នែករៀងៗខ្លួនដោយក្នុង ១ថ្ងៃ ត្រូវចុះវត្តមាននៃការសម្អាត ២ដង គឺពេលព្រឹកម្តង និងពេលរសៀលម្តង។

បុគ្គលិកអនាម័យតាមផ្នែក និងតាមអគារនីមួយៗត្រូវធានាថា នៅក្នុងបន្ទប់តាមអគារក្នុងផ្នែករបស់ខ្លួនពុំមានធូលីដី សំរាម នៅលើផ្នែកម្រាល ពិដាន ជញ្ជាំង ទ្វារ បង្អួចឡើយ។ ចំពោះការសម្អាតរបស់បុគ្គលិកអនាម័យគឺអនុវត្តតាមបច្ចេកទេស និងតាមនីតិវិធីនៃការសម្អាតដែលបានបង្ហាត់បង្ហាញដោយបុគ្គលិកពេទ្យតាមផ្នែក។ បុគ្គលិកអនាម័យនៅមន្ទីរពេទ្យខេត្តកោះកុងមានការយល់ដឹងពីបច្ចេកទេសនៃការសម្អាត ដូចជាការសម្អាតនៅតាមតំបន់ដែលមានការឆ្លងរោគទាប និងតំបន់ដែលមានការឆ្លងរោគខ្ពស់ ដោយមានសម្ភារៈគ្រប់គ្រាន់សម្រាប់ធ្វើការសម្អាតតាមតំបន់ទាំងនោះ។

មន្ទីរពេទ្យមានគោលការណ៍ **គ្រូពេទ្យម្នាក់ ដាំដើមឈើ១ដើម** ដែលតាមរយៈគោល-ការណ៍នេះ បុគ្គលិកទាំងអស់បានសាមគ្គីគ្នាដាំដើមឈើនៅជុំវិញ និងក្នុងបរិវេណមន្ទីរពេទ្យ។ ការងារកែលម្អបរិស្ថាន តាមផ្នែកនានានៃមន្ទីរពេទ្យបានធ្វើឱ្យមានការចាប់អារម្មណ៍ និងមានការចូលរួមពីសំណាក់អ្នកជំងឺ បងប្អូនអ្នកជំងឺដោយបានផ្តល់ជំនួយជាថវិកា ឬជាសម្ភារៈផ្សេងៗដូចជា ជួយផ្តល់ជាដើមឈើ ជួយផ្តល់ជាកង់ឡានចាស់ៗ ជួយផ្តល់ជាបង់អង្គុយលេង និងមានផ្តល់ជារបស់របរប្រើប្រាស់មួយចំនួន។ ក្រៅពីការចូលរួមដោយថវិកានិងសម្ភារៈអ្នកកំដរមួយចំនួនបានជួយស្រោចទឹកដើមឈើ និងផ្កាក្នុងសួននៅក្នុងបរិវេណមន្ទីរពេទ្យដោយក្តីស្រឡាញ់ពេញចិត្តចំពោះបរិស្ថានរបស់មន្ទីរពេទ្យ។

ចំណែកអនាម័យនៅតាមអគារក្នុងមន្ទីរពេទ្យ មានបន្ទប់ទឹក និងបង្គន់ដែលមានការបែងចែកសម្រាប់បុរស សម្រាប់នារី និងសម្រាប់ជនពិការ។ នៅតាមបង្គន់ និងបន្ទប់ទឹកទាំងនោះមានការសម្អាតជាប្រចាំដោយបុគ្គលិកអនាម័យតាមផ្នែកនីមួយៗ ព្រមទាំងមានការចូលរួមពីអ្នកដែលប្រើប្រាស់បន្ទប់ទឹក និងបង្គន់អនាម័យរួចជួយសម្អាត ថែរក្សាឱ្យមានអនាម័យខ្ពស់។ បន្ទប់ទឹក និងបង្គន់មានបែងចែក (១)បង្គន់អនាម័យនិងបន្ទប់ទឹកបុរស (២)បង្គន់អនាម័យនិងបន្ទប់ទឹកស្ត្រី (៣)និងបង្គន់អនាម័យ និងបន្ទប់ទឹកសម្រាប់ជនពិការ។ បង្គន់អនាម័យសម្រាប់ជនពិការនេះមានទំហំធំទូលាយ មានជម្រាល និងមានបង្កាន់ដៃសម្រាប់តោងយឹតឡើង ដែលផ្តល់ភាពងាយស្រួលដល់ជនពិការក្នុងពេលប្រើប្រាស់។

សម្រាប់បន្ទប់ទឹកស្ត្រី មានធុងពណ៌លឿងមានគម្រប និងថង់លឿង អក្សរខ្មៅ សម្រាប់ស្ត្រីដាក់សំឡីអនាម័យ។

ចំពោះការប្រើប្រាស់ធុងសំណល់ទូទៅ មន្ទីរពេទ្យខេត្តកោះកុងមានគំនិតផ្តួចផ្តើមក្នុងការកែប្រែទម្លាប់របស់អ្នកប្រើប្រាស់សេវា ដោយចាប់ពីការអនុវត្តការបោះចោលសំរាមឱ្យបានត្រឹមត្រូវនៅក្នុងធុងសំរាមដែលគ្រូពេទ្យបានដាក់នៅក្នុងបន្ទប់សម្រាក បន្ទាប់មកគ្រូពេទ្យបានដកធុងសំរាមយកទៅដាក់នៅខាងក្រៅបន្ទប់សម្រាករួចចាំមើលថាតើអ្នកប្រើប្រាស់សេវាបានផ្លាស់ប្តូរទម្លាប់ ដោយយកសំរាមដើររកធុងដាក់ដែរឬទេ? បន្ទាប់មកទៀតគ្រូពេទ្យក៏ប្តូរទីតាំងដាក់ធុងសំរាមម្តងទៀតដោយដាក់នៅខាងមុខអគារ រួចគ្រូពេទ្យក៏សង្កេតឃើញថាអ្នកប្រើប្រាស់សេវាបានផ្លាស់ប្តូរទម្លាប់ទាំងស្រុង ទោះបីជាធុងសំរាមនៅទីណាក៏អ្នកប្រើប្រាស់សេវានៅតែចោលសំរាមក្នុងធុងដដែល។ ទាំងនេះគឺជាគំនិតផ្តួចផ្តើមមួយដ៏ល្អរបស់មន្ទីរពេទ្យខេត្តកោះកុងក្នុងការកែប្រែអាកប្បកិរិយា ទម្លាប់របស់ប្រជាពលរដ្ឋក្នុងផ្នែកអនាម័យ និងថែរក្សាបរិស្ថានដោយផ្តើមចេញពីភាពស្អាត និងមានអនាម័យរបស់មន្ទីរពេទ្យទាំងមូល។

ទាក់ទងនឹងសណ្តាប់ធ្នាប់ក្នុងមន្ទីរពេទ្យ ទោះបីជាមន្ទីរពេទ្យខេត្តកោះកុងមានអគាររហូតដល់ទៅ ២០ តែការរៀបចំហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់គ្នាពីអគារមួយទៅមួយមានផ្លូវតភ្ជាប់គ្នាដោយមានចាក់បេតុងរាបស្មើល្អ មានដំបូលប្រក់ការពារភ្លៀង និងកំដៅ និងមានផ្លូវជម្រាលសម្រាប់សម្រួលដល់ជនពិការអាចធ្វើដំណើរដោយរទេះរុញបាន។ នៅតាមផ្លូវភ្ជាប់អគារមួយទៅអគារមួយមានបិទស្លាកសញ្ញាបង្ហាញទិស បង្ហាញឈ្មោះទីតាំងផ្តល់សេវាមានសញ្ញាព្រួញបង្ហាញផ្លូវទៅកាន់ផ្នែកផ្សេងៗ ដើម្បីផ្តល់ភាពងាយស្រួលដល់អ្នកប្រើប្រាស់សេវា។ នៅតាមអគារសម្រាកព្យាបាលសម្រាប់អ្នកជំងឺមានរៀបចំជាធ្នើសម្រាប់ដាក់ស្បែកជើងរបស់អ្នកជំងឺ និងអ្នកកំដរ ដែលដាក់នៅខាងក្រៅបន្ទប់សម្រាកព្យាបាលដើម្បីរក្សាសណ្តាប់ធ្នាប់របៀបរៀបរយ និងអនាម័យ។

### ៣.៥.៣. ទីតាំងអង្គុយលំហែ

ទីតាំងសម្រាប់អង្គុយលំហែ មាននៅក្បែរដើមឈើដែលមានម្លប់ត្រជាក់ មានខ្យល់បក់ចេញចូល និងបរិយាកាសល្អ ហើយនៅតាមសួនច្បារទាំងអស់ក្នុងបរិវេណមន្ទីរពេទ្យ មានបំពាក់អំពូលភ្លើងបំភ្លឺពេលយប់ដើម្បីសុវត្ថិភាពក្នុងមន្ទីរពេទ្យ។ បង់អង្គុយលំហែមានស្ទើរគ្រប់កន្លែងដូចជានៅក្នុងសួនមុខអគារនីមួយៗ និងនៅផ្នែកខាងមុខមន្ទីរពេទ្យ នៅក្បែរចំណតម៉ូតូ និងក្បែរចំណតរថយន្ត និងមានដាំផ្កា ដាំដើមឈើ និងដាំស្មៅដើម្បីឱ្យមានភាពបៃតងស្រស់។

ចំពោះការរៀបចំសណ្តាប់ធ្នាប់យានជំនិះមន្ទីរពេទ្យមានចំណតចំនួន ៤ គឺចំណតម៉ូតូ ចំណតរថយន្តបុគ្គលិក ចំណតរថយន្តភ្ញៀវ និងចំណតរថយន្តគិលានសង្គ្រោះ។ នៅចំណតម៉ូតូ និងចំណតរថយន្តមានសន្តិសុខយាម ២៤ម៉ោង ដើម្បីរក្សាសុវត្ថិភាពក្នុងបរិវេណមន្ទីរពេទ្យទាំងមូល។ លើសពីនេះទៀតដើម្បីពង្រឹង និងការពារសន្តិសុខ សុវត្ថិភាពនៅក្នុងមន្ទីរពេទ្យ កាមេរ៉ាសុវត្ថិភាពមួយចំនួនត្រូវបានបំពាក់នៅតាមអគារ គ្រប់ផ្នែកក្នុងមន្ទីរពេទ្យ។ នៅជុំវិញចំណតយានជំនិះមានដាំផ្កា ដាំស្មៅ ដាំដើមឈើ មានបិទផ្លាកសញ្ញាណែនាំពីអនាម័យ និងបរិស្ថាន អមដោយពាក្យស្លោកណែនាំឱ្យថែរក្សាបរិស្ថាន ស្រលាញ់បរិស្ថាន និងអនាម័យ។

ចំណតម៉ូតូក្នុងមន្ទីរពេទ្យជាចំណតធំមួយបានកសាងនៅឆ្នាំ២០១៨ សម្រាប់ម៉ូតូអតិថិជន និងម៉ូតូរបស់បុគ្គលិកត្រូវយកមកចតនៅក្នុងចំណតនេះ តែមានការបែងចែកទីតាំងសម្រាប់ចតម៉ូតូអតិថិជន និងបុគ្គលិកពេទ្យផ្សេងពីគ្នា។

ចំណតរថយន្តសម្រាប់បុគ្គលិកពេទ្យ បានកសាងនៅឆ្នាំ២០១៩ ដែលឧបត្ថម្ភដោយឯកឧត្តម ស្រេង ហុង អភិបាលរងនៃគណៈអភិបាលខេត្តកោះកុង។

### ៣.៥.៤. ការគ្រប់គ្រងសំណល់រាវនៅមន្ទីរពេទ្យ

ពាក់ព័ន្ធការគ្រប់គ្រងសំណល់រាវរបស់មន្ទីរពេទ្យខេត្តកោះកុងបានអនុវត្តដូចតទៅ៖ (១) សំណល់ទឹកភ្លៀងហូរចូលក្នុងប្រព័ន្ធលូគ្រប់កន្លែងដែលមានក្នុងមន្ទីរពេទ្យ រួចហូរចាក់

ជំពូកទី៣

ទៅប្រព័ន្ធលូសាធារណៈ (២) សំណល់រាវចេញពីបន្ទប់ទឹក ហូរចូលទៅក្នុងប្រព័ន្ធលូស្តុក ដែលមាននៅតាមបណ្តាអគារនីមួយៗរបស់មន្ទីរពេទ្យមានអាងស្តុកមួយសម្រាប់ផ្ទុកសំណល់តាមផ្នែករៀងៗខ្លួន (៣) សំណល់រាវ ចេញពីមន្ទីរពិសោធន៍ ហូរចូលទៅក្នុងលូស្តុកមន្ទីរពិសោធន៍ និងមិនបង្ហូរទៅលូសាធារណៈទេ។

ទោះបីជាការគ្រប់គ្រងសំណល់រាវបែងចែកជា ៣ ប្រភេទដូចបានរៀបរាប់ខាងលើ ក៏មន្ទីរពេទ្យខេត្តកោះកុងជួបបញ្ហាខូះលូ ឬអាងមេសម្រាប់ផ្ទុកសំណល់ និងចម្រោះមុនបង្ហូរចូលប្រព័ន្ធលូសាធារណៈដែរ។ ទោះជាយ៉ាងនេះក្តីសំណល់រាវត្រូវបានគ្រប់គ្រងយ៉ាងល្អ ពុំមានការហូរហៀរពាសវាលពាសកាលទេ ព្រោះមន្ទីរពេទ្យធ្វើការបូមលូជាប្រចាំរៀងរាល់បីខែម្តង។ ម្យ៉ាងទៀតមន្ទីរពេទ្យមានលូផ្ទុកសំណល់ និងប្រព័ន្ធលូបង្ហូរទឹកដែលមានគម្របបិទជិតស្អាតល្អ ដូច្នេះពុំមានបញ្ហាក្លិនមិនល្អចេញពីលូសាយភាយប៉ះពាល់បរិស្ថានក្នុងមន្ទីរពេទ្យ និងជុំវិញមន្ទីរពេទ្យទេ។

### ៣.៥.៥. ការប្រើប្រាស់ទឹកស្អាត ការបំពុលដោយក្លិន និងសំឡេង

មន្ទីរពេទ្យមួយផ្តល់សេវាសុខាភិបាលប្រកបដោយគុណភាពដល់ប្រជាពលរដ្ឋ ចាំបាច់ណាស់ត្រូវមានការផ្គត់ផ្គង់គ្រប់គ្រាន់ ក្នុងនោះការផ្គត់ផ្គង់ទឹកស្អាតសម្រាប់ប្រើប្រាស់គ្រប់គ្រាន់គ្រប់ទីកន្លែង និងគ្រប់ពេលវេលាគឺជារឿងចាំបាច់។ មន្ទីរពេទ្យខេត្តកោះកុងមានទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់ នៅក្នុងបន្ទប់ទឹក ក្នុងបង្គន់អនាម័យ និងនៅគ្រប់កន្លែងដែលមានក្បាលរ៉ូប៊ីណេ ពុំធ្លាប់មានការខ្វះខាតទឹកស្អាតសម្រាប់ប្រើប្រាស់ឡើយ។ បច្ចុប្បន្នមន្ទីរពេទ្យប្រើប្រាស់ទឹកស្អាត ផ្គត់ផ្គង់ដោយរដ្ឋាករទឹកខេត្តកោះកុងហើយមន្ទីរពេទ្យក៏មានអាងទឹកធំសម្រាប់ស្តុកទឹកបម្រុង ដែលអាចប្រើប្រាស់បានក្នុងមួយរយៈពេលប្រហែល ៣ ទៅ ៤ថ្ងៃ និងមានអណ្តូងទឹកចំនួន ៤។

ក្រៅពីទឹកស្អាតសម្រាប់ប្រើប្រាស់ក្នុងបន្ទប់ទឹក ក្នុងបង្គន់ និងការលាងសម្អាត មន្ទីរពេទ្យបានផ្គត់ផ្គង់ទឹកស្អាតសម្រាប់បរិភោគដែលប្រើជាធុងទឹកដែលមានចែកជាទឹកក្តៅ និងទឹកត្រជាក់ដាក់ជូនបុគ្គលិក ភ្ញៀវ និងអ្នកដែលមកប្រើប្រាស់សេវាក្នុងមន្ទីរពេទ្យទាំងអស់បរិភោគ

នៅគ្រប់ផ្នែក និងគ្រប់អគារសម្រាកព្យាបាលរបស់មន្ទីរពេទ្យ។

ពាក់ព័ន្ធជាមួយការបំពុលដោយផ្សែង និងក្លិន មន្ទីរពេទ្យខេត្តកោះកុងមិនអនុញ្ញាតឱ្យមានការលក់បារី និងលក់គ្រឿងស្រវឹងនៅក្នុងមន្ទីរពេទ្យឡើយ ហើយក៏មានការហាមប្រាមមិនឱ្យជក់បារី ឬផឹកគ្រឿងស្រវឹងនៅក្នុងបរិវេណមន្ទីរពេទ្យដែរ។ បម្រាមហាមជក់បារីត្រូវបានបិទផ្សាយនៅតាមអគារ តាមបន្ទប់សម្រាកព្យាបាល តាមសួន តាមចំណតម៉ូតូ និងចំណតរថយន្ត។ ដូច្នេះនៅក្នុងបរិវេណមន្ទីរពេទ្យពុំមានការបំពុលដោយផ្សែងបារីឡើយ។

### ៣.៥.៦. ក្រុមការងារត្រួតពិនិត្យការបង្ការ និងការចម្លងរោគក្នុងមន្ទីរពេទ្យ

តាមការណែនាំរបស់ក្រសួងសុខាភិបាល មន្ទីរពេទ្យបានបង្កើតក្រុមការងារត្រួតពិនិត្យការបង្ការ និងការចម្លងរោគក្នុងមន្ទីរពេទ្យ ដែលមានសមាសភាពជាថ្នាក់ដឹកនាំមន្ទីរពេទ្យ ហើយសមាសភាពនេះត្រូវធ្វើបច្ចុប្បន្នភាពឱ្យស្របទៅតាមស្ថានភាព និងតម្រូវការរបស់មន្ទីរពេទ្យ។ ក្រៅពីក្រុមការងារខាងលើ មន្ទីរពេទ្យខេត្តកោះកុងក៏បានបង្កើតក្រុមការងារត្រួតពិនិត្យតាមដាន វាយតម្លៃគុណភាព និងប្រសិទ្ធភាពការងារ ដើម្បីតាមដានការអនុវត្តការងារ ការគោរពវិន័យរបស់បុគ្គលិក និងធ្វើការវាយតម្លៃ និងកែលម្អក្នុងគោលដៅធ្វើយ៉ាងណាជំរុញការផ្ដល់សេវាសុខាភិបាលជូនប្រជាពលរដ្ឋឱ្យកាន់តែមានគុណភាព សុវត្ថិភាព និងប្រសិទ្ធភាពខ្ពស់។ ក្រុមការងារនេះមានសមាសភាពមកពីគ្រប់ផ្នែកទាំង ៨ របស់មន្ទីរ-ពេទ្យ។ សមាជិកក្រុមនេះគឺជាបុគ្គលដែលបានជ្រើសរើសដោយមានលក្ខណៈពិសេសមួយចំនួនដូចជា អ្នកអព្យាក្រឹត រក្សាភាពសុចរិត ជាអ្នកម៉ឺងម៉ាត់ហ្មត់ចត់ និងមានឆន្ទៈខ្ពស់ក្នុងការបំពេញការងារ។

## រូបភាពទី៧៖ ការរៀបចំ និងកែលម្អបរិស្ថានមន្ទីរពេទ្យ



ការចូលរួមធ្វើអនាម័យរបស់បុគ្គលិក (២០១៩)



ការអប់រំបរិស្ថាន និងអនាម័យដល់អ្នកថែទាំអ្នកជំងឺ (២០១៩)



ចំណតម៉ូតូ (២០១៩)



ចំណតរថយន្ត (២០១៩)



ទីធ្លាមុខមន្ទីរពេទ្យ (២០១៩)



ទីធ្លាលំហែ (២០១៩)

## ៣.៦. ទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ សហគមន៍ និងដៃគូអភិវឌ្ឍព្រមទាំងការចូលរួមវាយតម្លៃពីអ្នកប្រើប្រាស់សេវាសាធារណៈ

ការទទួលបានជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូ ចំណាត់ថ្នាក់លេខ១ ក្នុងចំណោមមន្ទីរពេទ្យបង្អែកផ្តល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត២ (CPA2) ក្នុងវិស័យសុខាភិបាលរបស់មន្ទីរពេទ្យខេត្តកោះកុង គឺដោយសារមានការចូលរួម និងការជ្រោមជ្រែងពីថ្នាក់ដឹកនាំ និងបុគ្គលិកគ្រប់លំដាប់ថ្នាក់របស់មន្ទីរពេទ្យ និងពីមជ្ឈដ្ឋានខាងក្រៅដែលមានប្រជាពលរដ្ឋ សហគមន៍ ដៃគូអភិវឌ្ឍ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់។

ដើម្បីបង្កើនជំនឿ និងទំនុកចិត្តពីប្រជាពលរដ្ឋ សហគមន៍ អាជ្ញាធរមូលដ្ឋាន និងដៃគូអភិវឌ្ឍក្នុងការជួយជ្រោមជ្រែងនិងកៀរគរធនធានជួយដល់ការអភិវឌ្ឍមន្ទីរពេទ្យ និងដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសុខាភិបាលជូនប្រជាពលរដ្ឋ គណៈកម្មការ និងអនុគណៈកម្មការមួយចំនួនត្រូវបានបង្កើតឡើង។

### ៣.៦.១. ការរៀបចំគណៈកម្មការ និងអនុគណៈកម្មការ

គណៈកម្មការសេវាហិរញ្ញប្បទាន និងអនុគណៈកម្មការចំនួន ៣ទៀត ដែលរួមមាន÷ អនុគណៈកម្មការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ អនុគណៈកម្មការផ្គត់ផ្គង់ និងលទ្ធកម្ម និងអនុគណៈកម្មការវិន័យ និងទណ្ឌកម្ម ត្រូវបានបង្កើតឡើងតាមរយៈសេចក្តីសម្រេចរបស់មន្ទីរសុខាភិបាលខេត្តកោះកុង[២១]។

គណៈកម្មការនិងអនុគណៈកម្មការបង្កើតឡើងក្នុងគោលបំណងកែលម្អគុណភាពនិងប្រសិទ្ធភាពនៃការផ្តល់សេវាសុខាភិបាលជូនប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរ ដោយតាមដានត្រួតពិនិត្យឥរិយាបថរបស់បុគ្គលិកពេទ្យចំពោះអ្នកជំងឺ គ្រប់គ្រងសេវាហិរញ្ញប្បទាន ការដោះស្រាយសំណូមពរមតិយោបល់រិះគន់ដែលលើកឡើងដោយអតិថិជនចំពោះមន្ទីរពេទ្យនិងសិក្សារៀបចំគោលការណ៍លើកលែងការបង់ថ្លៃសេវាចំពោះប្រជាពលរដ្ឋក្រីក្រ។



[២១] សេចក្តីសម្រេចលេខ ០០២ សរ.មសខ.កក ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៩ របស់មន្ទីរសុខាភិបាលខេត្តកោះកុង

សមាសភាពតួនាទី និងភារកិច្ចលម្អិតរបស់គណៈកម្មការសេវាហិរញ្ញប្បទាន និងអនុគណៈកម្មការទាំង៣ ខាងលើមានកំណត់ក្នុងសេចក្តីសម្រេចជូនភ្ជាប់ក្នុងឧបសម្ព័ន្ធ។

### ៣.៦.២. ការពង្រឹងទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ

មន្ទីរពេទ្យបានទទួលការគាំទ្រ និងការពេញចិត្តពីសំណាក់ប្រជាពលរដ្ឋនៅមូលដ្ឋាន ដោយសារមន្ទីរពេទ្យបានគិតគូរសុខទុក្ខ សុខសុវត្ថិភាពរបស់អ្នកជំងឺជាចម្បង ជាពិសេសប្រជាពលរដ្ឋទីទ័លក្រដែលគ្មានលទ្ធភាពបង់ថ្លៃសេវាព្យាបាលជំងឺ និងអ្នកជំងឺដែលជាព្រះសង្ឃ ជនពិការ ជនវិបល្លាសស្មារតី កុមារកំព្រា និងអ្នកទោសដោយលើកលែងការបង់ថ្លៃព្យាបាល។ កត្តាទាំងនេះជាកម្លាំងចលករ ជួយជំរុញឱ្យមន្ទីរពេទ្យមានទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ អ្នកជំងឺ ឬអតិថិជនកាន់តែល្អប្រសើរ។

### ៣.៦.៣. ពិគ្រោះយោបល់ជាមួយសហគមន៍អំពីតម្លៃសេវាហិរញ្ញប្បទាន

តារាងតម្លៃសេវាហិរញ្ញប្បទានរបស់មន្ទីរពេទ្យខេត្តកោះកុង ត្រូវបានសម្រេច និងប្រកាសដាក់ឱ្យអនុវត្តដំបូងនៅឆ្នាំ២០១១។ ការកំណត់តម្លៃសេវា ដូចមានក្នុងតារាងសេវាហិរញ្ញប្បទាននេះ គឺត្រូវបានពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយសហគមន៍ដៃគូអភិវឌ្ឍ និងអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់។

ជាក់ស្តែងនៅទី១៩ ខែមករា ឆ្នាំ២០១១ មន្ទីរពេទ្យបានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការកំណត់សេវាហិរញ្ញប្បទានដែលមានការអញ្ជើញចូលរួមពីភាគីពាក់ព័ន្ធចំនួនសរុប ៥៦រូប ដែលក្នុងនោះ មកពីមន្ទីរសុខាភិបាលខេត្ត មន្ទីរពេទ្យខេត្ត ការិយាល័យស្រុកប្រតិបត្តិស្មាច់មានជ័យ មណ្ឌលសុខភាព ប៉ុស្តិ៍សុខភាព តំណាងមកពីមន្ទីរពាក់ព័ន្ធជុំវិញខេត្តចំនួន ៣រូប អាជ្ញាធរដែនដីថ្នាក់ក្រុងស្រុកចំនួន ៤រូប ក្រុមប្រឹក្សាសង្កាត់ចំនួន ២រូប ចៅសង្កាត់ចំនួន ២រូប អ្នកទ្រទ្រង់សុខភាពភូមិចំនួន ៤រូប និងតំណាងអង្គការក្រៅរដ្ឋាភិបាលចំនួន ៨រូប។

ការចូលរួមពីភាគីពាក់ព័ន្ធពិតជាមានសារសំខាន់ក្នុងការផ្តល់មតិយោបល់ និងអនុសាសន៍នានា លើការកំណត់សេវាហិរញ្ញប្បទាន និងដើម្បីលើកកម្ពស់គុណភាពសេវា

និងនិរន្តរភាពនៃការផ្តល់សេវា។

បន្ទាប់ពីតារាងតម្លៃសេវាហិរញ្ញប្បទានត្រូវបានអនុម័តដាក់ឱ្យអនុវត្ត សេវាហិរញ្ញប្បទានត្រូវបានសរសេរលើក្តារខៀនព័ត៌មានដោយមានបញ្ជាក់ពីប្រភេទសេវា និងតម្លៃ ដែលបិទជាប់នឹងជញ្ជាំងនៅកន្លែងសាធារណៈក្នុងបរិវេណមន្ទីរពេទ្យ ដែលសាធារណជន ឬអ្នកជំងឺងាយស្រួលមើលនិងឃើញច្បាស់។

ក្រៅពីវិធីសាស្ត្រនេះដើម្បីផ្សព្វផ្សាយសេវាហិរញ្ញប្បទានដល់សហគមន៍នៅតំបន់ដាច់ស្រយាលឱ្យបានដឹង និងជ្រាបកាន់តែច្បាស់មន្ទីរពេទ្យខេត្តកោះកុងបានផ្សព្វផ្សាយសេវាហិរញ្ញប្បទានតាមរយៈអ្នកទ្រទ្រង់សុខភាពភូមិ និងអាជ្ញាធរ ដែលជាអ្នកតំណាងសហគមន៍មូលដ្ឋាន។ ក្រោយពីអ្នកទ្រទ្រង់សុខភាពភូមិ និងអាជ្ញាធរទទួលបានព័ត៌មានពីសេវាហិរញ្ញប្បទាន ព័ត៌មានទាំងនេះនឹងត្រូវផ្សព្វផ្សាយបន្តនៅក្នុងកិច្ចប្រជុំរបស់ក្រុមទ្រទ្រង់សុខភាពភូមិដែលធ្វើឡើងជាប្រចាំខែនៅក្នុងមូលដ្ឋាន។

រួមជាមួយគ្នានេះ តារាងតម្លៃសេវាហិរញ្ញប្បទាន ក៏ត្រូវបានផ្សព្វផ្សាយផងដែរ តាមរយៈវេទិកាសាធារណៈដែលរៀបចំដោយអាជ្ញាធរថ្នាក់ជាតិ និងអាជ្ញាធរថ្នាក់មូលដ្ឋាន។

### ៣.៦.៤. ការលើកលែងបង់ថ្លៃសេវាដល់ជនក្រីក្រ

ដើម្បីជួយសម្រួលដល់ជីវភាពរស់នៅរបស់ប្រជាជនក្រីក្រដែលគ្មានលទ្ធភាពបង់ថ្លៃព្យាបាលជំងឺ និងសម្រាកព្យាបាលនៅមន្ទីរពេទ្យ រាជរដ្ឋាភិបាលបានបង្កើតនូវយន្តការហិរញ្ញប្បទានគាំទ្រសុខភាពសង្គម ដោយរាជរដ្ឋាភិបាលជាអ្នកទទួលបង់ថ្លៃជំនួសតាមរយៈមូលនិធិសមធម៌ និងតាមរយៈប័ណ្ណបេឡាជាតិសន្តិសុខសង្គម (បណ្ណ័ ប.ស.ស) សម្រាប់កម្មករនិយោជិត និងមន្ត្រីរាជការ។ អ្នកដែលទទួលបានប័ណ្ណមូលនិធិសមធម៌នេះត្រូវចេញដោយអាជ្ញាធរឃុំ/ សង្កាត់ តាមរយៈការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្ររបស់ក្រសួងផែនការ។ ក្រសួងសុខាភិបាលបានបង្កើតយន្តការមួយដែលជាឧបករណ៍វាយតម្លៃអ្នកជំងឺក្រីក្រដោយធ្វើការសម្ភាសសាច់ញាតិ ឬក្រុមគ្រួសាររបស់អ្នកជំងឺ ដើម្បីទទួលបានប័ណ្ណអាទិភាព និងមានសិទ្ធិទទួលបានផលប្រយោជន៍ពីកម្មវិធីមូលនិធិសមធម៌ ដែល

ហៅថាការកំណត់អត្តសញ្ញាណកម្មគ្រួសារជនក្រីក្រនៅមន្ទីរពេទ្យ (Post ID)។

ក្នុងករណីអ្នកជំងឺក្រីក្រគ្មានបណ្ណមូលនិធិសមធម៌ ឬប័ណ្ណ ប.ស.ស និងមិនមានលទ្ធភាពបង់ថ្លៃសេវាព្យាបាលជំងឺក៏អាចមកទទួលសេវានៅមន្ទីរពេទ្យបានដោយលើកលែងការបង់ថ្លៃដែរ។ ការលើកលែងបង់ថ្លៃសេវានេះ ជាការអនុគ្រោះរបស់ថ្នាក់ដឹកនាំមន្ទីរពេទ្យក្នុងការចូលរួមចំណែកផ្តល់សេវាសុខភាពជូនប្រជាពលរដ្ឋទីទ័លក្រគ្មានលទ្ធភាពបង់ថ្លៃព្យាបាលជំងឺ។ ការបង់ថ្លៃព្យាបាលជំងឺនេះ គឺមន្ទីរពេទ្យបានដកប្រាក់ចំណូលពីសេវាហិរញ្ញប្បទានជួសអ្នកជំងឺទីទ័លក្រ។ មន្ទីរពេទ្យក៏មានការលើកលែងការបង់ថ្លៃសេវាសុខភាពចំពោះ ព្រះសង្ឃ ជនចាស់ជរា និងជនពិការ និងអ្នកទោសផងដែរ។

### ៣.៦.៥. ការគ្រប់គ្រងចំណូលពីសេវាសុខភាព

ចំណូលដែលមន្ទីរពេទ្យខេត្តកោះកុងទទួលបានពីសេវាសុខភាពបានមកពីបីប្រភព គឺ ទី១. ការបង់ថ្លៃដោយផ្ទាល់មានប្រមាណ ៤០លានរៀល ក្នុង ១ខែ ទី២. ការបង់ថ្លៃដោយប័ណ្ណមូលនិធិសមធម៌មានប្រមាណ ២៥លានរៀល ក្នុង ១ខែ និង ទី៣. ចំណូលតាមរយៈការប្រើប្រាស់ប័ណ្ណ ប.ស.ស មានប្រមាណ ៣០លានរៀល ក្នុង ១ខែ។ សរុបចំណូលប្រចាំខែមានប្រមាណ ៩៥លានរៀល ក្នុង ១ខែ គិតជាមធ្យម។ ក្នុងចំណោមថវិកាទាំង ៩៥លានរៀលនេះ គឺយក ៦០% សម្រាប់ជាប្រាក់លើកទឹកចិត្តដល់បុគ្គលិក ចាប់ពីលោកប្រធានមន្ទីរពេទ្យ រហូតដល់កម្មករ និងបុគ្គលិកជាប់កិច្ចសន្យា ទៅតាមថ្នាក់ ដោយរក្សាគម្លាតបែងចែកមិនឱ្យលើសពី ០,៣% ទេ។ ចំណូល៣ ៩% ទៀត យកទៅដំណើរការការងារនៅក្នុងមន្ទីរពេទ្យ ហើយ ១% បង់ចូលរតនាគារជាតិ ហើយគោលការណ៍នៃការបែងចែកចំណូលនេះធ្វើឡើងតាមការកំណត់របស់ក្រសួងសុខាភិបាល។

### ៣.៦.៦. ការគ្រប់គ្រងចំណូលក្រៅពីសេវាសុខភាព

ចំណូលក្រៅពីសេវាសុខភាព ក៏មានចំណូលបានមកពីការកៀរគរពីសប្បុរសជនដែលមានថវិកាមួយចំនួន ហើយភាគច្រើនសប្បុរសជនបានឧបត្ថម្ភជាសម្ភារបរិក្ខារប្រើប្រាស់ក្នុងមន្ទីរពេទ្យ។ ការកៀរគរធនធានពីសប្បុរសជននេះធ្វើឡើងតាមរយៈការ

ព្យាបាលជំងឺ ការបង្កើតទំនាក់ទំនងល្អរវាងលោកប្រធានមន្ទីរពេទ្យ ឬក្រុមគ្រូពេទ្យជាមួយបណ្ដាសប្បុរសជន ដែលជាអ្នកស្គាល់គ្នា ជាអតីតអ្នកជំងឺដែលធ្លាប់មកព្យាបាលនៅមន្ទីរ-ពេទ្យ និងជាសាច់ញាតិ ឬមិត្តភក្ដិជាដើម។

### ៣.៦.៦.១. ការសហការជាមួយដៃគូអភិវឌ្ឍ អង្គការជាតិ អន្តរជាតិ និង សប្បុរសជនដៃគូអភិវឌ្ឍ

បច្ចុប្បន្ននេះមានអង្គការមូលនិធិថែទាំព្យាបាលអ្នកជំងឺអេដស៍ (AHF) បានជួយសហការជាដៃគូផ្ដល់បរិក្ខារមួយចំនួនដល់ផ្នែកជំងឺឱកាសនិយម។ អង្គការក្រុមគ្រូពេទ្យស្ម័គ្រចិត្តបារាំង (French Humaniterian Organization) បានជួយពិនិត្យនិងព្យាបាលជំងឺនៅផ្នែកវះកាត់ជារៀងរាល់ឆ្នាំ (២ក្រុម ក្នុងមួយឆ្នាំ) ដោយក្រុមទី១ ព្យាបាលលើជំងឺរោគស្ត្រីដែលមានរយៈពេល ២សប្ដាហ៍ ហើយមួយក្រុមទៀតព្យាបាលលើជំងឺច្រមុះត្រចៀក បំពង់ក ដូចជាការវះកាត់ដុំពកក ដុំគីសបំពង់ក ដែលមានរយៈពេលប្រហែល ២សប្ដាហ៍ ក្នុង ១ឆ្នាំ។ ក្រុមសប្បុរសធម៌បារាំងទាំងពីរក្រុមនេះបានអញ្ជើញមកមន្ទីរពេទ្យខេត្តកោះកុងជារៀងរាល់ឆ្នាំ (ចាប់តាំងពី ២០០០ រហូតដល់បច្ចុប្បន្ន)។ ក្រុមគ្រូពេទ្យស្ម័គ្រចិត្តបារាំងបានជួយទាំងបច្ចេកទេសព្យាបាល ទាំងសម្ភារៈឧបករណ៍បរិក្ខារពេទ្យ និងឱសថមួយចំនួនដែលមានប្រសិទ្ធភាពក្នុងការព្យាបាលជំងឺ។

ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការរវាងសកលវិទ្យាល័យពុទ្ធិសាស្ត្រ និង University Of New South Wales, Australia បានបញ្ជូននិស្សិតជំនាញវិស្វករចំនួន ៨នាក់ នៃ University Of New South Wales, Australia (ចំនួន ២នាក់ ក្នុងមួយវគ្គ រយៈពេលមួយខែ) ជួយជួសជុលសម្ភារៈ ឧបករណ៍បរិក្ខារពេទ្យនិងចែករំលែកបទពិសោធន៍ដល់បុគ្គលិកផ្នែកថែទាំឧបករណ៍បរិក្ខារពេទ្យនៃមន្ទីរពេទ្យខេត្តកោះកុង។

ក្រៅពីនេះ មន្ទីរពេទ្យក៏មានកិច្ចសហប្រតិបត្តិការជាមួយព្រះរាជាណាចក្រថៃឡង់ គឺមន្ទីរសុខាភិបាលខេត្តត្រាត ដែលមានព្រំដែនជាប់នឹងខេត្តកោះកុង ដោយបានជួយជួសជុលនិងបំពាក់សម្ភារៈឡើងវិញ នូវអគាររម្ងាប់មេរោគ និងផ្គត់ផ្គង់កណ្ដាលរួម។ មន្ទីរពេទ្យខេត្ត

កោះកុងបានបញ្ជូនគ្រូពេទ្យទៅបណ្តុះបណ្តាលវគ្គខ្លីក្នុងមួយឆ្នាំចំនួន ៤វគ្គ តែក្នុងមួយវគ្គៗ មានរយៈពេល ១សប្តាហ៍ ទៅ២សប្តាហ៍ ដើម្បីចែករំលែកបទពិសោធន៍។ ឧទាហរណ៍ វគ្គថែទាំទារកទើបកើត វគ្គសង្គ្រោះបន្ទាន់ វគ្គសង្គ្រោះបឋមពីសហគមន៍ វគ្គថែទាំវះកាត់ឆ្អឹង។ ក្រៅពីនេះទៀតមន្ទីរពេទ្យខេត្តកោះកុងមានទំនាក់ទំនងល្អជាមួយមន្ទីរពេទ្យខេត្តត្រាតក្នុងការបញ្ជូនអ្នកជំងឺទៅព្យាបាលបន្តនៅប្រទេសថៃ ក្នុងករណីលើសពីសមត្ថភាពព្យាបាលរបស់មន្ទីរពេទ្យ។

ទន្ទឹមនឹងនេះភាគីថៃក៏បានឧបត្ថម្ភរថយន្តគិលានសង្គ្រោះ ១គ្រឿង មានតម្លៃប្រហែល ២៥០លានរៀល ហើយក៏មានកិច្ចសហប្រតិបត្តិការក្នុងការទប់ស្កាត់ជំងឺឆ្លងតាមព្រំដែនបានយ៉ាងល្អដែរ។

ជាងនេះទៅទៀត ភាគីថៃតាមរយៈទីភ្នាក់ងារប្រតិបត្តិការអន្តរជាតិថៃ (TICA) បានជួយកសាង អគារសង្គ្រោះបន្ទាន់កម្រិតធ្ងន់ ១ខ្នង ក្នុងតម្លៃទឹកប្រាក់ ៨៨៤ លានរៀល និងបំពាក់សម្ភារៈមួយចំនួនទៀតក្នុងតម្លៃទឹកប្រាក់ចំនួន ១.០៤០លានរៀល។

បន្ថែមពីនេះរដ្ឋបាលខេត្តកោះកុង និងរដ្ឋបាលខេត្តត្រាតនៃព្រះរាជាណាចក្រថៃមានកិច្ចសហប្រតិបត្តិការ និងមានទំនាក់ទំនងល្អ ជាមួយគ្នា។ ក្នុងនោះដែរ មន្ទីរពេទ្យខេត្តកោះកុងក៏មានទំនាក់ទំនងល្អជាមួយមន្ទីរពេទ្យស្រុកខ្លងយ៉ៃ និងមន្ទីរពេទ្យខេត្តត្រាតនៃប្រទេសថៃផងដែរ។ ទំនាក់ទំនងនេះបានក្លាយជាមិត្តភាពដ៏ល្អអស់រយៈពេលប្រមាណ ៥០ឆ្នាំ កន្លងមកហើយ។

ដើម្បីឱ្យម្ចាស់ជំនួយមានទំនុកចិត្តលើមន្ទីរពេទ្យ មន្ទីរពេទ្យមានការប្តេជ្ញាចិត្ត និងបង្ហាញតម្លាភាពតាមរយៈការបិទឈ្មោះម្ចាស់ជំនួយលើឧបករណ៍បរិក្ខារពេទ្យ និងមានចុះផ្សាយការថ្លែងអំណរគុណដល់ម្ចាស់ជំនួយតាមគេហទំព័ររបស់មន្ទីរពេទ្យ។

## រូបភាពទី៨÷ ទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ សហគមន៍ និងដៃគូអភិវឌ្ឍព្រមទាំង ការចូលរួមវាយតម្លៃពីអ្នកប្រើប្រាស់សេវាសាធារណៈ



ការចូលរួមសង្គ្រោះអ្នកជំងឺនៅតាមសហគមន៍ (២០១៨)



ការទទួលអំណោយពីសប្បុរសជនក្នុងស្រុក (២០១៩)



ការទទួលអំណោយពីសប្បុរសជនក្នុងស្រុក (២០១៨)



ការផ្តល់ និងទទួលអំណោយ (២០១៩)



ការផ្តល់ និងទទួលអំណោយ (២០១៩)



ការផ្តល់ និងទទួលអំណោយ (២០១៩)

## ៣.៧. ការដោះស្រាយបញ្ហាប្រឈមជាមួយប្រជាពលរដ្ឋ និងសហគមន៍

ដំណោះស្រាយចំពោះបញ្ហាប្រឈមនានាជាមួយប្រជាពលរដ្ឋ និងសហគមន៍ មន្ទីរពេទ្យខេត្តកោះកុងបានរៀបចំនូវយន្តការឆ្លើយតបនិងដោះស្រាយចំពោះបញ្ហាប្រឈម និងបណ្តឹងតវ៉ាផ្សេងៗតាមរយៈប្រអប់សំបុត្រមតិយោបល់ ការចុះសម្ភាសប្រជាពលរដ្ឋដោយផ្ទាល់ ការសម្ភាសអតិថិជនតាម ទូរស័ព្ទ វេទិកាសាធារណៈ ការដោះស្រាយមតិយោបល់តាមបណ្តាញសង្គមទំព័រហ្វេសប៊ុក (Facebook Page) និងតាមរយៈការិយាល័យប្រជា-ពលរដ្ឋ។

### ៣.៧.១. ពិនិត្យ និងវិភាគលើមតិរបស់អ្នកជំងឺ

បន្ទាប់ពីទទួលបានព័ត៌មាន មតិយោបល់ សំណូមពរ និងបណ្តឹងតវ៉ានានាតាមរយៈប្រអប់សំបុត្រ មន្ទីរពេទ្យខេត្តកោះកុង ត្រូវចាត់វិធានការសមស្របក្នុងការឆ្លើយតបទៅអ្នកដែលបានលើកឡើងនូវបញ្ហាប្រឈម មតិយោបល់ សំណូមពរ ឬបណ្តឹងតវ៉ា។ មន្ទីរពេទ្យនឹងដោះស្រាយនូវបញ្ហាប្រឈមនានា ឱ្យទាន់ពេលវេលា ដោយតម្លាភាពនិងយុត្តិធម៌។

### ៣.៧.២. វិធានការដោះស្រាយក្រោយពេលទទួលបានព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ា

មន្ទីរពេទ្យខេត្តកោះកុង មានយន្តការទទួលព័ត៌មានត្រឡប់និងបណ្តឹងតវ៉ា ព្រមទាំងមានវិធានការដោះស្រាយនិងការឆ្លើយតបទៅនឹងព័ត៌មានត្រឡប់និងបណ្តឹងតវ៉ា ក្នុងពេលវេលាសមស្របតាមករណីជាក់ស្តែងនីមួយៗ តាមមធ្យោបាយមួយចំនួនដូចខាងក្រោម÷

**ប្រអប់សំបុត្រ÷** មន្ទីរពេទ្យមានការរៀបចំដាក់ប្រអប់សំបុត្រគ្រប់ផ្នែកផ្តល់សេវាទាំងអស់ក្នុងមន្ទីរពេទ្យ ដែលមានសរុបចំនួន ១០ប្រអប់សំបុត្រ និងទម្រង់លិខិតបញ្ចេញមតិ និងសំណូមពររបស់អតិថិជននៅតាមបណ្តាផ្នែកនីមួយៗ ដើម្បីឱ្យអតិថិជនអាចបង្ហាញពីភាពពេញចិត្ត ឬមិនពេញចិត្ត និងមានមតិយោបល់ ឬសំណូមពរផ្សេងៗចំពោះមន្ទីរពេទ្យ។ ប្រអប់សំបុត្រត្រូវបានបើករៀងរាល់ថ្ងៃទី២៨ ជារៀងរាល់ខែ ដែលមានការចូលរួមដោយតំណាងគណៈកម្មការគ្រប់គ្រងមន្ទីរពេទ្យចំនួន ២ ឬ ៣នាក់ និងតំណាងនៃបណ្តាផ្នែក

នីមួយៗ។ ជាបន្ទាប់មានការបើកកិច្ចប្រជុំរបស់ក្រុមការងារលើកកម្ពស់គុណភាព និងសុវត្ថិភាពថ្នាក់មន្ទីរពេទ្យ នៅថ្ងៃទី២៩ ដើម្បីពិនិត្យនិងវិភាគព័ត៌មានត្រឡប់ដែលទទួលបានពីប្រអប់សំបុត្រ ដោយមានការចូលរួមពីគ្រប់ប្រធានផ្នែក ឬតំណាងនៃផ្នែកនីមួយៗ។ ក្នុងករណីរកឃើញបណ្តឹងតវ៉ារបស់អតិថិជន គណៈកម្មការនឹងប្រគល់ឱ្យផ្នែកដែលមានបញ្ហានោះត្រូវធ្វើការដោះស្រាយ និងត្រូវរាយការណ៍អំពីលទ្ធផល ឬបញ្ហាប្រឈមដែលមិនអាចដោះស្រាយទៅគណៈកម្មការដើម្បីសម្របសម្រួលដោះស្រាយបន្ត។

**ទំព័រហ្វេសប៊ុក (Facebook Page) របស់មន្ទីរពេទ្យ÷** មន្ទីរពេទ្យមានក្រុមការងារតាមដាន និងពិនិត្យមើលមតិយោបល់ (comment) និងការផ្ញើសាររបស់ប្រជាពលរដ្ឋទៅកាន់ទំព័រហ្វេសប៊ុករបស់មន្ទីរពេទ្យ។ មន្ទីរពេទ្យបានរៀបចំឱ្យមានក្រុមការងារចំនួន៣រូបដើម្បីទទួលបន្ទុកជាប្រចាំនូវហ្វេសប៊ុកផេករបស់មន្ទីរពេទ្យ ក្នុងការឆ្លើយតបរាល់ចម្ងល់និងស្រាយបំភ្លឺរាល់បញ្ហាប្រឈមផ្សេងៗដែលទទួលបានពីទំព័រហ្វេសប៊ុក។ បើក្នុងករណីមានបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវាផ្ញើសារដោយផ្ទាល់ (Inbox) ទៅកាន់ទំព័រហ្វេសប៊ុករបស់មន្ទីរពេទ្យ ឬករណីខ្លះមានគណនីណាមួយដែលបានបង្ហោះសារិះគន់ជាសាធារណៈអំពីការផ្តល់សេវារបស់មន្ទីរពេទ្យ ឬរបស់បុគ្គលិកដែលផ្តល់សេវាមិនបានល្អ ភាគីមន្ទីរពេទ្យតែងតែរៀបចំកិច្ចប្រជុំពិភាក្សា និងអញ្ជើញភាគីដែលបានផ្ញើសារ ឬបង្ហោះជាសាធារណៈមកចូលរួមប្រជុំ ដើម្បីដោះស្រាយបញ្ហានានា។ ជាក់ស្តែងបើក្នុងករណីភាគីមន្ទីរពេទ្យពិតជាមានកំហុសនោះ ភាគីមន្ទីរពេទ្យនឹងធ្វើការសូមអភ័យទោស និងលើកយកបញ្ហានោះដើម្បីធ្វើការកែលម្អ ឬបើករណីបុគ្គលិករូបណាប្រព្រឹត្តខុស គណៈគ្រប់គ្រងមន្ទីរពេទ្យនឹងធ្វើការអប់រំ ឬដាក់ពិន័យ។ បើករណីភាគីដែលបានបង្ហោះជាសាធារណៈជាអ្នកខុសដោយមិនបានស្វែងយល់អំពីការពិតច្បាស់លាស់ ហើយបានបង្ហោះរិះគន់ជាសាធារណៈធ្វើឱ្យប៉ះពាល់ដល់មន្ទីរពេទ្យ បុគ្គលរូបនោះត្រូវធ្វើការលុបការបង្ហោះរបស់ខ្លួន និងធ្វើការសូមអភ័យទោសដល់ភាគីមន្ទីរពេទ្យដើម្បីបញ្ចប់បញ្ហា។

ជំពូកទី៣

**វេទិកាសាធារណៈ÷** មន្ទីរពេទ្យ បានចូលរួមសហការជាមួយអាជ្ញាធរ និងធ្វើការរៀបចំវេទិកាសាធារណៈចំនួន ២ដង ក្នុង ១ឆ្នាំ (រយៈពេល ១ថ្ងៃ ក្នុង ១វេទិកា) ដើម្បីផ្សព្វផ្សាយ និងអប់រំអំពីចំណេះដឹងពាក់ព័ន្ធនឹងការថែរក្សាសុខភាពដូចជាការថែទាំកុមារ បញ្ហារោគស្ត្រី ជំងឺគ្រុនឈាម ជំងឺគ្រុនចាញ់ និងថ្មីៗនេះពាក់ព័ន្ធនឹងបញ្ហាកូវីដ-១៩ ជាដើមនៅតាមបណ្តាឃុំ ស្រុកដោយមានការចូលរួមពីក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត គណៈអភិបាលក្រុង ស្រុក មេភូមិ មេឃុំ ចៅសង្កាត់ មន្ទីរពាក់ព័ន្ធជុំវិញខេត្ត និងប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ នៅក្នុងវេទិកានេះ មន្ទីរពេទ្យក៏ទទួលរាល់មតិយោបល់ និងសំណូមពរផ្សេងៗរបស់ប្រជា-ពលរដ្ឋ។ រាល់ចម្ងល់ និងបញ្ហាប្រឈមរបស់ប្រជាពលរដ្ឋនឹងត្រូវឆ្លើយតបបំភ្លឺ និងបកស្រាយភ្លាមៗនៅក្នុងវេទិកាសាធារណៈនោះ និងរាល់មតិយោបល់និងសំណូមពររបស់ប្រជាពលរដ្ឋនឹងត្រូវបានមន្ទីរពេទ្យកត់ត្រាទុក ដើម្បីបញ្ចូលក្នុងរបៀបវារៈនៃកិច្ចប្រជុំរបស់ក្រុមការងារដើម្បីលើកកម្ពស់គុណភាព និងសុវត្ថិភាពថ្នាក់មន្ទីរពេទ្យ។

ចំពោះវិធានការដោះស្រាយបញ្ហា និងឆ្លើយតបទៅនឹងបណ្តឹងតវ៉ាក្នុងករណីខ្លះអាចមានការចូលរួមសម្របសម្រួល និងដោះស្រាយដោយអាជ្ញាធរពាក់ព័ន្ធ រួមមានតំណាងគណៈអភិបាលខេត្ត ឬស្នងការនគរបាលខេត្ត ឬអាជ្ញាធរក្រុង ឬការិយាល័យប្រជាពលរដ្ឋជាដើម។

# រូបភាពទី៩÷ ការដោះស្រាយបញ្ហាប្រឈមជាមួយប្រជាពលរដ្ឋ និងសហគមន៍




ការដោះស្រាយបណ្តឹងតវ៉ារបស់អតិថិជន
តាមបណ្តាញសង្គម (ឆ្នាំ២០១៨)



សកម្មភាពចុះបើកប្រអប់សំបុត្រ (ឆ្នាំ២០១៦)









សកម្មភាពដោះស្រាយបណ្តឹងតវ៉ា
ជាមួយអ្នកជំងឺ (២០១៨)

ជំពូកទី៣

## ៣.៨. ការផ្តួចផ្តើមគំនិតថ្មីៗ នវានុវត្តន៍ ដើម្បីធ្វើឱ្យអង្គភាពមានដំណើរការកាន់តែល្អប្រសើរឡើង

### ៣.៨.១. ការបញ្ជ្រាបប្រធានបទពាក់ព័ន្ធនឹងនវានុវត្តន៍ និងការច្នៃប្រឌិត

មន្ទីរពេទ្យខេត្តកោះកុងតែងតែបញ្ជ្រាបអំពីប្រធានបទនវានុវត្តន៍ និងគំនិតច្នៃប្រឌិតដល់មន្ត្រីនិងបុគ្គលិកគ្រប់រូបតាមរយៈកម្មវិធីចែករំលែកចំណេះដឹង និងបទពិសោធន៍ដែលធ្វើឡើងក្នុងកិច្ចប្រជុំពេលព្រឹករៀងរាល់ថ្ងៃ កិច្ចប្រជុំប្រចាំខែ ត្រីមាស ជាដើម។

### ៣.៨.២. ការដឹកនាំអនុវត្ត ការជំរុញ និងការគាំទ្រការអនុវត្តគំនិតច្នៃប្រឌិត និងនវានុវត្តន៍

#### ៣.៨.២.១. ការលើកកម្ពស់បរិស្ថាន

ក្នុងគោលបំណងលើកកម្ពស់ការថែរក្សាបរិស្ថានក្នុងមន្ទីរពេទ្យ ប្រធានមន្ទីរពេទ្យបានដាក់ចេញនូវគោលការណ៍សម្រាប់មន្ត្រីគ្រប់រូបយកទៅអនុវត្តនូវពាក្យស្លោកគឺ **“បុគ្គលិកម្នាក់ដាំដើមឈើមួយដើម”**។ ជាលទ្ធផលនៃការអនុវត្តនូវគោលការណ៍នេះ ឃើញថាបរិស្ថាន និងអនាម័យត្រូវបានកែលម្អ។ សួនច្បារជុំវិញអគារនៃផ្នែកនីមួយៗក្នុងមន្ទីរពេទ្យត្រូវបានតុបតែងតាមរយៈការដាំកូនឈើ ផ្កាចម្រុះពណ៌ និងរុក្ខជាតិផ្សេងៗយ៉ាងស្រស់បំព្រងប្រកបដោយគំនិតច្នៃប្រឌិត និងបំពាក់ភ្លើងបំភ្លឺថែមទៀត។

#### ៣.៨.២.២. ការកៀរគរសប្បុរសជន

ក្នុងនោះដែរ ដើម្បីលើកកម្ពស់ការចូលរួម និងការកៀរគរធនធាន ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍមន្ទីរពេទ្យប្រធានមន្ទីរពេទ្យបានដាក់ចេញនូវពាក្យស្លោក គឺ“**មន្ត្រីម្នាក់ សប្បុរសជនម្នាក់**” ដើម្បីជំរុញ និងលើកទឹកចិត្តឱ្យមន្ត្រី និងបុគ្គលិកគ្រប់រូបចូលរួមទំនាក់ទំនង និងកៀរគរធនធានពីដៃគូអភិវឌ្ឍ និងសប្បុរសជនជាតិ និងអន្តរជាតិ។ សម្ភារៈ និងបរិក្ខារពេទ្យដែលសប្បុរសជនផ្តល់ជូននឹងយកប្រើប្រាស់ក្នុងផ្នែក អង្គភាពដែលសាមីមន្ត្រីរូបណាទំនាក់ទំនង ឬកៀរគរបាន។ សម្ភារៈដទៃទៀត ដូចជាបង់ថ្ម ឬបង់ឈើសម្រាប់អង្គុយ សាឡុងឈើជាដើម ត្រូវបានដាក់ឱ្យប្រើប្រាស់រួម ឬនៅកន្លែងដែលមានតម្រូវការ។ ជាលទ្ធផលនៃការ

អនុវត្តគោលការណ៍នេះ ឃើញថា សម្ភារបរិក្ខារពេទ្យដែលមានតម្លៃថ្លៃដូចជា ម៉ាស៊ីនតាមដានសញ្ញាជីវិត ចំនួន ៥គ្រឿង ម៉ាស៊ីនតាមដានការកន្ត្រាក់ស្បូន និងចង្វាក់បេះដូងទារក ចំនួន ០១គ្រឿង គ្រែអ្នកជំងឺ និងសម្ភារៈមួយចំនួនទៀតមន្ទីរពេទ្យទទួលបានពីសប្បុរសជនជាច្រើន ជាឧទាហរណ៍ជាក់ស្តែង លោកជំទាវ **មិថុនា ភូថង** អភិបាលនៃគណៈអភិបាលខេត្តកោះកុង បានជួយឧបត្ថម្ភម៉ាស៊ីនត្រជាក់ចំនួន ០៤គ្រឿង ដល់មន្ទីរពេទ្យ ឯកឧត្តម **ស្រេង ហុង** អភិបាលរងនៃគណៈអភិបាលខេត្តកោះកុង បានជួយកសាងចំណតរថយន្តបុគ្គលិកមន្ទីរពេទ្យ។

### ៣.៨.២.៣. ការបង្កើតទម្រង់ឯកសាររួមសម្រាប់ការបញ្ជូន និងការទទួលអ្នកជំងឺ

មន្ទីរពេទ្យបានផ្តួចផ្តើមគំនិតបង្កើតឱ្យមានទម្រង់ឯកសាររួមមួយស្តីពីការបញ្ជូន និងទទួលអ្នកជំងឺដើម្បីផ្តល់ភាពងាយស្រួលក្នុងការបញ្ជូននិងទទួលអ្នកជំងឺ និងពុំចំណាយពេលវេលាច្រើនក្នុងការពិនិត្យ និងធ្វើរោគវិនិច្ឆ័យរបស់អ្នកជំងឺឡើងវិញ ដែលនៅក្នុងទម្រង់នោះមានកំណត់នូវស្ថានភាព និងព័ត៌មានសំខាន់ៗរបស់អ្នកជំងឺដូចជា ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកជំងឺ ស្ថានភាពជំងឺ ការពិពណ៌នាអំពីស្ថានភាពរាងកាយរបស់អ្នកជំងឺ លទ្ធផលនៃការវិភាគរកជំងឺ គោលការណ៍នៃការធ្វើរោគវិនិច្ឆ័យ និងមូលហេតុនៃការបញ្ជូនអ្នកជំងឺ។

### ៣.៨.២.៤. ការកៀរគរធនធានដើម្បីគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រី

ការកៀរគរធនធាន ដើម្បីគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីរាជការ និងបុគ្គលិក ប្រធានមន្ទីរពេទ្យបានអនុវត្តតាមវិធីដូចខាងក្រោម÷

- ពិនិត្យមើលលើតម្រូវការអភិវឌ្ឍសមត្ថភាពជាក់ស្តែង និងជាតម្រូវការអាទិភាព ដែលមានកំណត់ក្នុងផែនការអភិវឌ្ឍសមត្ថភាព រួចកំណត់យកមួយ ឬពីរជំនាញ ដើមស្វែងរកការគាំទ្រ
- ទំនាក់ទំនងទៅអង្គការ ស្ថាប័ន ដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិ ដែលទទួលបន្ទុកបណ្តុះបណ្តាលអភិវឌ្ឍសមត្ថភាពលើជំនាញដែលមន្ទីរពេទ្យត្រូវការ ដើម្បីបញ្ជូន

មន្ត្រី និងបុគ្គលិកទៅបណ្តុះបណ្តាល

- នៅពេលរកសាលាបណ្តុះបណ្តាលបានហើយ ប៉ុន្តែសាលាឬវគ្គបណ្តុះបណ្តាលតម្រូវឱ្យបង់ថ្លៃសិក្សា មន្ទីរពេទ្យបានស្វែងរកសប្បុរសជនដើម្បីជួយគាំលើថ្លៃសិក្សា ក្នុងនោះដែរមន្ទីរពេទ្យក៏រួមចំណែកចេញថ្លៃស្នាក់នៅ ឬថ្លៃហូបចុក ក្នុងករណីសាមីមន្ត្រីគ្មានលទ្ធភាព។

### ៣.៨.២.៥. ការគ្រប់គ្រងវត្ថុមាននៃឈាមក្រហម

ជាគំនិតនវានុវត្តន៍ក្នុងការប្រមូល និងគ្រប់គ្រងឈាមក្រហមមន្ទីរពេទ្យបានអនុវត្តតាមយន្តការដូចខាងក្រោម÷

- ក្នុងករណីមានអ្នកបរិច្ចាគឈាមច្រើននាក់ក្នុងអំឡុងពេលដែលមន្ទីរពេទ្យមិនទាន់មានតម្រូវការប្រើប្រាស់ឈាម មន្ទីរពេទ្យមិនទាន់បូមឈាមទុកទេព្រោះបើសិនយកមកទុកអាចហួសកាលកំណត់ប្រើប្រាស់ ប៉ុន្តែមន្ទីរពេទ្យបានកត់ឈ្មោះ និងលេខទូរស័ព្ទរបស់អ្នកទាំងនោះទុកពេលណាមន្ទីរពេទ្យត្រូវការប្រើឈាមទើបអញ្ជើញគាត់មកធ្វើការបរិច្ចាគឈាម
- យន្តការមួយទៀតក្នុងការប្រមូលឈាម គឺមន្ទីរពេទ្យបានបង្កើតគណៈកម្មការគ្រប់គ្រងឈាមដែលមានអភិបាលរងខេត្តម្នាក់ជាប្រធាន ប្រធានមន្ទីរសុខាភិបាលជាអនុប្រធាន និងប្រធានមន្ទីរ អង្គភាពនានាជាសមាជិក ហើយគណៈកម្មការនេះមានតួនាទីបង្កើតកម្មវិធីផ្សព្វផ្សាយតាមអង្គភាពចំណុះខេត្ត ឱ្យចូលរួមបរិច្ចាគឈាមដោយធ្វើការផ្លាស់វេនគ្នាពីអង្គភាពមួយទៅអង្គភាពមួយទៀត។ ហេតុដូច្នេះហើយការផ្គត់ផ្គង់ឈាមមិនសូវមានកង្វះខាតទេ។ ម្យ៉ាងទៀតមន្ទីរពេទ្យមានលក្ខខណ្ឌតម្រូវឱ្យគ្រប់អ្នកជំងឺវះកាត់ត្រូវផ្តល់ឈាមសម្រាប់ត្រៀមបំរុងយ៉ាងតិច ២ប្លោក សម្រាប់ការវះកាត់មួយករណី ប៉ុន្តែពេលខ្លះមន្ទីរពេទ្យក៏មិនបានប្រើប្រាស់ឈាមទាំងអស់នោះដែរ។ ហេតុដូច្នេះមន្ទីរពេទ្យក៏មានសល់ឈាមខ្លះបម្រុងសម្រាប់អ្នកជំងឺក្រោយៗ។

### ៣.៨.២.៦. ការផ្តល់ការលើកទឹកចិត្ត

ជាការលើកទឹកចិត្តដល់អង្គភាព មន្ត្រី និងបុគ្គលិកគ្រប់រូបក្នុងការអនុវត្តគំនិតច្នៃប្រឌិត និងនវានុវត្តន៍ មន្ទីរពេទ្យបានបង្កើតប័ណ្ណសរសើរសម្រាប់ផ្តល់ជូនទាំងកម្រិតអង្គភាព និងកម្រិតបុគ្គលម្នាក់ៗក្នុងមន្ទីរពេទ្យ។ ប័ណ្ណសរសើរនេះសម្រាប់ផ្តល់ជូនដល់អង្គភាព មន្ត្រី ព្រមទាំងបុគ្គលិកដែលមានគំនិតច្នៃប្រឌិត និងនវានុវត្តន៍ និងមានស្នាដៃល្អក្នុងការបំពេញការងារជូនមន្ទីរពេទ្យ។

## រូបភាពទី១០÷ ការផ្តួចផ្តើមគំនិតថ្មីៗ នវានុវត្តន៍



ការលើកទឹកចិត្តជាប័ណ្ណសរសើរដល់បុគ្គលិកក្នុងមន្ទីរពេទ្យ (២០១៩)



ច្នៃកង់ឡានធ្វើជាសួនច្បារ (២០១៨)



ច្នៃកង់ឡានធ្វើជាសួនច្បារតាមផ្នែក (២០១៨)



ច្នៃប្រឌិតទីធ្លាខាងមុខសម្រាប់ក្មេងលេងផ្នែកជំងឺកុមារ (២០១៨)

# រូបភាពទី១១÷ បណ្ណសរសើរ




ប័ណ្ណសរសើរ
Certificate of Appreciation
KOH KONG Provincial Hospital
Highly appreciated
Dr. Philippe Lecomte


ប័ណ្ណសរសើរ
Certificate of Appreciation
KOH KONG Provincial Hospital
Highly appreciated
Dr. Laurent Rami











## ៣.៩. កត្តាជោគជ័យរបស់មន្ទីរពេទ្យ

កត្តាជោគជ័យរបស់មន្ទីរពេទ្យបានមកដោយសារ÷

១. ការចូលរួមគាំទ្រ និងកិច្ចសហប្រតិបត្តិការល្អពីបុគ្គលិក មន្ត្រីរាជការគ្រប់ផ្នែក អាជ្ញាធរ និងអ្នកពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់។

២. ថ្នាក់ដឹកនាំមន្ទីរពេទ្យប្រកាន់ខ្ជាប់នូវគុណតម្លៃនៃការគ្រប់គ្រង និងដឹកនាំអង្គភាព ដូចជា÷ គុណធម៌ សីលធម៌ សមត្ថភាព តម្លាភាព សុចរិតភាព សាមគ្គីភាព និងការទទួលខុសត្រូវ។

៣. ការលើកទឹកចិត្តដល់មន្ត្រីគ្រប់លំដាប់ថ្នាក់ក្នុងអង្គភាព។

៤. ការគាំទ្របច្ចេកទេស (អភិបាល តាមដាន វាយតម្លៃ) ពីក្រសួងសុខាភិបាល និងមន្ទីរសុខាភិបាល ហើយក៏មានគំនិតផ្តួចផ្តើមក្នុងការផ្ទេរសិទ្ធក្នុងការដឹកនាំ ការទទួលខុសត្រូវ និងការអភិវឌ្ឍតាមផ្នែកនីមួយៗ។

៥. ការពង្រឹងសមត្ថភាពមន្ត្រី និងពង្រីកសេវាថ្មីៗក្នុងគោលបំណងទាក់ទាញអតិថិជនឱ្យមកប្រើប្រាស់សេវានៅមន្ទីរពេទ្យ។

៦. មន្ត្រី និងបុគ្គលិកមន្ទីរពេទ្យមានឆន្ទៈក្នុងការកែលម្អក្នុងការចូលរួមកសាងទំនុកចិត្តពីអតិថិជន តាមរយៈការកែប្រែឥរិយាបទ ទាំងអាកប្បកិរិយា ពាក្យសំដី កាយវិការ និងការយកចិត្តដាក់ក្នុងការផ្តល់សេវាដោយមិនប្រកាន់ឋានៈ ពូជសាសន៍ ពណ៌សម្បុរ និងគ្មានការរើសអើងជាមួយអ្នកជំងឺ។

ទាំងអស់នេះជាកត្តាជោគជ័យ និងជាបទពិសោធន៍ក្នុងការគ្រប់គ្រងសេវាសាធារណៈឱ្យកាន់តែប្រសើរឡើង ដូច្នេះដើម្បីរក្សានិរន្តភាព និងកាន់តែល្អប្រសើរឡើងថែមទៀត ទាមទារឱ្យថ្នាក់ដឹកនាំមន្ទីរពេទ្យ និងបុគ្គលិកទាំងអស់រក្សានូវទស្សនាទានការលើកកម្ពស់គុណភាពសេវា។

# ជំពូកទី៤. សេចក្តីសន្និដ្ឋាន

ក្នុងរយៈពេល ៥ឆ្នាំ នៃការអនុវត្តការងាររបស់មន្ទីរពេទ្យខេត្តកោះកុងគិតចាប់ពីឆ្នាំ ២០១៥ ដល់ឆ្នាំ២០១៩ មន្ទីរពេទ្យបានខិតខំបំពេញការងារ ដោយសម្រេចបាននូវលទ្ធផលជាច្រើនដូចជា÷ ចំនួនប្រជាពលរដ្ឋមកទទួលយកសេវាមានការកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ អត្រាស្លាប់របស់អ្នកជំងឺមានការថយចុះ បរិស្ថាននិងសោភ័ណភាពរបស់មន្ទីរពេទ្យកាន់តែស្រស់ស្អាត ហេដ្ឋារចនាសម្ព័ន្ធរបស់មន្ទីរពេទ្យមានភាពល្អប្រសើរឡើង ឆ្លើយតបទៅនឹងសេចក្តីត្រូវការជាក់ស្តែង និងមានការចូលរួមគាំទ្រពីសប្បុរសជន និងដៃគូអភិវឌ្ឍកាន់តែច្រើនឡើង។

ការសម្រេចបាននូវលទ្ធផលខាងលើ ដោយសារមន្ទីរពេទ្យបានអនុវត្តយ៉ាងខ្ជាប់ខ្ជួនតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និងការចង្អុលបង្ហាញពីក្រសួងសុខាភិបាល ព្រមទាំងមានការគាំទ្រ និងទំនាក់ទំនងល្អជាមួយអាជ្ញាធរខេត្ត ក្រុង មន្ទីរសុខាភិបាល មន្ទីរជំនាញនៅជុំវិញខេត្ត ប្រជាពលរដ្ឋ និងដៃគូអភិវឌ្ឍ។ រួមជាមួយគ្នានេះដែរ ក៏មានការចូលរួមប្រកបដោយឆន្ទៈមោះមុត និងស្មារតីសាមគ្គីភាពពីបុគ្គលិកមន្ទីរពេទ្យ។ ការចូលរួមគាំទ្រទាំងនេះ កើតចេញពីការជឿជាក់ និងមានទំនុកចិត្តចំពោះថ្នាក់ដឹកនាំមន្ទីរពេទ្យដែលប្រកាន់ខ្ជាប់នូវគុណតម្លៃនៃការគ្រប់គ្រង និងដឹកនាំអង្គភាព ដូចជា÷ គុណធម៌ តម្លាភាព សុច្ចរិតភាព ការទទួលខុសត្រូវ និងសាមគ្គីភាពជាមួយមន្ត្រី បុគ្គលិកគ្រប់លំដាប់ថ្នាក់។

លទ្ធផល និងកត្តាជោគជ័យខាងលើនេះ ជាមូលហេតុនាំឱ្យមន្ទីរពេទ្យខេត្តកោះកុងទទួលបាន ចំណាត់ថ្នាក់លេខ១ ក្នុងចំណោមមន្ទីរពេទ្យដែលផ្តល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត២ (CPA ២) នៅទូទាំងប្រទេសនាឆ្នាំ២០១៩។

សមិទ្ធផលដែលមន្ទីរពេទ្យខេត្តកោះកុងសម្រេចបាននាពេលកន្លងមក គឺជាមោទភាពរបស់មន្ទីរពេទ្យក៏ដូចជាខេត្តកោះកុងទាំងមូល។ ជាពិសេសសមិទ្ធផលទាំងនេះ គឺជាមេរៀន និងបទពិសោធន៍ល្អៗសម្រាប់មន្ទីរពេទ្យ ឬអង្គភាពផ្តល់សេវាសាធារណៈដទៃទៀត ធ្វើការសិក្សារៀនសូត្រ និងដកស្រង់បទពិសោធន៍ ដើម្បីពង្រឹងការគ្រប់គ្រង និងការកែលម្អការផ្តល់សេវារបស់ខ្លួន ជូនប្រជាពលរដ្ឋកាន់តែប្រសើរឡើងថែមទៀត។

# គន្ថនិទ្ទេស

| ល.រ | ឈ្មោះឯកសារ |
|---|---|
| ១ | ព្រះរាជក្រមលេខ ០៦ ន.ស.៨៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា |
| ២ | អនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការកំណត់ម៉ោងការងារប្រចាំសប្តាហ៍របស់មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា |
| ៣ | អនុក្រឹត្យលេខ ៦១ អនក្រ.បក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៣ ស្តីពីក្រមសីលធម៌របស់គ្រូពេទ្យ |
| ៤ | អនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ ស្តីពីការបង្កើតនិងដាក់ឱ្យដំណើរការទីភ្នាក់ងារប្រតិបត្តិការពិសេសនៃក្រសួងសុខាភិបាល |
| ៥ | អនុក្រឹត្យលេខ ៤៥៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិវាយតម្លៃសេវាសាធារណៈ |
| ៦ | អនុក្រឹត្យលេខ ៥៦ អន.ក្របក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា |
| ៧ | អនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ស្តីពីការវាយតម្លៃ និងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល |
| ៨ | រាជរដ្ឋាភិបាលកម្ពុជា, ឆ្នាំ២០១៣ *កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥* |
